

សៀវភៅសម្រាប់អ្នកសម្របសម្រួល

# ពលរដ្ឋវិជ្ជា

## សេចក្តីផ្តើមនៃច្បាប់ សិទ្ធិ និង លទ្ធិប្រជាធិបតេយ្យ សម្រាប់ប្រជាពលរដ្ឋកម្ពុជា





# ពលរដ្ឋវិជ្ជា

## *សេចក្តីផ្តើមនៃច្បាប់ សិទ្ធិ និងលទ្ធិប្រជាធិបតេយ្យ សម្រាប់ប្រជាពលរដ្ឋកម្ពុជា*






សៀវភៅសម្រាប់អ្នកសម្របសម្រួល

បោះពុម្ពផ្សាយដោយអង្គការស្ពានទៅកាន់សន្តិភាពកម្ពុជា

រក្សាសិទ្ធិគ្រប់បែបយ៉ាងដោយអង្គការស្ពានទៅកាន់សន្តិភាពកម្ពុជា ឆ្នាំ២០១១។

**ពលរដ្ឋវិជ្ជា: សេចក្តីផ្តើមនៃច្បាប់ សិទ្ធិ និងលទ្ធិប្រជាធិបតេយ្យសម្រាប់ប្រជាពលរដ្ឋកម្ពុជា**
សៀវភៅសម្រាប់អ្នកសម្របសម្រួល

បោះពុម្ពលើកទី១៖ ខែឧសភា ឆ្នាំ២០១១

យើងលើកទឹកចិត្តឲ្យអ្នកដទៃថតចម្លង ផលិតឡើងវិញ ឬយកលំនាំតាម ផ្នែកខ្លះ ឬគ្រប់ផ្នែកទាំងអស់នៃសៀវភៅនេះ ដើម្បីបំពេញតម្រូវការមូលដ្ឋានចំពោះ តែក្នុងករណីដែលផ្នែកទាំងឡាយដែលត្រូវបានផលិតឡើងវិញនោះមានយោងទៅនឹងសៀវភៅច្បាប់ដើម និងត្រូវចែកចាយក្នុងគោលបំណងមិនស្វែងរកប្រាក់ចំណេញ។ អង្គការ ឬបុគ្គលណាក៏ដោយ ដែលចង់ថតចម្លង ផលិតឡើងវិញ ឬយកលំនាំតាមនូវផ្នែកខ្លះ ឬគ្រប់ផ្នែកទាំងអស់នៃសៀវភៅនេះក្នុងគោលបំណងធ្វើពាណិជ្ជកម្មត្រូវតែសុំការអនុញ្ញាតពីអ្នកផលិត និងអ្នកនិពន្ធជាមុនសិន។

មុនពេលនឹងចាប់ផ្តើមបកប្រែ ឬយកលំនាំតាមសៀវភៅនេះ ឬខ្លឹមសាររបស់វា សូមទាក់ទងអ្នកបោះពុម្ពសៀវភៅនេះ ដើម្បីស្នើសុំយោបល់ ដើម្បីធ្វើបច្ចុប្បន្នភាពព័ត៌មាននៅក្នុងសៀវភៅនេះ និងដើម្បីជៀសវាងកិច្ចប្រឹងប្រែងដែលជាន់គ្នា។ សូមផ្ញើមកអ្នកបោះពុម្ពនូវឯកសារថតចម្លងទាំងឡាយណាដែលបានដកស្រង់ចេញពីសៀវភៅនេះយកទៅប្រើប្រាស់។

អង្គការស្ពានទៅកាន់សន្តិភាពកម្ពុជា
ផ្ទះលេខ២៦១ AB ផ្លូវលេខ៣៧១
សង្កាត់បឹងទំពុន ខណ្ឌមានជ័យ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
អ៊ីមែល : office@babcambodia.org
គេហទំព័រ : www.babcambodia.org

គាំទ្រផ្នែកហិរញ្ញវត្ថុដោយ៖

planet wheeler

NORWEGIAN PEOPLE'S AID

Global Development Group

THE McKNIGHT FOUNDATION

OPEN SOCIETY INSTITUTE

# សេចក្តីថ្លែងអំណរគុណ

សៀវភៅ *ពលរដ្ឋវិជ្ជា៖ សេចក្តីផ្តើមនៃច្បាប់ សិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យសម្រាប់ប្រជាពលរដ្ឋកម្ពុជា* ជាលទ្ធផលពីការស្រាវជ្រាវ និពន្ធ និងសាកល្បង ពីឆ្នាំ២០០៩ រហូតដល់ឆ្នាំ២០១០។ គម្រោងនេះទទួលបានការគាំទ្រពី អង្គការ Planet Wheeter Foundation, Global Development Group, McKnight Foundation, Norwegian People's Aid (NPA) និងវិទ្យាស្ថានសង្គមបើកទូលាយ (OSI)។ យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះដៃគូទាំងអស់ដែលបានផ្តល់មូលនិធិគាំទ្រដល់យើងខ្ញុំ ព្រមទាំងជួយជំរុញឲ្យគម្រោងនេះបានកើតឡើង និងក្លាយជាការពិត។

**អ្នកនិពន្ធទូទៅ៖**

ណាតាលី ប៊ុលហ្គាស្តិ

**អ្នកកែសម្រួល៖**

ដេវីដ ព្រេដ

សៅ សុធារី

**អ្នកដែលបានចូលរួមក្នុងការនិពន្ធ៖**

រ៉េធើល បាឌីហ្គ័រ

ចូសឺលីន មែលដាឡូ

អាឡិចសាន់ដ្រា ចូន

អាលីស ណ័រមែន

**រចនាក្រមដោយ៖**

ចាន់ វិចិត្រ

**បកប្រែដោយ៖**

**សោម តុម**

**សេក សុខា**

**រូបភាព៖**

រូបភាពនៅក្នុងសៀវភៅនេះបានផ្តល់ជូនដោយ លោក ចាន់ វិចិត្រ និង **សៀវភៅយើង**

( http://www.siewphewyeung.org.kh )

យើងខ្ញុំសូមថ្លែងអំណរគុណ Bruce Lasky មកពីអង្គការ ស្ពានទៅកាន់សន្តិភាព អាស៊ីអាគ្នេយ៍ គំនិតផ្តួចផ្តើមអប់រំច្បាប់សម្រាប់សហគមន៍ និង David McQuoid Mason មកពី Street Law South Africa ដែលបានជួយជំរុញ និងផ្តល់គំនិតឲ្យកើតចេញជាសកម្មភាព ព្រមទាំងផ្តល់វិធីសាស្ត្រនានាដែលប្រើប្រាស់នៅក្នុងសៀវភៅនេះ។

យើងខ្ញុំសូមថ្លែងអំណរគុណជាពិសេស ចំពោះក្រុមការងារកម្មវិធីពង្រឹង និងផ្សព្វផ្សាយច្បាប់សម្រាប់សហគមន៍របស់អង្គការស្ពានទៅកាន់សន្តិភាពកម្ពុជា ដែលបានរៀបចំការធ្វើតេស្ត និងរៀបចំវគ្គផ្តល់យោបល់កែលម្អ ក្នុងរយៈពេលពីរឆ្នាំកន្លងមកនេះ ដើម្បីធានាថា បទពិសោធន៍ អនុសាសន៍ និងគំនិតរបស់ប្រជាពលរដ្ឋខ្មែរត្រូវបានបញ្ចូលទៅក្នុងទំព័រនានានៃសៀវភៅនេះ។ យើងខ្ញុំសូមថ្លែងអំណរគុណផងដែរ ចំពោះ Michael Otto ដែលបានពិនិត្យមើលគំរោងនេះ ចាប់តាំងពីគំរោងនេះបានចាប់ផ្តើមនៅក្នុងឆ្នាំ២០០៧ និងបានពិនិត្យឡើងវិញនូវសេចក្តីព្រាងដំបូងនៃមាតិកា និងកិច្ចតែងការបង្រៀន។

យើងខ្ញុំក៏សូមថ្លែងអំណរគុណដែរចំពោះ សៅ សុធារី, ប៊ុន មករា, សុខ សុធារ៉ា, គង់ ចាន់ណែត, ស នីផាន់ណា, អៀង វុទ្ធី, សេង វិទូ, កួន លីនណា, រស់ សុជីតា, Mark Grimsditch, Allison Fajan, Kelly Khoerger, Alice Normand, Makenzi Travis, Alexandra Jones, Yuan Tang, និង Nick Katz ដែលបានចូលរួមក្នុងការធ្វើតេស្ត និងត្រួតពិនិត្យសៀវភៅនេះ។

# មាតិកា


**សេចក្តីថ្លែងអំណរគុណ** ....... i

**របៀបប្រើសៀវភៅ** ....... i

១. ការរៀបចំ ....... i

២. ការបង្រៀនមុខវិជ្ជាពលរដ្ឋវិជ្ជា ....... ii

៣. ការបង្រៀនបែបអន្តរកម្ម ....... iii

៤. វិធីសាស្ត្របង្រៀន ....... iv

៥. ប្លង់មេរៀន ....... x

៦. ជំនាញសម្របសម្រួល ....... xiii

៧. ការវាយតម្លៃ ....... xvi

៨. ការធ្វើតេស្ត មុន និងក្រោយវគ្គសិក្សា ....... xvii

កាលវិភាគវគ្គសិក្សា ....... xviii

**សេចក្តីផ្តើមនៃច្បាប់** ....... ១

១. ហេតុអ្វីយើងត្រូវការបទបញ្ញា? ....... ១

២. ហេតុអ្វីបានជាសង្គមត្រូវមានច្បាប់? ....... ៤

*មេរៀនទី១៖ ហេតុអ្វីបានជាយើងត្រូវមានបទបញ្ញា?* ....... ៦

៣. តើច្បាប់មានមុខងារអ្វី? ....... ១១

៤. អ្វីទៅជាច្បាប់ល្អ? ....... ១៣

*មេរៀនទី ២៖ អ្វីទៅជាច្បាប់ល្អ?* ....... ១៦

**សេចក្តីផ្តើមនៃសិទ្ធិមនុស្ស** ....... ២៣

១. តើសិទ្ធិមនុស្សជាអ្វី ? ....... ២៣

២. តើសិទ្ធិមនុស្សកើតមកពីណា ? ....... ២៤

៣. សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ....... ២៥

៤. ហេតុអ្វីចាំបាច់ត្រូវការដឹង និងយល់ពីសិទ្ធិរបស់យើង ....... ៣៤

*មេរៀនទី១៖ តើសិទ្ធិមនុស្សជាអ្វី?* ....... ៣៦

៥. ប្រភេទនៃសិទ្ធិ ....... ៤៤

៦. សិទ្ធិមនុស្សទាំងអស់សុទ្ធតែទាក់ទងគ្នា ....... ៤៥

*មេរៀនទី២៖ សិទ្ធិមនុស្សទាំងអស់មានទំនាក់ទំនងគ្នា* ....... ៤៦

៧. សិទ្ធិមនុស្ស និងកាតព្វកិច្ចរបស់រដ្ឋាភិបាល ....... ៥២

៨. សន្ធិសញ្ញាអន្តរជាតិស្តីពីសិទ្ធិមនុស្ស ....... ៥៤

៩. សិទ្ធិមនុស្ស និងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ..... ៥៥
*មេរៀនទី៣៖ សិទ្ធិមនុស្ស និងកាតព្វកិច្ចរបស់រដ្ឋាភិបាល* ..... ៥៧

**សេចក្តីផ្តើមនៃលទ្ធិប្រជាធិបតេយ្យ** ..... ៦៧
១. ការធ្វើសេចក្តីសម្រេចចិត្តអំពីសង្គម ..... ៦៧
២. តើលទ្ធិប្រជាធិបតេយ្យជាអ្វី? ..... ៦៨
៣. លទ្ធិប្រជាធិបតេយ្យនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ..... ៧០
*មេរៀនទី១ ៖ តើលទ្ធិប្រជាធិបតេយ្យជាអ្វី?* ..... ៧១
៤. សិទ្ធិក្នុងការចូលរួមបោះឆ្នោតដោយសេរី និងយុត្តិធម៌ ..... ៧៥
៥. គណបក្សនយោបាយ ..... ៧៨
*មេរៀនទី២ ៖ ការបោះឆ្នោតដោយសេរី និងយុត្តិធម៌* ..... ៨០
៦. ព័ត៌មាន និងការចូលរួម ..... ៨៧
*មេរៀនទី៣ ៖ ព័ត៌មាន និងការចូលរួម* ..... ៩០
៧. សិទ្ធិក្រុមភាគតិច ..... ៩៧
៨. នីតិរដ្ឋ ..... ៩៩
*មេរៀនទី៤៖ សិទ្ធិក្រុមភាគតិច និងនីតិរដ្ឋ* ..... ១០២
៩. ការបែងចែកអំណាច ..... ១០៧
*មេរៀនទី៥៖ ការបែងចែកអំណាចដាច់ពីគ្នា* ..... ១១០
*មេរៀនទី៦៖ តុលាការឯករាជ្យ* ..... ១១៦
១០. លក្ខណៈជាប្រជាពលរដ្ឋសកម្ម ..... ១២២
*មេរៀនទី៧ ៖ ប្រជាពលរដ្ឋដែលសកម្ម និងមានការទទួលខុសត្រូវ* ..... ១២៦

**សន្ទានុក្រម** ..... ១៣១

**សំនួរស្ទាបស្ទង់ចំណេះដឹងអ្នកចូលរួម មុន និងក្រោយវគ្គបណ្តុះបណ្តាល** ..... ១៣៧

# សេចក្តីផ្តើម

**ពលរដ្ឋវិជ្ជា** គឺជាការសិក្សាអំពីសិទ្ធិ និងតួនាទីរបស់ប្រជាពលរដ្ឋ។ ប្រជាពលរដ្ឋដើរតួនាទីយ៉ាងសំខាន់ក្នុងសង្គមប្រជាធិបតេយ្យ ដែលពឹងផ្អែកទៅលើការចូលរួមរបស់ពួកគាត់ ដើម្បីឲ្យសង្គមមានដំណើរការ និងការលូតលាស់ល្អ។ ប៉ុន្តែប្រជាពលរដ្ឋមិនអាចបំពេញតួនាទីរបស់ពួកគាត់បានទេ ប្រសិនបើពួកគាត់មិនបានដឹងអំពីសិទ្ធិ និងការទទួលខុសត្រូវរបស់ពួកគាត់នោះ។ ការដែលបានដឹងអំពីពលរដ្ឋវិជ្ជាមានសារៈសំខាន់ពិសេសនៅក្នុងសង្គមដូចជា ប្រទេសកម្ពុជា ដែលកំពុងតែផ្លាស់ប្តូរទៅកាន់សង្គមប្រជាធិបតេយ្យមួយ ដែលមានការអភិវឌ្ឍយ៉ាងពេញលេញ។

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានអនុម័តឡើងនៅក្នុងឆ្នាំ១៩៩៣ បានបង្កើតប្រព័ន្ធលទ្ធិប្រជាធិបតេយ្យសេរី ពហុបក្ស ដែលរដ្ឋាភិបាល ត្រូវគោរពសិទ្ធិមនុស្ស និងនីតិរដ្ឋ។ ប៉ុន្តែជាក់ស្តែងប្រទេសកម្ពុជា និងស្ថាប័នអភិបាលកិច្ចផ្សេងៗនៅត្រូវការពេលវែងឆ្ងាយដើម្បីឈានដល់គំនិតយ៉ាងល្អឥតខ្ចោះនេះ។ នេះមិនមែនជារឿងខុសប្រក្រតីនោះទេ។ សហរដ្ឋអាមេរិកបានចំណាយពេលជិត២០០ឆ្នាំបន្ទាប់ពីប្រទេសនេះបានអនុម័តរដ្ឋធម្មនុញ្ញបែបប្រជាធិបតេយ្យ មុនពេលដែលប្រជាពលរដ្ឋរបស់គេទាំងអស់ត្រូវបានធានាឲ្យមានសិទ្ធិពេញលេញក្នុងការបោះឆ្នោត និងសិទ្ធិពេញលេញក្នុងការចូលរួមនៅក្នុងកិច្ចការនយោបាយ។

សេចក្តីណែនាំនេះត្រូវបានសរសេរឡើងដោយស្មារតីសុទិដ្ឋិនិយមសម្រាប់អ្នកជំនាន់ក្រោយ និងដោយការជឿជាក់ថា វានឹងធ្វើឲ្យប្រជាពលរដ្ឋដែលសកម្មនិងទទួលព័ត៌មានគ្រប់គ្រាន់ និងចេះពង្រឹងលទ្ធិប្រជាធិបតេយ្យ និងធ្វើឲ្យរដ្ឋាភិបាលដែលត្រូវបានបង្កើតឡើងដើម្បីបម្រើប្រជាពលរដ្ឋ និងមានការទទួលខុសត្រូវចំពោះប្រជាពលរដ្ឋរបស់ខ្លួន។ វាត្រូវបានជំរុញដោយជំនឿមួយដែលថា ភាពសកម្ម និងការធ្វើការដោយសហការគ្នា នោះប្រជាពលរដ្ឋនឹងមានអំណាចនយោបាយយ៉ាងសំខាន់មួយ និងមានតួនាទីចាំបាច់ក្នុងការអភិវឌ្ឍលទ្ធិប្រជាធិបតេយ្យយ៉ាងរស់រវើករបស់ប្រទេសកម្ពុជា។

ការណែនាំនេះមានបីផ្នែកៈ សេចក្តីផ្តើមនៃច្បាប់ សេចក្តីផ្តើមនៃសិទ្ធិមនុស្ស និងសេចក្តីផ្តើមនៃលទ្ធិប្រជាធិបតេយ្យ។ វាពន្យល់អំពីគោលការណ៍ទូទៅ និងគោលការណ៍សកលអំពីផ្នែកទាំងបីនោះ ក៏ដូចជាព័ត៌មានពាក់ព័ន្ធអំពីស្ថានភាពនៅក្នុងប្រទេសកម្ពុជាដែរ។ វាមានឧទាហរណ៍ ករណីសិក្សា និងសកម្មភាពដែលមានគោលដៅក្នុងការបង្កឲ្យមានការគិតល្អិតល្អន់ និងឆ្លុះបញ្ចាំងអំពីបទពិសោធន៍ផ្ទាល់របស់អ្នកចូលរួម និងការចែករំលែកចំណេះដឹងរបស់ពួកគាត់។

# របៀបប្រើសៀវភៅ

**ពលរដ្ឋវិជ្ជា**: *សេចក្តីផ្តើមនៃច្បាប់ សិទ្ធិ និងលទ្ធិប្រជាធិបតេយ្យសម្រាប់ប្រជាពលរដ្ឋកម្ពុជា* ត្រូវបានរចនា និងសរសេរឡើងដើម្បីឲ្យសិស្សនៅវិទ្យាល័យអាចយកមកមើលបាន ប៉ុន្តែក៏អាចប្រើសម្រាប់ការអប់រំដល់ប្រជាពលរដ្ឋយ៉ាងទូលំទូលាយដែរ។ ភាសាដែលប្រើនៅក្នុងសៀវភៅនេះ មានលក្ខណៈសាមញ្ញ និងងាយស្រួលយល់ ចំណែកឯលំហាត់វិញមានលក្ខណៈអន្តរកម្ម និងគួរឲ្យរីករាយ។

សៀវភៅនេះក៏អាចប្រើប្រាស់បានដោយអ្នក ដែលចង់សម្របសម្រួលវគ្គបណ្តុះបណ្តាលណាមួយ និងអ្នកដែលគ្រាន់តែចង់ប្រើវាសម្រាប់ជាប្រភពនៃព័ត៌មានដែរ ។ សៀវភៅនេះត្រូវបាននិពន្ធឡើងជា "សៀវភៅសម្រាប់អ្នកសម្របសម្រួល" និង ជា "សៀវភៅសម្រាប់អ្នកចូលរួម"។ សៀវភៅសម្រាប់អ្នកសម្របសម្រួលមានរួមបញ្ចូលនូវសេចក្តីណែនាំ និងអ្វីៗផ្សេងៗទៀតយ៉ាងលម្អិត ដែលអ្នកសម្របសម្រួលត្រូវការដើម្បីបើកវគ្គបណ្តុះបណ្តាល។ ចំណែកឯសៀវភៅសម្រាប់អ្នកចូលរួមវិញ មានតែព័ត៌មានទាក់ទឹងនឹងប្រធានបទនីមួយៗ ដោយមិនមានបញ្ចូលសេចក្តីណែនាំសម្រាប់អ្នកសម្របសម្រួលទេ។ វាមានប្រយោជន៍ណាស់ដែលត្រូវចែក សៀវភៅសម្រាប់អ្នកចូលរួមទៅអ្នកដែលមកចូលរួមក្នុងវគ្គបណ្តុះបណ្តាល ឬអាចប្រើវាជាប្រភពព័ត៌មានរៀនដោយខ្លួនឯងក៏បាន។

ជំពូកនេះ ពន្យល់អំពីមូលដ្ឋានស្តីពីរបៀបប្រើសៀវភៅនេះដើម្បីបង្រៀនមុខវិជ្ជាអំពី "ពលរដ្ឋវិជ្ជា"។

## ១. ការរៀបចំ

ដំបូងអ្នកចាំបាច់ត្រូវរៀបចំអំពីរបៀបដែលអ្នកត្រូវបង្រៀនវគ្គនោះ។ វាមានសារៈសំខាន់ណាស់ដែលអ្នកត្រូវត្រៀម និងរៀបចំរួចស្រេចជាមុនឲ្យបានល្អ ចាប់ពីទីកន្លែងរហូតដល់ការជ្រើសរើសជំពូក ដើម្បីបង្រៀន។ ប្រសិនបើអ្វីៗដំណើរការមិនរលូន នោះវគ្គសិក្សានោះមិនមានប្រសិទ្ធភាពទេ។ អ្នកគួរពិចារណាលើចំណុចខាងក្រោម៖

### ១.១. អ្នកចូលរួម

សៀវភៅនេះត្រូវបានសរសេរពិសេសសម្រាប់សិស្សថ្នាក់វិទ្យាល័យ ប៉ុន្តែវាក៏អាចសម្រាប់អ្នកដែលមានចំណាប់អារម្មណ៍រៀនអំពីមូលដ្ឋានច្បាប់ សិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យដែរ។ ចំនួនអ្នកចូលរួមដែលល្អបំផុតគឺចន្លោះ២០ទៅ៣០នាក់។

### ១.២. របៀបវារៈ

របៀបវារៈគឺជាការរៀបចំផែនការប្រចាំថ្ងៃនៃវគ្គសិក្សា។ យើងត្រូវការបី ឬបួនថ្ងៃដើម្បីបង្រៀនមេរៀនទាំងអស់នៅក្នុងវគ្គសិក្សានេះ។ ម្យ៉ាងទៀត មេរៀននីមួយៗអាចបង្រៀនដាច់តែឯង ហើយវគ្គសិក្សាអាចមានរយៈពេលរហូតដល់១២សប្តាហ៍។ កាលវិភាគវគ្គសិក្សានៅខាងចុងបញ្ចប់នៃផ្នែកនេះអាចជួយក្នុងការរៀបចំរបៀបវារៈ។

ត្រូវប្រាកដថា អ្នកមានពេលគ្រប់គ្រាន់ក្នុងការបង្រៀនគ្រប់មេរៀនទាំងអស់។ ត្រូវប្រាកដថា អ្នកបានបញ្ចូលពេលសម្រាក (អាហារសម្រន់) អាហារថ្ងៃត្រង់ និងល្បែងបង្កើតថាមពល (មានពន្យល់នៅខាងក្រោម)។ កុំព្យាយាមធ្វើច្រើនពេកក្នុងមួយថ្ងៃ។

### ១.៣. សៀវភៅសម្រាប់អ្នកចូលរួម

នៅចុងបញ្ចប់នៃវគ្គសិក្សានេះ វាជារឿងល្អក្នុងការផ្តល់ឲ្យអ្នកចូលរួមនូវរាល់ព័ត៌មានទាំងអស់ដែលអ្នកត្រូវបង្រៀន។ សូមព្យាយាមត្រៀមសៀវភៅគ្រប់គ្រាន់សម្រាប់អ្នកចូលរួមទាំងអស់។ សៀវភៅអាចរកបាននៅអង្គការស្ពានទៅកាន់សន្តិភាព កម្ពុជា។

## ២. ការបង្រៀនមុខវិជ្ជាពលរដ្ឋវិជ្ជា

នៅពេលដែលអ្នកចូលរួមបានមកដល់និងមានកន្លែងអង្គុយហើយ ជំហានទីមួយគឺណែនាំខ្លួនអ្នកឲ្យអ្នកចូលរួមស្គាល់ និងផ្តល់ឱកាសដល់អ្នកចូលរួមឲ្យណែនាំខ្លួនរបស់ពួកគាត់។ ការធ្វើរបៀបនេះ ជាទូទៅគឺត្រូវធ្វើនៅពេលចាប់ផ្តើមវគ្គបណ្តុះបណ្តាល ឬសិក្ខាសាលា ។ ដើម្បីចាប់ផ្តើមវគ្គសិក្សា តាមរបៀបមួយដែលធ្វើឲ្យមានការចាប់អារម្មណ៍ សូមព្យាយាមធ្វើឲ្យការណែនាំខ្លួនមានរយៈពេលខ្លី ឬព្យាយាមឲ្យពួកគាត់ចូលរួមលេងល្បែង ឬធ្វើសកម្មភាពសប្បាយៗដែលអាចជាលក្ខណៈសាមញ្ញៗដូចជា សុំឲ្យអ្នកចូលរួមទាំងអស់ប្រាប់ឈ្មោះរបស់ពួកគាត់ គាត់មកពីណា និងគាត់ចូលចិត្តម្ហូប ឬចម្រៀងអ្វីជាដើម។



វាក៏ជាការល្អដែរក្នុងការចាប់ផ្តើម ដោយពន្យល់អ្នកចូលរួមអំពីគោលបំណងចម្បងនៃវគ្គសិក្សា។ អ្នកក៏អាចសួរអ្នកចូលរួមអំពីការរំពឹងទុករបស់ពួកគាត់បន្ទាប់ចំពោះវគ្គសិក្សានេះ។ អ្នកគួរតែសុំអ្នកចូលរួមមួយចំនួន ឬទាំងអស់គ្នាឲ្យនិយាយអំពីអ្វីមួយដែលពួកគាត់រំពឹង ឬសង្ឃឹមថានឹងបានចេះនៅក្នុងកំឡុងវគ្គសិក្សានេះ។ អ្នកអាចផ្ទៀងផ្ទាត់ឡើងវិញអំពីការរំពឹងរបស់ពួកគាត់ នៅពេលបញ្ចប់នៃវគ្គសិក្សានេះថា តើការវគ្គសិក្សានេះបំពេញតាមការរំពឹងរបស់ពួកគាត់ដែរឬទេ។

## ៣. ការបង្រៀនបែបអន្តរកម្ម

វិធីដែលមានប្រសិទ្ធភាពបំផុតសម្រាប់ការបង្រៀនអំពីខ្លឹមសារ គឺវិធីបង្រៀនបែបអន្តរកម្ម ដោយផ្អែកលើការចូលរួមយ៉ាងសកម្ម និងផ្តោតទៅលើអ្នកចូលរួម ជាជាងអ្នកសម្របសម្រួល។ បច្ចេកទេសទាំងនេះជួយឲ្យអ្នកចូលរួមរៀនចេះលឿនជាងមុន និងចងចាំបានច្រើនជាង ពេលដែលពួកគាត់រៀនតាមវិធីបង្រៀនតាមបែបបុរាណ ដូចជា ការបង្រៀនបែបបាឋកថា (បទឧទ្ទេស) ជាដើម។

តាមការសិក្សា និងពិសោធន៍ជាច្រើនបានបង្ហាញថា បរិមាណ និងគុណភាពនៃព័ត៌មាន ដែលអ្នកចូលរួមចងចាំគឺអាស្រ័យលើវិធីសាស្ត្រនៃការបង្រៀន។ ការសិក្សាស្រាវជ្រាវនេះបានបង្ហាញថា ការបង្រៀនបែបបាឋកថា (បទឧទ្ទេស) មានប្រសិទ្ធភាពតិចក្នុងការផ្តល់ចំណេះដឹងទៅអ្នកចូលរួម។ ឧទាហរណ៍នៃវិធីសាស្ត្របង្រៀនបែបអន្តរកម្មរួមមាន៖

- ការសម្តែងតួ
- ការឡើងបង្ហាញ
- ការនិទានរឿង
- ការពិភាក្សាជាក្រុម

វិធីមួយដែលល្អសម្រាប់អ្នកដើម្បីបង្កើនការយល់ដឹងរបស់អ្នកចំពោះព័ត៌មាន និងជំនាញថ្មី គឺបង្រៀនទៅអ្នកដទៃ។ ការបង្រៀនអ្នកដទៃ គឺអ្នកនឹងទទួលបាននូវការយល់ដឹងប្រសើរជាងមុន ដឹងរបៀបពន្យល់អំពីអ្វីមួយដោយប្រើភាសាសាមញ្ញ និងអាចបង្ហាញពីរបៀបដែលអាចប្រើព័ត៌មាន និងជំនាញទាំងនោះ។ ការបណ្តុះបណ្តាលសហគមន៍ គឺជាដំណើរការបង្រៀន និងរៀន។ នៅពេលអ្នកបង្រៀន អ្នកចូលរួមរៀន ហើយអ្នកនឹងមានភាពជឿជាក់ជាងមុន និងបង្កើនការយល់ដឹងរបស់អ្នកចំពោះបញ្ហាដែលអ្នកកំពុងបង្រៀន។ អ្នកក៏នឹងទទួលបាននូវឱកាសដ៏មានតម្លៃក្នុងការរៀនពីបទពិសោធន៍ និងសាច់រឿងរបស់អ្នកចូលរួមវិញដែរ។

**រយៈពេលមួយឆ្នាំក្រោយពីអ្នកចូលរួមបានរៀន តើពួកគាត់មានការចងចាំបានប៉ុន្មាន?**

- ប្រសិនបើ ប្រើវិធីបង្រៀនបែបបាឋកថា (បទឧទ្ទេស) នោះអ្នកចូលរួមចងចាំប្រហែល ៥%
- ប្រសិនបើអ្នកចូលរួមប្រើវិធីអាន នោះពួកគាត់ចងចាំប្រហែល ១០%
- ប្រសិនបើ ប្រើវិធីបង្រៀនបែបសោតទស្សន៍ (ការប្រើវីដេអូ ឬកម្មវិធី PowerPoint) នោះអ្នកចូលរួមចងចាំប្រហែល ២០%
- ប្រសិនបើអ្នកចូលរួមមើលការបង្ហាញ នោះពួកគាត់នឹងចងចាំប្រហែល ៣០%
- ប្រសិនបើអ្នកចូលរួមពិភាក្សាជាក្រុមតូច នោះពួកគាត់នឹងចងចាំប្រហែល ៥០%
- ប្រសិនបើអ្នកចូលរួមអនុវត្តជាក់ស្តែង នោះពួកគាត់នឹងចងចាំ ៧៥%
- ប្រសិនបើអ្នកចូលរួមបង្រៀនអ្នកដទៃ នោះពួកគាត់នឹងចងចាំប្រហែល ៩០%




## ៤. វិធីសាស្ត្របង្រៀន

មានវិធីសាស្ត្របង្រៀនខុសៗគ្នាជាច្រើន ដែលអាចមានប្រយោជន៍ក្នុងការបង្រៀនសិស្ស។ វិធីសាស្ត្រទាំងនេះមានគោលបំណងធ្វើឲ្យអ្នកចូលរួមក្នុងសិក្ខាសាលាក្លាយទៅជា *អ្នកចូលរួមសកម្ម* និងមិនមែនជាអ្នកសង្កេតអសកម្ម។ វិធីសាស្ត្រទាំងនេះទទួលស្គាល់ថា អ្នកចូលរួមតែងតែមកចូលរួមក្នុងវគ្គបណ្តុះបណ្តាលដោយនាំមកនូវចំណេះដឹង និងបទពិសោធន៍អំពីជីវិតរបស់ពួកគេ ហើយពួកគាត់មានរឿងច្រើនដែលអាចចូលរួមជាមួយនឹងការរៀន ដែលនឹងកើតឡើងនៅក្នុងថ្នាក់រៀន។ ខាងក្រោមនេះជាឧទាហរណ៍ខ្លះនៃវិធីសាស្ត្របង្រៀនបែបអន្តរកម្ម។

## ៤.១. ការបំផុសគំនិត

ការបំផុសគំនិតគឺជាវិធីមួយដែលអនុញ្ញាតឲ្យអ្នកចូលរួមបញ្ចេញគំនិតដោយសេរី។ ជាទូទៅ ចម្លើយ និងគំនិតទាំងនោះគឺគ្មានខុស ឬត្រូវនោះទេ។

ក្នុងកំឡុងពេលបំផុសគំនិតអំពីប្រធានបទណាមួយ អ្នកចូលរួមអាចនឹងត្រូវសួរសំណួរ។ ឧទាហរណ៍ ដូចជា "តើវិធីផ្សេងៗគ្នាក្នុងការបង្រៀនមានអ្វីខ្លះ?" ពេលនោះអ្នកចូលរួមគិតរកគំនិតផ្សេងៗគ្នាតាមតែពួកគាត់អាចគិតឃើញ ហើយគំនិតទាំងនេះគួរតែសរសេរ ឬគូរនៅលើក្តារខៀន ឬក្រដាសផ្ទាំងធំ។ បន្ទាប់មក គំនិតរបស់គ្រប់គ្នាត្រូវបានយកមកពិភាក្សា។




## ៤.២. ការពិភាក្សាក្រុមតូច

ចំពោះការពិភាក្សាក្រុមតូច អ្នកគប្បីត្រូវតែគ្រោងទុកជាមុនដោយប្រយ័ត្នប្រយែង។ អ្នកចូលរួមគួរតែទទួលបាននូវបទបញ្ជា និងការណែនាំច្បាស់លាស់ ហើយគួរតែមានពេលវេលាគ្រប់គ្រាន់ក្នុងការពិភាក្សា។ ប្រសិនបើអាច ក្រុមទាំងអស់មិនគួរមានអ្នកចូលរួមលើសពី៥នាក់ទេ ដើម្បីឲ្យអ្នកគ្រប់គ្នាមានឱកាសក្នុងការនិយាយ។

## ៤.៣. ករណីសិក្សា

ករណីសិក្សា គឺជាសាច់រឿង ឬការអធិប្បាយអំពីព្រឹត្តិការណ៍មួយដែលអាចជារឿងពិត ឬប្រឌិត និងអាចប្រើសម្រាប់ជួយឲ្យយល់អំពីរបៀបដែលអាចអនុវត្តព័ត៌មាន និងជំនាញថ្មី។ ករណីសិក្សាអាចប្រើនៅក្នុងកំឡុងពេលពិភាក្សាជាក្រុម ដើម្បីជួយអ្នកចូលរួមឲ្យវិភាគ និងគិតល្អិតល្អន់អំពីរបៀបក្នុងការប្រើព័ត៌មាន និងជំនាញថ្មីក្នុងការអនុវត្តជាក់ស្តែង។



## ៤.៤. ការសម្តែងតួ

នៅក្នុងការសម្តែងតួ អ្នកចូលរួម (ឬជួនកាលអ្នកសម្របសម្រួល) សម្តែងអំពីស្ថានការណ៍ណាមួយ។ អ្នកចូលរួមអាចនឹងទទួលបានស្ថានការណ៍ណាមួយតាមរយៈករណីសិក្សា ឬពួកគាត់ត្រូវបានស្នើឲ្យប្រឌិតរឿងឡើងដោយពួកគាត់។ វត្ថុផ្សេងៗដែលមាននៅក្នុងថ្នាក់រៀនអាចយកមកប្រើនៅក្នុងការសម្តែងតួ ដើម្បីឲ្យកាន់តែមានភាពសប្បាយរីករាយ។ ការសម្តែងតួមានប្រយោជន៍ដោយសារអ្នកចូលរួមអាចមានគំនិតច្នៃប្រឌិតដែលអាចធ្វើឲ្យពួកគាត់ចូលរួមរៀនមេរៀនកាន់តែខ្លាំង និងធ្វើឲ្យពួកគាត់កាន់តែសកម្ម និងមានការចាប់អារម្មណ៍កាន់តែខ្លាំង។

## ៤.៥. សំណួរ និងចម្លើយ

ការពិភាក្សាតាមរយៈសំណួរ និងចម្លើយអាចប្រើជារឿយៗជំនួសឲ្យការបង្រៀនបែបបាឋកថា (បទឧទ្ទេស)។ តាមរបៀបនេះគឺ គ្រប់គ្នានិយាយ និងត្រូវការគិតដោយប្រយ័ត្នអំពីបញ្ហា មិនមែនមានតែអ្នកសម្របសម្រួលទេដែលគិតនោះ។ អ្នកចូលរួមច្រើនតែដឹងអំពីព័ត៌មានខ្លះទាក់ទងនឹងបញ្ហា ឬប្រធានបទដែលកំពុងរៀន ឬដឹងថា បញ្ហានោះទាក់ទងនឹងជីវិតរបស់ពួកគាត់យ៉ាងណា។ អ្នកសម្របសម្រួលដែលល្អ គឺអាចទាញយកចំណេះដឹង និងបទពិសោធន៍របស់អ្នកចូលរួម និងពង្រឹងបន្ថែមចំណេះដឹង និងបទពិសោធន៍ថ្មីទាំងនោះ។ ការសួរសំណួរគួរសមទៅអ្នកចូលរួមដែលស្ងៀមស្ងាត់ គឺជាវិធីល្អមួយដែលលើកទឹកចិត្តពួកគាត់ឲ្យនិយាយ និងចូលរួមកាន់តែសកម្ម ។

វិធីដ៏ល្អមួយក្នុងការចាប់ផ្តើមបង្រៀន ប្រធានបទថ្មីស្រឡាងមួយមកបង្រៀន គឺការសួរទៅកាន់ក្រុមទាំងមូលនូវសំណួរងាយៗខ្លះអំពីប្រធានបទនោះ។ តាមការធ្វើរបៀបនេះ អ្នកនឹងដឹងថា តើអ្នកណាដឹងអ្វីខ្លះអំពីប្រធានបទនេះ។ ការសួរសំណួរនៅចុងមេរៀន ក៏ជាវិធីមួយល្អក្នុងការផ្ទៀងផ្ទាត់ថា តើអ្នកចូលរួមយល់មេរៀន និងអាចឲ្យយើងដឹងថា យើងបានសម្រេចតាមគោលបំណងមេរៀនដែរឬទេ។




## ៤.៦. ល្បែងថាមពល

ល្បែងគឺជាវិធីបង្រៀនបែបសប្បាយៗសម្រាប់មនុស្សទាំងក្មេង ទាំងចាស់។ យើងអាចលេងល្បែងជា "ការបំបែកបរិយាកាសខ្មាសអៀន" ដែលជាសកម្មភាពសប្បាយៗ ដែលអ្នកអាចប្រើដើម្បីជួយឲ្យអ្នកចូលរួមបានស្គាល់គ្នាកាន់តែច្បាស់ និងមានភាពស្និទ្ធស្នាលជាមួយគ្នា។ ជួនកាលគេលេងល្បែងនេះជា "ការបង្កើនថាមពល" ដើម្បីប្តូរបរិយាកាសឲ្យអ្នកចូលរួមស្វាហាប់ឡើងវិញ ឬបំបាត់ភាពងងុយនៅពេលរៀន។ យើងក៏

អាចលេងល្បែងសម្រាប់បង្រៀនប្រធានបទពិបាកៗ ដូចជា ច្បាប់ និងជួយអ្នកចូលរួមឲ្យចងចាំខ្លឹមសារថ្មីៗ។ ល្បែងនេះអាចលេងជាក្រុម ឬលេងជាលក្ខណៈប្រកួតប្រជែង ប៉ុន្តែត្រូវប្រយ័ត្នកុំបង្កឲ្យអ្នកចូលរួមណាម្នាក់អាម៉ាស់មុខដោយសារតែគេមិនដឹងពីចម្លើយចំពោះសំណួរណាមួយ។ វាអាចជាការលើកទឹកចិត្តកាន់តែខ្លាំង ប្រសិនបើ គ្រប់គ្នាជាអ្នកឈ្នះ។

## ៤.៧. ការធ្វើបទបង្ហាញរបស់អ្នកចូលរួម

នៅពេលពិភាក្សាជាក្រុម យើងអាចចែកប្រធានបទមួយ ឬករណីសិក្សាមួយ ឬឲ្យសំណួរមួយដើម្បីពិភាក្សានៅក្នុងក្រុមតូច រួចហើយពួកគាត់ឡើងធ្វើបទបង្ហាញដល់ក្រុមទាំងមូល។ យើងអាចសុំឲ្យក្រុមនីមួយៗរៀបចំបទបង្ហាញ ដូចជាតាមរយៈ ការគូររូប ការច្រៀងចម្រៀង ការសម្តែងតួ ការរៀបគម្រោង គំនិត ឬការឆ្លើយសំណួរ។ អ្នកចូលរួមអាចធ្វើបទបង្ហាញជាក្រុម ឬជ្រើសរើសអ្នកតំណាងក្រុមម្នាក់ឲ្យឡើងបង្ហាញក៏បាន។ ក្រោយពីធ្វើបទបង្ហាញរួច អ្នកចូលរួម (រួមទាំងអ្នកឡើងបង្ហាញ និងអ្នកមើល) អាចពិភាក្សាអំពីបទបង្ហាញនេះបាន។

## ៤.៨. សម្ភារៈចក្ខុឧទ្ទេស

វត្ថុ រូបថត រូបភាព រូបគំនូរ ផ្ទាំងរូបភាពធំៗ និងភាពយន្តជាដើម ទាំងអស់នេះគឺជាសម្ភារៈចក្ខុឧទ្ទេស។ សម្ភារៈចក្ខុឧទ្ទេសជួយធ្វើឲ្យអ្នកចូលរួម ផ្តោតអារម្មណ៍លើមេរៀន និងជាវិធីមួយយ៉ាងមានប្រសិទ្ធភាពក្នុងការនាំយកបទពិសោធន៍ជីវិតពិតៗពីប្រទេសកម្ពុជា និងពីជុំវិញពិភពលោកមកបង្ហាញក្នុងក្រុមទាំងមូល។ សម្ភារៈចក្ខុឧទ្ទេសក៏មានប្រយោជន៍ ក្នុងការបង្ហាញគំនិត ទស្សនៈ និងផែនការផ្សេងៗដែរ។ នៅក្នុងពេលប្រើសម្ភារៈចក្ខុឧទ្ទេសនោះ គេអាចសុំឲ្យអ្នកចូលរួមរៀបរាប់ និងវិភាគអ្វីដែលពួកគាត់ទើបឃើញ និងឲ្យពួកគាត់អនុវត្ត ឬប្រៀបធៀបវា ទៅនឹងបទពិសោធន៍និងស្ថានភាពរបស់គាត់ផ្ទាល់។ សម្ភារៈចក្ខុទទ្ទេសខ្លះ ដូចជា ភាពយន្តជាដើម អាចមានប្រយោជន៍ខ្លាំងណាស់ ពេលធ្វើការពន្យល់បង្ហាញអំពីរបៀបអនុវត្តជំនាញថ្មីៗ។ (ចូរចាំថា ស្ថានភាពដូចគ្នានេះ ក៏អាចត្រូវអនុវត្តដោយការសម្តែងតួ)។



ក្រុមសហគមន៍ អង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័ននៃអង្គការសហប្រជាជាតិ ជាច្រើនបានផលិតវីដេអូខ្លីៗអំពីច្បាប់ សិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យ។ អ្នកប្រហែលជាអាចរកបានវីដេអូទាំងនេះតាមអ៊ីនធើរណិត ឬអ្នកអាចសួរទៅអង្គការមិនមែនរដ្ឋាភិបាល ក្រែងពួកគេអាចជួយរកឲ្យអ្នកបាន។ ត្រូវប្រាកដថាអ្នកមានអគ្គិសនី និងឧបករណ៍ដែលអ្នកត្រូវការ ប្រសិនបើអ្នកមានគម្រោងបញ្ចាំងវីដេអូណាមួយ។

## ៤.៩. បទចម្រៀង

ប្រជាពលរដ្ឋខ្មែរភាគច្រើនចូលចិត្តច្រៀងនិងរាំ។ ដូច្នេះ អ្នកអាចប្រើឱកាសនេះនៅក្នុងសិក្ខាសាលាបណ្ដុះបណ្ដាលរបស់អ្នក។ ជួនកាលអ្នកអាចឲ្យក្រុមសម្រាកមួយភ្លែតពីការបង្រៀន និងនាំគ្នាច្រៀងរាំដើម្បីបំបាត់ភាពងងុយ។ អ្នកក៏អាចប្រើបទចម្រៀងក្នុងការបង្រៀនដែរ។ ឧទាហរណ៍ ក្រោយពីបង្រៀនអំពីប្រធានបទណាមួយរួចហើយ អ្នកអាចសុំឲ្យអ្នកចូលរួមតែងចម្រៀងមួយបទអំពីអ្វីដែលពួកគាត់បានរៀននោះ។ ប្រសិនបើអាចធ្វើបានដោយប្រើទំនុកភ្លេងណាមួយដែលកំពុងពេញនិយម នោះវាកាន់តែធ្វើឲ្យពួកគាត់ងាយចាំនូវអ្វីដែលពួកគាត់ទើបបានរៀនទៀតផង។



| អ្នកចូលរួមដែលមានបញ្ហាពិបាកក្នុងការអាន |
| --- |
| ជួនកាល អាចនឹងមានអ្នកចូលរួមខ្លះនៅក្នុងវគ្គសិក្សារបស់អ្នកដែលមានការលំបាកក្នុងការអាន និងសរសេរ។ អ្នកចាំបាច់ត្រូវដឹងអំពីបញ្ហានេះ ហើយវាប្រហែលជាទង្វើមិនល្អទេ ដែលយើងសួរពួកគាត់ត្រង់ៗនៅក្នុងថ្នាក់ទាំងមូលយ៉ាងនេះ ព្រោះវាអាចធ្វើឲ្យពួកគាត់មានភាពអាម៉ាស់។<br><br>លំហាត់ជាច្រើនតម្រូវឲ្យយើងប្រើករណីសិក្សា និងវិធីសាស្ត្រផ្សេងៗ ដែលទាមទារឲ្យមានការអាន និងសរសេរខ្លះៗ។ ប្រសិនបើមានអ្នកចូលរួមណាដែលមានការលំបាកក្នុងការអាន និងសរសេរ នោះអ្នកមានជម្រើសពីរ បីផ្សេងទៀត ដែលគេអាចយកមកប្រើ ដូចជា ជម្រើសមួយគឺត្រូវដាក់សមាជិកយ៉ាងតិចម្នាក់ក្នុងក្រុមនីមួយៗដែលចេះអាន និងសរសេរ ដើម្បីជានាថា នៅពេលធ្វើលំហាត់ដែលប្រើករណីសិក្សា ឬសំណួរ គាត់អាចជួយអានឲ្យក្រុមគាត់ស្តាប់ និងជួយសរសេរគំនិតយោបល់ ឬចម្លើយរបស់ក្រុមគាត់ប្រសិនបើចាំបាច់។<br><br>ប្រសិនបើគ្មានអ្នកចេះអាន ឬចេះសរសេរគ្រប់គ្រាន់នៅក្នុងចំណោមអ្នកចូលរួមទេ ខ្លួនអ្នកផ្ទាល់ ឬអ្នកសម្របសម្រួលដទៃទៀតអាចជួយអានករណីសិក្សាឲ្យលឺខ្លាំងៗ និងជួយកត់ត្រាចម្លើយរបស់ពួកគាត់។ អ្នកអាចរិះរកវិធីផ្សេងៗទៀត ដើម្បីបង្កលទ្ធភាពដល់ក្រុមទាំងអស់បានកត់ត្រានូវគំនិត និងចម្លើយ ដូចជាគូររូបភាព ឬក៏ពួកគាត់ទន្ទេញសំណួរ និងចម្លើយឲ្យបានរត់មាត់ក៏បាន។<br><br>សកម្មភាពទាំងអស់នៅក្នុងសៀវភៅនេះ ងាយស្រួលនឹងកែសម្រួលទៅតាមស្ថានភាពរបស់អ្នកចូលរួមគ្រប់រូបណាស់ សូម្បីតែអ្នកចូលរួមដែលមានការលំបាកក្នុងការអាន ក៏អាចចូលរួមក្នុងសកម្មភាពរៀនបានយ៉ាងសកម្មដែរ។ |

## ៥. ប្លង់មេរៀន

*ប្លង់មេរៀនគឺប្រៀបដូចជាផែនទីបង្ហាញផ្លូវដែរ*។ ឧទាហរណ៍ បើយើងចង់ទៅកន្លែងណាមួយ តែយើងស្គាល់ផ្លូវមិនច្បាស់ យើងអាច ប្រើផែនទីដើម្បីរកផ្លូវ។ យើងត្រូវរកមើលកន្លែងចាប់ផ្តើម និងកន្លែងដែលយើងត្រូវទៅ យើងក៏ត្រូវរកមើលកន្លែងដែលយើងត្រូវឆ្លងកាត់មុនទៅដល់គោលដៅដែរ។ ប្លង់មេរៀនមានមុខងារដូចគ្នានឹងផែនទីដែរ។ កន្លែងចាប់ផ្តើមជាគោលបំណងមេរៀន រីឯគោលដៅចុងក្រោយជាការសម្រេចគោលបំណងនៃមេរៀន។ ប៉ុន្តែដើម្បីទៅដល់គោលដៅនោះ មានជំហានច្រើនដែលត្រូវឈាន ដើម្បីឲ្យបានសម្រេចគោលដៅនោះ។

ប្លង់មេរៀន នៅក្នុងសៀវភៅនេះមាន ៨ ផ្នែក។ ផ្នែកទីមួយគឺ **អត្ថបទមេរៀន** បន្ទាប់មក **លំហាត់** ដែលបំបែកជា ៧ ផ្នែកតូចៗថែមទៀត។ ផ្នែកដទៃទៀតគឺ៖ គោលបំណង សម្ភារៈ/ឯកសារ វិធីសាស្ត្រប្រើប្រាស់ ដំណើរការ/រយៈពេលគិតជានាទី ការណែនាំសម្រាប់អ្នកសម្របសម្រួល ចម្លើយដែលអាចទទួលយកបាន និង ការសង្ខេបមេរៀន។ ខាងក្រោមនេះ គឺជាសេចក្តីពន្យល់ត្រួសៗអំពីគោលបំណងនៃផ្នែកនីមួយៗនៃមេរៀន។

## ៥.១. អត្ថបទមេរៀន

នៅក្នុងផ្នែកអត្ថបទមេរៀនមានព័ត៌មានអំពីប្រធានបទសម្រាប់មេរៀននីមួយៗ។ ឧទាហរណ៍ ប្រសិនបើមេរៀននោះទាក់ទងនឹងសិទ្ធិមនុស្ស ដូច្នេះអត្ថបទមេរៀនត្រូវមានព័ត៌មាន ដូចជា និយមន័យរបស់សិទ្ធិមនុស្ស សិទ្ធិមនុស្សមានឫសគល់មកពីណា និងមានឧទាហរណ៍ខ្លះៗស្តីពីសិទ្ធិមនុស្ស។ ជាធម្មតា ក្នុងផ្នែកអត្ថបទមេរៀនមានរូបភាពខ្លះៗទាក់ទងនឹងប្រធានបទក្នុងមេរៀន។ ផ្នែកអត្ថបទមេរៀននេះ មានលំហាត់ខ្លះ និងការណែនាំសម្រាប់ធ្វើលំហាត់ទាំងនោះ។

## ៥.២. មេរៀន

### ៥.២.១. គោលបំណង

គោលបំណងនៃមេរៀនគឺជាអ្វីដែលអ្នកចូលរួមគប្បីត្រូវរៀន និងយល់ដឹងអំពីប្រធានបទដោយរៀនមេរៀននោះ។

ឧទាហរណ៍៖

| |
|---|
| **គោលបំណង៖ អ្នកចូលរួមនឹងគិតថា តើសិទ្ធិមនុស្សជាអ្វី មានប្រភពមកពីណា និងហេតុអ្វីបានជាយើងត្រូវដឹងអំពីសិទ្ធិមនុស្ស។** |

### ៥.២.២. សម្ភារៈ

នេះគឺជាបញ្ជីសម្ភារៈដែលយើងត្រូវការចាំបាច់សម្រាប់បង្រៀន។ ដូច្នេះអ្នកត្រូវត្រៀមឲ្យមានសម្ភារៈទាំងអស់នេះ មុននឹងចាប់ផ្តើមបង្រៀនមេរៀន។

ឧទាហរណ៍៖

| |
|---|
| **សម្ភារៈ៖** ក្រដាសផ្ទាំងធំ ឬក្តារខៀន ហ្វឺតសម្រាប់សរសេរ កូនបាល់ ឯកសារសម្រាប់ចែកទី១។ |

### ៥.២.៣. វិធីសាស្ត្រប្រើប្រាស់

ជាវិធីសាស្ត្របង្រៀនតាមបែបអន្តរកម្មមួយចំនួន ដែលត្រូវយកមកប្រើប្រាស់ក្នុងការបង្រៀន សម្រាប់មេរៀននីមួយៗ។

ឧទាហរណ៍៖

| |
|---|
| **វិធីសាស្ត្រប្រើប្រាស់៖** ការបំផុសគំនិត ការពិភាក្សាជាក្រុមធំ ការគូររូប។ |

### ៥.២.៤. ដំណើរការ/ពេលវេលា

កូឡោនខាងឆ្វេងដៃនៃតារាងនេះ មានកំណត់អំពីជំហាននីមួយៗ ដើម្បីយកមកអនុវត្តតាមក្នុងពេលបង្រៀនមេរៀន។ កូឡោនខាងស្តាំ បង្ហាញរយៈពេលដែលត្រូវការចាំបាច់សម្រាប់ជំហាននីមួយៗ។ រយៈពេលសរុបដើម្បីបង្រៀនមេរៀន មានបង្ហាញនៅចុងខាងក្រោមនៃតារាង។ តារាងនេះមានសារៈសំខាន់ណាស់សម្រាប់រៀបចំរបៀបវារៈ។

ឧទាហរណ៍៖

| ដំណើរការ | រយៈពេល ( គិតជានាទី ) |
|---|---|
| ១. ការបំផុសគំនិត និងការពិភាក្សាជាក្រុម | ១៥ |
| ២. ណែនាំព័ត៌មានក្នុងផ្នែកទី១ និងទី២ | ២០ |
| ៣. ការពិភាក្សាក្រុមតូច | ១៥ |
| ៤. ការឡើងបង្ហាញរបស់ក្រុមនីមួយៗ | ២០ |
| ៥. ការសង្ខេប | ១០ |
| **សរុប៖** | **៨០** |

### ៥.២.៥. ការណែនាំសម្រាប់អ្នកសម្របសម្រួល

នៅក្នុងវគ្គនេះ មានការណែនាំលម្អិតអំពីរបៀបបង្រៀនមេរៀននីមួយៗ និងគ្រប់ដំណាក់កាលនៃមេរៀនដូចដែលបានកំណត់នៅក្នុងតារាងដំណើរការខាងលើ។ ក្នុងនោះមានទាំងព័ត៌មានសំខាន់ៗ និងការប្រាប់អំពីរបៀបដែលអាចជួយអ្នកក្នុងការបង្រៀនមេរៀនឲ្យទទួលបានលទ្ធផលល្អ។

### ៥.២.៦. ចម្លើយដែលអាចទទួលយកបាន

ប្រសិនបើមានសំណួរនៅក្នុងមេរៀនដែលទាមទារឲ្យអ្នកចូលរួមផ្តល់ព័ត៌មាន ជាជាងផ្តល់យោបល់ផ្ទាល់ខ្លួន នោះនៅក្នុងផ្នែកនេះ មានចម្លើយដែលអាចទទួលយកបានសម្រាប់សំណួរខាងលើ។

### ៥.២.៧. ការសង្ខេប

ផ្នែកនេះមានគោលដៅវាយតម្លៃ ឬស្ទាបស្ទង់មើលថា តើគោលបំណងនៃមេរៀននេះបានសម្រេចដែរឬទេ។ ចំណុចសំខាន់គឺយើងមិនមែនគ្រាន់តែសង្ខេបមេរៀន ឬការរំលឹកមេរៀននោះទេ ព្រោះថា ការធ្វើបែបនេះមិនជួយឲ្យអ្នកក្នុងការផ្ទៀងផ្ទាត់ដឹងថា អ្នកចូលរួមបានរៀន និងបានយល់ដឹងច្បាស់អំពីចំណុចសំខាន់ៗនៃមេរៀនឡើយ។ ដូច្នេះអ្នកអាចធ្វើការផ្ទៀងផ្ទាត់ថា បានសម្រេច ឬមិនបានគោលបំណងនៃមេរៀនដោយប្រើសកម្មភាពខ្លះ ដូចជា សំណួរ ចម្លើយ ដោយសុំអ្នកចូលរួមឲ្យសង្ខេបមេរៀន ឬដោយការលេងល្បែងសប្បាយៗ ដូចជាសំណួរល្បងប្រាជ្ញាជាដើម។

# ៦. ជំនាញសម្របសម្រួល

ក្នុងនាមជាអ្នកសម្របសម្រួល មានរឿងជាច្រើនណាស់ដែលយើងត្រូវគិត រួមមានខ្លឹមសារមេរៀន ការណែនាំសម្រាប់ធ្វើលំហាត់ និងសម្ភារៈចាំបាច់នានាសម្រាប់ការបង្រៀន។ ជាមួយគ្នានេះដែរ អ្នកសម្របសម្រួលត្រូវដឹងអំពីឥរិយាបថ ដែលខ្លួនប្រព្រឹត្តក្នុងពេលសម្របសម្រួល និងអំពីវិធីសមស្របសម្រាប់បង្រៀនមេរៀន។ វាសំខាន់ណាស់ដែលថា អ្នកចូលរួមគោរពអ្នក និងថា ពួកគាត់ក៏មានអារម្មណ៍ថាពួកគាត់ទទួលការគោរពពីអ្នកបង្រៀន និងថាពួកគាត់មានអារម្មណ៍សប្បាយរីករាយក្នុងការចូលរួមសកម្មភាពក្នុងវគ្គបណ្តុះបណ្តាល។ ខាងក្រោមនេះ ជាគន្លឹះសំខាន់ៗអំពីរបៀបក្លាយជា អ្នកសម្របសម្រួលយ៉ាងពូកែ។ វាអាចមានចំណុចច្រើនណាស់ដែលត្រូវចងចាំ ប៉ុន្តែយូរៗទៅជំនាញទាំងនេះនឹងក្លាយទៅជាធម្មតា។



## ៦.១. ការត្រៀមរៀបចំ

ប្រសិនបើអ្នកចេះចាំមេរៀនស្ទាត់ នោះអ្នកនឹងមានទំនុកចិត្តលើខ្លួនឯងកាន់តែខ្លាំង អ្នកនឹងអាចបង្រៀនបានកាន់តែច្បាស់ល្អ ចំណែកឯ អ្នកចូលរួមក៏កាន់តែទុកចិត្តលើសមត្ថភាពក្នុងការបង្រៀនរបស់អ្នកច្រើនជាងមុនដែរ។ សំខាន់គឺយើងត្រូវតែយល់ច្បាស់លាស់អំពីមេរៀន និងមានទំនុកចិត្តក្នុងការបង្រៀន និងត្រូវដឹងថា សម្ភារៈអ្វីខ្លះ ដែលយើងត្រូវការចាំបាច់សម្រាប់ពេលបង្រៀន និងសេចក្តីណែនាំណាខ្លះដែលអ្នកត្រូវផ្តល់ដល់អ្នកចូលរួម។

## ៦.២. ការគ្រប់គ្រងពេលវេលា

អ្នកត្រូវចេះបត់បែនតាមស្ថានការណ៍ និងកាលៈទេសៈ។ ប្រសិនបើអ្នកចូលរួមយល់ថា មេរៀនពិបាកយល់ពេក អ្នកអាចផ្តល់ពេលបន្ថែមឲ្យបានវែងជាងពេលកំណត់បន្តិច និងសមល្មមឲ្យពួកគាត់។ ប្រសិនបើពួកគាត់ថាមេរៀនស្រួលពេក ឬពួកគាត់ចេះដឹងច្រើនអំពីប្រធានបទនៃមេរៀននោះហើយ នោះអ្នកអាចបង្កើនល្បឿន និងបញ្ចប់មេរៀនមុនពេលកំណត់ក៏បាន។ ប៉ុន្តែត្រូវចាំថា ប្រសិនបើអ្នករៀបចំកម្មវិធីបង្រៀនច្រើន និងត្រូវបង្រៀនប្រធានបទជាច្រើន ពេលនោះអ្នកត្រូវតែគោរពតាមកាលវិភាគដែលបានរៀបចំរួចមកតាមដែលយើងអាចធ្វើទៅបាន។

## ៦.៣. កាយវិការ

អ្នកសម្របសម្រួលត្រូវសម្តែងឲ្យអ្នកចូលរួមដឹងថា អ្នកមានឆន្ទៈនិងចង់បង្រៀន។ សំខាន់ត្រូវឈរឲ្យត្រង់ដងខ្លួន ដើរចុះឡើងក្នុងថ្នាក់នៅពេលបង្រៀន។ ត្រូវរំពៃមើលទៅអ្នកចូលរួមឲ្យបានគ្រប់គ្នា និងមិនត្រូវសម្លឹងទៅក្រោម ឬទៅក្រៅបង្អួចឡើយ និងក៏មិនត្រូវរំពៃមើលតែអ្នកដែលនៅជួរខាងមុខអ្នកប៉ុណ្ណោះទេ។ កាយវិការរបស់អ្នកមិនគួរបង្កឲ្យអ្នកចូលរួមមានភាពទើសទាល់ឡើយ។ ឧទាហរណ៍ អ្នកមិនត្រូវចង្អុលអ្នកចូលរួមណាម្នាក់ឡើយ។ ប្រសិនបើអ្នកណាម្នាក់កំពុងឆ្លើយសំណួរ កុំបន្ទចបង្អាក់គាត់ ឬសម្លឹងគាត់ក្នុងន័យមើលស្រាលឡើយ។ ផ្ទុយទៅវិញ ត្រូវសម្តែងការចាប់អារម្មណ៍ និងលើកទឹកចិត្តឲ្យពួកគាត់ ដោយពោលពាក្យសរសើរ ហើយប្រសិនបើចាំបាច់ត្រូវកែសម្រួលចម្លើយដោយសុភាពរាបសារ និងប្រកបដោយសេចក្តីគោរព។

## ៦.៤. ជៀសវាងការធ្វើបទឧទ្ទេស

ជួនកាលបទឧទ្ទេស ហាក់ដូចជាវិធីងាយស្រួលបំផុតក្នុងការបង្រៀនមេរៀនថ្មីៗ។ តែដូចបានពិភាក្សាខាងលើ វាគឺជាវិធីដែលមានប្រសិទ្ធភាពតិចបំផុតក្នុងការបង្រៀន និងការរៀន។ វិធីសាស្ត្របង្រៀនដែលយើងបានពិភាក្សាខាងលើ ជាវិធីយកមកបណ្តុះបណ្តាលចំណេះដឹងថ្មីដោយជៀសវាងការធ្វើបាឋកថានេះ។ ប្រសិនបើក្នុងពេលបង្រៀន អ្នកចាប់អារម្មណ៍ថា អ្នកនិយាយច្រើនពេកលើផ្នែកណាមួយ ចូរឈប់បន្តិច រួចសួរសំណួរខ្លះៗ ឬនាំអ្នកចូលរួមឲ្យធ្វើសកម្មភាពណាមួយដើម្បីប្តូរបរិយាកាស។ ជាញឹកញាប់ណាស់ដែលគេអាចប្តូរការមេរៀនបែបបទឧទ្ទេស ទៅជាការបង្រៀនដែលមានអន្តរកម្ម ដោយសួរសំណួរ និងបើកឲ្យមានការពិភាក្សាវិញ។ ធ្វើយ៉ាងនេះ អ្នកចូលរួមស្វែងយល់អំពីព័ត៌មានដោយខ្លួនឯង មិនចាំបាច់យើងបកស្រាយច្រើនពេកទេ។ ទោះជាវិធីក្រោយនេះ ចំណាយពេលច្រើនបន្តិចមែន ប៉ុន្តែវាអាចធ្វើឲ្យមេរៀនមានការចាប់អារម្មណ៍ខ្លាំង និងមានប្រសិទ្ធភាពសម្រាប់អ្នកចូលរួមជាជាងការនិយាយតែម្នាក់ឯង ដូចជាការធ្វើបទឧទ្ទេស ជាដើម។

## ៦.៥. ត្រួតពិនិត្យការយល់ដឹងរបស់អ្នកចូលរួម

អ្នកសម្របសម្រួលល្អតែងតែត្រួតពិនិត្យមើលការយល់ដឹងរបស់អ្នកចូលរួម ពីដើមដល់ចប់មេរៀន។ ប៉ុន្តែ សូមកុំបង្រៀនមួយម៉ោងរួចសួរអ្នកចូលរួមថា "យល់ទេ?" អ្នកអាចផ្ទៀងផ្ទាត់ការយល់ដឹងរបស់អ្នកចូលរួមរៀងរាល់ពីរ បីនាទីម្តង ដោយលើកជាសំណួរពីប្រធានបទកំពុងបង្រៀន ឬសុំឲ្យអ្នកណាម្នាក់ស្ម័គ្រចិត្តសង្ខេបមេរៀនដែលបានរៀន។ ចូរចាំថា មិនត្រូវឲ្យតែអ្នកដែលមានសំឡេងខ្លាំង ឬអ្នកមានទំនុកចិត្តឡើង

សង្ខេបមេរៀនទេ។ វាមានសារៈសំខាន់ណាស់ដែលអ្នកត្រូវពិនិត្យមើលថា តើអ្នកចូលរួមដែលមានលក្ខណៈស្ងៀមស្ងាត់ក៏យល់មេរៀនផងដែរ។

## ៦.៦. ការលើកទឹកចិត្តអ្នកចូលរួមដែលស្ងៀមស្ងាត់

នៅគ្រប់វគ្គសិក្សា តែងតែមានអ្នកចូលរួមដែលស្ងៀមស្ងាត់ ដែលមានអារម្មណ៍ខ្មាសអៀន ឬមានការលំបាកក្នុងការរៀន។ នៅក្នុងករណីខ្លះ ស្ត្រី ឬជនជាតិភាគតិច ច្រើនតែនៅស្ងៀមស្ងាត់ ហើយមិនសូវហ៊ានឆ្លើយសំណួរទេ បើទោះជាគាត់ដឹងចម្លើយក៏ដោយ។

វាមានសារៈសំខាន់ណាស់ដែលធ្វើឲ្យអ្នកចូលរួមដែលស្ងៀមស្ងាត់ មានអារម្មណ៍កក់ក្តៅ រីករាយ និងធូរស្រាលក្នុងអារម្មណ៍ ដោយឧស្សាហ៍ញញឹមរាក់ទាក់ដល់ពួកគាត់ និងយកចិត្តទុកដាក់នឹងពួកគាត់។ អ្នកអាចសាកល្បងលើកទឹកចិត្តពួកគាត់ឲ្យឆ្លើយសំណួរ ឬឡើងធ្វើជាតំណាងនៅក្នុងក្រុមរបស់ខ្លួន ហើយផ្តល់ការសាទរដល់ពួកគាត់ នៅពេលដែលពួកគាត់ចូលរួមយ៉ាងសកម្មក្នុងសកម្មភាពណាមួយ។ ពេលសម្រាក បើអាចធ្វើទៅបាន ឆ្លៀតឱកាសសាកសួររាក់ទាក់ជាមួយនឹងពួកគាត់ បន្ថែមទៀតព្រោះពួកគាត់អាចមានអារម្មណ៍សន្ទនាជាមួយអ្នកអំពីអ្វីដែលពួកគាត់ទើបបានរៀន ឬចង់សួរអ្នកអំពីអ្វីមួយទាក់ទិននឹងមេរៀន។

## ៦.៧. កសាងទំនាក់ទំនងល្អជាមួយអ្នកចូលរួម

អ្នកត្រូវព្យាយាមបង្កើតមិត្តភាពជាមួយអ្នកចូលរួមទាំងឡាយ ដោយធ្វើតាមឧទាហរណ៍ដូចខាងក្រោម៖

- ជម្រាបសួរពួកគាត់ ពេលចូលមកដល់បន្ទប់បណ្តុះបណ្តាល
- ហៅពួកគាត់ឲ្យចំៗឈ្មោះ
- សួរសំណួរដល់ពួកគាត់ និងប្រាប់ពួកគាត់អំពីអ្នក
- លើកទឹកចិត្តអ្នកចូលរួមឲ្យចូលរួមរៀនយ៉ាងសកម្ម
- និយាយជាមួយពួកគាត់ម្នាក់ទល់ម្នាក់ មុនចាប់ផ្តើម និងក្រោយពេលបញ្ចប់មេរៀន ព្រមទាំងក្នុងពេលសម្រាក (ជាពិសេសជាមួយអ្នកដែលតែងតែស្ងៀមស្ងាត់)
- ផ្តល់ឱកាសដល់អ្នកចូលរួមឲ្យចែករំលែកអំពីរឿងរ៉ាវផ្ទាល់ខ្លួន
- ចូលរួមពិសាអាហារថ្ងៃត្រង់ជាមួយអ្នកចូលរួម និង
- សរសើរចំពោះការខិតខំប្រឹងប្រែង និងការចូលរួមចំណែក ព្រមទាំងលើកទឹកចិត្តអ្នកណា ដែលតែងតែអៀនខ្មាសច្រើន ឬមានការលំបាកក្នុងការរៀនមេរៀន។

## ៦.៨. ល្បែងថាមពល

វាមានសារៈសំខាន់ណាស់ដែលអ្នករក្សាឲ្យអ្នកចូលរួមមានការចាប់អារម្មណ៍លើមេរៀន។ ប្រសិនបើអ្នកចូលរួមមិនមានការចាប់អារម្មណ៍ នោះពួកគាត់នឹងស្តាប់មិនបានល្អ ហើយពួកគាត់នឹងមិនមានការចងចាំចំពោះអ្វីដែលគាត់បានរៀននោះទេ។

វិធីមួយដើម្បីចៀសពីបញ្ហានេះ គឺការអនុវត្តលំហាត់ "ល្បែងផ្តល់ថាមពល" យ៉ាងខ្លីមួយនៅចន្លោះមេរៀននីមួយៗ ឬនៅពេលណាដែលអ្នកមានអារម្មណ៍ថា អ្នកចូលរួមមានភាពនឿយហត់ ឬលែងចាប់អារម្មណ៍នឹងមេរៀន។ អ្នកប្រហែលជាត្រូវការធ្វើលំហាត់នេះជារឿយៗនៅពេលបញ្ចប់មេរៀនប្រចាំថ្ងៃ ឬក្រោយពីអាហារថ្ងៃត្រង់ នៅពេលដែលអ្នកចូលរួមអស់កម្លាំង។ ល្បែងផ្តល់ថាមពល រួមមាន ចម្រៀង រាំល្បែង ការនិទានរឿង និងសកម្មភាពដទៃទៀតដែលធ្វើឲ្យអ្នកចូលរួមដើរចុះឡើងនិងមានភាពសប្បាយរីករាយ។



## ៧. ការវាយតម្លៃ

បន្ទាប់ពីចប់វគ្គសិក្សា វាមានសារៈសំខាន់ណាស់ដែលអ្នកត្រូវដឹងថា តើអ្នកចូលរួមមានអារម្មណ៍យ៉ាងណាចំពោះវគ្គសិក្សានេះ និងដឹងថា តើពួកគាត់រៀនចេះអ្វីខ្លះ។ យើងអាចដឹងបែបនេះបាន តាមរយៈការវាយតម្លៃ។ ការវាយតម្លៃអាចធ្វើតាមរបៀបខុសៗគ្នាជាច្រើន និងពេលខុសៗគ្នាដែរ។ ជាទូទៅ ពេលដែលល្អបំផុតសម្រាប់ធ្វើការវាយតម្លៃ គឺនៅពេលបញ្ចប់ការបង្រៀនប្រចាំថ្ងៃ។ ពេលខ្លះវាក៏ល្អដែរ ក្នុងការវាយតម្លៃវគ្គសិក្សាពីរ បីសប្តាហ៍ ឬពីរ បីខែក្រោយមក។ វិធីនេះ អ្នកនឹងអាចពិនិត្យមើលថា តើអ្នកចូលរួមនៅចងចាំអ្វីខ្លះ។

អ្នកអាចធ្វើការវាយតម្លៃដោយគ្រាន់តែនិយាយនិងសួរសំណួរខ្លះៗជាមួយអ្នកចូលរួម។ ការធ្វើបែបនេះ អ្នកអាចធ្វើជាមួយក្រុមទាំងមូល ឬជាមួយក្រុមតូចក៏បាន។ ការធ្វើជាក្រុមបែបនេះ វាល្អណាស់ចំពោះអ្នកចូលរួមដែលមិនសូវចេះអានអក្សរ។ វិធីសាស្ត្រក្នុងការវាយតម្លៃមួយទៀត គឺចែកទម្រង់វាយតម្លៃឲ្យអ្នកចូលរួមបំពេញ។

សម្រាប់វិធីសាស្ត្រទាំងពីរនេះ អ្នកគួរសួរសំណួរដូចខាងក្រោមៈ

- តើអ្នកយល់មេរៀនទេ?
- តើមេរៀនដែលផ្ដល់ឲ្យនេះ មានប្រយោជន៍ទេ?
- តើមេរៀនណាដែលមានប្រយោជន៍ខ្លាំង ហើយមេរៀនណាដែលមិនសូវមានប្រយោជន៍? (អ្នកអាចឲ្យអ្នកចូលរួមរៀបរាប់ពីលំដាប់ថ្នាក់នៃមេរៀនដែលមានសារៈសំខាន់បំផុតពីលើចុះក្រោម)
- បើអ្នកសម្របសម្រួលរៀបចំ និងបង្រៀនបានល្អដែរឬទេ?

តាមរយៈការសួរសំណួរទាំងនេះ អ្នកអាចកែលំអ និងរៀបចំឲ្យបានកាន់តែប្រសើរឡើងនៅវគ្គក្រោយៗ។ លើសពីនេះ អ្នកសម្របសម្រួលអាចវាយតម្លៃទៅលើវគ្គសិក្សាដោយការកត់សំគាល់ខ្លួនឯងថា តើមានភាពជោគជ័យកម្រិតណាចំពោះលំហាត់ និងការយល់ដឹងរបស់អ្នកចូលរួម។

## ៨. ការធ្វើតេស្ត មុន និងក្រោយវគ្គសិក្សា

វាជាគំនិតល្អក្នុងការដែលដឹងពីការយល់ដឹងរបស់អ្នកចូលរួមចំពោះខ្លឹមសាររបស់វគ្គសិក្សា មុនពេលចាប់ផ្ដើមវគ្គសិក្សា។ វិធីសាស្ត្រនេះនឹងធ្វើឲ្យអ្នកមានមូលដ្ឋានមួយក្នុងការវាយតម្លៃថា តើពួកគាត់បានរៀនចេះកម្រិតណានៅពេលបញ្ចប់វគ្គសិក្សា។ វាក៏អាចដឹងអំពីកម្រិតនៃចំណេះដឹងដែលអ្នកចូលរួមមាននៅពេលដំបូង។ អ្នកអាចយកចំណុចនេះមកពិចារណា នៅពេលដែលអ្នកបង្រៀន។ នៅខាងខ្នងនៃសៀវភៅនេះ មានតេស្ត ដែលអ្នកអាចយកទៅប្រើបានសម្រាប់គោលបំណងនេះ។

នៅចុងបញ្ចប់នៃវគ្គសិក្សា អ្នកគួរតែធ្វើតេស្តដដែលនេះម្ដងទៀត ដើម្បីប្រៀបធៀបលទ្ធផលរបស់ពួកគាត់ជាមួយនឹងតេស្តមុនវគ្គសិក្សា។ វិធីសាស្ត្រនេះនឹងជួយឲ្យអ្នកវាយតម្លៃលើភាពជោគជ័យនៃវគ្គសិក្សាក្នុងការបង្កើនចំណេះដឹង និងការយល់ដឹងរបស់អ្នកចូលរួមចំពោះខ្លឹមសារមេរៀន។

# ការវិភាគវគ្គសិក្សា

វគ្គសិក្សា *ពលរដ្ឋវិជ្ជា* ទាំងមូលនឹងត្រូវការរយៈពេលប្រហែល ១៦ ម៉ោង និង ១៥ នាទី។ វគ្គសិក្សាពេញលេញនឹងធ្វើឡើងក្នុងរយៈពេលបី ឬបួនថ្ងៃ សម្រាប់វគ្គបណ្ដុះបណ្ដាលដើម្បីបញ្ចប់ខ្លឹមសារទាំងមូល ឬអាចបំបែក ដើម្បីបង្រៀនម្ដងមួយឬពីរមេរៀនក្នុងរយៈពេលច្រើនសប្ដាហ៍ក៏បាន។

| សេចក្ដីផ្ដើមនៃច្បាប់ | | |
|---|---|---|
| *លេខរៀងមេរៀន* | *ឈ្មោះមេរៀន* | *រយៈពេល* |
| ១ | ហេតុអ្វីយើងមានបទបញ្ញា? | ៧៥ |
| ២ | អ្វីទៅជាច្បាប់ល្អ? | ៨០ |
| សរុប : ១៥៥ នាទី (២ ម៉ោង ៣៥ នាទី) | | |

| សេចក្ដីផ្ដើមនៃសិទ្ធិមនុស្ស | | |
|---|---|---|
| *លេខរៀងមេរៀន* | *ឈ្មោះមេរៀន* | *រយៈពេល* |
| ១ | អ្វីទៅជាសិទ្ធិមនុស្ស | ១០៥ |
| ២ | សិទ្ធិមនុស្សទាំងអស់ទាក់ទងគ្នា | ៨៥ |
| ៣ | សិទ្ធិមនុស្ស និងតួនាទីរបស់រដ្ឋាភិបាល | ៩០ |
| សរុប : ២៨០ នាទី (៤ ម៉ោង ៤០ នាទី) | | |

| សេចក្ដីផ្ដើមនៃលទ្ធិប្រជាធិបតេយ្យ | | |
|---|---|---|
| *លេខរៀងមេរៀន* | *ឈ្មោះមេរៀន* | *រយៈពេល* |
| ១ | អ្វីទៅជាលទ្ធិប្រជាធិបតេយ្យ | ៩០ |
| ២ | ការបោះឆ្នោតដោយសេរី និងយុត្តិធម៌ | ៨០ |
| ៣ | ព័ត៌មាន និងការចូលរួម | ៨០ |
| ៤ | សិទ្ធិភាគតិច និងនីតិរដ្ឋ | ៨០ |
| ៥ | ការបែងចែកអំណាច | ៥៥ |
| ៦ | ឯករាជ្យភាពរបស់អង្គតុលាការ | ៦៥ |
| ៧ | ប្រជាពលរដ្ឋដែលសកម្ម និងមានការទទួលខុសត្រូវ | ៩០ |
| សរុប : ៥៤០ នាទី (៩ ម៉ោង) | | |

# សេចក្តីផ្តើមនៃច្បាប់

លទ្ធផលទទួលបាន :

ក្រោយពីបញ្ចប់ជំពូកនេះ អ្នកចូលរួមនឹងអាច :

១. យល់ថាហេតុអ្វីបានជាសង្គមត្រូវមានច្បាប់។

២. យល់ពីមុខងារនៃច្បាប់។

៣. ដឹងថាច្បាប់មានទំនាក់ទំនងទៅនឹងមនុស្សក្នុងជីវិតប្រចាំថ្ងៃ។

៤. យល់ថាអ្វីដែលធ្វើឲ្យច្បាប់ល្អ។

## ១. ហេតុអ្វីយើងត្រូវការបទបញ្ញា?

ចូរស្រមៃថា យើងកំពុងលេងបាល់ទាត់ជាមួយមិត្តរបស់យើង។ អ្នកទាត់បាល់ទៅឲ្យក្រុមរបស់អ្នកម្នាក់ដែលកំពុងតែរត់តម្រង់ទៅកាន់ទី ស្រាប់តែភ្លាមៗនោះ មានមនុស្សម្នាក់ពីក្រុមប្រកួតជាមួយអ្នក រត់មករកបាល់ហើយចាប់បាល់ដោយដៃរបស់គាត់ បន្ទាប់មកក៏បោះបាល់នោះសំដៅទៅទីនៃក្រុមរបស់គាត់។



ចូរស្រមៃថាអ្នកនៅផ្ទះជាមួយក្រុមគ្រួសាររបស់អ្នកហើយបម្រុងនឹងហូបបាយពេលល្ងាច។ អ្នកមាននំម្ហូបអាម៉ុកត្រីគ្រប់គ្រាន់សម្រាប់សមាជិកនៅក្នុងក្រុមគ្រួសារអ្នក ម្នាក់មួយៗ។ បងស្រីរបស់អ្នកនិយាយថា គាត់ឃ្លានខ្លាំងណាស់ហើយយកម្ហូបអាម៉ុកត្រីទាំងអស់តែម្នាក់ឯង។



ចូរស្រមៃថាអ្នកកំពុងអង្គុយនៅក្នុងថ្នាក់រៀនរបស់អ្នកនៅសាលា។ គ្រូរបស់អ្នកកំពុងពន្យល់អំពីប្រវត្តិសម័យបុរាណនៃប្រទេសកម្ពុជា។ មានសិស្សមួយចំនួនធុញ ហើយនិយាយឮខ្លាំងៗនៅខាងក្រោយថ្នាក់ ដែលធ្វើឲ្យសិស្សដទៃទៀតមិនអាចស្តាប់ដឹងថា អ្នកគ្រូកំពុងនិយាយអ្វីឡើយ។



នៅក្នុងស្ថានភាពទាំងអស់ខាងលើនេះ យើងត្រូវការបទបញ្ញាដើម្បីឲ្យសកម្មភាពរបស់យើងមានការគោរពចំពោះអ្នកដទៃ ហើយមិនមែនគិតតែពីតម្រូវការនិងចំណង់ភ្លាមៗរបស់យើងនោះទេ។ ថ្វីត្បិតថា ការដែលយើងមានសេរីភាពក្នុងការធ្វើទៅតាមអ្វីដែលយើងអាចជ្រើសរើសបាននោះគឺជា ផ្នែកមួយយ៉ាងសំខាន់សម្រាប់ភាពសប្បាយរីករាយរបស់មនុស្សក៏ដោយ ក៏ប៉ុន្តែដោយសារភាគច្រើននៃសកម្មភាពរបស់យើងមានឥទ្ធិពលទៅលើអ្នកដទៃ ដូច្នេះយើងត្រូវការបទបញ្ញាដើម្បីដាក់ដែនកំណត់ខ្លះទៅលើអ្វីដែលយើងធ្វើ។ ដែនកំណត់ទាំងនេះមានសារៈសំខាន់ណាស់ដើម្បីឲ្យមានការគោរពទៅលើជីវិតនិងសេរីភាពរបស់អ្នកដទៃ។

- យើងមានបទបញ្ញានៅក្នុងកីឡាបាល់ទាត់ដើម្បីឲ្យអ្នកគ្រប់គ្នាលេងដោយយុត្តិធម៌ ហើយអ្នកគ្រប់គ្នាអាចទទួលបាននូវភាពសប្បាយក្នុងការលេងកីឡាដែលសមហេតុផល។ បទបញ្ញាមានសារៈសំខាន់ដោយសារអ្នកគ្រប់គ្នាយល់ពីរបៀបលេងកីឡានោះ ហើយប្រសិនបើអ្នកគ្រប់គ្នាលេងស្របទៅតាមបទបញ្ញាទាំងនោះដូចៗគ្នា នាំឲ្យការលេងនោះនឹងមានភាពត្រឹមត្រូវ។

- យើងមានបទបញ្ញានៅផ្ទះជាមួយក្រុមគ្រួសាររបស់យើង ដើម្បីឲ្យយើងអាចរស់នៅដោយសន្តិភាពជាមួយគ្នា និងគោរពតម្រូវការរបស់គ្នាទៅវិញទៅមក។ បទបញ្ញាមានសារៈសំខាន់ដោយសារវាឆ្លុះបញ្ចាំងពីសីលធម៌នៅក្នុងក្រុមគ្រួសារ ឧទាហរណ៍ សារៈសំខាន់នៃការចែករំលែកគ្នា។
- យើងមានបទបញ្ញានៅសាលារៀនដើម្បីឲ្យសិស្សទាំងអស់មានឱកាសក្នុងការរៀនមុខវិជ្ជា និងជំនាញថ្មីៗ។ បទបញ្ញាមានសារៈសំខាន់ដើម្បីឲ្យសាលារៀនដំណើរការមានប្រសិទ្ធភាព និងបំពេញគោលបំណងរបស់សាលាក្នុងការបង្រៀនសិស្ស។

**បទបញ្ញាល្អ** អាចជួយឲ្យមនុស្សមានទំនាក់ទំនងជាមួយគ្នា និងជាមួយបរិស្ថានរបស់ពួកគេទៅតាមរបៀបមួយដែលត្រឹមត្រូវ និងចេះគោរពគ្នា។ បទបញ្ញាជួយរក្សារបៀបរៀបរយរវាងមនុស្សនៅផ្ទះ នៅសាលារៀន នៅទីលានប្រកួត និងនៅកន្លែងដទៃទៀត។

## ២. ហេតុអ្វីបានជាសង្គមត្រូវមានច្បាប់?

សង្គមក៏ដូចជាគ្រួសារ ក្រុម ឬសហគមន៍ដែលត្រូវការបទបញ្ញាដើម្បីឲ្យការរស់នៅមានសន្តិភាព និងការគោរពទៅលើសិទ្ធិសេរីភាព និងតម្រូវការអ្នកដទៃដែរ គឺសង្គមមានច្បាប់ដើម្បីរក្សាសណ្តាប់ធ្នាប់ និងដំណើរការមានប្រសិទ្ធភាព ដូចជាដោះស្រាយជម្លោះដោយយុត្តិធម៌ និងការពារមិនឲ្យមនុស្សបង្កគ្រោះថ្នាក់ដល់អ្នកដទៃ។ **សង្គម** គឺជាក្រុមមនុស្សដ៏ធំមួយដែលរស់នៅក្នុងប្រទេសឬតំបន់ណាមួយដែលជាទូទៅមានទំនៀមទម្លាប់ វប្បធម៌ និងសីលធម៌ដូចគ្នា។ បុគ្គល ឬក្រុមមនុស្សនៅក្នុងសង្គមមានគុណតម្លៃ គំនិតនិងជំនឿខុសៗគ្នា ប៉ុន្តែជាទូទៅ ពួកគេមានកាតព្វកិច្ច ត្រូវរស់នៅទៅតាមវិធីមួយដែលស្របទៅតាមបទបញ្ញាជាក់លាក់មួយចំនួនដើម្បីគោរព ទំនៀមទម្លាប់របស់សង្គមនោះដូចគ្នា។



នៅពេលដែលមនុស្សជាច្រើននៅក្នុងសង្គមប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមកដោយផ្ទាល់ក្តី និង ដោយប្រយោលក្តី ពេលនោះហើយដែលយើងត្រូវការអ្វីមួយដែលខ្លាំងជាងបទបញ្ញាដើម្បីរក្សាសណ្តាប់ធ្នាប់។ **ច្បាប់**គឺជាបទបញ្ញាដែលត្រូវបានព្រមព្រៀងនិងធ្វើឲ្យទៅជាផ្លូវការដោយមនុស្សដែលមានសិទ្ធិអំណាចក្នុងការសម្រេចចិត្តអំពីរបៀបក្នុងការរៀបចំសង្គម។ សមាជិកគ្រប់រូបនៅក្នុងសង្គម រួមទាំងអ្នកដែលមានសិទ្ធអំណាចក្នុងការធ្វើច្បាប់ផង ត្រូវតែគោរពច្បាប់។ ប្រសិនបើរកឃើញថា មានអ្នកណាបំពានច្បាប់ នោះគេនឹងត្រូវដាក់ទោសទៅតាមយន្តការ ដែលបង្កើតឡើងដោយសង្គមនោះ។

## មេរៀនទី១៖ ហេតុអ្វីបានជាយើងត្រូវមានបទបញ្ញា?



**គោលបំណង ៖** អ្នកចូលរួមនឹងយល់ថា ហេតុអ្វីបានជាយើងត្រូវការបទបញ្ញា និងច្បាប់នៅក្នុងសង្គម។

**សម្ភារៈ ៖** ស្ករគ្រាប់ ក្រដាសផ្ទាំងធំ ហ្វឺត ភ្លេងប្រពៃណីខ្មែរ (ប្រសិនបើមាន)។

**វិធីសាស្ត្រ ៖** ការបង្កើតបទបញ្ញា ល្បែង ការពិភាក្សាជាក្រុម ការរំរែក។

| ដំណើរការ | រយៈពេល (គិតជានាទី) |
|---|---|
| ១. បទបញ្ញាផ្ទៃក្នុងនៃវគ្គបណ្តុះបណ្តាល | ២០ |
| ២. ល្បែងស្ករគ្រាប់ | ១៥ |
| ៣. ណែនាំព័ត៌មាននៅក្នុងផ្នែកទី១ និងទី២ | ២៥ |
| ៤. សង្ខេប | ១៥ |
| **សរុប៖** | **៧៥** |

# ការណែនាំសម្រាប់អ្នកសម្របសម្រួល

## ១. បទបញ្ជាផ្ទៃក្នុងនៃវគ្គបណ្ដុះបណ្ដាល :

- សូមពន្យល់អ្នកចូលរួមថា មុននឹងចាប់ផ្ដើមវគ្គបណ្ដុះបណ្ដាលនេះ ពួកគាត់នឹងត្រូវសម្រេចចិត្តទៅលើបទបញ្ជាផ្ទៃក្នុងនៃវគ្គបណ្ដុះបណ្ដាលទាំងអស់គ្នា។ គ្រប់គ្នាត្រូវគោរពតាមបទបញ្ជាទាំងនេះតាំងពីដើមរហូតដល់ចប់វគ្គបណ្ដុះបណ្ដាល ។

- អ្នកអាចលើកឧទាហរណ៍មួយ អំពីបទបញ្ជាផ្ទៃក្នុងនៃវគ្គបណ្ដុះបណ្ដាលដូចជា អ្នកគ្រប់គ្នាត្រូវបិទទូរស័ព្ទ។ សូមសួរទៅកាន់អ្នកចូលរួមថា តើពួកគាត់ទាំងអស់គ្នាយល់ស្របទៅនឹងបទបញ្ជាទី១នេះដែរឬទេ ហើយប្រសិនបើពួកគាត់យល់ស្រប សូមសរសេរបទបញ្ជានោះនៅលើក្រដាសផ្ទាំងធំ។

- បន្ទាប់មក សូមសួរអ្នកចូលរួមថា តើគួរមានបទបញ្ជាអ្វីផ្សេងទៀតសម្រាប់វគ្គបណ្ដុះបណ្ដាលនេះ។

- បន្ទាប់ពីអ្នកចូលរួមលើកឡើងពីបទបញ្ជាណាមួយ សូមពិនិត្យមើលថា តើអ្នកចូលរួមផ្សេងៗទៀតយល់ស្របដែរឬទេ បន្ទាប់មកសរសេរវាលើក្រដាសផ្ទាំងធំ។ បន្ទាប់ពីបានសរសេរបទបញ្ជាទាំងអស់រួចហើយ សូមសួរអ្នកចូលរួមថា តើពួកគាត់គិតថា បទបញ្ជាទាំងនោះល្អដែរឬទេ។

- នៅពេលដែលបទបញ្ជាទាំងអស់ត្រូវបានបង្កើតហើយ សូមរំលឹកអ្នកចូលរួមថា គ្រប់ៗគ្នាត្រូវគោរពបទបញ្ជាទាំងនេះក្នុងកំឡុងពេលវគ្គបណ្ដុះបណ្ដាល។ សូមសួរ ពួកគាត់ថា តើគួរមានការពិន័យទៅលើអ្នកណាដែលមិនគោរពបទបញ្ជាទាំងនោះដែរឬទេ។ សូមឲ្យអ្នកចូលរួមបញ្ចេញយោបល់។ ឧទាហរណ៍ដូចជា ប្រសិនបើ ទូរស័ព្ទអ្នកណាម្នាក់រោទ៍នៅក្នុងកំឡុងពេលរៀន នោះម្នាក់នោះត្រូវតែច្រៀងចម្រៀងមួយបទ ឬរាំនៅមុខអ្នកចូលរួមទាំងអស់នៅពេលចុងបញ្ចប់នៃមេរៀននោះ។

- បិទក្រដាសផ្ទាំងធំដែលមានសរសេរបទបញ្ជាផ្ទៃក្នុងនៃវគ្គបណ្ដុះបណ្ដាលលើជញ្ជាំង ដើម្បីឲ្យគ្រប់គ្នាអាចមើលវាឃើញក្នុងកំឡុងពេលវគ្គបណ្ដុះបណ្ដាលនោះ។

- **ចំណាំ** : ក្នុងកំឡុងពេលសម្រាក សូមបន្ថែមបទបញ្ជាពីរទៀតចូលក្នុងបញ្ជី។ បទបញ្ជាទាំងនោះគួរតែជាបទបញ្ជា ដែលមិនសមហេតុផល ឬអយុត្តិធម៌ ហើយមានបទបញ្ជាមួយដែលមានលក្ខណៈផ្ទុយគ្នានឹងបទបញ្ជាមុន។ ខាងក្រោមនេះជាឧទាហរណ៍ចំពោះបទបញ្ជាដែលត្រូវបន្ថែម៖

- មានតែអ្នកសម្របសម្រួលប៉ុណ្ណោះ អាចនិយាយទូរស័ព្ទក្នុងកំឡុងពេលវគ្គបណ្តុះបណ្តាល
- ស្ត្រីដែលស្លៀកពាក់ពណ៌ក្រហមនៅថ្ងៃនេះមិនអាចបញ្ចេញមតិបានទេ។ បុរសដែលស្លៀកពាក់ពណ៌ខៀវនៅថ្ងៃនេះគឺមានសិទ្ធិគ្រប់ពេលក្នុងការនិយាយ មុនអ្នកណាទាំងអស់។

សូមលាក់បទបញ្ញាថ្មីទាំងពីរនោះ ដោយបត់ក្រដាសផ្ទាំងធំនោះពីលើ ឬបិតក្រដាសមួយទៀតពីលើដើម្បីបាំង។ អ្នកនឹងប្រើបទបញ្ញាទាំងនេះនៅក្នុងការសង្ខេបមេរៀនលំហាត់ទី ២។

## ២. ល្បែងស្ករគ្រាប់ :

- ដំបូង យកស្បោងស្ករគ្រាប់មក ហើយសុំឲ្យអ្នកចូលរួមទាំងអស់ឈរជារង្វង់ជុំវិញអ្នក។
- បោះស្ករគ្រាប់ចូលទៅក្នុងរង្វង់នោះ។ សូមសួរទៅកាន់អ្នកចូលរួមថា គាត់ចូលចិត្តស្ករគ្រាប់ទាំងនោះដែរឬទេ។
- សូមប្រាប់អ្នកចូលរួមទាំងអស់ថា អ្នកបានភ្លេចរបស់អ្វីមួយនៅខាងក្រៅ ហើយអ្នកនឹងត្រលប់មកវិញក្នុងពីរ បីនាទីទៀត។ សូមទុកស្ករគ្រាប់ទាំងនោះនៅជាមួយអ្នកចូលរួមទាំងអស់។
- ពីរ បីនាទីក្រោយមក ត្រលប់មករកក្រុមអ្នកចូលរួមទាំងអស់វិញ ហើយមើលថា តើមានស្ករគ្រាប់បាត់ដែរឬទេ។
- សូមឲ្យអ្នកចូលរួមពន្យល់អ្នកពីអ្វីដែលបានកើតឡើងក្នុងកំឡុងពេលដែលអ្នកទៅក្រៅ។ អ្នកចូលរួមខ្លះប្រហែលជាបានយកស្ករគ្រាប់ ឬពួកគាត់បានទុកវាចោលនៅលើឥដ្ឋដដែល។
- សូមសួរអ្នកចូលរួមពីរ ឬបីនាក់ថា ហេតុអ្វី បានជាពួកគាត់ធ្វើដូច្នេះ។ ប្រសិនបើពួកគាត់បានយកស្ករគ្រាប់ សូមសួរពួកគាត់ថា ហេតុអ្វី។ ប្រសិនបើពួកគាត់មិនបានយក សូមសួរពួកគាត់ថា ហេតុអ្វីមិនយក ។
- បន្ទាប់មក សូមសួរទៅកាន់អ្នកចូលរួមថា តើពួកគាត់នឹងធ្វើយ៉ាងណា ប្រសិនបើបោះលុយទៅកណ្តាលរង្វង់វិញ។
  - តើពួកគាត់នឹងយកខ្លះដែរឬទេ?
  - ហេតុអ្វីពួកគាត់មិនធ្វើបែបនេះ? ឬហេតុអ្វីពួកគាត់ធ្វើបែបនេះដដែល?

- អ្នកចូលរួមទាំងអស់ប្រហែលជាឆ្លើយសំណួរទាំងនេះមិនដូចគ្នាទេ។ ពួកគាត់ប្រហែលជាមានភាពអាម៉ាស់ក្នុងការយកស្ករគ្រាប់ទាំងនោះ ដោយសារតែមានអ្នកដទៃទៀតកំពុងមើល។ អ្នកដទៃទៀតប្រហែលជាគិតថា ដោយសារស្ករគ្រាប់ទាំងនោះមិនសូវមានតម្លៃ ដូច្នេះវាមិនអីទេ ប្រសិនបើគាត់យក ប៉ុន្តែបើជាលុយវិញពួកគាត់នឹងមិនយកទេ។ អ្នកខ្លះមិនមានបញ្ហាក្នុងការយកស្ករគ្រាប់នោះទេ ព្រោះមិនមានបទបញ្ជាថា មិនឲ្យយកស្ករគ្រាប់នោះទេ។ ប៉ុន្តែទោះបីជាមិនទាន់មានបទបញ្ជាក៏ដោយ ក៏មានអ្នកមួយចំនួនយល់ថា យកស្ករគ្រាប់នោះដូចជាមិនស្រួលទេ ដោយសារពួកគាត់មានអារម្មណ៍ថាធ្វើបែបនោះខុស។
- សូមសួរទៅកាន់អ្នកចូលរួមថា តើពួកគាត់គិតថា សីលធម៌គ្រប់គ្រាន់ក្នុងការធ្វើឲ្យប្រាកដថា មនុស្សនឹងមិនលួចដែរឬទេ? ឬមួយយើងត្រូវការអ្វីផ្សេងទៀត? តើពួកយើងត្រូវការបទបញ្ជាដែរឬទេ?

<u>ចម្លើយអាចទទួលយកបាន</u>៖

- វាគ្មានចម្លើយណាដែលខុស ឬត្រូវទេ ដោយសារតែគោលបំណងរបស់លំហាត់នេះ គឺធ្វើឲ្យអ្នកចូលរួមគិតអំពីការត្រូវការនៃបទបញ្ជាដើម្បីធ្វើឲ្យមានសណ្តាប់ធ្នាប់នៅក្នុងសង្គម។
- ជួយឲ្យអ្នកចូលរួមយល់ថា សីលធម៌មិនគ្រប់គ្រាន់ក្នុងការធ្វើឲ្យប្រាកដថា មនុស្សនឹងធ្វើអ្វីដែលត្រឹមត្រូវ និងគោរពគ្នាទៅវិញទៅមកនោះទេ។
- សីលធម៌អាចខុសគ្នាពីមនុស្សម្នាក់ទៅម្នាក់។ អ្នកខ្លះមិនយកស្ករគ្រាប់នោះដោយសារពួកគាត់គិតថា វាខុសសីលធម៌ ប៉ុន្តែអ្នកខ្លះទៀតប្រហែលជាយកស្ករគ្រាប់ទាំងនោះ ប្រសិនបើគេដឹងថាគេអាចយកវាដោយមិនមានការពិន័យ ឬមានការអាម៉ាស់អ្វីនោះទេ។

## ៣. ណែនាំព័ត៌មាននៅក្នុងផ្នែកទី១ និងទី២ : (សូមមើលទំព័រទី១ ដល់ទី៥)

**ផ្នែកទី១ និងទី២** : វាមានសារៈសំខាន់ណាស់ដែលអ្នកចូលរួមយល់ថា :

- ហេតុអ្វីយើងត្រូវការបទបញ្ជា។
- ហេតុអ្វីសង្គមត្រូវមានច្បាប់។

## ៤. សង្ខេប :

- ដើម្បីបញ្ចប់លំហាត់នេះ សូមឲ្យអ្នកចូលរួមរាំរបាំប្រពៃណី (រាំវង់) ជារង្វង់។ អ្នកអាចចាក់ភ្លេងប្រសិនបើមាន ឬលើកទឹកចិត្តពួកគាត់ឲ្យច្រៀង។ នៅពេលអ្នកចូលរួមរាំ ពន្យល់ពួកគាត់ថា ពួកគាត់កំពុងអនុវត្តតាមបទបញ្ជានៃការរាំដែលមិនមានសរសេរទុក ដែលដូចគ្នាទៅនឹងបទបញ្ជានៅក្នុងសង្គមដែរ។

- អ្នកសម្របសម្រួលគួរចូលរួមរាំ ប៉ុន្តែគួររាំបញ្រ្ចាសទិសពីអ្នកគ្រប់ៗគ្នា រាំប៉ះជាមួយអ្នកដទៃ និង រំខានការរាំដោយដើរកាត់រង្វង់និងចន្លោះអ្នករាំទាំងអស់។

- សូមសួរអ្នកចូលរួមថា តើវាប៉ះពាល់អ្វីទៅដល់អ្នកដទៃដែលកំពុងរាំនោះ។ តើមានរឿងអ្វីកើត ឡើងនៅពេលដែលមានមនុស្សម្នាក់មិនធ្វើតាមបទបញ្ជា?

- សូមសួរអ្នកចូលរួមថា ហេតុអ្វីបទបញ្ជាមានសារៈសំខាន់ចំពោះការរាំ និងចំពោះសង្គមជាទូទៅ? សូមលើកទឹកចិត្តអ្នកចូលរួមពីរ ឬបីនាក់ឲ្យឆ្លើយដើម្បីជាការរំលឹកចំណុចគោលនៃលំហាត់។

- សូមពន្យល់ថា ទោះបីជាគ្រប់ៗគ្នាមានរបៀបក្នុងការរាំខុសៗគ្នាក៏ដោយ ក៏ទាំងអស់គ្នាបានអនុវត្តតាមបទបញ្ជាជាទូទៅនៃការរាំដូចៗគ្នា ដែលធ្វើឲ្យការរាំមានការគោរពគ្នាទៅវិញទៅមក និង មានភាពសប្បាយរីករាយ។ ប៉ុន្តែនៅពេលដែលអ្នកចាប់ផ្តើមរាំ ហើយអ្នកមិនគោរពបទបញ្ជា ឬ ភាពសប្បាយរបស់អ្នកគ្រប់ៗគ្នានៅពេលរាំ នោះការរាំមិនមានដំណើរការល្អទេ។

- សូមរំលឹកអ្នកចូលរួមថា បទបញ្ជានៃការរាំ និងច្បាប់នៅក្នុងសង្គម អាចជួយធ្វើឲ្យមាន សណ្តាប់ធ្នាប់ទៅតាមរបៀបមួយដែលមានភាពត្រឹមត្រូវ និងមានការគោរពចំពោះអ្នកដទៃ។ ប៉ុន្តែ ប្រសិនបើមនុស្សមិនគោរពច្បាប់ទេ នោះអ្វីៗនឹងមិនមានដំណើរការល្អ ជាពិសេស ប្រសិន បើ "អ្នកមិនគោរពបទបញ្ជា" នោះ ជាអ្នកដែលមានសិទ្ធិអំណាច ដូចជាអ្នកសម្របសម្រួលជា ដើម។

## ៣. តើច្បាប់មានមុខងារអ្វី?

ច្បាប់មានមុខងារជាច្រើននៅក្នុងសង្គម។ ឧទាហរណ៍ ច្បាប់ត្រូវបានបង្កើតឡើងដើម្បី :

- រក្សាភាពសុខសាន្ត និងសណ្តាប់ធ្នាប់
- ការពារសិទ្ធិ និងសេរីភាពរបស់ប្រជាពលរដ្ឋ
- ការពារប្រជាជន សង្គម និងបរិស្ថានមិនឲ្យមានគ្រោះថ្នាក់
- ដាក់ទោសចំពោះអ្នកដែលបង្កគ្រោះថ្នាក់ដល់អ្នកដទៃ
- ដោះស្រាយជម្លោះ
- បង្កើតប្រព័ន្ធរដ្ឋាភិបាល
- បង្កើតស្ថាប័ន និងផ្តល់អំណាច និងកាតព្វកិច្ចទៅស្ថាប័នទាំងនោះ។
- ធានាថា គ្មានអ្នកណាម្នាក់ ឬស្ថាប័នណាមួយមានអំណាចច្រើនពេក។

បើប្រៀបធៀបទៅ សារៈសំខាន់នៃគោលបំណង និងវិធីដែលច្បាប់អាចសម្រេចគោលបំណងទាំងនេះ គឺខុសគ្នានៅក្នុងសង្គមទាំងអស់ជុំវិញពិភពលោក ។ ច្បាប់នៅក្នុងសង្គមផ្សេងៗគ្នា បានទទួលឥទ្ធិពលពីប្រវត្តិសាស្ត្រ និងវប្បធម៌ សីលធម៌ និងគុណតម្លៃនៃសង្គមរបស់ពួកគេ ។ ច្បាប់ក៏បានទទួលឥទ្ធិពលពីសេដ្ឋកិច្ចសង្គម និងស្ថានភាពនយោបាយនៅក្នុងសង្គមនោះដែរ ។

| ច្បាប់នៅក្នុងជីវិតប្រចាំថ្ងៃ |
| --- |
| ច្បាប់មានទំនាក់ទំនងជាមួយប្រជាពលរដ្ឋគ្រប់គ្នានៅក្នុងជីវិតរស់នៅប្រចាំថ្ងៃ។ ទោះបីជាប្រជាពលរដ្ឋភាគច្រើនមិនបានគិតពីវាក៏ដោយ ក៏ច្បាប់ត្រូវបានអនុវត្តនៅពេលដែលយើងបើកម៉ូតូ ពេលទិញអីវ៉ាន់នៅផ្សារ ពេលទៅសាលារៀន ឬធ្វើការ និងពេលដែលអ្នករៀបការ។ មានច្បាប់អំពីដីធ្លីដែលអ្នកកំពុងរស់នៅលើ ទូរទស្សន៍ដែលអ្នកមើល និងប្រាក់ដែលក្រុមគ្រួសារអ្នករកបាន។<br><br>គ្រប់គ្នាគួរតែចាប់អារម្មណ៍ចំពោះច្បាប់ ដោយសារវាមានឥទ្ធិពលច្រើនលើការរស់នៅប្រចាំថ្ងៃរបស់ពួកគេ។ ក្នុងនាមជាសមាជិកនៅក្នុងសង្គមម្នាក់ វាមានសារៈសំខាន់ណាស់ដែលអ្នកត្រូវយល់អំពីច្បាប់ និងមានការចូលរួមក្នុងការសម្រេចចិត្តអំពីច្បាប់ ដែលមានឥទ្ធិពលដល់អ្នក និងអ្នកដទៃនៅជុំវិញអ្នក។ |



## ៤. អ្វីទៅជាច្បាប់ល្អ?

ទោះបីជាច្បាប់មានសារៈសំខាន់ក្នុងការរក្សាសណ្ដាប់ធ្នាប់នៅក្នុងសង្គម និងបំពេញមុខងារដទៃទៀត ដូចបានរៀបរាប់នៅក្នុងផ្នែកមុនក៏ដោយ ក៏មិនមែនគ្រប់ច្បាប់ទាំងអស់នៅក្នុងសង្គមសុទ្ធតែល្អទេ។ គេអាចបង្កើតច្បាប់ ឬប្រើក្នុងគោលបំណងអាក្រក់ក៏មានដែរ ដូចជា ការដកយកសិទ្ធិ និងសេរីភាពរបស់ប្រជាពលរដ្ឋ ការរើសអើងចំពោះប្រជាពលរដ្ឋ ឬក្រុមមនុស្ស ឬផ្ដល់ឲ្យមនុស្សម្នាក់ ឬក្រុមមនុស្សណាមួយនូវអំណាចច្រើនលើសលប់ ឬអំណាចក្នុងការគ្រប់គ្រងសង្គមទាំងមូល។

ច្បាប់គួរតែមានគោលបំណងក្នុងការបង្កើតសង្គមដែលប្រសើរមួយ។ ច្បាប់ល្អឆ្លុះបញ្ចាំងអំពីសីលធម៌ និងតម្លៃនៃសង្គមណាមួយ និងការពារសិទ្ធិ និងសេរីភាពរបស់ប្រជាជន។ ច្បាប់ល្អគឺអនុវត្តស្មើភាពគ្នា និងលើកតម្កើងយុត្តិធម៌។ ច្បាប់ល្អគឺជួយសង្គមឲ្យដំណើរការមានប្រសិទ្ធភាព និង**សមធម៌** ដើម្បីឲ្យគ្រប់ៗគ្នាទទួលបាននូវតម្រូវការមូលដ្ឋាន ហើយពួកគេមានឱកាសក្នុងការពង្រឹងជីវិតរបស់ពួកគេឲ្យប្រសើរឡើង។



*សញ្ញាជញ្ជីងជាទូទៅមានទំនាក់ទំនងជាមួយច្បាប់។ ជញ្ជីងនៅទីនេះស្មើ មានន័យថាវាតំណាងឲ្យភាពស្មើគ្នា និងភាពយុត្តិធម៌*

| ធាតុ៧យ៉ាងនៃច្បាប់ដែលល្អ |
|---|
| ទោះបីជាច្បាប់មានគោលបំណងសម្រាប់បង្កើតសង្គមមួយដែលប្រសើរក៏ដោយ ក៏ច្បាប់ល្អត្រូវមានធាតុជាក់លាក់មួយចំនួនដែលស្មើភាព និងមានដំណើរការល្អត្រឹមត្រូវ។<br><br>ច្បាប់ល្អគឺជាច្បាប់ដែល៖<br><br>១. ច្បាស់លាស់ និងអាចគោរពតាមបាន<br><br>២. មានហេតុផល និងមានន័យអាចយល់បាន<br><br>៣. សាធារណៈអាចយល់និងប្រើប្រាស់បាន |

៤. ត្រូវបានអនុវត្តដោយស្មើភាពគ្នាចំពោះមនុស្សទាំងអស់ រួមទាំងអ្នកដែលធ្វើច្បាប់នោះផង។

៥. អាចប្រតិបត្តិបាន ដូច្នេះវានឹងមានផលវិបាកចំពោះអ្នកដែលមិនគោរព។

៦. អនុវត្តចំពោះសកម្មភាពនៅពេលបច្ចុប្បន្ន និងអនាគត ហើយមិនមែនចំពោះអតីតកាលទេ។

៧. គ្មានទំនាស់នឹងច្បាប់ដទៃទៀត និងវប្បធម៌នៃសង្គម។

វិធីនៅក្នុងការតាក់តែងច្បាប់ក៏មានសារៈសំខាន់ដែរ។ ដោយសារតែច្បាប់មានឥទ្ធិពលលើជីវិតប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ នោះប្រជាពលរដ្ឋជាច្រើនគួរបានចូលរួមក្នុងការសម្រេចចិត្តថា តើគួរមានមាត្រាអ្វីខ្លះនៅក្នុងច្បាប់នោះ។ ប្រជាពលរដ្ឋគួរតែអាចចូលរួមក្នុងដំណើរការនៃការតាក់តែងច្បាប់ ដើម្បីឲ្យអ្នកតាក់តែងច្បាប់បានពិចារណាអំពីទស្សនៈ និងគំនិតរបស់ពួកគាត់។ ម្យ៉ាងទៀត គេគួរតែអាចកែប្រែច្បាប់ដែលលែងសមស្រប លែងស្មើភាព ឬលែងឆ្លុះបញ្ចាំងសីលធម៌ និងគុណតម្លៃរបស់សង្គម។



**អ្វីទៅជារដ្ឋធម្មនុញ្ញ?**

រដ្ឋធម្មនុញ្ញគឺជាច្បាប់កំពូលរបស់ប្រទេស ដែលមានចែង អំពីអំណាច និងមុខងាររបស់រដ្ឋាភិបាល។ រដ្ឋធម្មនុញ្ញនេះក៏មានចែងឲ្យគោរព និងការពារសិទ្ធនិងសេរីភាពរបស់ប្រជាពលរដ្ឋដែរ។ ច្បាប់ដទៃទៀតទាំងអស់ត្រូវតែស្របតាមរដ្ឋធម្មនុញ្ញ ហើយប្រសិនបើច្បាប់នោះផ្ទុយពីរដ្ឋធម្មនុញ្ញ ច្បាប់នោះមិនមានសុពលភាពទេ។ រដ្ឋធម្មនុញ្ញមានការលំបាកក្នុងការផ្លាស់ប្តូរជាងច្បាប់ធម្មតា ហើយមានផ្នែកខ្លះមានសារៈសំខាន់ខ្លាំងណាស់ ដែលមិនអាចប្តូរបាន។

# មេរៀនទី ២៖ អ្វីទៅជាច្បាប់ល្អ?

គោលបំណង ៖ អ្នកចូលរួមនឹងយល់ពីមុខងារនៃច្បាប់ ហើយនិងដឹងថា អ្វីដែលធ្វើឲ្យច្បាប់ល្អ ស្មើភាព និងប្រតិបត្តិបាននៅក្នុងសង្គម។



**សម្ភារៈ** ៖ ក្រដាសផ្ទាំងធំ ឬក្តារខៀន ហ្វឺត ប៊ិច បទបញ្ញាផ្ទៃក្នុងនៃវគ្គបណ្តុះបណ្តាលពីលំហាត់ទី១

**វិធីសាស្ត្រ** ៖ ការបំផុសគំនិត ល្បែង ការពិភាក្សាជាក្រុម ការវិភាគ

| ដំណើរការ | រយៈពេល (គិតជានាទី) |
|---|---|
| ១. បំផុសគំនិតអំពីមុខងារនៃច្បាប់ | ១៥ |
| ២. ណែនាំព័ត៌មាននៅក្នុងផ្នែកទី ៣ | ១០ |
| ៣. ល្បែងប៊ិច | ៥ |
| ៤. ការពិភាក្សាអំពីល្បែងប៊ិច | ១៥ |
| ៥. ណែនាំព័ត៌មាននៅក្នុងផ្នែកទី ៤ | ២០ |
| ៦. សង្ខេបអំពីបទបញ្ញាផ្ទៃក្នុងនៃវគ្គបណ្តុះបណ្តាល | ១៥ |
| សរុប ៖ | ៨០ |

# ការណែនាំសម្រាប់អ្នកសម្របសម្រួល

១. បំផុសគំនិតអំពីមុខងារនៃច្បាប់ :

- សូមឲ្យអ្នកចូលរួមចំណាយពេល៥នាទីដើម្បីគិតអំពី ហេតុអ្វីមានច្បាប់ និងតើច្បាប់មានមុខងារខុសគ្នាអ្វីខ្លះនៅក្នុងសង្គម។ អ្នកចូលរួមម្នាក់ៗគួរសរសេរ៣ចំណុចអំពី តើច្បាប់មានមុខងារអ្វីនៅក្នុងសង្គម។
- ៥នាទីក្រោយមក សូមឲ្យអ្នកចូលរួមខ្លះចែករំលែកចម្លើយរបស់ពួកគាត់។ សូមសួរទៅអ្នកចូលរួមដទៃទៀតថា តើពួកគេយល់ស្របដែរឬទេ ហើយប្រសិនបើពួកគេយល់ស្រប សូមសរសេរចម្លើយទាំងនោះទៅលើក្រដាសផ្ទាំងធំ។
- បន្ទាប់ពីអ្នកចូលរួមមួយចំនួនបានឆ្លើយហើយ សូមបូកបន្ថែមនូវមុខងារច្បាប់ដទៃទៀតដែលមានរាយនៅក្នុងផ្នែកទី ៣។
- សូមជ្រើសរើសមុខងារខ្លះពីមុខងារទាំងនេះ រួចសួរអ្នកចូលរួមថា តើពួកគាត់អាចនឹកឃើញឧទាហរណ៍ខ្លះនៃច្បាប់ដែលបំពេញមុខងារនោះដែរឬទេ។

<u>ចម្លើយអាចទទួលយកបាន</u> :

- សូមលើកទឹកចិត្តអ្នកចូលរួមឲ្យខំរកឧទាហរណ៍ទាំងនោះ ប៉ុន្តែប្រសិនបើពួកគាត់មិនអាចគិតឃើញទេ អ្នកសម្របសម្រួលអាចផ្តល់ឧទាហរណ៍ដូចខាងក្រោម (មិនចាំបាច់ប្រើទាំងអស់ទេ គ្រាន់តែរើសយកបី ឬបួនប៉ុណ្ណោះ)។

| **ច្បាប់ដែលត្រូវបានបង្កើតឡើងដើម្បី :** | **ឧទាហរណ៍** |
|---|---|
| រក្សាសន្តិភាព និងសណ្តាប់ធ្នាប់ | ច្បាប់ចរាចរណ៍ ច្បាប់ព្រហ្មទណ្ឌ |
| ការពារសិទ្ធិ និងសេរីភាពរបស់ប្រជាពលរដ្ឋ | ច្បាប់ប្រឆាំងការរើសអើង ច្បាប់ការងារ |
| ការពារប្រជាពលរដ្ឋ សង្គម និងបរិស្ថានមិនឲ្យមានគ្រោះថ្នាក់ | ច្បាប់ប្រឆាំងនឹងការធ្វើឲ្យខូចបរិស្ថាន ឬការកាប់ព្រៃឈើ ច្បាប់ចរាចរណ៍ |
| ដាក់ពិន័យចំពោះអ្នកដែលបង្កគ្រោះថ្នាក់ដល់អ្នកដទៃ | ច្បាប់ព្រហ្មទណ្ឌ (ដូចជា ច្បាប់និយាយអំពីការលួច ឃាតកម្ម។ល។) |
| ដោះស្រាយជម្លោះ | ច្បាប់កិច្ចសន្យា ច្បាប់ភូមិបាល (ដីធ្លី) ច្បាប់អាជ្ញាកណ្តាល |
| បង្កើតប្រព័ន្ធរដ្ឋាភិបាល | រដ្ឋធម្មនុញ្ញ |

| | |
|---|---|
| បង្កើតស្ថាប័ន និងផ្តល់សិទ្ធិអំណាច និង កាតព្វកិច្ចទៅស្ថាប័នទាំងនោះ | រដ្ឋធម្មនុញ្ញ ច្បាប់ពន្ធដារ (ផ្តល់អំណាចដល់រដ្ឋបាលពន្ធដារ) ច្បាប់ភូមិបាល (ផ្តល់អំណាចដល់ក្រសួងរៀបចំដែនដី) |
| ធ្វើឲ្យប្រាកដថា គ្មានអ្នកណាម្នាក់ ឬស្ថាប័នណាមួយមានអំណាចច្រើនលើសលប់ | រដ្ឋធម្មនុញ្ញ ច្បាប់ការពារសេរីភាពរបស់ប្រជាពលរដ្ឋ |

## ២. ណែនាំព័ត៌មាននៅក្នុងផ្នែកទី៣ : (សូមមើលទំព័រ ១១ ដល់ទី១២)

**ផ្នែកទី៣** : វាមានសារៈសំខាន់ណាស់ដែលអ្នកចូលរួមយល់ថា :

- មុខងារនៃច្បាប់ (មិនចាំបាច់និយាយឡើងវិញទេ ប៉ុន្តែត្រូវឲ្យប្រាកដថា អ្នកចូលរួមអាចមើលឃើញមុខងារទាំងនោះ)។
- ច្បាប់នៅក្នុងសង្គមផ្សេងៗគ្នាទទួលឥទ្ធិពលពីប្រវត្តិសាស្ត្រ និងវប្បធម៌ សីលធម៌ និងគុណតម្លៃ ព្រមទាំងទទួលឥទ្ធិពលពីសេដ្ឋកិច្ច សង្គម និងស្ថានភាពនយោបាយដែរ។
- ច្បាប់មានទំនាក់ទំនងជាមួយអ្នកគ្រប់ៗគ្នានៅក្នុងជីវិតប្រចាំថ្ងៃរបស់ពួកគេ។

## ៣. ល្បែងប៊ិច :

- សូមឲ្យអ្នកចូលរួមឈរជារង្វង់។
- សូមប្រាប់ អ្នកចូលរួមថា ពួកគាត់នឹងលេងល្បែងប៊ិច។ សូមឲ្យប៊ិច ឬហ្វឺតមួយទៅអ្នកចូលរួមម្នាក់ ហើយឲ្យគាត់ចាប់ផ្តើមលេង (មិនត្រូវប្រាប់គាត់ពីបទបញ្ជានៃល្បែងនោះទេ)។ ពួកគាត់នឹងច្របូកច្របល់ ដោយសារតែពួកគាត់មិនបានដឹងពីបទបញ្ជានៃល្បែងនោះ ប៉ុន្តែសូមប្រាប់ពួកគាត់ម្តងទៀតឲ្យចាប់ផ្តើមលេងឡើងវិញ។
- ប៉ុន្មានពីរ-បីវិនាទីក្រោយមក យកប៊ិច ឬហ្វឺតនោះវិញ ហើយពន្យល់អំពីល្បែងនោះ។ សូមប្រាប់អ្នកចូលរួមថា ពួកគាត់គួរតែហុចប៊ិច ឬហ្វឺតនោះទៅឲ្យអ្នកចូលរួមនៅក្បែរគាត់នៅក្នុងរង្វង់។
- ឲ្យអ្នកចូលរួមហុចប៊ិច ឬហ្វឺតពីរ-បីវិនាទី បន្ទាប់មកបញ្ឈប់ពួកគាត់។ សូមប្រាប់អ្នកចូលរួមពីរនាក់ដែលហុចប៊ិច ឬហ្វឺតនោះចុងក្រោយគេថា ពួកគាត់បានធ្វើខុសបទបញ្ជា នោះពួកគាត់ត្រូវបានដកសិទ្ធិលែងឲ្យចូលរួមលេង។ សូមប្រាប់ពួកគាត់ថា ពួកគាត់បានហុចប៊ិច ឬហ្វឺតនោះដោយប្រើដៃខុស

- សូមប្រាប់ឲ្យអ្នកចូលរួមបន្តការលេងតទៅទៀត។ បន្ទាប់ពី ពីរ-បីវិនាទីក្រោយមក សូមបង្កើតច្បាប់ផ្សេងទៀត ហើយប្រាប់ទៅកាន់អ្នកចូលរួមថា ពួកគាត់មិនបានលេងល្បែងប៊ិចនោះត្រឹមត្រូវទេ។ ឧទាហរណ៍ ប្រាប់ពួកគាត់ថា ពួកគាត់គួរតែហុចប៊ិច ឬហ្វឹតនោះទៅតាមទិសបញ្ច្រាសវិញ។

- នៅពេលដែលល្បែងនោះបន្ត សូមព្យាយាមធ្វើឲ្យអ្នកចូលរួមច្របូកច្របល់ ដោយបង្កើតច្បាប់ដែលទំនាស់នឹងច្បាប់មុន។ ឧទាហរណ៍ អ្នកសម្របសម្រួលអាចប្រាប់ទៅអ្នកចូលរួមថា ពួកគាត់គួរតែលោតនៅរាល់ពេលដែលហុចប៊ិច ឬហ្វឹត ហើយពីរ-បីវិនាទីក្រោយមក សូមប្រាប់ពួកគាត់ឲ្យបង្វិលខ្លួនមួយជុំរាល់ពេលដែលពួកគាត់ហុចប៊ិច ឬហ្វឹតនោះទៅកាន់អ្នកដទៃ។

- សូមចាប់ផ្តើមដកសិទ្ធិអ្នកចូលរួមមិនឲ្យលេងដោយគ្មានមូលហេតុ ប៉ុន្តែត្រូវនិយាយថា ពួកគាត់ហុចប៊ិច ឬហ្វឹតនោះយឺតពេក។ នៅពេលដែលអ្នកចូលរួមត្រូវបានដកសិទ្ធិចេញ ពួកគាត់ត្រូវឈប់លេង ហើយត្រូវចេញពីរង្វង់នោះ។

- សូមចាប់ផ្តើមដកសិទ្ធិអ្នកចូលរួមលេងដោយមូលហេតុផ្សេងៗ ឧទាហរណ៍ ពួកគេពាក់អាវខៀវ។ បន្ទាប់មកដកសិទ្ធិអ្នកចូលរួមដែលជាបុរសទាំងអស់។

- ៥នាទីក្រោយមក អ្នកសម្របសម្រួលគួរចូលរួមលេងល្បែងនោះ។ មិនត្រូវពន្យល់ពីមូលហេតុអ្វីឡើយ គឺគ្រាន់តែចូលទៅក្នុងរង្វង់នោះ។

- សូមបញ្ឈប់ល្បែងនោះដោយមិនប្រាប់មុន ហើយប្រកាសថា អ្នកជាអ្នកឈ្នះ។

## ៤. ការពិភាក្សាអំពីល្បែងប៊ិច :

- នៅក្នុងការពិភាក្សាជាក្រុម បន្ទាប់ពីលេងល្បែងហើយ សូមសួរទៅកាន់អ្នកចូលរួមថា:
  - តើល្បែងដែលបានលេងនោះល្អដែរឬទេ ? តើពួកគាត់បានសប្បាយដែរឬទេ ?
  - តើមានបញ្ហាអ្វីជាមួយល្បែង និងបទបញ្ញារបស់ល្បែងនោះ ?

ចម្លើយដែលអាចទទួលយកបាន :

- អ្នកចូលរួមត្រូវបានសុំឲ្យបញ្ចេញយោបល់ ដូច្នេះវាគ្មានចម្លើយណាដែលខុស ឬត្រូវទេ។ ប៉ុន្តែនេះគឺជាឧទាហរណ៍នៃបញ្ហាដែលមាននៅក្នុងល្បែងនោះ។ សូមព្យាយាមលើកទឹកចិត្តអ្នកចូលរួមឲ្យបញ្ចេញយោបល់ និងពិភាក្សាអំពីបញ្ហាទាំងនេះដោយសួរសំណួរខាងក្រោមនេះ :
    - ល្បែងនោះមិនច្បាស់៖ វាមានការច្រឡូកច្រឡំ និងពិបាកយល់។
    - អ្នកចូលរួមមិនបានដឹងពីបទបញ្ញាមុនពេលដែលពួកគាត់ចាប់ផ្តើមលេង៖ អ្នកចូលរួមមិនបានដឹងពីរបៀបលេង ឬរបៀបដែលត្រូវឈ្នះ។ ល្បែងមួយមិនអាចដំណើរការបានល្អទេ ប្រសិនបើអ្នកចូលរួមមិនបានដឹងពីបទបញ្ញាល្បែងនោះ។
    - បទបញ្ញាខ្លះត្រូវបានអនុវត្តទៅលើសកម្មភាពកន្លងទៅ៖ ច្បាប់ថ្មីបានដកសិទ្ធិអ្នកចូលរួមចំពោះអំពើ ដែលពួកគាត់បានធ្វើ មុនពេលដែលមានច្បាប់ថ្មី។
    - បទបញ្ញាមិនសមហេតុផល៖ មានបទបញ្ញាខ្លះមិនសមហេតុផល ហើយអ្នកដទៃមានការលំបាក ឬមិនអាចអនុវត្តតាមបាន។
    - ច្បាប់ទាំងនោះមានទំនាស់គ្នាទៅវិញទៅមក៖ វាមិនអាចទៅរួចក្នុងការអនុវត្តច្បាប់ខ្លះ នៅពេលតែមួយ។
    - ល្បែងនោះមិនមានភាពយុត្តិធម៌៖ អ្នកសម្របសម្រួលរើសអើងចំពោះអ្នកចូលរួមខ្លះ។ ឧទាហរណ៍ អ្នកសម្របសម្រួលបានដកសិទ្ធិអ្នកលេងដោយគ្មានមូលហេតុត្រឹមត្រូវ ហើយបន្ទាប់មកដកសិទ្ធិបុរសទាំងអស់។
    - អ្នកសម្របសម្រួលមានអំណាចខ្លាំងលើសលប់៖ អ្នកសម្របសម្រួលជាអ្នកបង្កើតបទបញ្ញាទាំងនោះ ហើយគាត់ក៏ប្តូរបទបញ្ញាទាំងនោះនៅពេលដែលគាត់ចង់។ គាត់ក៏បានប្រើសិទ្ធិរបស់គាត់ដើម្បីប្រកាសថា គាត់ជាអ្នកឈ្នះដោយគ្មានមូលហេតុត្រឹមត្រូវ។
    - បទបញ្ញាមិនត្រូវបានព្រមព្រៀងជាមុន៖ អ្នកចូលរួមមិនបានចូលរួមបង្កើតបទបញ្ញាទាំងនោះ ហើយត្រូវតែធ្វើទៅតាមអ្វីដែលអ្នកសម្របសម្រួលនិយាយ ទោះបីជា នៅពេលដែលបទបញ្ញាទាំងនោះមិនសមហេតុផលក៏ដោយ។

៥.	ណែនាំព័ត៌មាននៅក្នុងផ្នែកទី៤ : (សូមមើលទំព័រទី១៣ ដល់ទី១៥)

**ផ្នែកទី៤** : វាមានសារៈសំខាន់ណាស់ដែលអ្នកចូលរួមយល់ថា:

- មិនមែនច្បាប់ទាំងអស់សុទ្ធតែល្អនោះទេ ហើយច្បាប់ខ្លះត្រូវបានបង្កើតឡើង និងប្រើសម្រាប់គោលបំណងមិនល្អ។
- ច្បាប់ល្អមានគោលបំណងក្នុងការបង្កើតសង្គមដែលប្រសើរមួយដោយឆ្លុះបញ្ចាំងអំពី សីលធម៌ មានភាពស្មើភាពគ្នា និងជួយសង្គមដើម្បីឲ្យដំណើរការមានប្រសិទ្ធភាព និងសមធម៌។
- ជាតុទាំង៧នៃច្បាប់ល្អ។ (អ្នកសម្របសម្រួលអាចប្រើឧទាហរណ៍ក្នុងល្បែងប៊ិចដើម្បីជំនួយក្នុងការពន្យល់។)
- ប្រជាពលរដ្ឋគួរតែអាចចូលរួមក្នុងដំណើរការនៃការតាក់តែងច្បាប់។
- ការកែច្បាប់គួរតែអាចធ្វើទៅបាន។

៦. សង្ខេបអំពីបទបញ្ជានៃវគ្គបណ្តុះបណ្តាល :

- ត្រូវប្រាកដថា អ្នកចូលរួមអាចមើលឃើញបញ្ជីនៃជាតុទាំង៧ នៃច្បាប់ល្អ និងបទបញ្ជាផ្ទៃក្នុងនៃវគ្គបណ្តុះបណ្តាល។ (ត្រូវប្រាកដថាអ្នកសម្របសម្រួលបានបន្ថែមបទបញ្ជានៃវគ្គបណ្តុបណ្តាលចំនួន២ទៀតដែលមិនសមហេតុផល និងមិនត្រឹមត្រូវ ប៉ុន្តែត្រូវគ្រប់ឲ្យជិត)
- សូមឲ្យអ្នកចូលរួមពិនិត្យមើលបទបញ្ជាផ្ទៃក្នុងនៃវគ្គបណ្តុះបណ្តាល ដែលពួកគេបានសម្រេចចិត្ត។
  - តើបទបញ្ជាទាំងនេះល្អដែរឬទេ បើយោងទៅតាមជាតុទាំង៧ នោះ?
  - តើវាត្រឹមត្រូវដែរឬទេ និងតើវាជួយឲ្យវគ្គបណ្តុះបណ្តាលនេះដំណើរការមានប្រសិទ្ធភាពដែរឬទេ?
- សូមឲ្យអ្នកចូលរួមជ្រើសរើសយកបទបញ្ជាផ្ទៃក្នុងនៃវគ្គបណ្តុះបណ្តាលមួយ ហើយពន្យល់ថាហេតុអ្វីបានជាវាជាបទបញ្ជាមួយដែលល្អ ឬមិនល្អ។ សូមសុំឲ្យអ្នកចូលរួមផ្សេងទៀតធ្វើដូចគ្នាទៅលើបទបញ្ជាផ្សេងទៀត។
- សូមសួរថា តើមានបទបញ្ជាណាមួយ ដែលមិនមែនជាបទបញ្ជាល្អដែរឬទេ។
- សូមសួរអ្នកចូលរួមថា តើឥឡូវនេះពួកគាត់មានចង់ផ្លាស់ប្តូរបទបញ្ជានៃវគ្គបណ្តុះបណ្តាលទេក្រោយពីពួកគាត់បានពិភាក្សាគ្នាអំពីអ្វីដែលធ្វើឲ្យច្បាប់មួយល្អរួច។

- បន្ទាប់មក បង្ហាញអ្នកចូលរួមនូវបទបញ្ញាដែលអ្នក បានបន្ថែម។ សូមសួរអ្នកចូលរួមថា តើពួកគាត់គិតយ៉ាងណាចំពោះបទបញ្ញាទាំងនេះ។ ក្នុងចំណោមធាតុទាំង៧ នៃច្បាប់ល្អ តើធាតុមួយណាដែលបទបញ្ញាទាំងនេះមិនមាន?

- នៅចុងបញ្ចប់នៃការពិភាក្សា សូមគូសចោលនូវបទបទបញ្ញាផ្ទៃក្នុងនៃវគ្គបណ្តុះបណ្តាលចុងក្រោយ២ដែលអ្នកបានបន្ថែម។ ប្រសិនបើអ្នកចូលរួមមិនទាន់បានលើកឡើងអំពីចំណុចទាំងនោះទេ អ្នកអាចបន្ថែមថា បទបញ្ញាទាំងនេះមិនល្អដោយសារអ្នក មិនបានយកគំនិតអ្នកចូលរួមអំពីបទបញ្ញាទាំងនេះ។ ប៉ុន្តែអ្នកសម្របសម្រួលបែរជាប្រើសិទ្ធិក្នុងការធ្វើបទបញ្ញាដែលមិនមានភាពត្រឹមត្រូវនិងសមហេតុផល ហើយដែលមិនបានគោរពសិទ្ធិអ្នកដទៃ។

- សូមឲ្យអ្នកចូលរួមបន្តការគិតអំពីអ្វីដែលពួកគាត់បានរៀន នៅក្រោយពេលដែលពួកគាត់ចេញពីវគ្គបណ្តុះបណ្តាលនៅថ្ងៃនេះ។ សូមលើកទឹកចិត្តពួកគាត់ឲ្យគិតអំពីបទបញ្ញា និងច្បាប់ដែលប៉ះពាល់ដល់ជីវិតប្រចាំថ្ងៃរបស់ពួកគាត់ និងច្បាប់ដែលត្រូវបានពិភាក្សានៅក្នុងព័ត៌មានប្រចាំថ្ងៃ។ សូមឲ្យពួកគាត់គិតឡើងវិញថា តើច្បាប់ទាំងអស់នេះល្អ ឬមិនល្អ។

# សេចក្តីផ្តើមនៃសិទ្ធិមនុស្ស

**លទ្ធផលទទួលបាន៖**

ក្រោយពីបញ្ចប់ជំពូកនេះ អ្នកចូលរួមនឹងអាចៈ

១. យល់ដឹងថា តើសិទ្ធិមនុស្សមានអ្វីខ្លះ ?

២. យល់ដឹងថា មនុស្សគ្រប់រូបសុទ្ធតែមានសិទ្ធិរៀងៗខ្លួន

៣. ដឹងថា អ្វីជាសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងតើមានសិទ្ធិអ្វីខ្លះនៅក្នុងសេចក្តីប្រកាសនោះ

៤. យល់ដឹងថា ហេតុអ្វីបានជាពួកគាត់ត្រូវដឹងអំពីសារៈសំខាន់នៃសិទ្ធិរបស់ពួកគាត់

៥. យល់ដឹងថា សិទ្ធិមនុស្សទាំងអស់សុទ្ធតែមានទំនាក់ទំនងគ្នា ព្រមទាំងយល់ដឹងថា ត្រូវគោរពសិទ្ធិមនុស្សទាំងអស់នោះ

៦. យល់ដឹងថា រដ្ឋាភិបាលត្រូវមានកាតព្វកិច្ចត្រូវគោរព និងការពារសិទ្ធិរបស់ប្រជាពលរដ្ឋ

៧. ដឹងថា សិទ្ធិមនុស្ស និងតួនាទីរបស់រដ្ឋាភិបាល ត្រូវបានទទួលស្គាល់ដោយច្បាប់អន្តរជាតិ និង ច្បាប់នៃព្រះរាជាណាចក្រកម្ពុជា

## ១. តើសិទ្ធិមនុស្សជាអ្វី ?

សិទ្ធិមនុស្ស ធ្វើឱ្យប្រជាពលរដ្ឋរស់នៅដោយសប្បាយរីករាយ សុខភាពល្អ និងរស់នៅដោយមានសេរីភាព។ នៅក្នុងជីវភាពប្រចាំថ្ងៃ យើងមានសេចក្តីត្រូវការជាមូលដ្ឋានដូចជា មានម្ហូបអាហារគ្រប់គ្រាន់សម្រាប់បរិភោគ មានទឹកស្អាតសម្រាប់ផឹក និងមានមណ្ឌលសុខភាពសម្រាប់ព្យាបាលនៅពេលមានជំងឺ។ យើងក៏ចាំបាច់ត្រូវតែមានសេរីភាពជាមូលដ្ឋានខ្លះទៀត ដូចជា សេរីភាពក្នុងការបញ្ចេញមតិ និងការគោរពប្រតិបត្តិសាសនារបស់យើង។ ការទទួលបានតម្រូវការ និងសិទ្ធិសេរីភាពទាំងនេះគឺជាសិទ្ធិជាមូលដ្ឋានរបស់មនុស្ស។

*មនុស្សគ្រប់រូប នៅគ្រប់ទីកន្លែងមានសិទ្ធិទាំងនេះ* មិនថាជាបុរស ឬស្ត្រី ក្មេង ឬចាស់, មាន ឬក្រ, កើតនៅទីកន្លែងណា និងមានជំនឿសាសនាអ្វីនោះទេ។ គ្មាននរណាម្នាក់អាចដកហូតសិទ្ធិទាំងនេះពីយើងបានឡើយ ហើយសិទ្ធិទាំងនេះត្រូវបានគោរពគ្រប់ពេលទាំងអស់។




*មនុស្សម្នាក់ៗមានសិទ្ធិរបស់ខ្លួន មិនថា ស្រី ឬប្រុស ចាស់ ឬក្មេង អ្នកមាន ឬអ្នកក្រឡើយ។*

## ២. តើសិទ្ធិមនុស្សកើតមកពីណា ?

សិទ្ធិមនុស្សកើតចេញមកពីការឱ្យគុណតម្លៃរួមនៃវប្បធម៌ និងសហគមន៍នៅជុំវិញពិភពលោក។ គុណតម្លៃទាំងនេះមានការអភិវឌ្ឍន៍ទៅតាមសង្គម និងប្រទេសផ្សេងៗគ្នា ព្រោះមនុស្សភាគច្រើននៅជុំវិញពិភពលោកជឿថា គេត្រូវតែប្រព្រឹត្តចំពោះពួកគាត់ និងមនុស្សដែលនៅជុំវិញខ្លួនរបស់គាត់ដោយគោរព។

ជាអកុសល តាមប្រវត្តិសាស្ត្រ មនុស្សធ្លាប់បានឆ្លងកាត់បទពិសោធន៍ និងបានឃើញការរងគ្រោះយ៉ាងអាក្រក់ និងឈឺចាប់បំផុត ដែលច្រើនតែកើតឡើងដោយសារការប្រព្រឹត្តមិនល្អរបស់រដ្ឋាភិបាល កងទ័ព និងអ្នកដទៃទៀត។ មនុស្សជាច្រើនធ្លាប់រស់នៅឆ្លងកាត់សង្គ្រាម និងអំពើហិង្សា ក្រោមការគាបសង្កត់របស់រដ្ឋាភិបាលយ៉ាងឃោរឃៅ ឬមានអាហារមិនគ្រប់គ្រាន់ និងគ្មានថ្នាំព្យាបាលនៅពេលមានជំងឺ។

ឧទាហរណ៍ ប្រជាជនកម្ពុជាដែលធ្លាប់រស់នៅក្នុងសម័យកម្ពុជាប្រជាធិតេយ្យ (ខ្មែរក្រហម) ចន្លោះឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩ មានបទពិសោធន៍ធ្លាប់ឆ្លងកាត់របបឃោរឃៅបំផុតនៅសតវត្សរ៍ចុងក្រោយនេះ។ នៅក្នុងរបបប៉ុល ពត មានប្រជាពលរដ្ឋជាង ១,៥ លាននាក់ ត្រូវបានស្លាប់ដោយសារការធ្វើទារុណកម្ម ការកាប់ សម្លាប់ បង្អត់អាហារ និងធ្វើការហួសកម្លាំង រហូតដល់ស្លាប់ ។

ព្រឹត្តិការណ៍ និងបទពិសោធន៍ទាំងនេះបានធ្វើឱ្យមនុស្សកាន់តែជឿថា ចាំបាច់ត្រូវតែបង្កើតគោលការណ៍ឡើងដើម្បីបង្ការកុំឱ្យមានការប្រព្រឹត្តរំលោភសិទ្ធិទាំងនេះបន្តកើតមានចំពោះមនុស្សជាតិ។



## ៣. សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស

អង្គការសហប្រជាតិ គឺជាអង្គការអន្តរជាតិដែលបង្កើតឡើងដោយប្រទេសជាច្រើននៅលើពិភពលោក។ ការបង្កើតឡើងបែបនេះគឺ មានគោលបំណងធ្វើឱ្យមានសន្តិភាពលើពិភពលោក ដោយបង្ការកុំឱ្យមានជម្លោះ ការផ្សព្វផ្សាយអំពីសិទ្ធិមនុស្ស និងជួយដល់ការអភិវឌ្ឍសេដ្ឋកិច្ច។

នៅឆ្នាំ១៩៤៨ មានតំណាងពីបណ្តាប្រទេសជាច្រើនបានមកជួបជុំគ្នា នៅឯអង្គការសហប្រជាជាតិ ដើម្បីពិភាក្សាអំពីសិទ្ធិមនុស្ស។ នៅក្នុងកិច្ចប្រជុំយ៉ាងសំខាន់នេះ តំណាងរដ្ឋាភិបាលដែលមានវត្តមានបានធ្វើសេចក្តីថ្លែងការណ៍ទៅប្រជាពលរដ្ឋរបស់ខ្លួន រដ្ឋាភិបាលនិងរដ្ឋាភិបាល និងទៅពិភពលោកទាំងមូលថា រដ្ឋាភិបាលរបស់ខ្លួននឹងគោរពសិទ្ធិមនុស្ស។ សេចក្តីថ្លែងការណ៍នេះហៅថា សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស។ នៅក្នុងសេចក្តីថ្លែងការណ៍នេះ មានចែងអំពីសិទ្ធិជាមូលដ្ឋានរបស់មនុស្សគ្រប់រូប។

សិទ្ធិទាំងនោះរួមមានៈ

*សិទ្ធិរស់រានមានជីវិត*[១]



[១] សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស មាត្រា៣

## *សិទ្ធិគ្មានការការរើសអើង*[២]



## *សិទ្ធិទទួលបានការថែទាំសុខភាព*[៣]




[២] សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស មាត្រា២និងមាត្រា៧

[៣] សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស មាត្រា២៥

### *សិទ្ធិរួចផុតពីទាសភាព*[៨]



### *សិទ្ធិទទួលបានការអប់រំ*[៩]




[៨] សេចក្តីប្រកាជាសកលស្តីពីសិទ្ធិមនុស្ស មាត្រា៤

[៩] សេចក្តីប្រកាសជាសកលស្តីពិសិទ្ធិមនុស្ស មាត្រា២៦

*សិទ្ធិរួចផុតពីការឃុំខ្លួនដោយអយុត្តិធម៌*[៦]



*សិទ្ធិរួចផុតពីការធ្វើទារុណកម្ម*[៧]



---

[៦] សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស មាត្រា៩

[៧] សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស មាត្រា៥

## សិទ្ធិមានលំនៅដ្ឋានសមរម្យ[៨]



## សិទ្ធិក្នុងការបញ្ចេញមតិដោយសេរី[៩]



---

[៨] សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស មាត្រា២៥

[៩] សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស មាត្រា១៩

## *សិទ្ធិក្នុងការធ្វើបាតុកម្ម*[១០]



## *សិទ្ធិមានការងារធ្វើ*[១១]



---

[១០] សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស មាត្រា២០

[១១] សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស មាត្រា២៣

## *សិទ្ធិសេរីភាពខាងសាសនា*[១២]



## *សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌*[១៣]



[12] សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស មាត្រា១៨

[13] សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស មាត្រា១០

## *សិទ្ធិចូលរួមក្នុងការបោះឆ្នោត*[១៤]




## *សិទ្ធិមានគ្រួសារ*[១៥]



---

[១៤] សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស មាត្រា២១

[១៥] សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស មាត្រា១៦

## ៤. ហេតុអ្វីចាំបាច់ត្រូវការដឹង និងយល់ពីសិទ្ធិរបស់យើង

ទោះបីជាមនុស្សគ្រប់រូបមានសិទ្ធិរបស់ខ្លួនក៏ដោយ ក៏ជារឿយៗសិទ្ធិទាំងអស់នោះត្រូវបានរំលោភបំពានដោយរដ្ឋាភិបាល និងមនុស្សដទៃទៀត។ នៅពេលយើងមិនដឹងថា យើងមានសិទ្ធិអ្វីខ្លះ ពេលនោះវាងាយស្រួលណាស់សម្រាប់រដ្ឋាភិបាល និងអ្នកផ្សេងក្នុងការរំលោភបំពានលើសិទ្ធិរបស់យើង។ ការយល់ដឹងអំពីសិទ្ធិរបស់អ្នកគឺជាជំហានដំបូងក្នុងការការពារសិទ្ធិរបស់អ្នក។

តាមរយៈប្រវត្តិសាស្ត្រនៅជុំវិញពិភពលោក មនុស្សបានធ្វើការជាមួយគ្នាដើម្បីធានាថា រដ្ឋាភិបាលរក្សាកិច្ចសន្យារបស់ខ្លួនក្នុងការគោរពសិទ្ធិមនុស្ស។ មនុស្សធ្លាប់បានប្រឈមនឹង និងធ្លាប់បានតស៊ូពុះពារដើម្បីការពារសិទ្ធិខ្លួន និងដើម្បីបញ្ចប់អំពើអយុត្តិធម៌។ មនុស្សទូទាំងពិភពលោក បានទទួលផលប្រយោជន៍ពីភាពជោគជ័យ ដែលបានតស៊ូទាមទារដោយអ្នកការពារសិទ្ធិមនុស្សទាំងនោះ។

| មហាត្មៈគន្ធី |
| --- |
| អស់រយៈពេលជាច្រើនទសវត្សមកហើយ រដ្ឋាភិបាលនៃប្រទេសអង់គ្លេសបានដាក់ប្រទេសឥណ្ឌាក្រោមអាណានិគមរបស់ខ្លួន។ នៅកំឡុងពេលនោះ មានការរំលោភបំពានលើសិទ្ធិប្រជាពលរដ្ឋឥណ្ឌាជាច្រើន ដែលមានដូចជា ការសម្លាប់ ការបង្ខំឱ្យធ្វើការងារ និងការកាត់ក្តីដោយអយុត្តិធម៌ និងការដាក់គុកជាដើម។ អស់រយៈពេលជាច្រើនឆ្នាំមក ប្រជាពលរដ្ឋកាន់តែច្រើនឡើងៗបានប្តេជ្ញាចិត្តយ៉ាងខ្លាំងក្លា ដើម្បីបញ្ចប់ការគ្រប់គ្រងបែបអាណានិគមដែលមានការសង្កត់សង្កិនបែបនេះ ហើយទីបញ្ចប់ពួកគេបានទទួលសេរីភាព និងឯករាជ្យ។<br><br>ការតស៊ូដើម្បីទាមទារឯករាជ្យជូនប្រទេសឥណ្ឌា ត្រូវបានដឹកនាំដោយលោក មហាត្មគន្ធី។ គាត់បានរៀបចំ និងដឹកនាំកសិករ និងកម្មករនៅក្នុងចលនាតស៊ូដោយអហិង្សាប្រឆាំងនឹងការគ្រប់គ្រងរបស់ពួកអាណានិគមអង់គ្លេស។ លោក គន្ធី ត្រូវបានអាជ្ញាធរអង់គ្លេសចាប់ដាក់គុកជាច្រើនលើក និងថែមទាំងមានការប៉ុនប៉ងសម្លាប់លោកជាច្រើនដងទៀត។ ប្រជាពលរដ្ឋឥណ្ឌារាប់សែននាក់ត្រូវបានចាប់ខ្លួន ជាការឆ្លើយតបទៅនឹងការធ្វើចលនាទាមទារឯករាជ្យ ដែលគួរឲ្យសោកស្តាយនោះ គឺមនុស្សជាច្រើនត្រូវបានសម្លាប់។<br><br>ទោះបីមានការប្រើហិង្សាពីសំណាក់អាជ្ញាធរអង់គ្លេសក៏ដោយ ក៏ចលនាតស៊ូទាមទារឯករាជ្យនៅតែធ្វើឡើងក្នុងវិធីអហិង្សា ហើយចលនាអហិង្សានេះក៏បាននាំឯករាជ្យឱ្យប្រទេសឥណ្ឌានៅឆ្នាំ១៩៤៧។ តាំងពីនោះមក លោក គន្ធី ក៏បានជំរុញឱ្យមានចលនាអហិង្សាដើម្បីសិទ្ធិមនុស្ស និងសេរីភាពទូទាំងពិភពលោក។ |

## ចលនាទាមទារសិទ្ធិពលរដ្ឋនៅសហរដ្ឋអាមេរិក

ចលនាទាមទារសិទ្ធិពលរដ្ឋនៅសហរដ្ឋអាមេរិក (ពីឆ្នាំ១៩៥៥ ដល់ឆ្នាំ១៩៦៨) ត្រូវបានលើកទឹកចិត្តដោយមធ្យោបាយជាច្រើនតាមគំរូអហិង្សារបស់មហាត្មគន្ធី។ នៅសហរដ្ឋអាមេរិក ជនជាតិអាមេរិកស្បែកខ្មៅបានប្រឈមមុខនឹងការរើសអើង និងការគាបសង្កត់យ៉ាងខ្លាំងអស់រយៈពេលរាប់រយឆ្នាំ។ រហូតដល់ចុងទសវត្សទី៦០ នៅសហរដ្ឋអាមេរិកភាគខាងត្បូង ជនជាតិស្បែកខ្មៅត្រូវបានដាក់ឱ្យនៅដោយឡែកពីជនជាតិស្បែកស ហើយពួកគេត្រូវបានគេបង្ខំឱ្យទៅរៀននៅសាលាដាច់ដោយឡែក និងប្រើប្រាស់សេវាសាធារណៈដោយឡែក។ សេវាដែលជនជាតិស្បែកខ្មៅបានទទួលគឺតែងតែ មានគុណភាពអន់ជាងយ៉ាងខ្លាំង បើប្រៀបធៀបទៅនឹងអ្វីដែលពួកស្បែកសបានទទួល។ ជនជាតិស្បែកខ្មៅត្រូវបានហាមឃាត់មិនឲ្យចូលរួមបោះឆ្នោតទេ ហើយពួកគេមិនអាចរកការងារល្អបានធ្វើទេ។ ពួកនេះក៏ទទួលរងគ្រោះដោយអំពើហិង្សា និងការរំលោភបំពានសិទ្ធិមនុស្សផ្សេងទៀតដែរ ដែលជារឿយៗអំពើទាំងនេះបានអនុវត្តដោយនគរបាល។

ជនជាតិអាមេរិកស្បែកខ្មៅ និងពួកជនជាតិភាគតិចមួយចំនួនបានប្រឆាំងទៅនឹងការរើសអើងនេះ ។ ពួកគេបានជំទាស់ការរើសអើងនេះ ដោយប្រើមធ្យោបាយផ្សេងៗគ្នាជាច្រើន ដូចជា ដាក់ពាក្យបណ្តឹង និងរៀបចំអង្គការនយោបាយ។ ទោះបីជាពួកគេនៅតែបន្តប្រឈមមុខនឹងការប្រើអំពើហិង្សា និងការរើសអើងក៏ដោយ ក៏ពួកគេនៅតែបន្តធ្វើតាមគំរូអហិង្សារបស់មហាត្មគន្ធី ដោយមិនតបតវិញ ដោយអំពើហិង្សាឡើយ គឺពួកគេធ្វើការតបតដោយអហិង្សា ព្រមទាំងរៀបចំក្បួនដង្ហែរមហាជន ជួបជុំគ្នា និងធ្វើកូដកម្មដោយសន្តិវិធី។ លោក ម៉ាទីន លូឌឺឃីង *(Martin Luther King, Junior)* បានដឹកនាំចលនាអហិង្សានេះ ដោយទាមទារឱ្យមានការទទួលស្គាល់សិទ្ធិ ដោយរដ្ឋធម្មនុញ្ញរបស់សហរដ្ឋអាមេរិកដោយអនុវត្តចំពោះជនជាតិអាមេរិកគ្រប់រូប ដោយមិនរើសអើងពណ៌សំបុរទេ ។ ទីបំផុត ចលនានេះបានទទួលជោគជ័យដោយមានច្បាប់ថ្មីៗត្រូវបានអនុម័ត ដែលច្បាប់ទាំងនោះបានហាមប្រាមមិនឲ្យមានការរើសអើង និងបានធានាថា សិទ្ធិជាមូលដ្ឋានរបស់ជនជាតិអាមេរិកទាំងអស់ត្រូវបានគោរព ដូចជា សិទ្ធិបោះឆ្នោត ជាដើម។

# មេរៀនទី១៖ តើសិទ្ធិមនុស្សជាអ្វី?



**គោលបំណង : អ្នកចូលរួមនឹងគិតថា តើសិទ្ធិមនុស្សមានអ្វីខ្លះ តើសិទ្ធិទាំងនេះមានប្រភពមកពីណា និងហេតុអ្វីបានជាពួកគាត់ចាំបាច់ត្រូវដឹងអំពីសិទ្ធិមនុស្ស។**

**សម្ភារៈ៖** ក្រដាសផ្ទាំងធំ ឬក្ដារខៀន ហ្វឺតពណ៌ សៀវភៅសេចក្ដីថ្លែងការជាសកលស្ដីពីសិទ្ធិមនុស្ស ឯកសារសម្រាប់ចែកទី១ និងទី២។

**វិធីសាស្ត្រប្រើប្រាស់៖** ការគូររូប ការងារជាក្រុម ការបំផុសគំនិត និងការពិភាក្សាក្រុមធំ។

| ដំណើរការ | រយៈពេល (គិតជានាទី) |
|---|---|
| ១. ការគូររូបអំពីសិទ្ធិមនុស្ស | ១០ |
| ២. ការពិភាក្សាក្រុមធំ | ១០ |
| ៣. ណែនាំព័ត៌មាននៅក្នុងផ្នែកទី១ និងទី២ | ១៥ |
| ៤. ការបំផុសគំនិត និងការពិភាក្សាជាក្រុម | ១៥ |
| ៥. ណែនាំព័ត៌មាននៅក្នុងផ្នែកទី៣ | ១០ |
| ៦. ពិភាក្សាអំពីសេចក្ដីថ្លែងការណ៍ជាសកលស្ដីពីសិទ្ធិមនុស្ស | ១៥ |
| ៧. ណែនាំព័ត៌មាននៅក្នុងផ្នែកទី៤ | ១៥ |
| ៨. សង្ខេប | ១៥ |
| សរុប៖ | ១០៥ |

# ការណែនាំសម្រាប់អ្នកសម្របសម្រួល

## ១. ការគូររូបអំពីសិទ្ធិមនុស្ស

- សូមពន្យល់ថា អ្នកនឹងបែងចែកអ្នកចូលរួមទៅជាពីរ ឬបីក្រុមតូចៗ ហើយក្រុមនីមួយៗគប្បីត្រូវតែគិត និងពិភាក្សាថា តើ "**សិទ្ធិមនុស្ស**" មានន័យយ៉ាងដូចម្តេចសម្រាប់ពួកគាត់។ ក្រុមនីមួយៗគប្បីត្រូវតែគូររូបតំណាងអ្វីដែលពួកគាត់នឹកឃើញមុនគេនៅពេលដែលពួកគាត់គិតអំពី "**សិទ្ធិមនុស្ស**"។
- ចែកអ្នកចូលរួមជាក្រុម រួចឲ្យក្រដាសផ្ទាំងធំ និងហ្វឺតពណ៌ទៅក្រុមនីមួយៗ។
- ប្រហែលជា១០នាទីក្រោយមក សូមឲ្យអ្នកចូលរួមបិទរូបរបស់ពួកគាត់នៅលើជញ្ជាំងបន្ទប់។ លើកទឹកចិត្តអ្នកចូលរួមឲ្យដើរជុំវិញដើម្បីមើលរូបភាពទាំងនោះ

## ២. ការពិភាក្សាក្រុមធំ

- នៅពេលដែលអ្នកចូលរួមបានត្រលប់មកកាន់កន្លែងអង្គុយវិញហើយសូមសួរសំណួរខាងក្រោម :
  - ហេតុអ្វីបានជាយើងមានសិទ្ធិមនុស្ស ?
- សូមពន្យល់ថា គ្មានចម្លើយណាដែលខុស ឬត្រូវសម្រាប់សំណួរនេះទេ។ គោលបំណងនៃការពិភាក្សានេះ គឺដើម្បីចែករំលែកគំនិតអំពីសិទ្ធិមនុស្សតែប៉ុណ្ណោះ។
- សូមលើកទឹកចិត្តឲ្យអ្នកចូលរួមពីរ-បីនាក់ឡើងចែករំលែកគំនិតយោបល់របស់ពួកគាត់។

## ៣. ណែនាំព័ត៌មាននៅក្នុងផ្នែកទី១ និងទី២ : (សូមមើលទំព័រទី២៣ ដល់ទី២៤)

**ផ្នែកទី១ និងទី២** : វាមានសារៈសំខាន់ណាស់ដែលអ្នកចូលរួមយល់ថា៖

- សិទ្ធិមនុស្សជាអ្វី។
- មនុស្សម្នាក់ៗសុទ្ធតែមានសិទ្ធិមនុស្ស ទោះបីជាបុគ្គលទាំងនោះមានប្រវត្តិរូបយ៉ាងណាក៏ដោយ។
- សិទ្ធិមនុស្សបានមកពីគុណតម្លៃ និងទំនៀមទម្លាប់រួម ព្រោះមនុស្សភាគច្រើននៅជុំវិញពិភពលោកជឿថា គប្បីត្រូវមានការប្រព្រឹត្តចំពោះពួកគេ និងមនុស្សនៅជុំវិញខ្លួនពួកគេដោយសេចក្តីគោរព។

## ៤. ការបំផុសគំនិត និងការពិភាក្សាក្រុម

- សូមសរសេរសំណួរខាងក្រោមនៅលើក្រដាសផ្ទាំងធំ៖
    - តើអ្នកគិតថា អ្នកត្រូវការអ្វី ដើម្បីឲ្យអ្នករស់នៅប្រកបដោយភាពសប្បាយរីករាយ សុខភាពល្អ និងសេរីភាពក្នុងជីវិត?
- សូមលើកទឹកចិត្តឲ្យអ្នកចូលរួមចែករំលែកគំនិតរបស់ពួកគាត់ចំពោះសំណួរខាងលើនៅក្នុងក្រុមធំ។ អ្នកសម្របសម្រួលគប្បីត្រូវលើកទឹកចិត្តដល់អ្នកចូលរួមឲ្យឡើងផ្តល់គំនិត ឬឆ្លើយឲ្យបានច្រើននាក់តាមតែអាចធ្វើបាន ហើយសរសេរគំនិតថ្មីរបស់ពួកគាត់ទៅលើក្រដាសផ្ទាំងធំ។
- ប្រសិនបើអ្នកចូលរួមមានការលំបាកក្នុងការឆ្លើយ ឬផ្តល់គំនិតចំពោះសំណួរនេះ សូមជួយពួកគាត់ ដោយសួរសំណួរដូចជា "ប្រសិនបើអ្នកឃ្លានគ្រប់ពេល តើអ្នកអាចសប្បាយចិត្ត និងមានសុខភាពល្អដែរឬទេ?" ឬ "ប្រសិនបើអ្នកខ្លាចថា អ្នកនឹងត្រូវគេចាប់ខ្លួន នៅពេលដែលអ្នកបញ្ចេញមតិ តើអ្នកអាចសប្បាយចិត្ត និងមានសេរីភាពដែរឬទេ?
- បន្ទាប់មក អ្នកសម្របសម្រួលអាចបង្ហាញថា ដើម្បីរស់នៅឲ្យមានភាពសប្បាយរីករាយ និងជីវិតមានសុខភាពល្អ អ្នកត្រូវការវត្ថុចម្បងមួយចំនួន (ដូចជាម្ហូបអាហារ) ក៏ដូចជា សេរីភាពដែរ (ដូចជាការដែលអាចបញ្ចេញមិតរបស់ខ្លួនអ្នកដោយសេរី)។ បន្ទាប់មកអ្នកសម្របសម្រួលអាចសួររកឧទាហរណ៍បន្ថែមទៀត។

## ៥. ណែនាំអំពីព័ត៌មាននៅក្នុងផ្នែកទី៣ (សូមមើលទំព័រទី២៥ ដល់ទី៣៣)

- ដំបូង សូមសួរអ្នកចូលរួមថា តើពួកគាត់ធ្លាប់ឮអំពីសេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្សដែរឬទេ។ ប្រសិនបើមានអ្នកធ្លាប់ឮ សូមឲ្យពួកគាត់ពន្យល់ថាវាជាអ្វី។
- ទុកពេលពីរ-បីនាទីដើម្បីឲ្យអ្នកចូលរួមឆ្លើយ បន្ទាប់មកណែនាំអំពីព័ត៌មាននៅក្នុងផ្នែកទី៣។

**ផ្នែកទី៣៖** វាមានសារៈសំខាន់ណាស់ដែលអ្នកចូលរួមយល់ដឹងថា៖

- អង្គការសហប្រជាជាតិជាអ្វី។
- សេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្សជាអ្វី។
- សេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្សមានសិទ្ធិមូលដ្ឋានទាំងអស់របស់មនុស្សនៅក្នុងនោះ។

## ៦. ពិភាក្សាអំពីសេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស

- សូមចែកសៀវភៅ "សេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស"។ សូមឲ្យអ្នកចូលរួមជ្រើសរើស ឧទាហរណ៍មួយក្នុងចំណោមឧទាហរណ៍ជាច្រើនដែលពួកគាត់បានផ្តល់អំពីអ្វីដែលមនុស្សត្រូវការដើម្បីរស់នៅឲ្យមានភាពសប្បាយរីករាយ សុខភាពល្អ និងជីវិតមានសេរីភាព និងឲ្យពួកគាត់ព្យាយាមរកចំណុចទាំងនោះ នៅក្នុងសៀវភៅ "សេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស"។
- អ្នកសម្របសម្រួលក៏អាចចែករូបភាពអំពីសិទ្ធិមនុស្សដែលមាននៅក្នុងផ្នែកទី៣ និងសូមឲ្យអ្នកចូលរួមព្យាយាមស្វែងរកសិទ្ធិទាំងនោះ នៅក្នុងសៀវភៅសេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស។
- ពីរ-បីនាទីក្រោយមក សូមឲ្យអ្នកចូលរួមអានអត្ថបទដែលទាក់ទងនៅក្នុងសៀវភៅសេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្សដែលពួកគាត់បានរកឃើញឲ្យឮៗ។ តើពួកគាត់អាចគិតឃើញអំពីវិធីដែលសិទ្ធិមនុស្សទាំងនេះមានឥទ្ធិពលទៅលើជីវិតរបស់ពួកគាត់ផ្ទាល់ដែរឬទេ។

## ៧. ណែនាំព័ត៌មាននៅក្នុងផ្នែកទី៤ (សូមមើលទំព័រទី៣៤ ដល់ទី៣៥)

- ដំបូង សូមសួរថា៖
  - តើអ្នកគិតថា វាមានសារៈសំខាន់ដែរឬទេ ដែលអ្នកត្រូវដឹងអំពីសិទ្ធិរបស់អ្នក? ប្រសិនបើសំខាន់មែន តើមូលហេតុអ្វី?
- សូមទុកពេលពីរ-បីនាទីឲ្យអ្នកចូលរួមឆ្លើយ បន្ទាប់មកណែនាំព័ត៌មានក្នុងផ្នែកទី៤។

**ផ្នែកទី៤** : វាមានសារៈសំខាន់ណាស់ដែលអ្នកចូលរួមយល់ដឹងថា៖

- ទោះបីជាមនុស្សម្នាក់ៗ មានសិទ្ធិទាំងនេះក៏ដោយ ក៏សិទ្ធិទាំងនេះមិនត្រូវបានគេគោរពគ្រប់ពេលនោះទេ ប៉ុន្តែនេះមិនមែនមានន័យថា សិទ្ធិទាំងនោះមិនមានន័យអ្វីនោះទេ។
- ប្រសិនបើប្រជាពលរដ្ឋមិនដឹងថា សិទ្ធិរបស់គាត់មានអ្វីខ្លះ នោះពួកគាត់មិនអាចធ្វើឲ្យប្រាកដថា ពួកគាត់ត្រូវបានគេគោរពនោះទេ។
- ជាច្រើនឆ្នាំមកហើយ មនុស្សជាច្រើនបានតស៊ូដើម្បីទាមទារឲ្យគោរពសិទ្ធិរបស់ពួកគាត់ និងដើម្បីឲ្យមានការគោរពសិទ្ធិរបស់អ្នកដទៃ។

- សូមឲ្យអ្នកចូលរួមម្នាក់អានឧទាហរណ៍នៅក្នុងឯកសារសម្រាប់ចែកទី១ ស្ដីអំពីជនជាតិឥណ្ឌាដែលបានតស៊ូដើម្បីឯករាជ្យនោះ ឲ្យឮខ្លាំងៗ។ សូមឲ្យអ្នកចូលរួមម្នាក់ទៀតអានឧទាហរណ៍នៅក្នុងឯកសារសម្រាប់ចែកទី២ ស្ដីអំពីចលនាសិទ្ធិពលរដ្ឋនៅសហរដ្ឋអាមេរិកឲ្យឮខ្លាំងៗ។

- សូមសួរអ្នកចូលរួមថា តើពួកគាត់គិតយ៉ាងណាចំពោះរឿងទាំងនោះ។

- សូមសួរអ្នកចូលរួមថា តើពួកគាត់មានបានដឹងអំពីឧទាហរណ៍អ្វីផ្សេងទៀតដែលទាក់ទងទៅនឹងការតស៊ូមតិដើម្បីឲ្យមានការគាំទ្រលើសិទ្ធិមនុស្សដែរឬទេ។ ឧទាហរណ៍ទាំងនេះអាចជាការឆ្លងកាត់ការរស់នៅ និងរបស់សហគមន៍ផ្ទាល់ នៅប្រទេសកម្ពុជា ឬជុំវិញពិភពលោក។

## ៨. សង្ខេប

- ដើម្បីរំលឹកលំហាត់នេះ សូមលេងល្បែងខ្លីមួយ។ សូមចែកអ្នកចូលរួមទាំងអស់ជាបី-បួនក្រុម។ សូមឲ្យក្រុមនីមួយៗបង្កើតសំឡេងមួយ ដើម្បីបន្លឺឡើង នៅពេលដែលពួកគាត់ដឹងចម្លើយចំពោះសំណួរដែលអ្នកសួរពួកគាត់។ ឧទាហរណ៍ ក្រុមមួយអាចយកសំឡេងសត្វគោ ចំណែកឯក្រុមផ្សេងទៀតអាចយកសំឡេងទះដៃ ឬសំឡេងហួច។ ក្រុមនីមួយៗគប្បីត្រូវមានសំឡេងរៀងៗខ្លួន។

- សូមពន្យល់ថា អ្នកនឹងសួរសំណួរខ្លះ ហើយក្រុមណាដែលគិតថា គាត់ដឹងចម្លើយនោះ សូមបន្លឺសំឡេងប្រចាំក្រុមរបស់គាត់។ ក្រុមណាដែលស្រែកសំឡេងប្រចាំក្រុមបានមុន ក្រុមនោះនឹងអាចឆ្លើយសំណួរបាន ហើយប្រសិនបើចម្លើយរបស់ក្រុមនេះត្រឹមត្រូវ នោះពួកគាត់នឹងបាន២ពិន្ទុ។ ប្រសិនបើពួកគាត់ឆ្លើយមិនត្រឹមត្រូវទេ នោះក្រុមដទៃទៀតនឹងមានឱកាសឆ្លើយម្ដង។

- សូមប្រើសំណួរដូចខាងក្រោម (អ្នកសម្របសម្រួលអាចបន្ថែមសំណួរដែលអាចគិតឃើញ) :

  - តើសិទ្ធិមនុស្សជាអ្វី? (ចម្លើយ៖ សិទ្ធិមនុស្សគឺជាអ្វីដែលមនុស្សគ្រប់រូបត្រូវការដើម្បីធ្វើឲ្យការរស់នៅមានភាពសប្បាយរីករាយ សុខភាពល្អ និងជីវិតមានសេរីភាព។ អ្នកមានសិទ្ធិទាំងនេះ ដោយសារ អ្នកគឺជាមនុស្សជាតិ។)

  - សូមរកឧទាហរណ៍ អំពីសិទ្ធិមនុស្សឲ្យបាន៥។ (ចម្លើយ៖ សូមមើលរូបភាពនៅក្នុងផ្នែកទី៣ ជាឧទាហរណ៍)

  - អ្នកណាមានសិទ្ធិមនុស្ស? (ចម្លើយ៖ *មនុស្សគ្រប់រូប មិនថានៅកន្លែងណាទេ គឺមានសិទ្ធិមនុស្សដូចគ្នា* ទាំងបុរស ស្ត្រី ក្មេង ចាស់ មាន និងក្រ មិនថាពួកគេកើតនៅទីណា ឬមានជំនឿសាសនាអ្វីឡើយ)។

  - តើគេអាចដកហូតសិទ្ធិមនុស្សបានទេ? (ចម្លើយ៖ ទេ ពិតជាមិនអាចដកហូតបានទេ។ សិទ្ធិមនុស្សអាចត្រូវគេរំលោភបំពានបាន ប៉ុន្តែមិនអាចត្រូវគេដកហូតបានទេ។)

  - តើសេចក្តីប្រកាសជាសកលស្តីអំពីសិទ្ធិមនុស្សជាអ្វី? (ចម្លើយ៖ ជាសេចក្តីថ្លែងការណ៍មួយនៃសិទ្ធិជាមូលដ្ឋានរបស់មនុស្សទាំងអស់ ដែលធ្វើឡើងនៅឆ្នាំ១៩៤៨ដោយអង្គការសហប្រជាជាតិ)។
  - ហេតុអ្វីបានជា ការដឹងអំពីសិទ្ធិរបស់អ្នកមានសារៈសំខាន់? (ចម្លើយ៖ ព្រោះថា ប្រសិនបើអ្នកដឹងអំពីសិទ្ធិរបស់អ្នក ពេលនោះអ្នកអាចធ្វើឲ្យប្រាកដថា សិទ្ធិទាំងនោះត្រូវមានការពារ។

- សូមសរុបពិន្ទុដើម្បីមើលថា តើក្រុមណាឈ្នះ។

## មហាត្មៈគន្ធី

អស់រយៈពេលជាច្រើនទសវត្សមកហើយ ដែលរដ្ឋាភិបាលនៃប្រទេសអង់គ្លេសបានដាក់ប្រទេសឥណ្ឌាក្រោមអាណានិគមរបស់ខ្លួន។ នៅកំឡុងពេលនោះ មានការរំលោភបំពានលើសិទ្ធិប្រជាពលរដ្ឋឥណ្ឌាជាច្រើន ដែលមានដូចជា ការសម្លាប់ ការបង្ខំឱ្យធ្វើការងារ និងការកាត់ក្ដីដោយអយុត្តិធម៌និងការដាក់គុកជាដើម។ អស់រយៈពេលជាច្រើនឆ្នាំមក ប្រជាពលរដ្ឋកាន់តែច្រើនឡើងៗបានប្ដេជ្ញាចិត្តយ៉ាងខ្លាំងក្លា ដើម្បីបញ្ចប់ការគ្រប់គ្រងបែបអាណានិគមដែលមានការសង្កត់សង្កិនបែបនេះ ហើយទីបញ្ចប់ពួកគេបានទទួលសេរីភាព និងឯករាជ្យ។

ការតស៊ូដើម្បីទាមទារឯករាជ្យជូនប្រទេសឥណ្ឌា ត្រូវបានដឹកនាំដោយលោក មហាត្មគន្ធី។ គាត់បានរៀបចំ និងដឹកនាំកសិករ និងកម្មករនៅក្នុងចលនាតស៊ូដោយអហិង្សាប្រឆាំងនឹងការគ្រប់គ្រងរបស់ពួកអាណានិគមអង់គ្លេស។ លោក គន្ធី ត្រូវបានអាជ្ញាធរអង់គ្លេសចាប់ដាក់គុកជាច្រើនលើក និងថែមទាំងមានការប៉ុនប៉ងសម្លាប់លោកជាច្រើនដងទៀត។ ប្រជាពលរដ្ឋឥណ្ឌារាប់សែននាក់ត្រូវបានចាប់ខ្លួន ជាការឆ្លើយតបទៅនឹងការធ្វើចលនាទាមទារឯករាជ្យ ដែលគួរឲ្យសោកស្ដាយនោះ គឺមនុស្សជាច្រើនត្រូវបានសម្លាប់។

ទោះបីមានការប្រើហិង្សាពីសំណាក់អាជ្ញាធរអង់គ្លេសក៏ដោយ ក៏ចលនាតស៊ូទាមទារឯករាជ្យនៅតែធ្វើឡើងក្នុងវិធីអហិង្សា ហើយចលនាអហិង្សានេះក៏បាននាំឯករាជ្យឱ្យប្រទេសឥណ្ឌានៅឆ្នាំ ១៩៤៧។ តាំងពីនោះមក លោក គន្ធី ក៏បានជំរុញឱ្យមានចលនាអហិង្សាដើម្បីសិទ្ធិមនុស្ស និងសេរីភាពទូទាំងពិភពលោក។

## ចលនាទាមទារសិទ្ធិពលរដ្ឋនៅសហរដ្ឋអាមេរិក

ចលនាទាមទារសិទ្ធិពលរដ្ឋនៅសហរដ្ឋអាមេរិក (ពីឆ្នាំ១៩៥៥ ដល់ឆ្នាំ១៩៦៨) ត្រូវបានលើកទឹកចិត្តដោយមធ្យោបាយជាច្រើនតាមគំរូអហិង្សារបស់មហាត្មគន្ធី។ នៅសហរដ្ឋអាមេរិក ជនជាតិអាមេរិកស្បែកខ្មៅបានប្រឈមមុខនឹងការរើសអើង និងការគាបសង្កត់យ៉ាងខ្លាំងអស់រយៈពេលរាប់រយឆ្នាំ។ រហូតដល់ចុងទសវត្សទី៦០ នៅសហរដ្ឋអាមេរិកភាគខាងត្បូង ជនជាតិស្បែកខ្មៅត្រូវបានដាក់ឱ្យនៅដោយឡែកពីជនជាតិស្បែកស ហើយពួកគេត្រូវបានគេបង្ខំឱ្យទៅរៀននៅសាលាដាច់ដោយឡែក និងប្រើប្រាស់សេវាសាធារណៈដោយឡែក។ សេវាដែលជនជាតិស្បែកខ្មៅបានទទួលគឺតែងតែ មានគុណភាពអន់ជាងយ៉ាងខ្លាំង បើប្រៀបធៀបទៅនឹងអ្វីដែលពួកស្បែកសបានទទួល។ ជនជាតិស្បែកខ្មៅត្រូវបានហាមឃាត់មិនឲ្យចូលរួមបោះឆ្នោតទេ ហើយពួកគេមិនអាចរកការងារល្អបានធ្វើទេ។ ពួកនេះក៏ទទួលរងគ្រោះដោយអំពើហិង្សា និងការរំលោភបំពានសិទ្ធិមនុស្សផ្សេងទៀតដែរ ដែលជារឿយៗអំពើទាំងនេះបានអនុវត្តដោយនគរបាល។

ជនជាតិអាមេរិកស្បែកខ្មៅ និងពួកជនជាតិភាគតិចមួយចំនួនបានប្រឆាំងទៅនឹងការរើសអើងនេះ ។ ពួកគេបានជំទាស់ការរើសអើងនេះ ដោយប្រើមធ្យោបាយផ្សេងៗគ្នាជាច្រើន ដូចជា ដាក់ពាក្យបណ្ដឹង និងរៀបចំអង្គការនយោបាយ។ ទោះបីជាពួកគេនៅតែបន្តប្រឈមមុខនឹងការប្រើអំពើហិង្សា និងការរើសអើងក៏ដោយ ក៏ពួកគេនៅតែបន្តធ្វើតាមគំរូអហិង្សារបស់មហាត្មគន្ធីដោយមិនតបតវិញ ដោយអំពើហិង្សាឡើយ គឺពួកគេធ្វើការតបតដោយអហិង្សា ព្រមទាំងរៀបចំក្បួនដង្ហែរមហាជន ជួបជុំគ្នា និងធ្វើកូដកម្មដោយសន្តិវិធី។ លោក ម៉ាទីន លូឌឺឃីង *(Martin Luther King, Junior)* បានដឹកនាំចលនាអហិង្សានេះ ដោយទាមទារឱ្យមានការទទួលស្គាល់សិទ្ធិ ដោយរដ្ឋធម្មនុញ្ញរបស់សហរដ្ឋអាមេរិកដោយអនុវត្តចំពោះជនជាតិអាមេរិកគ្រប់រូប ដោយមិនរើសអើងពណ៌សំបុរទេ ។ ទីបំផុត ចលនានេះបានទទួលជោគជ័យដោយមានច្បាប់ថ្មីៗត្រូវបានអនុម័ត ដែលច្បាប់ទាំងនោះបានហាមប្រាមមិនឲ្យមានការរើសអើង និងបានធានាថា សិទ្ធិជាមូលដ្ឋានរបស់ជនជាតិអាមេរិកទាំងអស់ត្រូវបានគោរព ដូចជា សិទ្ធិបោះឆ្នោត ជាដើម។

## ៥. ប្រភេទនៃសិទ្ធិ

ជាទូទៅសិទ្ធិមនុស្សត្រូវបានចែកជាពីរប្រភេទគឺៈ

- សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ
- សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

### ៥.១. សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយគឺជាសេរីភាពបុគ្គល ការចូលរួមនៅក្នុងជីវភាពសាធារណៈ និងការប្រព្រឹត្តចំពោះគ្នាទៅវិញទៅមកដោយស្មើភាពគ្នា និងយុត្តិធម៌នៅក្នុងសង្គម។ ឧទាហរណ៍នៃសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មានដូចជាៈ

- សិទ្ធិរស់រានមានជីវិត
- សេរីភាពក្នុងការធ្វើដំណើរ
- សិទ្ធិចូលរួមក្នុងការបោះឆ្នោត
- សេរីភាពក្នុងការប្រតិបត្តិសាសនាទៅតាមការជ្រើសរើសរបស់អ្នក
- សេរីភាពក្នុងការបញ្ចេញមតិ
- សេរីភាពក្នុងការប្រមូលផ្តុំគ្នាដោយសន្តិវិធី និង
- សិទ្ធិទទួលបានការការពារស្មើគ្នាតាមផ្លូវច្បាប់

### ៥.២. សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ទាក់ទងទៅនឹងតម្រូវការមូលដ្ឋានរបស់បុគ្គលដើម្បីរស់នៅដោយសេចក្តីថ្លៃថ្នូរ។ ឧទាហរណ៍នៃសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌មានដូចជាៈ

- សិទ្ធិក្នុងការរស់នៅទៅតាមបទដ្ឋានសមរម្យ ដូចជា សិទ្ធិមានលំនៅឋានសមរម្យ ទឹក និងអាហារប្រើប្រាស់គ្រប់គ្រាន់
- សិទ្ធិមានការងារធ្វើ មានលក្ខខណ្ឌការងារសមរម្យ និងសិទ្ធិក្នុងការចូលរួមជាមួយសហជីព
- សិទ្ធិទទួលបានសន្តិសុខសង្គម ដែលមានដូចជា ការគាំពារដល់ជនក្រីក្រ ដែលមិនអាចមានលទ្ធភាពរកបានចំណូលគ្រប់គ្រាន់សម្រាប់ជីវភាពរស់នៅ ។
- សិទ្ធិទទួលបានការអប់រំ ដូចជា ទទួលការអប់រំថ្នាក់បឋមភូមិដោយឥតគិតថ្លៃ និង
- សិទ្ធិចូលរួមក្នុងជីវភាពខាងវប្បធម៌

## ៦. សិទ្ធិមនុស្សទាំងអស់សុទ្ធតែទាក់ទងគ្នា

ទោះបីជា គេអាចចែកសិទ្ធិចេញជាពីរផ្នែកផ្សេងគ្នាក៏ដោយ ក៏សិទ្ធិមនុស្សទាំងអស់សុទ្ធតែមានទាក់ទងគ្នាទៅវិញទៅមក។ សិទ្ធិមនុស្សទាក់ទងគ្នាមានន័យថា យើងមិនអាចទទួលបានសិទ្ធិតែមួយយ៉ាងពេញលេញ ដោយមិនបានទទួល សិទ្ធិផ្សេងទៀតយ៉ាងពេញលេញនោះទេ។ ឧទាហរណ៍ យើងមិនអាចទទួលបានសិទ្ធិក្នុងការរស់នៅសមរម្យយ៉ាងពេញលេញទេ ប្រសិនបើយើងគ្មានសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិយ៉ាងពេញលេញនោះ។ សិទ្ធិក្នុងការចូលរួមបោះឆ្នោតមិនអាចអនុវត្តបានទេ ប្រសិនបើមិនទទួលបានសិទ្ធិមានស្បៀងអាហារសមរម្យទេ គឺយើងមិនអាចចូលរួមក្នុងការធ្វើសេចក្តីសម្រេចផ្នែកនយោបាយសំខាន់ៗបានទេ ប្រសិនបើ យើងទន់ខ្សោយដោយសារភាពអត់ឃ្លាននោះ។

សិទ្ធិមនុស្សទាំងអស់ទាក់ទងគ្នាក៏មានន័យដែរថា កាលណាមានការគោរពសិទ្ធិមួយកាន់តែខ្លាំងនាំឲ្យឈានទៅរកការអាស្រ័យ (ទទួលបាន)សិទ្ធិមួយទៀតក៏កាន់តែខ្លាំងដែរ។ ឧទាហរណ៍ នៅពេលដែលមនុស្សមានលំនៅឋានសមរម្យ សុវត្ថិភាព និងភាពជាឯកជន ពេលនោះពួកគាត់នឹងទំនងជាកាន់តែមានសុខភាព និងការអប់រំប្រសើរឡើង។ មានសិទ្ធិទទួលបានការអប់រំ និងព័ត៌មានកាន់ប្រសើរជាងមុន មានន័យថា ប្រជាពលរដ្ឋនឹងកាន់តែអាចចូលរួមនៅក្នុងជីវិតសាធារណៈ។

គ្មានសិទ្ធិមនុស្សមួយណាមានសារៈសំខាន់ច្រើន ឬតិចជាងគ្នា ក្នុងការគោរពសេចក្តីថ្លៃថ្នូររបស់មនុស្សទេ។ សិទ្ធិមនុស្សទាំងអស់មានតម្លៃស្មើគ្នា និងការអាស្រ័យលើសិទ្ធិមួយ មិនអាចផ្តាច់ចេញពីការអាស្រ័យសិទ្ធិមនុស្សផ្សេងទៀតឡើយ។

## មេរៀនទី២៖ សិទ្ធិមនុស្សទាំងអស់មានទំនាក់ទំនងគ្នា



**គោលបំណង ៖ អ្នកចូលរួមនឹងគិតអំពីសិទ្ធិជាក់លាក់ ទំនាក់ទំនងរវាងពីសិទ្ធិមួយទៅសិទ្ធិមួយ និងគិតថា តើការដែលមានសិទ្ធិទាំងនោះមានន័យយ៉ាងណា។**

**សម្ភារៈ៖** ផ្លាកសញ្ញាដែលមានសរសេរថា៖ "សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌", ផ្លាកសញ្ញាដែលសរសេរថា៖ "សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ" រូបគំនូរយ៉ាងធំអំពីមនុស្សមកពីពិភពក្រៅ នៅក្នុងឯកសារសម្រាប់ចែកទី១ ឯកសារសម្រាប់ចែកទី២ អត្ថបទកាសែតចេញផ្សាយថ្មីៗដែលនិយាយអំពីការរំលោភសិទ្ធិមនុស្ស (មានក៏បានគ្មានក៏បាន ស្រេចតែលើអ្នកសម្របសម្រួលជ្រើសរើស) ក្ដារខៀន ឬក្រដាសផ្ទាំងធំ ហ្វឺត។

**វិធីសាស្ត្រប្រើប្រាស់៖** ការគូររូប ការពិភាក្សា ការងារក្រុមតូច ការឡើងបង្ហាញ ការពិភាក្សាក្រុមធំ

| ដំណើរការ | រយៈពេល (គិតជានាទី) |
|---|---|
| ១. ការគូររូប និងការរៀបសិទ្ធិមនុស្សទៅតាមក្រុម | ១៥ |
| ២. ណែនាំព័ត៌មាននៅក្នុងផ្នែកទី៥ | ១០ |
| ៣. ល្បែងមនុស្សមកពីពិភពក្រៅ | ២០ |
| ៤. ក្រុមនីមួយៗពន្យល់ពីការសម្រេចចិត្តរបស់ខ្លួន | ១៥ |
| ៥. ណែនាំព័ត៌មាននៅក្នុងផ្នែកទី៦ | ១០ |
| ៦. សង្ខេប | ១៥ |
| សរុប: | ៨៥ |

# ការណែនាំសម្រាប់អ្នកសម្របសម្រួល

## ១. ការគូររូប និងការរៀបសិទ្ធិមនុស្សទៅតាមក្រុម:

- សូមឲ្យអ្នកចូលរួមទាំងអស់គូររូបភាពដែលបង្ហាញអំពីសិទ្ធិមនុស្សម្នាក់មួយៗ។ ពួកគាត់អាចចង់គូរអំពីសិទ្ធិអ្វីក៏បានដែរស្រេចតែចិត្តរបស់គាត់។
- សូមទុកពេលឲ្យអ្នកចូលរួមពីរ-បីនាទីដើម្បីគូររូបភាពរបស់គាត់ឲ្យរួចរាល់។
- បន្ទាប់មកសូមដាក់សញ្ញាដែលនិយាយថា "សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ" នៅខាងចុងនៃបន្ទប់ ហើយសញ្ញាដែលនិយាយថា "សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌" នៅចុងម្ខាងទៀតនៃបន្ទប់។
- សូមឲ្យអ្នកចូលរួមគិតថា តើរូបភាពរបស់គាត់ត្រូវជាមួយសិទ្ធិមនុស្សប្រភេទមួយណា ហើយបន្ទាប់មកសូមឲ្យគាត់ទៅឈរនៅក្បែរប្រភេទសិទ្ធិនោះ ដូចជា "សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ" មួយក្រុម ឬ "សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌" មួយក្រុម។
- សូមជ្រើសរើសអ្នកចូលរួមពីរ-បីនាក់ដែលឈរនៅក្រុម សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ឲ្យបង្ហាញរូបភាពរបស់ពួកគាត់ ហើយពន្យល់ថា ហេតុអ្វីបានជាពួកគាត់គិតថា វាជា សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ។ សូមសួរអ្នកចូលរួមដទៃទៀត តើពួកគាត់យល់ស្របដែរឬទេ។
- សូមធ្វើដូចគ្នាជាមួយអ្នកចូលរួមដែលឈរនៅក្រុម សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។

## ២. ណែនាំព័ត៌មាននៅក្នុងផ្នែកទី៥ (សូមមើលទំព័រទី៤៤)

**ផ្នែកទី៥** : វាមានសារៈសំខាន់ណាស់ដែលអ្នកចូលរួមយល់ដឹងថា៖

- សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយជាអ្វី និងយល់អំពីឧទាហរណ៍មួយចំនួន។
- សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ជាអ្វី និងយល់អំពីឧទាហរណ៍មួយចំនួន។

## ៣. ល្បែងមនុស្សមកពីពិភពក្រៅ

- សូមដាក់រូបភាពយ៉ាងធំមួយអំពីមនុស្សមកពីពិភពក្រៅ ដែលមាននៅក្នុងឯកសារសម្រាប់ចែកទី១ នៅចំកណ្តាលបន្ទប់។
- សូមពន្យល់អ្នកចូលរួមថា មនុស្សមកពីពិភពក្រៅនោះបានគ្រប់គ្រងប្រទេសរបស់អ្នក។ ការគ្រប់គ្រងនេះនឹងធ្វើឲ្យជីវភាពរស់នៅរបស់ពួកគាត់មានការផ្លាស់ប្តូរ។ មនុស្សមកពីពិភពក្រៅនោះបានប្រកាសថា ពួកគេនឹងដកយកសិទ្ធិមនុស្សចំនួន៣ក្នុងចំណោមសិទ្ធិមនុស្សទាំង១២ដែលពួកគេបានរាយក្នុងបញ្ជី។ ពួកគេនឹងអនុញ្ញាតឲ្យប្រជាពលរដ្ឋរក្សាទុកតែសិទ្ធិដែលនៅសល់ក្នុងបញ្ជីនោះតែប៉ុណ្ណោះ។

- មនុស្សមកពីពិភពក្រៅទាំងនោះបានសម្រេចចិត្តឲ្យអ្នកចូលរួមទាំងអស់ជ្រើសរើសថា តើសិទ្ធិមួយណាគប្បីត្រូវតែត្រូវដកចេញ។ ពួកគេបានចែកអ្នកចូលរួមជាក្រុមតូចៗ ហើយក្រុមនីមួយៗត្រូវជ្រើសរើសសិទ្ធិមនុស្សចំនួន៣ដែលត្រូវដកចេញ។ ពួកគេឲ្យអ្នកចូលរួម១៥នាទីដើម្បីធ្វើការសម្រេចចិត្ត ប៉ុន្តែបើពួកគាត់មិនជ្រើសរើសសិទ្ធិទាំង៣ទេ នោះមនុស្សពិភពក្រៅនឹងដកយកសិទ្ធិទាំងអស់។

- សូមចែកអ្នកចូលរួមជា៣ ឬ៤ក្រុម។ វាអាចនឹងមានការចាប់អារម្មណ៍ប្រសិនបើ ចែកអ្នកចូលរួមជាក្រុមបុរស និងក្រុមស្ត្រី ដើម្បីមើលថា តើពួកគាត់មានចម្លើយផ្សេងគ្នា ឬដូចគ្នា។ សូមឲ្យឯកសារសម្រាប់ចែកទី២ទៅក្រុមនីមួយៗ។

- ក្រុមមានពេល១៥នាទីដើម្បីធ្វើការ និងប្រាប់ឲ្យពួកគាត់ដឹងនៅពេលដែលសល់ពេល២នាទី។ សូមរំលឹកពួកគាត់ថា បើពួកគាត់មិនជ្រើសរើសសិទ្ធិចំនួន៣ទេ នោះមនុស្សមកពីពិភពក្រៅនឹងដកយកសិទ្ធិទាំងអស់។

## ៤. ក្រុមនីមួយៗពន្យល់ពីការសម្រេចចិត្តរបស់ពួកគាត់

- សូមឲ្យក្រុមនីមួយៗសរសេរសិទ្ធិទាំង៣ដែលពួកគាត់សម្រេចចិត្តដកចេញនៅលើក្រដាសផ្ទាំងធំនៅពីមុខបន្ទប់ដើម្បីឲ្យគ្រប់គ្នាអាចមើលឃើញ។

- ស្នើសុំឲ្យអ្នកចូលរួមម្នាក់ពីក្នុងក្រុមនីមួយៗឡើងពន្យល់ថា ហេតុអ្វីពួកគាត់ជ្រើសរើសដកសិទ្ធិមនុស្សទាំង៣នោះចេញ។ ប្រសិនបើ មានក្រុមណាដែលមិនមានការសម្រេចចិត្តទេ សូមសួរពួកគាត់ថា តើមានរឿងអ្វីកើតឡើងនៅក្នុងការពិភាក្សានៅក្នុងក្រុមរបស់ពួកគាត់។

- បន្ទាប់ពីក្រុមនីមួយៗបានពន្យល់ហើយ សូមសួរអ្នកចូលរួមដទៃទៀតថា តើពួកគាត់មានមតិ ឬសំណួរអំពីការសម្រេចចិត្តរបស់ក្រុមនីមួយៗដែរឬទេ។ សូមលើកទឹកចិត្តឲ្យមានការពិភាក្សា ឬជជែកដេញដោលគ្នាយ៉ាងសកម្ម។

- សូមសួរអ្នកចូលរួមថា តើមានការលំបាកក្នុងការជ្រើសរើសដកសិទ្ធិមនុស្សទាំង៣នេះចេញដែរឬទេ។ ប្រសិនបើមាន តើមកពីហេតុអ្វី?

## ៥. ណែនាំព័ត៌មាននៅក្នុងផ្នែកទី៦ (សូមមើលទំព័រទី៤៥)

**ផ្នែកទី៦៖** វាមានសារៈសំខាន់ណាស់ដែលអ្នកចូលរួមយល់ថា៖

- សិទ្ធិមនុស្សទាំងអស់សុទ្ធតែមានទំនាក់ទំនងគ្នា
- ការគោរពកាន់តែខ្លាំងទៅលើសិទ្ធិមួយ ពិតជាឈានទៅរកការអនុវត្តសិទ្ធិផ្សេងៗទៀតកាន់តែខ្លាំង។
- យើងមិនអាចអាស្រ័យ (ទទួលបាន) សិទ្ធិតែមួយយ៉ាងពេញលេញ ដោយមិនបានអាស្រ័យ (ទទួលបាន) សិទ្ធិផ្សេងៗទៀតដោយពេញលេញនោះទេ។
- ក្នុងការគោរពសេចក្តីថ្លៃថ្នូររបស់មនុស្ស គ្មានសិទ្ធិមួយណាមានសារៈសំខាន់ច្រើន ឬតិចជាងមួយណានោះទេ។

## ៦. សង្ខេប :

- សូមរំលឹកអ្នកចូលរួមថា គ្មានអ្នកអាចដកហូតសិទ្ធិរបស់អ្នកណាបានទេ សម្បីតែ មនុស្សមកពីពិភពក្រៅក៏មិនអាចដកហូតបានដែរ។ ប្រសិនបើរដ្ឋាភិបាល ឬអ្នកណាម្នាក់បំពានសិទ្ធិណាមួយនោះមិនមែនរដ្ឋាភិបាលដកហូតសិទ្ធិនោះទេ ប៉ុន្តែរដ្ឋាភិបាលកំពុងតែខកខានមិនបានអនុវត្តកាតព្វកិច្ចរបស់ខ្លួនក្នុងការគោរពសិទ្ធិមនុស្ស។
- សូមសួរអ្នកចូលរួមមើលថា តើពួកគាត់អាចគិតអំពីឧទាហរណ៍នៅក្នុងជីវិតរបស់ពួកគាត់ ឬក្នុងព័ត៌មាន ដែលសិទ្ធិមនុស្សត្រូវបានគេបំពានដែរឬទេ។ នៅក្នុងស្ថានភាពដែលពួកគាត់បានគិតនោះ តើសិទ្ធិមនុស្សមួយណាដែលត្រូវគេបំពាន? តើមានសិទ្ធិមនុស្សអ្វីផ្សេងទៀតដែលវាអាចប៉ះពាល់ ដោយសារតែការបំពាននេះទេ?
- អ្នកសម្របសម្រួលអាចបញ្ចប់លំហាត់នេះ ដោយអានអត្ថបទថ្មីៗនៅក្នុងកាសែតដែលមានទាក់ទងនឹងការបំពានលើសិទ្ធិមនុស្ស ឲ្យឮខ្លាំងៗ។ សូមសួរអ្នកចូលរួមថា តើសិទ្ធិមនុស្សមួយណាដែលត្រូវគេបំពាន ហើយតើសិទ្ធិណាខ្លះទៀត ដែលអាចប៉ះពាល់ដោយសារការបំពានសិទ្ធិនេះ។


យើងនឹងយកសិទ្ធិមនុស្ស បីចំនុច ចេញ អ្នកជ្រើសរើសទៅ!
We are taking away 3 human rights. You choose!

## ឯកសារសម្រាប់ចែកទី២ : មេរៀនទី២

**ជូនចំពោះមនុស្សជាតិទាំងអស់**

ឥឡូវនេះពួកយើង ជាអ្នកគ្រប់គ្រងថ្មីនៅលើភពផែនដីនេះ។ សកម្មភាពទី១ របស់ពួកយើងក្នុងនាមជាអ្នកគ្រប់គ្រងរបស់មនុស្សជាតិគឺត្រូវដកហូតសិទ្ធិមនុស្សចំនួន៣។ ឥឡូវនេះ សិទ្ធិដែលនៅសល់ទាំងប៉ុន្មាន ពួកយើងនឹងអនុញ្ញាតឲ្យមនុស្សជាតិទាំងអស់គ្នារក្សាទុក ...។ ដោយសារតែពួកយើងជាមនុស្សមកពីពិភពក្រៅ និងជាអ្នកគ្រប់គ្រងដែលមានចិត្តល្អ ដូច្នេះពួកយើងនឹងទុកឲ្យអ្នកទាំងអស់គ្នាជាអ្នកជ្រើសរើសសិទ្ធិមនុស្សចំនួន៣ដើម្បីពួកយើងនឹងដកហូត។ សូមគូរបន្ទាត់កាត់សិទ្ធិទាំង៣នៅក្នុងចំណោមសិទ្ធិទាំង១២ខាងក្រោម។ អ្នកទាំងអស់គ្នាមានពេល១៥នាទី។

ដោយការគោរពពីពួកយើង

មនុស្សមកពីពិភពក្រៅ

១. សិទ្ធិរួចផុតពីការធ្វើទារុណកម្ម
២. សិទ្ធិទទួលបានលំនៅឋានសមរម្យ
៣. សិទ្ធិទទួលបានការកាត់ក្តីដោយយុត្តិធម៌
៤. សិទ្ធិមានទឹកប្រើប្រាស់
៥. សិទ្ធិរួចផុតពីការរើសអើង
៦. សិទ្ធិរស់រានមានជីវិត
៧. សិទ្ធិសេរីភាពខាងសាសនា
៨. សិទ្ធិក្នុងការបញ្ចេញមតិដោយសេរី
៩. សិទ្ធិរួចផុតពីទាសភាព
១០. សិទ្ធិទទួលបានការថែទាំសុខភាព
១១. សិទ្ធិទទួលបានការអប់រំ
១២. សិទ្ធិរួចផុតពីការឃុំខ្លួនដោយអយុត្តិធម៌

# ៧. សិទ្ធិមនុស្ស និងកាតព្វកិច្ចរបស់រដ្ឋាភិបាល

រដ្ឋាភិបាលមានអំណាចធំទូលាយក្នុងការធ្វើសេចក្ដីសម្រេចចិត្ត អនុម័តច្បាប់ និងក្នុងការចាត់ការ ដែលមានឥទ្ធិពលដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋទាំងអស់។ សិទ្ធិមនុស្សដាក់កំណត់ និងផ្ដល់ការ ណែនាំអំពីវិធីដែលរដ្ឋាភិបាលគប្បីត្រូវប្រើអំណាចទាំងនោះ។ ចំពោះសិទ្ធិមនុស្សនីមួយៗ រដ្ឋាភិបាលនៃ ប្រទេសជាសមាជិកមានកាតព្វកិច្ចដូចៗគ្នា។ កាតព្វកិច្ចទាំងនេះតម្រូវឲ្យរដ្ឋាភិបាល **អនុវត្ត គោរព** និង**ការពារ** សិទ្ធិមនុស្ស។

## ៧.១. រដ្ឋាភិបាលមានកាតព្វកិច្ចអនុវត្តសិទ្ធិមនុស្ស

ដោយសារតែរដ្ឋាភិបាលមានអំណាច ដូច្នេះរដ្ឋាភិបាលមានការទទួលខុសត្រូវក្នុងការធ្វើអ្វីៗដែលអាច ធ្វើបាន ដើម្បីឲ្យប្រាកដថា ប្រជាពលរដ្ឋអាចរស់នៅដោយសប្បាយរីករាយ មានសុខភាពល្អ និងមានសេរីភាព ក្នុងជីវភាពរស់នៅ។ នេះមានន័យថា រដ្ឋាភិបាលមានកាតព្វកិច្ចអនុវត្តសិទ្ធិមនុស្ស។ រដ្ឋាភិបាលត្រូវតែបង្កើត ច្បាប់ និងធ្វើសកម្មភាពដើម្បីឲ្យប្រាកដថា នៅទីបំផុតប្រជាពលរដ្ឋគ្រប់រូបអាចអាស្រ័យសិទ្ធិរបស់ពួកគាត់ យ៉ាងពេញលេញ។ រឿងនេះប្រហែលជាមិនអាចកើតឡើងភ្លាមៗនោះទេ ប៉ុន្តែយូរទៅ រដ្ឋាភិបាលត្រូវតែធ្វើការ ដើម្បីសម្រេចគោលដៅនេះ។ ឧទាហរណ៍ ដើម្បីអនុវត្តសិទ្ធិទទួលបានការអប់រំ រដ្ឋាភិបាលត្រូវតែបង្កើតច្បាប់ និងធ្វើសកម្មភាពដើម្បីឲ្យកុមារទាំងអស់អាចចូលរៀននៅសាលាបឋមសិក្សា។ ដើម្បីធ្វើដូច្នេះ រដ្ឋាភិបាលអាច នឹងបើកសាលារៀនថ្មីនៅតាមភូមិនៅជនបទ និងត្រូវបណ្ដុះបណ្ដាលគ្រូបន្ថែមទៀត។




*ដើម្បីអនុវត្តសិទ្ធិក្នុងការទទួលបានការអប់រំ រដ្ឋាភិបាលត្រូវបង្កើតសាលារៀនថ្មីនៅភូមិជនបទ*

## ៧.២. រដ្ឋាភិបាលមានកាតព្វកិច្ចត្រូវគោរពសិទ្ធិមនុស្ស

សិទ្ធិមនុស្សក៏បានដាក់កំណត់ទៅលើអំណាចរបស់រដ្ឋាភិបាលដែរ។ រដ្ឋាភិបាលមានកាតព្វកិច្ចចំពោះមុខក្នុងការគោរពសិទ្ធិមនុស្ស ដែលនេះមានន័យថា រដ្ឋាភិបាលមិនត្រូវបង្កើតច្បាប់ ឬធ្វើសកម្មភាពណាដែលបំពានសិទ្ធិមនុស្សទេ។ ឧទាហរណ៍ ប្រសិនបើរដ្ឋាភិបាលសង់ទំនប់ទឹកយ៉ាងធំមួយ ដែលនាំឲ្យសហគមន៍មួយមិនអាចប្រើប្រាស់ទឹកដើម្បីធ្វើស្រែចម្ការ និងនេសាទត្រីបាន នេះអាចជាការបំពានសិទ្ធិមានទឹកប្រើប្រាស់ និងចំណីអាហាររបស់ប្រជាពលរដ្ឋ។ ឧទាហរណ៍មួយទៀតគឺ រដ្ឋាភិបាលមិនគប្បីត្រូវបង្កើតច្បាប់ដែលហាមឃាត់ប្រជាពលរដ្ឋក្នុងការធ្វើបាតុកម្មដោយអហិង្សា ឬការគោរពប្រតិបត្តិជំនឿសាសនារបស់ពួកគាត់។




## ៧.៣. រដ្ឋាភិបាលមានកាតព្វកិច្ចត្រូវការពារសិទ្ធិមនុស្ស

រដ្ឋាភិបាលក៏មានកាតព្វកិច្ចត្រូវការពារសិទ្ធិប្រជាពលរដ្ឋមិនឲ្យមានការបំពានពី អ្នកដទៃ ក្រុមហ៊ុនឬស្ថាប័នផ្សេងៗដែរ។ ឧទាហរណ៍ រដ្ឋាភិបាលគប្បីត្រូវតែបង្កើតច្បាប់ដែលហាមក្រុមហ៊ុនមិនឲ្យបំផ្លាញលំនៅឋាន(ផ្ទះសម្បែង) និងការរំលោភយកដីរបស់ប្រជាពលរដ្ឋ។ ការធ្វើបែបនេះគឺ ការពារសិទ្ធិមានលំនៅឋានសមរម្យ និងសិទ្ធិមនុស្សផ្សេងៗទៀត។ រដ្ឋាភិបាលគប្បីត្រូវបណ្តុះបណ្តាលកងកម្លាំងនគរបាលឲ្យការពារសន្តិសុខ និងសុវត្ថិភាពរបស់ប្រជាពលរដ្ឋពីអំពើបង្កគ្រោះថ្នាក់របស់អ្នកដទៃ។ ការធ្វើបែបនេះគឺ ការពារសិទ្ធិរស់រានមានជីវិត និងសិទ្ធិមនុស្សផ្សេងៗទៀត។



*រដ្ឋាភិបាលមានកាតព្វកិច្ចមួយក្នុងការការពារសិទ្ធិប្រជាពលរដ្ឋពីការបំពានដោយក្រុមហ៊ុន ឬអ្នកដទៃ*

## ៨. សន្ធិសញ្ញាអន្តរជាតិស្តីពីសិទ្ធិមនុស្ស

នៅឆ្នាំ១៩៦០មានសន្ធិសញ្ញាអន្តរជាតិស្តីពីសិទ្ធិមនុស្ស២ត្រូវបានបង្កើតឡើង។ សន្ធិសញ្ញាទាំងពីរនេះ ដាក់កាតព្វកិច្ចឲ្យរដ្ឋាភិបាល។ សន្ធិសញ្ញាគឺជាកិច្ចព្រមព្រៀងតាមផ្លូវច្បាប់ ដែលធ្វើឡើងដោយរដ្ឋាភិបាលជាច្រើននៅលើពិភពលោក។ សន្ធិសញ្ញាអន្តរជាតិស្តីពីសិទ្ធិមនុស្សធំទាំង២នោះគឺៈ

- **កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ**
- **កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌**

សិទ្ធិភាគច្រើនដែលមានចែងនៅក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ត្រូវបានការពារដោយសន្ធិសញ្ញាទាំងពីរខាងលើនេះ។ *ដោយហេតុថា កតិកាសញ្ញាគឺជា កិច្ចព្រមព្រៀងអន្តរជាតិតាមផ្លូវច្បាប់ ដូច្នេះរដ្ឋាភិ បាលដែលយល់ព្រមចុះហត្ថលេខា ត្រូវមានតួនាទីតាមផ្លូវច្បាប់ក្នុងការគោរព និងអនុវត្តតាម។* នៅពេលដែលរដ្ឋាភិបាលយល់ព្រមធ្វើសច្ចាប័នលើសន្ធិសញ្ញាអន្តរជាតិទាំងនេះ ពេលនោះរដ្ឋាភិបាលត្រូវប្តេជ្ញាចិត្តចំពោះប្រជាពលរដ្ឋរបស់ខ្លួន និងរដ្ឋាភិបាលប្រទេសផ្សេងៗនៅជុំវិញពិភពលោកថា ខ្លួននឹង អនុវត្ត គោរព និងការពារសិទ្ធិមនុស្ស។ នេះមានន័យថា ស្ថានភាពសិទ្ធិមនុស្សនៅក្នុងប្រទេសមួយ គឺជាការបារម្ភរបស់សហគមន៍អន្តរជាតិទាំងអស់ មិនមែនត្រឹមតែរដ្ឋាភិបាលរបស់ប្រទេសនោះទេ។

## ការពង្រឹងសិទ្ធិមនុស្ស

នៅពេលដែលរដ្ឋាភិបាលបំពានសិទ្ធិមនុស្ស ពេលនោះគ្មានអ្នកណាអាចបញ្ជូនរដ្ឋាភិបាលទៅដាក់គុកទេ ផ្ទុយទៅវិញគឺប្រជាពលរដ្ឋទេដែលត្រូវរដ្ឋាភិបាលបញ្ជូនទៅដាក់គុក ដូច្នេះរដ្ឋាភិបាលនៃប្រទេសដទៃ និងអង្គការសហប្រជាជាតិអាចធ្វើសកម្មភាពអ្វីមួយពីរឿងនេះបាន។

- ប្រជាពលរដ្ឋអាចទាមទារឲ្យរដ្ឋាភិបាលផ្លាស់ប្តូរច្បាប់ នយោបាយ និងសកម្មភាពរបស់ខ្លួន។ នៅក្នុងលទ្ធិប្រជាធិបតេយ្យ ប្រជាពលរដ្ឋអាចបោះឆ្នោតទម្លាក់រដ្ឋាភិបាលចេញពីអំណាចនៅក្នុងពេលបោះឆ្នោតលើកក្រោយ ប្រសិនបើរដ្ឋាភិបាលមិនព្រមផ្លាស់ប្តូរតាមការទាមទារទេ។
- អង្គការមិនមែនរដ្ឋាភិបាល អង្គការសហប្រជាជាតិ និងប្រទេសដទៃទៀតអាចធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈដែលធ្វើឲ្យរដ្ឋាភិបាលមានភាពអាម៉ាស់ និងបាក់មុខ។
- រដ្ឋាភិបាលនៃប្រទេសដទៃទៀតអាចដាក់សម្ពាធផ្នែកនយោបាយ និងសេដ្ឋកិច្ចទៅលើរដ្ឋាភិបាលណាដែលបំពានសិទ្ធិមនុស្ស ព្រមទាំងបដិសេធមិនផ្តល់ជំនួយ ឬមិនធ្វើពាណិជ្ជកម្មជាមួយរដ្ឋាភិបាលដែលរំលោភសិទ្ធិមនុស្សនោះទេ។
- ប្រសិនបើមានការបំពានសិទ្ធិមនុស្សកម្រិតធ្ងន់ ដែលបានធ្វើទុក្ខទោសយ៉ាងខ្លាំងដល់ប្រជាពលរដ្ឋជាច្រើន ដូច្នេះអង្គការសហប្រជាជាតិអាចសម្រេចចិត្តបញ្ជូនកម្លាំងទាហានទៅក្នុងប្រទេសនោះ ដើម្បីបញ្ឈប់ការបំពានលើសិទ្ធិមនុស្ស។

## ៩. សិទ្ធិមនុស្ស និងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលនៃប្រទេសកម្ពុជាបានយល់ព្រមអនុវត្តកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌នៅឆ្នាំ១៩៩២។ **រដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជា**បានដាក់ច្បាប់អន្តរជាតិទាំងនេះជាផ្នែកមួយនៅក្នុងច្បាប់របស់ប្រទេសកម្ពុជា។ រដ្ឋធម្មនុញ្ញគឺជាច្បាប់កំពូលនៅក្នុងប្រទេសកម្ពុជា។ នេះមានន័យថា រដ្ឋាភិបាលមានកាតព្វកិច្ចតាមផ្លូវច្បាប់នៅក្រោមច្បាប់របស់ប្រទេសកម្ពុជាដើម្បីធ្វើឲ្យប្រាកដថា សិទ្ធិមនុស្សត្រូវបានគោរព។

**រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា**

មាត្រា៣១ : ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ។



## មេរៀនទី៣៖ សិទ្ធិមនុស្ស និងកាតព្វកិច្ចរបស់រដ្ឋាភិបាល

**គោលបំណង៖** អ្នកចូលរួមនឹងដឹងថា រដ្ឋាភិបាលមានកាតព្វកិច្ចក្នុងការអនុវត្ត គោរព និងការពារសិទ្ធិមនុស្ស។ ពួកគាត់នឹងដឹងថា សន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិដាក់កាតព្វកិច្ចឲ្យរដ្ឋាភិបាលដែលបានយល់ព្រមចុះហត្ថលេខាលើសន្ធិសញ្ញាទាំងនោះ។ ពួកគាត់ក៏នឹងដឹងដែរថា រដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជា ការពារសិទ្ធិមនុស្ស។

**សម្ភារៈ** ៖ ក្រដាសផ្ទាំងធំ ឬក្តារខៀន ហ្វឺត និងរូបភាពនៅក្នុងឯកសារសម្រាប់ចែកទី១។

**វិធីសាស្ត្រប្រើប្រាស់៖** ការបំផុសគំនិត ការពិភាក្សាជាក្រុម ការឡើងបង្ហាញ។

| ដំណើរការ | រយៈពេល (គិតជានាទី) |
|---|---|
| ១. ណែនាំព័ត៌មាននៅក្នុងផ្នែកទី៧ | ២០ |
| ២. ពន្យល់លំហាត់ | ៥ |
| ៣. កិច្ចការក្រុមតូច | ២០ |
| ៤. ការឡើងបង្ហាញតាមក្រុម | ១៥ |
| ៥. ណែនាំព័ត៌មាននៅក្នុងផ្នែកទី៨ និងទី៩ | ១៥ |
| ៦. សង្ខេប | ១៥ |
| **សរុប៖** | ៩០ |

## ការណែនាំចំពោះអ្នកសម្របសម្រួល

### ១. ណែនាំព័ត៌មាននៅក្នុងផ្នែកទី៧ (សូមមើលទំព័រទី៥២ ដល់ទី៥៣)

**ផ្នែកទី៧** : វាមានសារៈសំខាន់ណាស់ដែលអ្នកចូលរួមយល់ដឹងថា៖

- សិទ្ធិមនុស្សដាក់កម្រិតទៅលើរដ្ឋាភិបាល ព្រមទាំងបង្ហាញការណែនាំអំពីវិធីដែលរដ្ឋាភិបាលគប្បីត្រូវប្រើអំណាចរបស់ខ្លួន។
- ចំពោះសិទ្ធិមនុស្សនីមួយៗ រដ្ឋាភិបាលនៃប្រទេសដែលជាសមាជិកមានកាតព្វកិច្ចដូចៗគ្នា។
- រដ្ឋាភិបាលមានកាតព្វកិច្ចត្រូវ អនុវត្ត គោរព និងការពារសិទ្ធិមនុស្ស និងយល់ដឹងអំពីឧទាហរណ៍មួយចំនួនទាក់ទងនឹងប្រភេទនីមួយៗនៃកាតព្វកិច្ចទាំងនេះ។

### ២. ពន្យល់លំហាត់

- សូមពន្យល់អ្នកចូលរួមថា ពួកគាត់នឹងត្រូវបែងចែកជា៤ក្រុម ហើយក្រុមនីមួយៗនឹងទទួលបានរូបភាពអំពីសិទ្ធិមនុស្សមួយ។ ក្រុមនីមួយៗគប្បីត្រូវគិតអំពីឧទាហរណ៍ខាងក្រោម ចំពោះសិទ្ធិមនុស្សដែលពួកគាត់ទទួលបាន៖
  - អ្វីដែលរដ្ឋាភិបាលគប្បីត្រូវធ្វើក្នុងការអនុវត្តសិទ្ធិមនុស្ស ដែលទីបំផុតដើម្បីឲ្យគ្រប់គ្នាអាចអាស្រ័យ (ទទួលបាន) សិទ្ធិទាំងនោះយ៉ាងពេញ។
  - អ្វីដែលរដ្ឋាភិបាលមិនគប្បីត្រូវធ្វើ ដើម្បីឲ្យមានការគោរព និងមិនមានការបំពានលើសិទ្ធិមនុស្ស។
  - អ្វីដែលរដ្ឋាភិបាលគប្បីត្រូវធ្វើ ដើម្បីការពារសិទ្ធិមនុស្សកុំឲ្យមានការរំលោភបំពានពីអ្នកដទៃ។
- មុននឹងក្រុមទាំងអស់ចាប់ផ្តើម សូមពន្យល់អំពីកិច្ចការដែលគាត់ត្រូវធ្វើ ដោយប្រើឧទាហរណ៍អំពីសិទ្ធិទទួលបានការអប់រំ។
  - ដើម្បីអនុវត្តសិទ្ធិទទួលបានការអប់រំ រដ្ឋាភិបាលគប្បីត្រូវតែបើកសាលារៀនថ្មី នៅតាមភូមិនៅជនបទ និងបណ្តុះបណ្តាលគ្រូបន្ថែម ដែលទីបំផុត មនុស្សគ្រប់រូបអាចអាស្រ័យសិទ្ធិទទួលបានការអប់រំ។
  - ដើម្បីគោរព (មិនបំពាន) សិទ្ធិទទួលបានការអប់រំ រដ្ឋាភិបាលមិនគប្បីត្រូវតម្រូវឲ្យក្រុមគ្រួសារទាំងអស់បង់ប្រាក់ហួសពីលទ្ធភាព ដែលពួកគាត់អាចចុះឈ្មោះកូនឲ្យរៀននៅសាលាទេ។

  - ដើម្បីការពារកុំឲ្យមានការបំពានពីអ្នកដទៃលើសិទ្ធិទទួលបានការអប់រំ រដ្ឋាភិបាលគប្បីត្រូវបង្កើតច្បាប់ប្រឆាំងនឹងការប្រើពលកម្មកុមារ ដើម្បីឲ្យកុមារទាំងអស់ទៅសាលារៀន ជាជាងទៅធ្វើការ។

- ក្រុមទាំងអស់គប្បីត្រូវតែបិទរូបភាពអំពីសិទ្ធិមនុស្សនៅចំកណ្តាលក្រដាសផ្ទាំងធំ ហើយសរសេរ ឬគូររូបភាពដែលជាចម្លើយរបស់ពួកគាត់នៅជុំវិញរូបភាពនោះ ដើម្បីបង្កើតជារូបភាពផ្ទាំងធំមួយ។ ក្រុមទាំងអស់អាចបញ្ចូល ឧទាហរណ៍អំពីកាតព្វកិច្ចរបស់រដ្ឋាភិបាលឲ្យបានកាន់តែច្រើន តាមតែក្រុមចង់បញ្ចូល ប៉ុន្តែពួកគាត់គប្បីត្រូវគិតឲ្យបានយ៉ាងហោចណាស់ឧទាហរណ៍មួយ សម្រាប់ប្រភេទនីមួយៗដូចជា អនុវត្ត គោរព និងការពារ។

- ក្រុមនីមួយៗមានពេល២០នាទីដើម្បីធ្វើលំហាត់នេះ។ បន្ទាប់មកពួកគាត់ នឹងឡើងបង្ហាញចម្លើយរបស់ក្រុមក្រុមផ្សេងៗទៀត។

## ៣. កិច្ចការក្រុមតូច

- សូមចែកអ្នកចូលរួមជា៤ក្រុម រួចផ្តល់រូបភាពនៅក្នុងឯកសារសម្រាប់ចែកទី១ឲ្យក្រុមនីមួយៗ៖

  - សិទ្ធិទទួលបានការថែទាំសុខភាព

  - សិទ្ធិក្នុងការទទួលបានលំនៅឋានសមរម្យ

  - សិទ្ធិទទួលបានការកាត់ក្តីដោយយុត្តិធម៌

  - សិទ្ធិក្នុងការបញ្ចេញមតិដោយសេរី

- សូមប្រាកដថា ក្រុមនីមួយៗយល់អំពីសិទ្ធិដែលក្រុមទទួលបាន និងកិច្ចការដែលក្រុមត្រូវធ្វើ។

## ៤. ការឡើងបង្ហាញលទ្ធផលតាមក្រុម៖

- សូមអញ្ជើញក្រុមនីមួយៗឲ្យឡើងបង្ហាញលទ្ធផល ឬចម្លើយរបស់ក្រុម។

- បន្ទាប់ពីក្រុមនីមួយៗបានឡើងបង្ហាញហើយ សូមអញ្ជើញក្រុមដទៃទៀតឲ្យផ្តល់យោបល់ ឬសួរសំណួរប្រសិនបើមាន។

<u>ចម្លើយអាចទទួលយកបាន៖</u>

លំហាត់នេះ មានគោលបំណងជួយឲ្យអ្នកចូលរួមគិតអំពីកាតព្វកិច្ចទាំងឡាយ ដែលរដ្ឋាភិបាលត្រូវអនុវត្ត គោរព និងការពារសិទ្ធិមនុស្ស។ ខាងក្រោមនេះគ្រាន់តែជាឧទាហរណ៍ខ្លះៗនៃកាតព្វកិច្ចដែលរដ្ឋាភិបាលត្រូវមានចំពោះសិទ្ធិមនុស្ស។ វាអាចមានចម្លើយត្រឹមត្រូវច្រើនជាងចម្លើយខាងក្រោម៖

*សិទ្ធិទទួលបានការថែទាំសុខភាព*

- ដើម្បីអនុវត្តសិទ្ធិនេះ រដ្ឋាភិបាលគប្បីត្រូវប្រាកដថា ប្រជាពលរដ្ឋគ្រប់រូបអាចទៅមន្ទីរពេទ្យបាន ដោយរដ្ឋាភិបាលសង់មន្ទីរពេទ្យបន្ថែម និងបណ្តុះបណ្តាលវេជ្ជបណ្ឌិតថែម ប្រសិនបើចាំបាច់។

- ដើម្បីគោរពសិទ្ធិនេះ រដ្ឋាភិបាលមិនគប្បីត្រូវបណ្តេញប្រជាពលរដ្ឋដោយប្រើកម្លាំង ឲ្យចេញពីភូមិរបស់ពួកគាត់ និងមិនគប្បីត្រូវតាំងលំនៅឋានថ្មីឲ្យពួកគាត់នៅកន្លែងដែលឆ្ងាយពីមណ្ឌលសុខភាពឡើយ។

- ដើម្បីការពារសិទ្ធិនេះ រដ្ឋាភិបាលមិនត្រូវអនុញ្ញាតឲ្យក្រុមហ៊ុនសង់រោងចក្រ ដែលបំពុលទឹកនៅក្នុងសហគមន៍ និងធ្វើឲ្យប្រជាពលរដ្ឋឈឺទេ។

*សិទ្ធិមានលំនៅឋានសមរម្យ*

- ដើម្បីអនុវត្តសិទ្ធិនេះ រដ្ឋាភិបាលគប្បីត្រូវចាត់វិធានការក្នុងការធ្វើឲ្យលំនៅឋានរបស់ប្រជាពលរដ្ឋមានភាពប្រសើរឡើង។ ឧទាហរណ៍ លំនៅឋានទាំងអស់ត្រូវមានហេដ្ឋារចនាសម្ព័ន្ធដូចជា ទឹក និងអគ្គិសនី។

- ដើម្បីគោរពសិទ្ធិនេះ រដ្ឋាភិបាលមិនគប្បីត្រូវបំផ្លាញលំនៅឋានរបស់ប្រជាពលរដ្ឋក្រីក្រ ដោយសារតែលំនៅឋានទាំងនោះមានសភាពមិនល្អនោះទេ។

- ដើម្បីការពារសិទ្ធិនេះ រដ្ឋាភិបាលមិនត្រូវអនុញ្ញាតឲ្យក្រុមហ៊ុនរំលោភយកដីប្រជាពលរដ្ឋ ហើយបណ្តេញពួកគាត់ដោយប្រើកម្លាំងទេ។

*សិទ្ធិទទួលបានការកាត់ក្តីដោយយុត្តិធម៌*

- ដើម្បីអនុវត្តសិទ្ធិនេះ រដ្ឋាភិបាលគប្បីត្រូវបង្កើនចំណេះដឹង និងជំនាញដល់ចៅក្រម ហើយត្រូវប្រាកដថា ចៅក្រមទាំងនោះឯករាជ្យ និងមិនស្ថិតនៅក្រោមឥទ្ធិពលនយោបាយ។

- ដើម្បីគោរពសិទ្ធិនេះ រដ្ឋាភិបាលមិនគប្បីត្រូវព្យាយាមប្រើឥទ្ធិពលទៅលើការសម្រេចចិត្តរបស់តុលាការលើរឿងក្តីណាមួយទេ។

- ដើម្បីការពារសិទ្ធិនេះ រដ្ឋាភិបាលគប្បីត្រូវដាក់ទោសអ្នកណាដែលព្យាយាមសូកប៉ាន់ចៅក្រម និងដាក់ទោសចំពោះចៅក្រមណាដែលទទួលសំណូក។

*សិទ្ធិក្នុងការបញ្ចេញមតិដោយសេរី*

- ដើម្បីអនុវត្តសិទ្ធិនេះ រដ្ឋាភិបាលគប្បីត្រូវបង្កើតច្បាប់ដើម្បីការពារសិទ្ធិប្រជាពលរដ្ឋដើម្បីឲ្យគាត់អាចនិយាយអ្វីដែលពួកគាត់យល់ឃើញ និងជឿជាក់។

- ដើម្បីគោរពសិទ្ធិនេះ រដ្ឋាភិបាលមិនគប្បីត្រូវចាប់ខ្លួនប្រជាពលរដ្ឋ ឬបិទការចុះផ្សាយព័ត៌មានដែលរិះគន់រដ្ឋាភិបាលទេ។
- ដើម្បីការពារសិទ្ធិនេះ រដ្ឋាភិបាលមិនគប្បីត្រូវអនុញ្ញាតឲ្យគណបក្សនយោបាយណាមួយ បំភិតបំភ័យ ឬគំរាមប្រជាពលរដ្ឋពីការបញ្ចេញមតិខាងនយោបាយឡើយ។

## ៥. ណែនាំព័ត៌មាននៅក្នុងផ្នែកទី៨ និងទី៩ (សូមមើលទំព័រទី៥៤ ដល់ទី៥៦)

**ផ្នែកទី៨ និងទី៩៖** វាមានសារៈសំខាន់ណាស់ដែលអ្នកចូលរួមយល់ដឹងថា៖

- នៅពេលដែលរដ្ឋាភិបាលផ្តល់សច្ចាប័នលើសន្ធិសញ្ញាអន្តរជាតិស្តីពីសិទ្ធិមនុស្ស ដូចជា កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នោះរដ្ឋាភិបាលបានព្រមព្រៀងជាមួយប្រជាពលរដ្ឋរបស់ខ្លួន និងរដ្ឋាភិបាលដទៃទៀតថា រដ្ឋាភិបាលនឹងអនុវត្ត គោរព និងការពារសិទ្ធិមនុស្ស។
- តើសិទ្ធិមនុស្សអាចនឹងត្រូវពង្រឹងការអនុវត្តដោយវិធីណា។
- ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នលើកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ចំណែកឯរដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជាក៏បានដាក់សិទ្ធិទាំងនេះជាផ្នែកមួយនៃច្បាប់របស់ប្រទេសកម្ពុជាដែរ។
- នេះមានន័យថា រដ្ឋាភិបាលមានកាតព្វកិច្ច ដែលទទួលស្គាល់ដោយច្បាប់នៃប្រទេសកម្ពុជា និងច្បាប់អន្តរជាតិក្នុងការគោរព និងការពារសិទ្ធិមនុស្ស។

## ៦. សង្ខេប

- សូមបិទក្រដាសផ្ទាំងធំដែលជាចម្លើយរបស់ក្រុមនីមួយៗនៅលើជញ្ជាំងជុំវិញបន្ទប់ ដើម្បីឲ្យពួកគាត់មើលឃើញដោយងាយស្រួល។ សម្រាប់សិទ្ធិខ្លះ ឬសិទ្ធិទាំង៤នោះ សូមធ្វើដូចខាងក្រោម៖
    - សូមជ្រើសរើសឧទាហរណ៍ខ្លះអំពីកាតព្វកិច្ចរបស់រដ្ឋាភិបាល និងសួរអ្នកចូលរួមថា តើពួកគាត់គិតថា ទាំងអស់នេះជាអ្វីដែលរដ្ឋាភិបាលកម្ពុជាកំពុងតែធ្វើ ឬមិនធ្វើ។
    - សូមឲ្យអ្នកចូលរួមចែករំលែកសាច់រឿងក្នុងជីវិតរបស់គាត់ ឬព័ត៌មានដែលបង្ហាញថា តើរដ្ឋាភិបាលបាន ឬមិនបានបំពេញកាតព្វកិច្ចរបស់ខ្លួនទាំងនោះ និងតើរដ្ឋាភិបាលបាន ឬមិនបានគោរពសិទ្ធិទាំងនោះ។

- សូមបញ្ចប់ដោយសួរអ្នកចូលរួមថា តើពួកគាត់គិតថា ពួកគាត់អាចធ្វើអ្វីខ្លះក្នុងនាមជាពលរដ្ឋមួយរូប ប្រសិនបើរដ្ឋាភិបាលមិនបានអនុវត្តកាតព្វកិច្ចរបស់ខ្លួន និងមិនបានគោរពសិទ្ធិមនុស្សទាំងនោះទេ។

- ដើម្បីបញ្ចប់ការពិភាក្សា អ្នកសម្របសម្រួលអាចរំលឹកអ្នកចូលរួមថា ការដឹងអំពីសិទ្ធិរបស់ខ្លួន គឺជាជំហានទីមួយ ក្នុងការការពារខ្លួនពួកគាត់។ សូមរំលឹកអ្នកចូលរួមអំពីរឿងរបស់មហាត្មគន្ធីនៅឥណ្ឌា និងចលនាទាមទារសិទ្ធិពលរដ្ឋនៅសហរដ្ឋអាមេរិក ព្រមទាំងរំលឹកថា ទីបំផុត វាស្រេចទៅលើប្រជាពលរដ្ឋនៃប្រទេសមួយក្នុងការទាមទារឲ្យរដ្ឋាភិបាលគោរពសិទ្ធិមនុស្សទាំងនោះ។

## សិទ្ធិទទួលបានការថែទាំសុខភាព



សិទ្ធិមានលំនៅឋានសមរម្យ



## សិទ្ធិទទួលបានការកាត់ក្តីដោយយុត្តិធម៌



សិទ្ធិក្នុងការបញ្ចេញមតិដោយសេរី



# សេចក្តីផ្តើមនៃលទ្ធិប្រជាធិបតេយ្យ

**លទ្ធផលទទួលបាន៖**

ក្រោយពីបញ្ចប់ជំពូកនេះ អ្នកចូលរួមនឹងបាន៖

១. យល់ដឹងថា ហេតុអ្វីយើងមានរដ្ឋាភិបាល

២. យល់ដឹងថា លទ្ធិប្រជាធិបតេយ្យបែបតំណាងជាអ្វី

៣. ដឹងអំពីលក្ខណៈគន្លឹះនៃលទ្ធិប្រជាធិបតេយ្យ

៤. យល់ដឹងថា តើការបោះឆ្នោតដោយសេរី និងយុត្តិធម៌ជាអ្វី

៥. ដឹងថា តើគណបក្សនយោបាយជាអ្វី និងដឹងថាហេតុអ្វីបានជាគណបក្សទាំងនោះមានសារៈសំខាន់

៦. យល់ដឹងថា សិទ្ធិទទួលបានព័ត៌មាន និងសិទ្ធិចូលរួម ជាផ្នែកមួយយ៉ាងសំខាន់ក្នុងលទ្ធិប្រជាធិបតេយ្យ

៧. យល់ដឹងអំពីគោលការណ៍គ្រប់គ្រងភាគច្រើន និងសិទ្ធិភាគតិច

៨. ដឹងថា ហេតុអ្វីបាននីតិរដ្ឋសំខាន់នៅក្នុងលទ្ធិប្រជាធិបតេយ្យ

៩. ដឹងអំពីស្ថាប័នទាំងបីរបស់រដ្ឋាភិបាល និងយល់អំពីគោលការណ៍នៃការបែងចែកអំណាច

១០. យល់អំពីសារៈសំខាន់នៃប្រព័ន្ធតុលាការឯករាជ្យ

១១. យល់ដឹងអំពីតួនាទីរបស់ប្រជាពលរដ្ឋនៅក្នុងសង្គមប្រជាធិបតេយ្យ

## ១. ការធ្វើសេចក្តីសម្រេចចិត្តអំពីសង្គម

នៅពេលដែលមនុស្សក្រុមតូចៗមានការប្រាស្រ័យទាក់ទងគ្នា សមាជិកម្នាក់ៗនៅក្នុងក្រុមអាចចូលរួមយ៉ាងសកម្មក្នុងការធ្វើសេចក្តីសម្រេចចិត្តអំពីអ្វីដែលពួកគាត់ធ្វើ និងរបៀបដែលពួកគាត់ធ្វើវា។ នៅពេលដែលមិត្តភ័ក្តិមួយក្រុមសម្រេចចិត្តលេងល្បែងមួយ ពេលនោះពួកគាត់ទាំងអស់គ្នាអាចចូលរួមយ៉ាងសកម្មក្នុងការសម្រេចចិត្តថា តើត្រូវលេងល្បែងអ្វី និងមានបទបញ្ញាអ្វីខ្លះសម្រាប់លេងល្បែងនោះ។

នៅក្នុងសង្គមមួយ ដូចជា ស្រុក-ខណ្ឌ ខេត្ត-ក្រុង ឬប្រទេសជាដើម មានការសម្រេចចិត្តជាច្រើនដែលត្រូវធ្វើ និងមានមនុស្សជាច្រើនប្រាស្រ័យទាក់ទងគ្នាតាមវិធីផ្សេងៗគ្នារៀងរាល់ថ្ងៃ។ វាកាន់តែលំបាកទៅៗសម្រាប់ប្រជាពលរដ្ឋគ្រប់ៗគ្នាក្នុងការចូលរួមយ៉ាងសកម្មគ្រប់ការសម្រេចចិត្តទាំងអស់អំពី របៀបដែលត្រូវរៀបចំសង្គមបែបណានោះ។ សូមនឹកគិតមើលថា ប្រសិនបើច្បាប់ថ្មីនីមួយៗនៅក្នុងប្រទេសកម្ពុជា ឬការធ្វើសេចក្តីសម្រេចចិត្តទាំងអស់អំពីទីក្រុងភ្នំពេញ ដែលប្រជាពលរដ្ឋត្រូវតែចូលរួមគ្រប់គ្នានោះ តើវាមាលំបាកយ៉ាងណា។



នៅក្នុងសង្គមភាគច្រើន មានមនុស្សមួយក្រុមដែលមានសិទ្ធិអំណាចក្នុងការសម្រេចចិត្តអំពីច្បាប់ គោលនយោបាយ និងរបៀបរបបដែលសង្គមដំណើរការ។ ក្រុមមនុស្សដែលមានសិទ្ធិក្នុងការធ្វើសេចក្ដីសម្រេចចិត្តទាំងនេះហៅថា **រដ្ឋាភិបាល។**

## ២. តើលទ្ធិប្រជាធិបតេយ្យជាអ្វី?

រដ្ឋាភិបាលនៅក្នុងសង្គមផ្សេងៗគ្នានៅទូទាំងពិភពលោកទទួលបានសិទ្ធិអំណាចតាមវិធីខុសៗគ្នា និងតាមរយៈប្រព័ន្ធផ្សេងៗគ្នា។ ឆ្លងតាមប្រវត្តិសាស្ត្រ រដ្ឋាភិបាលខ្លះទទួលបានអំណាច និងក្ដោមក្ដាប់អំណាចនោះ ដោយប្រើកម្លាំង ឬដោយវិធីអយុត្តិធម៌ផ្សេងៗទៀត។ នៅក្នុង**លទ្ធិប្រជាធិបតេយ្យ** អំណាចនយោបាយបានមកពីឆន្ទៈរបស់ប្រជាពលរដ្ឋ។ សព្វថ្ងៃនេះ វិធីសាស្ត្រដែលមានប្រជាប្រិយបំផុតក្នុងការផ្ដល់សិទ្ធិអំណាចដល់រដ្ឋាភិបាលក្នុងការធ្វើសេចក្ដីសម្រេចចិត្តអំពីសង្គមគឺ តាមរយៈ**លទ្ធិប្រជាធិបតេយ្យបែបតំណាង។** នៅក្នុងលទ្ធិប្រជាធិបតេយ្យបែបតំណាង ប្រជាពលរដ្ឋអាចជ្រើសរើសតំណាងរាស្ត្រដោយសេរី ដើម្បីឲ្យធ្វើសេចក្ដីសម្រេចចិត្តលើសង្គម ជំនួសពួកគាត់។ ប្រជាពលរដ្ឋមានសិទ្ធិអាចទទួលបានព័ត៌មាន និងមានឱកាសក្នុងការចូលរួមក្នុងការពិភាក្សាជជែកវែកញែកជាសាធារណៈអំពីបញ្ហាសំខាន់ៗ ។ ទោះបីជាប្រជាពលរដ្ឋត្រូវបានតំណាងដោយរដ្ឋាភិបាលក៏ដោយ ក៏សមាជិកនៅក្នុងសង្គមទាំងអស់មានសិទ្ធិក្នុងការចូលរួម និងមានសិទ្ធិក្នុងការនិយាយអំពីបញ្ហា និងការសម្រេចចិត្ត ដែលមានឥទ្ធិពលលើពួកគេ ។

នៅក្នុងលទ្ធិប្រជាធិបតេយ្យ រដ្ឋាភិបាលមាន**ការទទួលខុស**ទាំងស្រុងក្នុងការសម្រេចចិត្ត និងសកម្មភាពរបស់ខ្លួនចំពោះមុខប្រជាពលរដ្ឋ។ នេះមានន័យថា អ្នកធ្វើសេចក្តីសម្រេចចិត្តត្រូវទទួលខុសត្រូវចំពោះផលប៉ះពាល់ដែលបណ្តាលមកពីការសម្រេចចិត្ត និងសកម្មភាពរបស់ខ្លួន។ ទម្រង់នៃការទទួលខុសត្រូវដែលសំខាន់ជាងគេនៅក្នុងលទ្ធិប្រជាធិបតេយ្យគឺថា ប្រសិនបើ ប្រជាពលរដ្ឋភាគច្រើនមិនសប្បាយចិត្តនឹងការសម្រេចចិត្តរបស់តំណាងរបស់ពួកគាត់ទេ នោះប្រជាពលរដ្ឋអាចបោះឆ្នោតទម្លាក់ពួកគេពីអំណាចនៅពេលបោះឆ្នោតលើកក្រោយ ។

### លក្ខណៈនៃលទ្ធិប្រជាធិបតេយ្យ

លទ្ធិប្រជាធិបតេយ្យពិត គឺមានលក្ខណៈគន្លឹះមួយចំនួន រួមមានដូចជា៖

- សិទ្ធិចូលរួមក្នុងការបោះឆ្នោត និងឈរឈ្មោះជាបេក្ខជននៅក្នុងការបោះឆ្នោតដោយសេរី និងយុត្តិធម៌
- មានគណបក្សនយោបាយលើសពីមួយ និងមានសិទ្ធិសេរីភាពក្នុងការបង្កើត និងចូលរួមក្នុងគណបក្សនយោបាយទាំងនោះ។
- មានសិទ្ធិទទួលបានព័ត៌មាន និងបើកវេទិកាសម្រាប់ការចូលរួមក្នុងការពិភាក្សាជជែកវែកញែកជាសាធារណៈ
- សេរីភាពក្នុងការបញ្ចេញមតិ
- សិទ្ធិមតិភាគតិច
- នីតិរដ្ឋ និងសិទ្ធិស្មើគ្នាចំពោះមុខច្បាប់
- ការបែងចែកអំណាច និងប្រព័ន្ធតុលាការឯករាជ្យ និង
- ប្រជាពលរដ្ឋ ដែលមានការអប់រំល្អ សកម្ម និងមានការទទួលខុសត្រូវ

ទាំងនេះជាលក្ខណៈដែលត្រូវតែមាននៅក្នុងសង្គម ដើម្បីឲ្យសង្គមនោះជាសង្គមដែលអនុវត្តលទ្ធិប្រជាធិបតេយ្យពិតប្រាកដ។

## ៣. លទ្ធិប្រជាធិបតេយ្យនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

ក្រោយពីសង្គ្រាមស៊ីវិលជាច្រើនឆ្នាំ និងក្រោយពីមានប្រព័ន្ធនៃការគ្រប់គ្រងប្រទេសជាច្រើន ដែលមិនមែនជាលទ្ធិប្រជាធិបតេយ្យនោះមក រដ្ឋធម្មនុញ្ញថ្មីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានអនុម័ត និងប្រកាសឲ្យប្រើប្រាស់នៅឆ្នាំ១៩៩៣។ រដ្ឋធម្មនុញ្ញនេះបានបង្កើតប្រព័ន្ធរដ្ឋាភិបាលថ្មីមួយដោយយោងទៅតាមលទ្ធិប្រជាធិបតេយ្យបែបតំណាង ការការពារសិទ្ធិបុគ្គល និងការគោរពចំពោះមតិ និងជំនឿផ្សេងៗគ្នា។ ប្រព័ន្ធរដ្ឋាភិបាលនេះ ក៏ត្រូវបានគេស្គាល់ថាជា **លទ្ធិប្រជាធិបតេយ្យសេរី** ដែរ។

**រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា**

មាត្រា៥១៖ ព្រះរាជាណាចក្រកម្ពុជាអនុវត្តនយោបាយប្រជាធិបតេយ្យសេរីពហុបក្ស។

ប្រជាពលរដ្ឋខ្មែរជាម្ចាស់វាសនានៃប្រទេសជាតិរបស់ខ្លួន។ អំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋ។ ប្រជាពលរដ្ឋប្រើអំណាចរបស់ខ្លួនតាមរយៈ រដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល និងសាលាជម្រះក្តី។



# មេរៀនទី១ ៖ តើលទ្ធិប្រជាធិបតេយ្យជាអ្វី?

**គោលបំណង៖** អ្នកចូលរួមនឹងគិតថា តើមូលហេតុអ្វីបានជាយើងត្រូវការរដ្ឋាភិបាល និងគិតអំពីវិធីល្អបំផុតក្នុងការផ្ដល់សិទ្ធិអំណាចទៅរដ្ឋាភិបាល។ ពួកគាត់ក៏គិតដែរថា តើ "លទ្ធិប្រជាធិបតេយ្យ" មានន័យយ៉ាងដូចម្ដេចចំពោះពួកគាត់។

**សម្ភារៈ៖** ក្រដាសផ្ទាំងធំ និងហ្វឺតពណ៌។

**វិធីសាស្ត្រ៖** ការគូររូប ការងារជាក្រុម ការបំផុសគំនិត ការពិភាក្សាក្រុមធំ។

| ដំណើរការ | រយៈពេល (គិតជានាទី) |
|---|---|
| ១. ណែនាំព័ត៌មានក្នុងផ្នែកទី១ | ១០ |
| ២. ការធ្វើត្រាប់តាម និងការពិភាក្សាក្រុមធំ | ១៥ |
| ៣. ការងារក្រុម និងការគូររូប | ១៥ |
| ៤. ការឡើងបង្ហាញអំពីផ្ទាំងរូបភាពអំពីលទ្ធិប្រជាធិបតេយ្យ | ១៥ |
| ៥. ណែនាំព័ត៌មាននៅក្នុងផ្នែកទី២ និងទី៣ | ២០ |
| ៦. សង្ខេប | ១៥ |
| **សរុប៖** | **៩០** |

## ការណែនាំសម្រាប់អ្នកសម្របសម្រួល

### ១. ណែនាំព័ត៌មាននៅក្នុងផ្នែកទី១ (សូមមើលទំព័រទី៦៧ ដល់ទី៦៨)

**ផ្នែកទី១៖** វាមានសារៈសំខាន់ណាស់ដែលអ្នកចូលរួមយល់ដឹងថា៖

- ហេតុអ្វីបានជាយើងត្រូវការរដ្ឋាភិបាល
- រដ្ឋាភិបាលមានសិទ្ធិអំណាចក្នុងការធ្វើសេចក្ដីសម្រេចចិត្តអំពីច្បាប់ នយោបាយ និងរបៀបដំណើរការសង្គម។

### ២. ការធ្វើត្រាប់តាម និងការពិភាក្សាក្រុមធំ

- សូមពន្យល់ថា អ្នកចូលរួមនឹងចាំបាច់ត្រូវការធ្វើសេចក្ដីសម្រេចចិត្តមួយចំនួនអំពីវគ្គបណ្ដុះបណ្ដាល ដែលមានឥទ្ធិពលដល់អ្នកចូលរួម។ ឧទាហរណ៍ អ្នកចូលរួមត្រូវធ្វើសេចក្ដីសម្រេចចិត្តថា តើអ្នកណានឹងដឹកនាំការងារជាក្រុមនៅក្នុងសកម្មភាពបន្ទាប់ និងតើត្រូវប្រើរយៈពេលសម្រាកប៉ុន្មាន។ អ្នកចូលរួមត្រូវធ្វើសេចក្ដីសម្រេចចិត្តអំពីបទបញ្ញានានាថា ប្រសិនបើមានអ្នកណាម្នាក់មកយឺត ឬប្រសិនបើមានអ្នកណាម្នាក់មានទូរស័ព្ទរោទិ៍នៅពេលកំពុងរៀន តើគាត់ត្រូវទទួលទោសបែបណា។
- សូមពន្យល់ថា អ្នកសម្របសម្រួលបានសម្រេចចិត្តថា អ្នកសម្របសម្រួលនឹងធ្វើសេចក្ដីសម្រេចចិត្ត និងធ្វើបទបញ្ញាទាំងនេះដោយខ្លួនឯងផ្ទាល់។ សូមចង្អុលអ្នកចូលរួម៤នាក់ ហើយនិយាយថា ពួកគាត់នឹងដឹកនាំការងារក្រុមនៅក្នុងសកម្មភាពបន្ទាប់។ សូមនិយាយថា រយៈពេលសម្រាកគឺ៥នាទី។ សូមពន្យល់ថា អ្នកសម្របសម្រួលក៏បានសម្រេចចិត្តដែរថា ប្រសិនបើអ្នកណាមកយឺត ឬប្រសិនបើទូរស័ព្ទរោទ៍ និងរំខានដល់វគ្គបណ្ដុះបណ្ដាល នោះពួកគាត់ត្រូវបង់ប្រាក់ពិន័យចំនួន១០ដុល្លារ។
- សូមសួរអ្នកចូលរួមថា តើពួកគាត់គិតយ៉ាងណាចំពោះរឿងទាំងនេះ។ សូមសួរអ្នកចូលរួមថា តើពួកគាត់គិតយ៉ាងណាចំពោះការសម្រេចចិត្ត និងរបៀបនៃការសម្រេចចិត្តទាំងនេះ។ តើដំណើរការនេះយុត្តិធម៌ទេ?
- តើអ្នកចូលរួមមានគំនិតអ្វីផ្សេង ដែលទាក់ទងនឹងរបៀបក្នុងការធ្វើសេចក្ដីសម្រេចចិត្តទាំងនេះទេ? តើរបៀបណា ដែលយុត្តិធម៌ជាងនេះ?
- បន្ទាប់ពីអ្នកចូលរួមមានឱកាសក្នុងការបញ្ចេញគំនិតរបស់ពួកគាត់ហើយ សូមពន្យល់ថា របៀបដែលយុត្តិធម៌ជាងនេះគឺ ឲ្យអ្នកគ្រប់គ្នាបោះឆ្នោតទៅលើចំណុចនីមួយៗ។ វិធីសាស្ត្រមួយទៀតគឺឲ្យអ្នកគ្រប់គ្នាជ្រើសរើសយកតំណាងម្នាក់ ឬមួយចំនួន ដែលពួកគេអាចធ្វើសេចក្ដីសម្រេចចិត្តទាំងនេះជំនួសពួកគាត់បាន ដូចជាក្រុមគណៈកម្មាធិការ ជាដើម។

- សូមសួរអ្នកចូលរួមថា តើពួកគាត់បានដឹងថា ប្រភេទនៃវិធីសាស្ត្រក្នុងការសម្រេចចិត្តទាំងនេះហៅថាអ្វី។ ប្រសិនបើគ្មាននរណាដឹងទេ សូមពន្យល់ថា ទាំងនេះគឺជាប្រភេទនៃការសម្រេចចិត្តតាមបែបលទ្ធិប្រជាធិបតេយ្យ។

## ៣. ការងារក្រុម និងការគូររូប

- សូមពន្យល់ថា អ្នកចូលរួមនឹងត្រូវចែកជាក្រុមតូចៗ។ ក្រុមនីមួយៗនឹងពិភាក្សាថា តើលទ្ធិប្រជាធិបតេយ្យមានន័យដូចម្តេចចំពោះពួកគាត់។ ក្រុមទាំងអស់នឹងទទួលបានក្រដាសផ្ទាំងធំ ហើយពួកគាត់គួរតែសរសេរពាក្យដែលពួកគាត់នឹកឃើញភ្លាមៗ នៅពេលដែលពួកគាត់គិតដល់លទ្ធិប្រជាធិបតេយ្យ ឬគូររូបដែលជាតំណាងលទ្ធិប្រជាធិបតេយ្យ។ បន្ទាប់មកពួកគាត់នឹងត្រូវបានអញ្ជើញឲ្យឡើងបង្ហាញអ្នកចូលរួមអំពីលទ្ធផលអំពីលទ្ធិប្រជាធិបតេយ្យដែលបានពិភាក្សា។
- សូមចែកអ្នកចូលរួមជា៣ ឬ៤ក្រុម រួចឲ្យក្រដាសផ្ទាំងធំនិងហ្វឺតពណ៌ទៅក្រុមនីមួយៗ។

## ៤. ការឡើងបង្ហាញលទ្ធផលអំពីលទ្ធិប្រជាធិបតេយ្យរបស់ក្រុម

- សូមអញ្ជើញក្រុមនីមួយៗឲ្យឡើងបង្ហាញលទ្ធផលរបស់ពួកគាត់ ហើយពន្យល់ថា តើពាក្យពេចន៍និងរូបភាពរបស់ពួកគាត់តំណាងអ្វី។ បន្ទាប់ពីក្រុមនីមួយៗឡើងបង្ហាញហើយ សូមបិទផ្ទាំងផ្សព្វផ្សាយទាំងនោះនៅជុំវិញបន្ទប់។

## ៥. ណែនាំព័ត៌មាននៅក្នុងផ្នែកទី២ និងទី៣ (សូមមើលទំព័រទី៦៨ ដល់ទី៧០)

**ផ្នែកទី២ និងទី៣៖** វាមានសារៈសំខាន់ណាស់ដែលអ្នកចូលរួមយល់ដឹងថា៖

- រដ្ឋាភិបាលទទួលបានសិទ្ធិអំណាចក្នុងការធ្វើសេចក្តីសម្រេចចិត្តចំពោះសង្គមទៅតាមវិធីផ្សេងៗគ្នា។
- នៅក្នុងលទ្ធិប្រជាធិបតេយ្យបែបតំណាង ប្រជាពលរដ្ឋជ្រើសរើសតំណាងដោយសេរីដើម្បីធ្វើសេចក្តីសម្រេចចិត្តចំពោះសង្គមជំនួសពួកគេ។
- នៅក្នុងលទ្ធិប្រជាធិបតេយ្យ ប្រជាពលរដ្ឋក៏អាចមានសិទ្ធិទទួលបានព័ត៌មាន និងមានឱកាសក្នុងការចូលរួមក្នុងការពិភាក្សា ជជែកវែកញែកអំពីបញ្ហាសំខាន់ៗជាសាធារណៈដែរ។
- នៅក្នុងលទ្ធិប្រជាធិបតេយ្យ រដ្ឋាភិបាលមានការទទួលខុសត្រូវចំពោះប្រជាពលរដ្ឋ និងអាចត្រូវបានបោះឆ្នោតដកចេញពីអំណាច ប្រសិនបើប្រជាពលរដ្ឋមិនសប្បាយចិត្តជាមួយការធ្វើសេចក្តីសម្រេចចិត្ត និងសកម្មភាពរបស់ខ្លួន។
- លក្ខណៈគន្លឹះនៃលទ្ធិប្រជាធិបតេយ្យ (នឹងត្រូវបានពិភាក្សាលម្អិតរហូតដល់ចប់វគ្គបណ្តុះបណ្តាល)
- នៅឆ្នាំ១៩៩៣ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានបង្កើតប្រព័ន្ធរដ្ឋាភិបាលថ្មី ដោយយោងទៅតាមលទ្ធិប្រជាធិបតេយ្យសេរីនិយម។

## ៦. សង្ខេប

- សូមឲ្យអ្នកចូលរួមម្នាក់ ឬពីរនាក់រៀបរាប់ថា តើលទ្ធិប្រជាធិបតេយ្យបែបតំណាងជាអ្វី។
- សូមសួរថា តើអ្នកចូលរួមទាំងអស់គិតយ៉ាងណាអំពីស្ថានភាពនៅក្នុងប្រទេសកម្ពុជា។ តើប្រជាពលរដ្ឋកម្ពុជាអាចជ្រើសរើសតំណាងរបស់ខ្លួន អាចមានសិទ្ធិទទួលបានព័ត៌មាន និងមានឱកាសចូលរួមក្នុងការពិភាក្សា ជជែកវែកញែកអំពីបញ្ហាសំខាន់ៗជាសាធារណៈ ដល់កម្រិតណា? សូមសម្របសម្រួលការពិភាក្សាថា តើប្រទេសកម្ពុជាមានលទ្ធិប្រជាធិបតេយ្យដល់កម្រិតណា។

## ៤. សិទ្ធិក្នុងការចូលរួមបោះឆ្នោតដោយសេរី និងយុត្តិធម៌

នៅក្នុងលទ្ធិប្រជាធិបតេយ្យ ប្រជាពលរដ្ឋនៅក្នុងសង្គមជ្រើសរើសតំណាងរបស់ខ្លួនដោយ**ការបោះឆ្នោតដោយសេរី** និងយុត្តិធម៌។ នៅក្នុងកំឡុងពេលបោះឆ្នោត ប្រជាពលរដ្ឋមានឱកាសសិក្សាស្វែងយល់អំពីទស្សនៈនិងតម្លៃរបស់**បេក្ខជន**ផ្សេងៗ គឺអ្នកដែលចង់ធ្វើជាតំណាងពួកគាត់នៅក្នុងរដ្ឋាភិបាល រួចសម្រេចចិត្តជ្រើសរើសបេក្ខជនដែលល្អជាងគេដើម្បីធ្វើជាតំណាង និងការពារគំនិត ដែលទាក់ទងនឹងអ្វីដែលពួកគាត់គិតថានឹងធ្វើដើម្បីផលប្រយោជន៍សង្គម។

ប្រជាពលរដ្ឋគ្រប់រូបដែលមានសិទ្ធិបោះឆ្នោតអាចទៅបោះឆ្នោតមួយសន្លឹកដែលជាសម្លេងមួយ ក្នុងការបោះឆ្នោតនោះ។ គ្មានសន្លឹកឆ្នោតរបស់អ្នកណាសំខាន់ជាងរបស់អ្នកណាទេ មានន័យថាសន្លឹកឆ្នោតទាំងអស់មានតម្លៃ ឬសំខាន់ដូចគ្នា។ ប្រជាពលរដ្ឋពេញវ័យទាំងអស់ត្រូវតែមានសិទ្ធិចូលរួមក្នុងការបោះឆ្នោត។ សិទ្ធិបោះឆ្នោតនេះអាចត្រូវហាមប្រាមបាន តែក្នុងករណីមានមូលហេតុត្រឹមត្រូវតែប៉ុណ្ណោះ ដូចជា នៅពេលដែលអ្នកណាម្នាក់មានបញ្ហាសតិបញ្ញា ឬមានជំងឺផ្លូវចិត្តដែលមិនអាចឲ្យគាត់សម្រេចចិត្តដោយសមហេតុផល និងឯករាជ្យនោះបាន។



## សិទ្ធិក្នុងការចូលរួមបោះឆ្នោត

សិទ្ធិក្នុងការចូលរួមបោះឆ្នោតគឺជាសិទ្ធិយ៉ាងសំខាន់របស់ប្រជាពលរដ្ឋម្នាក់ៗ ដែលត្រូវបានទទួលស្គាល់នៅក្នុងសេចក្តីប្រកាសជាសកល ស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ។

សិទ្ធិក្នុងការចូលរួមបោះឆ្នោតរបស់បុរស និងស្ត្រីដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ ក៏ត្រូវបានធានានៅក្នុងមាត្រា៣៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាដែរ។

សិទ្ធិរបស់មនុស្សពេញវ័យក្នុងការឈរឈ្មោះជាបេក្ខជនឲ្យប្រជាពលរដ្ឋការបោះឆ្នោតជ្រើសរើសធ្វើជាតំណាងឲ្យប្រជាពលរដ្ឋ ក៏ជាសិទ្ធិមនុស្សចាំបាច់មួយ ដែលត្រូវបានធានាដោយរដ្ឋធម្មនុញ្ញ និងច្បាប់អន្តរជាតិ

នៅពេលដែលប្រជាពលរដ្ឋគ្រប់រូបមានឱកាសបានបោះឆ្នោតរួចហើយ បេក្ខជនដែលជាប់ឆ្នោតជាតំណាងនឹងក្លាយទៅជាផ្នែកមួយនៃរដ្ឋាភិបាល។ ប្រជាពលរដ្ឋបោះឆ្នោតជ្រើសរើសរដ្ឋាភិបាលដើម្បីធ្វើអ្វីៗជំនួសពួកគាត់។ នៅក្នុងកំឡុងពេលដែលរដ្ឋាភិបាលនោះកាន់អំណាច រដ្ឋាភិបាលត្រូវបម្រើ ឬការពារផលប្រយោជន៍របស់ប្រជាពលរដ្ឋ។

ប្រសិនបើប្រជាពលរដ្ឋណាម្នាក់មិនពេញចិត្តនឹងការសម្រេចចិត្ត ឬសកម្មភាពរបស់រដ្ឋាភិបាលទេពេលនោះ ពួកគាត់មានសិទ្ធិនិងសេរីភាពក្នុងការបោះឆ្នោតជ្រើសរើសតំណាងផ្សេងៗទៀត នៅពេលការបោះឆ្នោតអាណត្តិក្រោយ។ នេះគឺជាវិធីសំខាន់បំផុតដើម្បីឲ្យរដ្ឋាភិបាលមានគណនេយ្យភាព ឬមានការទទួលខុសត្រូវចំពោះប្រជាពលរដ្ឋដែលបានបោះឆ្នោតឲ្យខ្លួនតំណាងពួកគាត់នៅក្នុងជួររដ្ឋាភិបាល។ ប្រសិនបើរដ្ឋាភិបាលធ្វើការមិនបានល្អ មិនគោរពពាក្យសន្យា ឬបង្កើតគោលនយោបាយដែលមិនល្អដល់ប្រជាពលរដ្ឋទេដូច្នេះរដ្ឋាភិបាលនោះអាចនឹងលែងមានការគាំទ្រពីសំណាក់ប្រជាពលរដ្ឋភាគច្រើនតទៅទៀតឡើយ។ ការបោះឆ្នោតអាចនាំទៅរកការផ្លាស់ប្តូររដ្ឋាភិបាល។ នេះមានន័យថា គណបក្សនយោបាយផ្សេងនឹងឈ្នះឆ្នោត ហើយនឹងបង្កើតរដ្ឋាភិបាលមួយថ្មី។

## ដូចម្តេចដែលហៅថាការបោះឆ្នោតដោយសេរី និងយុត្តិធម៌?

ការបោះឆ្នោតត្រូវតែបំពេញលក្ខខណ្ឌជាក់លាក់មួយចំនួន ដើម្បីឲ្យមានន័យ និងពិតជាតំណាងយ៉ាងពិតប្រាកដទៅតាមបំណងប្រាថ្នារបស់ប្រជាពលរដ្ឋ។ មានគោលការណ៍ណែនាំអន្តរជាតិ ដែលដាក់ចេញនូវបទដ្ឋានសម្រាប់ការបោះឆ្នោត។ មានប្រទេសជាច្រើន រួមទាំងប្រទេសកម្ពុជា បានយល់ព្រមជាមួយបទដ្ឋានទាំងអស់នេះ។[១៦]

[១៦] សេចក្តីប្រកាសជាសកលស្តីពីលក្ខណៈវិនិច្ឆ័យចំពោះការបោះឆ្នោតដោយសេរី និងយុត្តិធម៌ ដែលបានអនុម័តជាឯកច្ឆន្ទ ដោយក្រុមប្រឹក្សាសហភាពអន្តរសភា នៅទីក្រុងប៉ារីស នៅខែមីនា ឆ្នាំ១៩៩៤។

គោលការណ៍ណែនាំទាំងនេះបានដាក់ចេញនូវអ្វីដែលត្រូវធ្វើដើម្បីឲ្យការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី និងយុត្តិធម៌។ គោលការណ៍ទាំងនេះមានៈ

- គ្រប់គ្នាត្រូវតែអាចបោះឆ្នោតបាន។
- គ្រប់គ្នាត្រូវតែអាចបោះឆ្នោតជ្រើសរើសបេក្ខជនណាម្នាក់ទៅតាមការជ្រើសរើសរបស់គាត់។
- គ្រប់គ្នាត្រូវតែអាចបោះឆ្នោតដោយសម្ងាត់។
- គ្រប់គ្នាត្រូវតែមានសិទ្ធិទទួលបានព័ត៌មានត្រឹមត្រូវអំពីគណបក្សទាំងអស់ដើម្បីជួយសម្រួលពួកគាត់ក្នុងការសម្រេចចិត្តថាត្រូវបោះឆ្នោតឲ្យគណបក្សណាមួយ។

ប្រជាពលរដ្ឋត្រូវតែមានអារម្មណ៍ថា ពួកគាត់អាចបោះឆ្នោតដោយសេរីក្នុងការជ្រើសរើសអ្នកណាម្នាក់ដែលពួកគាត់គិតថា អាចធ្វើជាតំណាងរបស់ពួកគាត់បានល្អបំផុត។ ប្រសិនបើមានការគាបសង្កត់ ឬការគំរាមកំហែងឲ្យបោះឆ្នោតឲ្យអ្នកណាម្នាក់ ឬ**គណបក្សនយោបាយ**ណាមួយ នោះការបោះឆ្នោតបែបនេះមិនមែនជាការបោះឆ្នោតដោយសេរី និងយុត្តិធម៌ទេ។ វិធីយ៉ាងសំខាន់មួយដើម្បីធ្វើឲ្យការបោះឆ្នោតនោះប្រព្រឹត្តទៅដោយសេរី និងយុត្តិធម៌គឺ សន្លឹកឆ្នោតត្រូវតែជាសន្លឹកឆ្នោតសម្ងាត់ ដែលជួយធានាបានថា ប្រជាពលរដ្ឋអាចចូលរួមបោះឆ្នោតដោយសេរីដើម្បីជ្រើសរើសបេក្ខជន និងគណបក្សនយោបាយដែលពួកគាត់ជឿជាក់ដោយគ្មានភាពភ័យខ្លាចថា ពួកគេនឹងត្រូវគេដាក់ទោស។

## រឿងរ៉ាវរបស់ស៊ីថន

ស៊ីថនទើបតែមានអាយុ១៨ឆ្នាំ ហើយកំពុងតែទៅបោះឆ្នោតថ្នាក់ជាតិ។ នៅតាមផ្លូវទៅបោះឆ្នោតមានបុរសពីរនាក់នៅក្នុងភូមិជាមួយគ្នា ដែលគេដឹងថា ជាសមាជិកនៃគណបក្សនយោបាយមួយបានបញ្ឈប់ស៊ីថន។ បុរសទាំងពីរនាក់នោះបានប្រាប់ស៊ីថនថា ប្រសិនបើស៊ីថនមិនបោះឆ្នោតឲ្យគណបក្សនយោបាយរបស់ខ្លួនទេ នោះក្រុមគ្រួសាររបស់ស៊ីថនមុខជានឹងជួបបញ្ហានៅក្នុងពេលអនាគតជាមិនខាន។

ស៊ីថនមានអារម្មណ៍តក់ស្លុត និងភ័យខ្លាច ដោយសារគាត់ធ្លាប់បានឮថា បុរសពីរនាក់នោះអាចធ្វើឲ្យការរស់នៅរបស់ប្រជាពលរដ្ឋមានភាពលំបាក។ ស៊ីថនបោះឆ្នោតឲ្យគណបក្សនយោបាយរបស់បុរសទាំងពីរនាក់នោះ ហើយទីបំផុតគណបក្សនោះក៏ឈ្នះឆ្នោត។

ការបោះឆ្នោតទាំងនេះមិនមែនជាការបោះឆ្នោតដោយសេរី និងយុត្តិធម៌ទេ រីឯសិទ្ធិរបស់ស៊ីថនត្រូវបុរសទាំងពីរនាក់នោះបំពាន។




## ៥. គណបក្សនយោបាយ

ដើម្បីឲ្យប្រជាពលរដ្ឋចូលរួមបោះឆ្នោតទៅតាមរបៀបដែលមានន័យអាចទទួលយកបាន ដូច្នេះពួកគាត់ត្រូវតែមានសិទ្ធិជ្រើសរើសបេក្ខជនពិតប្រាកដដែលគាត់ចង់បាន។ ជាទូទៅបេក្ខជនទាំងនេះ គឺជាសមាជិកនៃគណបក្សនយោបាយ ដែលមានគុណតម្លៃ និងទស្សនៈផ្សេងគ្នាចំពោះរបៀបក្នុងការរៀបចំសង្គម និងរបៀបក្នុងការធ្វើសេចក្តីសម្រេចចិត្ត។ **គណបក្សនយោបាយ**គឺជា អង្គការមួយដែលបង្កើតឡើងដោយមនុស្សមួយក្រុមដែលមានគុណតម្លៃ និងទស្សនៈដូចគ្នា ដែលមានគោលបំណងចង់មានអំណាចនយោបាយនៅក្នុងរដ្ឋាភិបាល។ ប្រសិនបើមានគណបក្សនយោបាយតែមួយឈរឈ្មោះ ដូច្នេះប្រជាពលរដ្ឋមិនមានជម្រើសពិតប្រាកដក្នុងការជ្រើសគណបក្សនយោបាយ នៅពេលបោះឆ្នោត។

**សិទ្ធិក្នុងការបង្កើតសមាគម** គឺជាសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការសម្រេចចិត្តថា៖

- ត្រូវបង្កើត ឬចូលរួមជាមួយស្ថាប័នការ ឬក្រុមណាមួយ។
- មិនចូលរួម ឬមិនគាំទ្រស្ថាប័នការ ឬក្រុមណាមួយ។

សិទ្ធិសេរីភាពក្នុងការបង្កើតសមាគមមានន័យថា ប្រជាពលរដ្ឋមានសិទ្ធិក្នុងការចូលរួមជាមួយប្រជាពលរដ្ឋដទៃទៀតដែលមានចំណាប់អារម្មណ៍ និងគោលបំណងដូចគ្នា។ នេះរួមទាំងសិទ្ធិក្នុងការបង្កើត ឬចូលរួមក្នុងគណបក្សនយោបាយណាមួយ។ សិទ្ធិនេះត្រូវបានទទួលស្គាល់ដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

| **សិទ្ធិក្នុងការបង្កើត និងចូលរួមជាមួយគណបក្សនយោបាយ** |
|---|
| សិទ្ធិរបស់ពលរដ្ឋទាំងអស់ក្នុងការបង្កើតសមាគម និងគណបក្សនយោបាយ ត្រូវបានធានាដោយមាត្រា៤២ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។<br><br>សិទ្ធិក្នុងការបង្កើតសមាគម ក៏ត្រូវបានទទួលស្គាល់ដោយសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយដែរ។ |

# មេរៀនទី២ ៖ ការបោះឆ្នោតដោយសេរី និងយុត្តិធម៌



គោលបំណង៖ អ្នកចូលរួមនឹងយល់ដឹងថា ការបោះឆ្នោតដោយសេរី និងយុត្តិធម៌មានន័យដូចម្ដេច និងយល់ដឹងថា សិទ្ធិក្នុងការបោះឆ្នោត គឺជាសិទ្ធិជាមូលដ្ឋានរបស់មនុស្សគ្រប់រូប។ ពួកគាត់នឹងយល់ដឹងអំពីសារៈសំខាន់នៃការបោះឆ្នោតដោយសេរី និងយុត្តិធម៌ ដើម្បីធ្វើឲ្យរដ្ឋាភិបាលមានការទទួលខុសត្រូវចំពោះប្រជាពលរដ្ឋ។ ពួកគាត់ក៏នឹងដឹងដែរថា មានគណបក្សនយោបាយច្រើនចូលរួមក្នុងការបោះឆ្នោតគឺជា ផ្នែកមួយយ៉ាងសំខាន់នៃដំណើរការនេះ។

សម្ភារៈ៖ ក្រដាសផ្ទាំងធំ ឬក្ដារខៀន ហ្វឺតពណ៌ ឯកសារសម្រាប់ចែកទី១ និងទី២។

**វិធីសាស្ត្រ៖** ការសម្ដែងតួ សាច់រឿង ការពិភាក្សាក្រុមធំ ការបំផុសគំនិត។

| ដំណើរការ | រយៈពេល (គិតជានាទី) |
|---|---|
| ១. ការសម្ដែងតួអំពីការបោះឆ្នោត | ២០ |
| ២. ណែនាំព័ត៌មាននៅក្នុងផ្នែកទី៤ | ២០ |
| ៣. ការពិភាក្សាអំពីរឿងរ៉ាវរបស់ស៊ីថន | ១០ |
| ៤. ណែនាំព័ត៌មាននៅក្នុងផ្នែកទី៥ | ១០ |
| ៥. ការបំផុសគំនិតអំពីគណបក្សនយោបាយ | ៥ |
| ៦. សង្ខេប | ១៥ |
| សរុប៖ | ៨០ |

## សេចក្តីណែនាំសម្រាប់អ្នកសម្របសម្រួល

### ១. ការសម្តែងតួអំពីការបោះឆ្នោត

- ស្នើសុំអ្នកចូលរួមបីនាក់ស្ម័គ្រចិត្តជួយអ្នកសម្របសម្រួលនៅក្នុងសកម្មភាពបន្ទាប់។ ផ្តល់សេចក្តីណែនាំមួយ ដែលជាឯកសារសម្រាប់ចែកទី១ ទៅអ្នកស្ម័គ្រចិត្តម្នាក់ៗ។

- ទុកពេលឲ្យអ្នកស្ម័គ្រចិត្តពីរ ឬបីនាទីដើម្បីអានសេចក្តីណែនាំនេះដោយស្ងាត់ៗ។ នៅពេលដែលពួកគាត់កំពុងអាន សូមពន្យល់អ្នកចូលរួមទាំងអស់ថា ឥឡូវនេះពួកគាត់ទាំងអស់គ្នានឹងមានឱកាសបោះឆ្នោតជ្រើសរើសមនុស្សម្នាក់ក្នុងចំណោមអ្នកស្ម័គ្រចិត្តទាំងបីនេះ។ អ្នកស្ម័គ្រចិត្តម្នាក់ៗមានគំនិតខុសៗគ្នាអំពីបញ្ហាដែលបង្កផលប៉ះពាល់ដល់ក្រុម រីឯអ្នកស្ម័គ្រចិត្តម្នាក់ៗនឹងពន្យល់អ្នកចូលរួមអំពីគំនិតរបស់ពួកគាត់ មុនពេលពួកគាត់បោះឆ្នោត។

- សុំឲ្យអ្នកស្ម័គ្រចិត្តម្នាក់ៗបង្ហាញ អ្នកចូលរួមទាំងអស់នៅក្នុងថ្នាក់អំពីគំនិតដែលជាបញ្ហារបស់ពួកគាត់ (ប្រើសេចក្តីណែនាំដែលអ្នកសម្របសម្រួលឲ្យគាត់)។

- បន្ទាប់ពីអ្នកស្ម័គ្រចិត្តម្នាក់ៗបានបង្ហាញអំពីគំនិតរបស់ពួកគាត់ហើយ សូមឲ្យអ្នកចូលរួមលើកដៃប្រសិនបើពួកគាត់បោះឆ្នោតឲ្យអ្នកស្ម័គ្រចិត្តទី១។ សូមកត់ត្រាចំនួនអ្នកចូលរួមដែលបានលើកដៃ។ សូមធ្វើដូចគ្នាចំពោះអ្នកស្ម័គ្រចិត្តទី២ និងទី៣។ រួចប្រកាសលទ្ធផល។

- សូមពន្យល់ថា អ្នកចូលរួមទាំងអស់ត្រូវបានសុំឲ្យលើកដៃដូច្នេះ ដើម្បីឲ្យគ្រប់គ្នាដឹងថា ពួកគាត់បោះឆ្នោតឲ្យអ្នកណា។ តើពួកគាត់គិតយ៉ាងណាដែរចំពោះរឿងនេះ? តើពួកគាត់គិតថាមានសម្ពាធទេក្នុងការបោះឆ្នោតតាមរបៀបដែលជាគំនិតរបស់អ្នកដទៃ?

- បន្ទាប់មក សូមពន្យល់ថា ពួកគាត់នឹងមានឱកាសក្នុងការបោះឆ្នោតម្តងទៀត ប៉ុន្តែលើកនេះពួកគាត់នឹងសរសេរឈ្មោះអ្នកដែលគាត់ចង់បោះឆ្នោតឲ្យ ដើម្បីមិនឲ្យមានអ្នកណាដឹង ហើយអ្នកសម្របសម្រួលនឹងប្រមូលសន្លឹកឆ្នោត។ សូមប្រាប់អ្នកចូលរួមថា អ្នកសម្របសម្រួលចង់ឲ្យពួកគាត់បោះឆ្នោតឲ្យអ្នកស្ម័គ្រចិត្តទី១ ដោយសារតែអ្នកសម្របសម្រួលគិតថា គាត់មានគំនិតល្អជាងគេ។ ប្រសិនបើ ពួកគាត់មិនបោះឆ្នោតឲ្យអ្នកស្ម័គ្រចិត្តទី១ទេ នោះពួកគាត់ប្រហែលជានឹងមិនទទួលបានវិញ្ញាបនបត្រនៅចុងបញ្ចប់នៃវគ្គនេះទេ។

- ទុកពេលឲ្យអ្នកចូលរួមសរសេរសន្លឹកឆ្នោតរបស់ពួកគាត់ ហើយប្រមូលសន្លឹកឆ្នោតទាំងនោះ។ សូមរាប់សន្លឹកឆ្នោត ហើយប្រកាសលទ្ធផល។

- សូមសួរអ្នកចូលរួមថា តើពួកគាត់មានអារម្មណ៍យ៉ាងណា នៅពេលដែលអ្នកសម្របសម្រួលបង្ខំឲ្យពួកគាត់បោះឆ្នោតឲ្យអ្នកស្ម័គ្រចិត្តទី១។ តើពួកគាត់បានបោះឆ្នោតឲ្យអ្នកស្ម័គ្រចិត្តទី១ តាមសម្ពាធនោះមែនទេ? ហេតុអ្វីបានជាពួកគាត់បោះតាម ឬមិនបោះតាមសម្ពាធនោះ?

## ២. ណែនាំព័ត៌មាននៅក្នុងផ្នែកទី៤ (សូមមើលទំព័រទី៧៥ ដល់ទី៧៧)

**ផ្នែកទី៤៖** វាមានសារៈសំខាន់ណាស់ដែលអ្នកចូលរួមយល់ដឹងថា៖

- នៅក្នុងលទ្ធិប្រជាធិបតេយ្យ ប្រជាជនជ្រើសរើសតំណាងរបស់ពួកគាត់តាមរយៈការបោះឆ្នោតដោយសេរី និងយុត្តិធម៌។
- នៅក្នុងកំឡុងពេលនៃដំណើរការនៃការបោះឆ្នោត ប្រជាពលរដ្ឋមានឱកាសក្នុងការសិក្សាស្វែងយល់អំពីទស្សនៈ និងគុណតម្លៃរបស់បេក្ខជនផ្សេងៗ រួចបន្ទាប់មកពួកគាត់នឹងសម្រេចចិត្តថា តើបេក្ខជនមួយណាដែលអាចធ្វើជាតំណាងទៅតាមគំនិត ឬយោបល់របស់ពួកគាត់បានល្អបំផុត។
- មនុស្សពេញវ័យទាំងអស់ (ប្រជាពលរដ្ឋដែលមានអាយុអាចបោះឆ្នោតបាន នៅប្រទេសកម្ពុជា គឺអាយុ១៨ឆ្នាំ) មានសិទ្ធិបោះឆ្នោត លើកលែងតែមានមូលហេតុណាមួយសមរម្យ។
- សន្លឹកឆ្នោតទាំងអស់មានតម្លៃស្មើៗគ្នា។
- មនុស្សពេញវ័យទាំងអស់ក៏មានសិទ្ធិក្នុងការឈរឈ្មោះជាបេក្ខជននៅក្នុងការបោះឆ្នោតដែរ។
- បេក្ខជនដែលឈ្នះឆ្នោតនឹងក្លាយជាតំណាងរបស់ប្រជាពលរដ្ឋនៅក្នុងរដ្ឋាភិបាល
- រដ្ឋាភិបាលត្រូវបានបោះឆ្នោតឲ្យធ្វើការជំនួសប្រជាពលរដ្ឋ ហើយនៅក្នុងកំឡុងពេលកាន់តំណែងនេះ រដ្ឋាភិបាលត្រូវតែតំណាងឲ្យផលប្រយោជន៍ប្រជាពលរដ្ឋ។
- ប្រសិនបើ ប្រជាពលរដ្ឋភាគច្រើនមិនឯកភាព ឬមិនពេញចិត្តនឹងការសម្រេចចិត្ត និងសកម្មភាពការងាររបស់រដ្ឋាភិបាលទេ ពេលនោះប្រជាពលរដ្ឋអាចបោះឆ្នោតទម្លាក់រដ្ឋាភិបាលនោះចេញពីអំណាចនៅពេលបោះឆ្នោតលើកក្រោយ។
- ការបោះឆ្នោតត្រូវតែជាការបោះឆ្នោតដោយសម្ងាត់ និងមិនត្រូវមានការកៀបសង្កត់ ឬដាក់សម្ពាធលើប្រជាពលរដ្ឋឲ្យបោះឆ្នោតឲ្យជនណាម្នាក់ ឬគណបក្សនយោបាយណាមួយឡើយ។

## ៣. ការពិភាក្សាអំពីរឿងរ៉ាវរបស់ស៊ីថន

- សូមចែកឯកសារសម្រាប់ចែកទី២អំពីរឿងរ៉ាវរបស់ស៊ីថន ហើយស្នើសុំឲ្យអ្នកចូលរួមអានឲ្យឮខ្លាំងៗ។
- សូមសួរអ្នកចូលរួមថា តើពួកគាត់គិតយ៉ាងណាចំពោះរឿងរ៉ាវនេះ។
- សូមឲ្យអ្នកចូលរួមពន្យល់ថា ហេតុអ្វីបានជាសិទ្ធិក្នុងការបោះឆ្នោតរបស់ស៊ីថនត្រូវគេបំពាន និងថាហេតុអ្វីបានជាការបោះឆ្នោតនោះមិនមែនជាការបោះឆ្នោតដោយសេរី និងយុត្តិធម៌។
- សូមសួរពួកគាត់ថា តើពួកគាត់ធ្លាប់បានឮរឿងរ៉ាវស្រដៀងគ្នានេះជាក់ស្តែងនៅប្រទេសកម្ពុជា ឬប្រទេសណាផ្សេងនៅលើពិភពលោកដែរឬទេ។

## ៤. ណែនាំព័ត៌មាននៅក្នុងផ្នែកទី៥ (សូមមើលទំព័រទី៧៨ ដល់ទី៧៩)

**ផ្នែកទី៥៖** វាមានសារៈសំខាន់ណាស់ដែលអ្នកចូលរួមយល់ដឹងថា៖

- ដើម្បីឲ្យប្រជាពលរដ្ឋបោះឆ្នោតទៅតាមរបៀបមួយដែលមានន័យនោះ គឺត្រូវមានជម្រើសពិតប្រាកដចំពោះបេក្ខជន ដែលពួកគេចង់បាន។
- គណបក្សនយោបាយ គឺជាស្ថាប័នការដែលបង្កើតឡើងដោយមនុស្សមួយក្រុមដែលមានគុណតម្លៃ និងទស្សនៈដូចគ្នា និងមានគោលបំណងចង់មានអំណាចនយោបាយនៅក្នុងរដ្ឋាភិបាល។
- សិទ្ធិក្នុងការបង្កើតសមាគម រួមទាំងសិទ្ធិសម្រាប់ប្រជាពលរដ្ឋក្នុងការបង្កើត និងចូលរួមជាមួយគណបក្សនយោបាយណាមួយ។
- សិទ្ធិនេះត្រូវបានទទួលស្គាល់ដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់អន្តរជាតិ។

## ៥. ការបំផុសគំនិតអំពីគណបក្សនយោបាយ

- សួរអ្នកចូលរួមមើលថា តើពួកគាត់អាចនឹករកឈ្មោះគណបក្សនយោបាយនៅក្នុងប្រទេសកម្ពុជាបានទេ។
- បន្ទាប់ពីអ្នកចូលរួមបាននឹករកឈ្មោះគណបក្សនយោបាយមួយចំនួនហើយ សូមអ្នកសម្របសម្រួលបន្ថែមឈ្មោះដែលពួកគាត់មិនទាន់រកឃើញ។ គណបក្សនយោបាយទាំងនោះរួមមាន៖
  - គណបក្សប្រជាជនកម្ពុជា
  - គណបក្សសមរង្ស៊ី
  - គណបក្សហ៊្វុនស៊ីនប៉ិច
  - គណបក្សនរោត្តមរណឫទ្ធិ
  - គណបក្សសិទ្ធិមនុស្ស
  - គណបក្សសម្ព័ន្ធប្រជាធិបតេយ្យ

## ៦. សង្ខេប

- សុំឲ្យអ្នកចូលរួមម្នាក់ ឬពីរនាក់រៀបរាប់អំពីការបោះឆ្នោតដោយសេរី និងយុត្តិធម៌។
- សុំឲ្យអ្នកចូលរួមម្នាក់ពន្យល់ថា តើគណបក្សនយោបាយជាអ្វី និងពន្យល់ថា ហេតុអ្វីបានជាវាជាការសំខាន់ ដែលត្រូវមានគណបក្សនយោបាយច្រើនចូលរួមក្នុងការបោះឆ្នោត។
- សួរពួកគាត់ថា តើពួកគាត់យល់យ៉ាងណាចំពោះស្ថានភាពនៅប្រទេសកម្ពុជា។ តើប្រជាពលរដ្ឋកម្ពុជាអាចចូលរួមក្នុងការបោះឆ្នោតដោយសេរី និងយុត្តិធម៌ដល់កម្រិតណា?

## ឯកសារសម្រាប់ចែកទី១ : មេរៀនទី២

### សេចក្ដីណែនាំសម្រាប់អ្នកស្ម័គ្រចិត្តទី១៖

អ្នកចូលរួមទាំងអស់នឹងសម្រេចចិត្តថា តើអ្នកណាម្នាក់ក្នុងចំណោមអ្នកស្ម័គ្រចិត្តបី ដែលពួកគាត់ត្រូវបោះឆ្នោតជ្រើសរើសឲ្យធ្វើជាតំណាងពួកគាត់ទាំងអស់គ្នា។ មុនពេលដែលម្នាក់ៗមានឱកាសចូលរួមបោះឆ្នោត អ្នកស្ម័គ្រចិត្តមានពេលក្នុងការពន្យល់អំពីគំនិតរបស់ខ្លួនលើបញ្ហាមួយចំនួនដែលអាចជះឥទ្ធិពលដល់ពួកគាត់។ អ្នកគួរពន្យល់អ្នកចូលរួមទាំងអស់ថា ប្រសិនបើបោះឆ្នោតឲ្យអ្នក នោះអ្នកនឹងធ្វើដូចខាងក្រោមនេះ៖

១. អ្នកនឹងអនុញ្ញាតឲ្យសម្រាកតែ៥នាទីប៉ុណ្ណោះ ព្រោះថា ធ្វើរបៀបនេះ វគ្គបណ្ដុះបណ្ដាលនឹងអាចឆាប់ចប់មុនពេលកំណត់ ដើម្បីឲ្យអ្នកទាំងអស់គ្នាអាចឆាប់បានទៅផ្ទះដែរ។

២. ទណ្ឌកម្មចំពោះអ្នកដែលមកយឺត ឬនិយាយទូរស័ព្ទនៅកំពុងរៀន គឺត្រូវពិន័យ១០$ ព្រោះអ្នកគិតថា ការធ្វើដូច្នេះនឹងធ្វើឲ្យប្រាកដថា គ្មានអ្នកណានឹងបំពានបទបញ្ជាទាំងនេះឡើយ។

សូមសុំឲ្យអ្នកចូលរួមទាំងអស់បោះឆ្នោតឲ្យអ្នក

---

### សេចក្ដីណែនាំសម្រាប់អ្នកស្ម័គ្រចិត្តទី២៖

អ្នកចូលរួមទាំងអស់នឹងសម្រេចចិត្តថា តើអ្នកណាម្នាក់ក្នុងចំណោមអ្នកស្ម័គ្រចិត្តបី ដែលពួកគាត់ត្រូវជ្រើសរើសឲ្យធ្វើជាតំណាងពួកគាត់ទាំងអស់គ្នា។ មុនពេលដែលម្នាក់ៗមានឱកាសចូលរួមបោះឆ្នោត អ្នកស្ម័គ្រចិត្តមានពេលក្នុងការពន្យល់អំពីគំនិតរបស់ខ្លួនលើបញ្ហាមួយចំនួន ដែលអាចជះឥទ្ធិពលដល់ពួកគាត់។ អ្នកគួរពន្យល់អ្នកចូលរួមទាំងអស់គ្នាថា ប្រសិនបើ បោះឆ្នោតឲ្យអ្នក នោះអ្នកនឹងធ្វើដូចខាងក្រោមនេះ៖

១. អ្នកនឹងអនុញ្ញាតឲ្យសម្រាកដល់ទៅ៣០នាទី ដោយសារការធ្វើដូច្នេះអ្នកចូលរួមនឹងមានអារម្មណ៍ធូរស្រាលហើយនឹងអាចយកចិត្តទុកដាក់ខ្លាំងក្នុងការរៀនសូត្រក្នុងម៉ោងបន្ទាប់

២. គ្មានការដាក់ទណ្ឌកម្មចំពោះអ្នកដែលមកយឺត ឬអ្នកដែលនិយាយទូរស័ព្ទនៅពេលកំពុងរៀនទេ ព្រោះអ្នកជឿជាក់ថា អ្នកចូលរួមទាំងអស់គ្នានឹងធ្វើរឿងដែលត្រឹមត្រូវដោយមិនឲ្យមានការដាក់ទណ្ឌកម្មទេ។

សូមសុំឲ្យអ្នកចូលរួមទាំងអស់បោះឆ្នោតឲ្យអ្នក

---

## សេចក្តីណែនាំសម្រាប់អ្នកស្ម័គ្រចិត្តទី៣ :

អ្នកចូលរួមទាំងអស់នឹងសម្រេចចិត្តថា តើអ្នកណាម្នាក់នៅក្នុងចំណោមអ្នកស្ម័គ្រចិត្តបី ដែលពួកគាត់ត្រូវបោះឆ្នោតជ្រើសរើសឲ្យធ្វើជាតំណាងពួកគាត់ទាំងអស់គ្នា។ មុនពេលម្នាក់ៗមានឱកាសគ្នាបោះឆ្នោត អ្នកស្ម័គ្រចិត្តមានពេលក្នុងការពន្យល់អំពីគំនិតរបស់ខ្លួនលើបញ្ហាមួយចំនួនដែល អាចជះឥទ្ធិពលដល់ពួកគាត់។ អ្នកគួរពន្យល់អ្នកចូលរួមទាំងអស់គ្នាថា ប្រសិនបើពួកគាត់បោះឆ្នោតឲ្យអ្នក នោះអ្នកនឹងធ្វើដូចខាងក្រោមនេះ៖

១. អ្នកនឹងអនុញ្ញាតឲ្យសម្រាក១៥នាទី ព្រោះរយៈ១៥នាទីនេះវែងគ្រប់គ្រាន់ដើម្បីពិសាកាហ្វេ និងការចូលបន្ទប់ទឹក។

២. ទណ្ឌកម្មចំពោះអ្នកដែលមកយឺត ឬនិយាយទូរស័ព្ទនៅពេលកំពុងរៀនគឺត្រូវពិន័យឲ្យច្រៀង ឬរាំនៅចំពោះមុខអ្នកចូលរួមទាំងអស់គ្នាមុននឹងចាប់ផ្តើមមេរៀនម៉ោងបន្ទាប់។ ធ្វើយ៉ាងនេះអាចនាំឲ្យអ្នកចូលរួមទាំងអស់គ្នាសប្បាយ ប៉ុន្តែវាក៏អាចធ្វើឲ្យមានភាពអាម៉ាស់ដល់មនុស្សខ្លះដើម្បីឲ្យពួកគាត់ធ្វើអ្វីដែលត្រឹមត្រូវ។

សូមសុំឲ្យអ្នកចូលរួមទាំងអស់បោះឆ្នោតឲ្យអ្នក

## ឯកសារសម្រាប់ចែកទី២ : មេរៀនទី២

| រឿងរ៉ាវរបស់ស៊ីថន |
|---|
| ស៊ីថនទើបតែមានអាយុ១៨ឆ្នាំ ហើយកំពុងតែធ្វើដំណើរទៅបោះឆ្នោតថ្នាក់ជាតិ។ នៅតាមផ្លូវទៅបោះឆ្នោត មានបុរសពីរនាក់នៅក្នុងភូមិជាមួយគ្នា ដែលគេដឹងថា ជាសមាជិកនៃគណបក្សនយោបាយមួយបានបញ្ឈប់ស៊ីថន រួចប្រាប់ស៊ីថនថា ប្រសិនបើស៊ីថនមិនបោះឆ្នោតឲ្យគណបក្សនយោបាយរបស់ខ្លួនទេ នោះក្រុមគ្រួសាររបស់ស៊ីថនមុខជានឹងជួបបញ្ហានៅក្នុងពេលអនាគតជាមិនខាន។<br><br>ស៊ីថនមានអារម្មណ៍ភ័យខ្លាចដោយការគំរាមកំហែង ព្រោះគាត់ធ្លាប់ឮថា បុរសពីរនាក់នោះអាចធ្វើឲ្យការរស់នៅរបស់ប្រជាពលរដ្ឋមានភាពលំបាក។ ស៊ីថនបោះឆ្នោតឲ្យគណបក្សនយោបាយនោះ ហើយទីបំផុតគណបក្សនោះក៏ឈ្នះឆ្នោត។<br><br>ការបោះឆ្នោតទាំងនេះមិនមែនជាការបោះឆ្នោតដោយសេរី និងយុត្តិធម៌ទេ ហើយសិទ្ធិបោះឆ្នោតរបស់ស៊ីថនត្រូវបុរសទាំងពីរនាក់នោះរំលោភបំពាន។ |

# ៦. ព័ត៌មាន និងការចូលរួម

សិទ្ធិទទួលបានព័ត៌មានអំពីបញ្ហាសង្គម និងបញ្ហាសាធារណៈគឺជា ផ្នែកមួយយ៉ាងសំខាន់នៅក្នុងលទ្ធិប្រជាធិបតេយ្យ។ យើងទាំងអស់គ្នាត្រូវការព័ត៌មានអំពីបញ្ហាមួយចំនួន រួមទាំងព័ត៌មានអំពីគណបក្សនយោបាយជាដើម ដើម្បីឲ្យប្រជាពលរដ្ឋអាចសម្រេចចិត្តដែលមានន័យគ្រប់គ្រាន់ថា ពួកគាត់ត្រូវបោះឆ្នោតឲ្យអ្នកណា។ យើងក៏ត្រូវការព័ត៌មាន ដើម្បីឲ្យយើងអាចចូលរួមយ៉ាងពេញលេញក្នុងដំណើរការអភិវឌ្ឍន៍សង្គមតាមវិធីផ្សេងៗទៀតដែរ។

ប្រភពព័ត៌មានមួយក្នុងចំណោមប្រភពព័ត៌មានសំខាន់ៗអំពីបញ្ហាសាធារណៈគឺ តាមរយៈប្រព័ន្ធផ្សព្វផ្សាយ។ ប្រព័ន្ធផ្សព្វផ្សាយនានាមានដូចជា វិទ្យុ កាសែត និងទូរទស្សន៍។ ប្រព័ន្ធផ្សព្វផ្សាយសេរី និងឯករាជ្យ ដែលអ្នកកាសែត និងអ្នកដទៃទៀត អាចចុះផ្សាយព័ត៌មាន គំនិត និងការយល់ឃើញដោយគ្មានការភ័យខ្លាច គឺជាផ្នែកមួយយ៉ាងសំខាន់នៅក្នុងសង្គមដែលកាន់លទ្ធិប្រជាធិបតេយ្យពិតប្រាកដ។ ប្រជាពលរដ្ឋត្រូវមានសេរីភាពក្នុងការបញ្ចេញទស្សនៈរបស់គាត់ រួមទាំង មតិសំខាន់ៗដែលនិយាយរិះគន់រដ្ឋាភិបាលផង។ ប្រភពព័ត៌មានយ៉ាងសំខាន់មួយទៀតគឺ តាមរយៈវេទិកាសាធារណៈអំពីបញ្ហាផ្សេងៗ។ ឧទាហរណ៍ៈ រដ្ឋាភិបាល ឬស្ថាប័នណាមួយអាចរៀបចំវេទិកាសាធារណៈអំពីសិទ្ធិកម្មករ ដែលប្រជាពលរដ្ឋអាចចូលរួម និងពិភាក្សាអំពីទស្សនៈ និងផ្តល់បទពិសោធន៍របស់ពួកគាត់។



## សេរីភាពក្នុងការបញ្ចេញមតិ

**សិទ្ធិក្នុងការបញ្ចេញមតិដោយសេរី** មាន២ផ្នែកធំៗគឺ៖

១. សិទ្ធិទទួលបានព័ត៌មាននិងគំនិត

២. សិទ្ធិផ្សព្វផ្សាយព័ត៌មាន គំនិត និងមតិជាសាធារណៈ

ការបញ្ចេញមតិ អាចមានទម្រង់ផ្សេងៗគ្នាជាច្រើន ដែលរួមមាន ការសរសេរ ការថ្លែងសុន្ទរកថា ប្រព័ន្ធផ្សព្វផ្សាយ និងការប្រើសញ្ញា។

សេរីភាពក្នុងការបញ្ចេញមតិ មានសារៈសំខាន់ណាស់ដើម្បីឲ្យសង្គមប្រជាធិបតេយ្យមួយ ដំណើរការទៅដោយយុត្តិធម៌ និងត្រឹមត្រូវ។ ប្រជាពលរដ្ឋត្រូវតែអាចនិយាយអំពីអ្វីដែលពួកគាត់គិត និងជឿ ដោយគ្មានការភ័យខ្លាចថា ពួកគាត់នឹងត្រូវគេដាក់ទណ្ឌកម្មឡើយ ទោះបីជា អ្នកផ្សេង ឬរដ្ឋាភិបាលមិនគិត ឬជឿដូចពួកគាត់ក៏ដោយ។ នេះក៏មានន័យថា អ្នកកាសែតក៏ត្រូវមានសេរីភាពក្នុងការរាយការណ៍ការពិតអំពីព្រឹត្តិការណ៍ផ្សេងៗដែរ។ លទ្ធិប្រជាធិបតេយ្យអនុញ្ញាតឲ្យប្រព័ន្ធផ្សព្វផ្សាយ ដំណើរការរបស់ខ្លួន ក្នុងការប្រមូល និងរាយការណ៍ព័ត៌មាន និងដំណឹងអ្វីមួយ ដោយគ្មានការភ័យខ្លាច ឬការអនុគ្រោះពីរដ្ឋាភិបាល ឬអ្នកមានឥទ្ធិពលផ្សេងៗទៀតឡើយ។

សិទ្ធិរបស់ពលរដ្ឋគ្រប់រូបក្នុងការបញ្ចេញមតិដោយសេរី ត្រូវបានធានាដោយមាត្រា៤១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

សិទ្ធិក្នុងការបញ្ចេញមតិនេះ ក៏ត្រូវបានទទួលស្គាល់ដោយសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយដែរ។

នៅពេលដែលប្រជាពលរដ្ឋអាចទទួលបានព័ត៌មានដែលរួមទាំងមតិរបស់អ្នកដទៃអំពីបញ្ហាសាធាណៈ និងបញ្ហានយោបាយផងនោះ ដូច្នេះពួកគាត់អាចប្រើព័ត៌មានទាំងនោះដើម្បីបង្កើតបានជាគំនិតរបស់គាត់ផ្ទាល់។ ពេលនោះ ពួកគាត់មានព័ត៌មានគ្រប់គ្រាន់ជាស្រេចក្នុងការបោះឆ្នោតឲ្យគណបក្សនយោបាយណាមួយ ព្រមទាំងត្រៀមខ្លួនជាស្រេចដើម្បីចូលរួមក្នុងការពិភាក្សាជាសាធារណៈ និងក្នុងការធ្វើសេចក្តីសម្រេចចិត្តក្នុងចន្លោះពេលការបោះឆ្នោតពីអាណត្តិមួយទៅអាណត្តិមួយ។

**រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា**

មាត្រា៣៥ :

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ប្រទេសជាតិ។

សេចក្តីស្នើទាំងឡាយរបស់ប្រជាពលរដ្ឋត្រូវបានទទួលការពិនិត្យ និងដោះស្រាយយ៉ាងហ្មត់ចត់ពីស្ថាប័នការរដ្ឋ។

លទ្ធិប្រជាធិបតេយ្យមិនមែនមានត្រឹមតែការបោះឆ្នោតនោះទេ វាក៏ត្រូវតែមានការចូលរួមយ៉ាងសកម្ម នៅក្នុងការធ្វើសេចក្តីសម្រេចចិត្តជាសាធារណៈដែរ។ នៅក្នុងលទ្ធិប្រជាធិបតេយ្យមានវេទិកាផ្សេងៗគ្នាជាច្រើនដើម្បីឲប្រជាពលរដ្ឋចូលរួម។ វេទិកាទាំងនោះមានដូចជា ការសរសេរលិខិតផ្ញើទៅតំណាងរដ្ឋាភិបាល ឬទៅជួបពិភាក្សាជាមួយតំណាងរដ្ឋាភិបាល ការប្រជុំសហគមន៍ ការសរសេរសំបុត្រដើម្បីចុះផ្សាយនៅក្នុងកាសែត ឬផ្សាយតាមវិទ្យុ និងការរៀបចំ និងចូលរួមក្នុងការធ្វើបាតុកម្មអហិង្សាជាសាធារណៈអំពីបញ្ហាណាមួយ។ ទាំងអស់នេះគឺជាផ្នែកសំខាន់ៗនៅក្នុងដំណើរការនៃលទ្ធិប្រជាធិបតេយ្យ។

| សិទ្ធិក្នុងការប្រមូលផ្តុំ |
| --- |
| សិទ្ធិក្នុងការប្រមូលផ្តុំជួបជុំមានន័យថា ប្រជាពលរដ្ឋមានសិទ្ធិក្នុងការជួបជុំគ្នាដោយសន្តិវិធី ដោយមិនមានអ្នកជទែបញ្ឈប់ពួកគាត់ឡើយ។ នេះមានន័យថា រដ្ឋាភិបាលមិនត្រូវបញ្ឈប់ប្រជាពលរដ្ឋពីការជួបជុំគ្នាដោយសន្តិវិធីដើម្បីពិភាក្សាពីទស្សនៈ និងគំនិតរបស់ពួកគាត់ឡើយ។<br><br>សិទ្ធិរបស់ពលរដ្ឋគ្រប់រូបក្នុងការប្រមូលផ្តុំ ត្រូវបានធានាដោយមាត្រា៤១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងសិទ្ធិក្នុងការធ្វើបាតុកម្មអហិង្សាត្រូវបានទទួលស្គាល់ដោយមាត្រា៣៧។<br><br>សិទ្ធិក្នុងការ ជួបជុំក៏ត្រូវបានទទួលស្គាល់នៅក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយដែរ។ |



# មេរៀនទី៣ ៖ ព័ត៌មាន និងការចូលរួម

គោលបំណង៖ អ្នកចូលរួមនឹងយល់ដឹងថា ការទទួលបានព័ត៌មាន និងការចូលរួមចំណែកនៅក្នុងការពិភាក្សាជជែកវែកញែកជាសាធារណៈគឺជា ផ្នែកយ៉ាងសំខាន់នៃលទ្ធិប្រជាធិបតេយ្យ។ ពួកគេនឹងយល់អំពីសារៈសំខាន់នៃ សេរីភាព និងឯករាជ្យភាពនៃប្រព័ន្ធផ្សព្វផ្សាយ ព្រមទាំងដឹងអំពីប្រភេទនៃវេទិកាផ្សេងៗទៀតដើម្បីទទួលព័ត៌មាន និងចូលរួមក្នុងកិច្ចការសាធារណៈ។

**សម្ភារៈ៖** ក្រដាសផ្ទាំងធំ ឬក្តារខៀន ហ្វឺតពណ៌ ឯកសារសម្រាប់ចែកទី១។

**វិធីសាស្ត្រ :** ការងារជាក្រុម ការសម្តែងតួ ការពិភាក្សា។

| ដំណើរការ | រយៈពេល (គិតជានាទី) |
|---|---|
| ១. ណែនាំព័ត៌មាននៅក្នុងផ្នែកទី៦ | ២០ |
| ២. ការងារជាក្រុម និងការត្រៀម | ២០ |
| ៣. ការសម្តែងតួជាក្រុម | ២០ |
| ៤. សង្ខេប | ២០ |
| សរុប៖ | ៨០ |

## ការណែនាំសម្រាប់អ្នកសម្របសម្រួល

### ១. ណែនាំព័ត៌មាននៅក្នុងផ្នែកទី៦ (សូមមើលទំព័រទី៨៧ ដល់ទី៨៩)

**ផ្នែកទី៦៖** វាមានសារៈសំខាន់ណាស់ដែលអ្នកចូលរួមយល់ដឹង៖

- ថា សិទ្ធិទទួលបានព័ត៌មានអំពីបញ្ហាសង្គម និងបញ្ហាសាធារណៈគឺជា ផ្នែកមួយយ៉ាងសំខាន់នៅក្នុងលទ្ធិប្រជាធិបតេយ្យ។
- ថា **ប្រព័ន្ធផ្សព្វផ្សាយ**សេរី និងឯករាជ្យដែលអ្នកសារព័ត៌មាន និងអ្នកដទៃទៀតអាចចុះផ្សាយ ព័ត៌មាន គំនិត និងមតិដោយគ្មានការភ័យខ្លាចគឺជា ផ្នែកយ៉ាងសំខាន់នៃលទ្ធិប្រជាធិបតេយ្យ។
- អំពី អត្ថន័យនៃសិទ្ធិក្នុងការបញ្ចេញមតិដោយសេរី។
- ថា ប្រជាពលរដ្ឋនៅក្នុងលទ្ធិប្រជាធិបតេយ្យត្រូវតែអាចនិយាយអំពីអ្វីដែលពួកគាត់គិត ឬជឿដោយគ្មានការភ័យខ្លាចថា ពួកគាត់នឹងត្រូវគេដាក់ទោស ទោះបីជាអ្នកដទៃ ឬរដ្ឋាភិបាលមិនគិត ឬជឿដូចពួកគាត់ក៏ដោយ។
- ថា នៅក្នុងលទ្ធិប្រជាធិបតេយ្យ ត្រូវតែមានវេទិកាផ្សេងៗមួយចំនួនដើម្បីឲ្យមានការចូលរួមពីសំណាក់ប្រជាពលរដ្ឋ បន្ថែមពីលើការបោះឆ្នោត។
- អត្ថន័យនៃសិទ្ធិក្នុងការប្រមូលផ្តុំ

### ២. ការងារជាក្រុម និងការត្រៀម

- សូមពន្យល់ថា អ្នកចូលរួមនឹងត្រូវបែងចែកជា៣ក្រុម ហើយក្រុមនីមួយៗនឹងទទួលបានសេចក្តីណែនាំដើម្បីត្រៀមសម្រាប់ការសម្តែងតួ។ ការសម្តែងតួនីមួយៗនឹងធ្វើអំពីប្រភេទនៃការចូលរួមផ្សេងៗគ្នា អំពីបញ្ហាសាធារណៈយ៉ាងសំខាន់មួយ ដែលអាចជះឥទ្ធិពលដល់ពួកគាត់ដូចជា៖ ថ្លៃបង់សាកលវិទ្យាល័យ (សូមមើលឯកសារសម្រាប់ចែកទី១)។
- សូមពន្យល់ថា ក្រុមមានពេល២០នាទីសម្រាប់ការពិភាក្សាយោបល់របស់ពួកគាត់អំពីបញ្ហានោះសម្រាប់ត្រៀមការសម្តែងតួ។ ការសម្តែងតួមិនគួរលើសពី៥នាទីទេ។
- សូមបែងចែកអ្នកចូលរួមជា៣ក្រុម ហើយឲ្យសេចក្តីណែនាំនៅក្នុងឯកសារសម្រាប់ចែកទី១ទៅក្រុម នីមួយៗ។
- សូមអ្នកសម្របសម្រួលត្រូវប្រាកដថា ក្រុមទាំងអស់យល់អំពីកិច្ចការដែលក្រុមត្រូវធ្វើ និងសូមរំលឹកពួកគាត់ នៅពេលដែលសល់ពេលពីរឬបីនាទីសម្រាប់ការត្រៀមនោះ។

៣. ការសម្តែងតួជាក្រុម

- សូមអញ្ជើញក្រុមនីមួយៗដើម្បីឡើងសម្តែងតួ។ បន្ទាប់ពីក្រុមនីមួយសម្តែងចប់ សូមសួរថា តើមានអ្នកណាមានសំណួរ ឬមតិអ្វីទេ។

៤. សង្ខេប :

- សុំអ្នកចូលរួមម្នាក់ ឬពីរនាក់ដើម្បីឡើងរៀបរាប់ថា ហេតុអ្វីបានជាសិទ្ធិទទួលបានព័ត៌មាន មានសារៈសំខាន់នៅក្នុងលទ្ធិប្រជាធិបតេយ្យ។
- បន្ទាប់មកសូមសួរថា នៅក្នុងលទ្ធិប្រជាធិបតេយ្យ ហេតុអ្វីបានជាការចូលរួមរវាងអាណត្តិមួយទៅអាណត្តិមួយក្នុងការបោះឆ្នោត មានសារៈសំខាន់យ៉ាងនេះ។
- សូមឲ្យអ្នកចូលរួមម្នាក់អានអត្ថបទនៅក្នុងឯកសារសម្រាប់ចែកទី២ ដែលអត្ថបទរបស់កាសែតភ្នំពេញប៉ុស្តិ៍ ចេញផ្សាយនៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១០។
- សូមសួរថា តើអ្នកចូលរួមគិតយ៉ាងណាចំពោះរឿងរ៉ាវនោះ។
- តើសិទ្ធិមនុស្សណាខ្លះដែលត្រូវគេរំលោភបំពាន?

# ឯកសារសម្រាប់ចែកទី១ : មេរៀនទី៣

## សេចក្តីណែនាំសម្រាប់ក្រុមទី១៖

រដ្ឋាភិបាលកំពុងពិភាក្សាវែកញែកអំពីបញ្ហានៃការបង់ថ្លៃរៀននៅសាកលវិទ្យាល័យ។ ដោយសារសិស្សានុសិស្សដែលទើបបានប្រឡងបញ្ចប់ថ្នាក់មធ្យមសិក្សាទុតិយភូមិ គ្មានលទ្ធភាពចូលរៀននៅសាកលវិទ្យាល័យ ដូច្នេះរដ្ឋាភិបាលកំពុងពិភាក្សាដើម្បីរកវិធីបញ្ចុះថ្លៃសិក្សានៅសាកលវិទ្យាល័យ ដែលធ្វើដូច្នេះគឺដើម្បីឲ្យក្មេងជំនាន់ក្រោយអាចទទួលបានការអប់រំប្រសើរជាងមុន នេះជាវិធីដែលយូរៗទៅ នាំឲ្យប្រទេសមានការរីកចម្រើនរុងរឿង។

មានគណបក្សនយោបាយមួយ បានឲ្យយោបល់អំពីផែនការមួយ ដែលអាចអនុវត្តបាននៅក្នុងប្រទេសដទៃ។ និស្សិតទាំងឡាយដែលគ្មានលទ្ធភាពក្នុងការបង់ថ្លៃសិក្សានៅសាកលវិទ្យាល័យ អាចខ្ចីប្រាក់ពីរដ្ឋាភិបាល ហើយសងរដ្ឋាភិបាលវិញជាដំណាក់កាលៗ នៅពេលដែលគេចាប់ផ្តើមមានការងារធ្វើ និងមានប្រាក់ចំណូល។ គណបក្សនយោបាយដែលកំពុងកាន់អំណាចមានការបារម្ភ និងមិនគាំទ្រគំនិតមួយនេះទេ ព្រោះថា ផែនការនេះនឹងធ្វើឲ្យរដ្ឋាភិបាលត្រូវចំណាយច្រើន។

ក្រុមនិស្សិតអ្នកបានសម្រេចចិត្តជួបជុំដើម្បីពិភាក្សាថា គួរគាំទ្រ ឬមិនគាំទ្រផែនការនេះ។ អ្នកគួរពិភាក្សា និងសរសេរមូលហេតុ ដែលអ្នកគាំទ្រ ឬមិនគាំទ្រផែនការនៃការកាត់បន្ថយថ្លៃសិក្សានៅសាកលវិទ្យាល័យ។

ក្រុមរបស់អ្នកបានសម្រេចចិត្តថានឹងរៀបចំបាតុកម្មជាសាធារណៈមួយ ដើម្បីបង្ហាញពីការគាំទ្រ ឬមិនគាំទ្រផែនការនោះ។ អ្នកត្រូវគិតអំពីទីតាំងសម្រាប់ការតវ៉ា និងអំពីមធ្យោបាយសម្រាប់ការបញ្ចេញទស្សនៈរបស់អ្នក ដូចជា តាមរយៈ បដា និងឧបករណ៍បំពងសំឡេងជាដើម។

សូមត្រៀមការសម្តែងតួអំពីបាតុកម្មរបស់អ្នក។

**សេចក្តីណែនាំសម្រាប់ក្រុមទី២៖**

រដ្ឋាភិបាលកំពុងពិភាក្សាវែកញែកអំពីបញ្ហានៃការបង់ថ្លៃរៀននៅសាកលវិទ្យាល័យ ។ ដោយសិស្សានុសិស្សដែលទើបបានប្រឡងបញ្ចប់ថ្នាក់មធ្យមសិក្សាទុតិយភូមិ គ្មានលទ្ធភាពចូលរៀននៅសកលវិទ្យាល័យ ដូច្នេះ រដ្ឋាភិបាលកំពុងពិភាក្សាដើម្បីរកវិធីបញ្ចុះថ្លៃសិក្សានៅសាកលវិទ្យាល័យ ដែលធ្វើដូច្នេះដើម្បីក្មេងជំនាន់ក្រោយអាចទទួលបានការអប់រំប្រសើរជាងមុន នេះជាវិធីដែលយូរៗទៅ នាំឲ្យប្រទេសមានការចម្រើន រុងរឿង។

មានគណបក្សនយោបាយមួយបានឲ្យយោបល់អំពីផែនការមួយ ដែលអាចអនុវត្តបាននៅក្នុងប្រទេសដទៃ។ និស្សិតទាំងឡាយដែលគ្មានលទ្ធភាពក្នុងការបង់ថ្លៃសិក្សានៅសាកលវិទ្យាល័យអាចខ្ចីប្រាក់ពីរដ្ឋាភិបាល ហើយសងរដ្ឋាភិបាលវិញជាដំណាក់កាលៗ នៅពេលដែលពួកគេចាប់ផ្តើមមានការងារធ្វើ និងមានប្រាក់ចំណូល។ គណបក្សនយោបាយដែលកំពុងកាន់អំណាចមានការបារម្ភ និងមិនគាំទ្រគំនិតមួយនេះទេ ព្រោះថា ផែនការនេះនឹងធ្វើឲ្យរដ្ឋាភិបាលត្រូវចំណាយច្រើន។

ក្រុមនិស្សិតបានសម្រេចចិត្តជួបជុំដើម្បីពិភាក្សាថាគួរគាំទ្រ ឬមិនគាំទ្រផែនការនេះ។ អ្នកគួរពិភាក្សា និងសរសេរមូលហេតុ ដែលអ្នកគាំទ្រ ឬមិនគាំទ្រផែនការនៃការកាត់បន្ថយថ្លៃបង់សាកលវិទ្យាល័យនេះ។

ក្រុមរបស់អ្នកបានសម្រេចចិត្តទាក់ទងស្ថានីយវិទ្យុដើម្បីសួរថា តើអ្នកអាចបញ្ចេញទស្សនៈរបស់អ្នក ក្នុងនាមជានិស្សិតក្នុងការគាំទ្រ ឬប្រឆាំងនឹងផែនការនោះបាន ឬមិនបាន។ អ្នកត្រូវបានអញ្ជើញឲ្យមកស្ថានីយវិទ្យុ ដែលអ្នកសារព័ត៌មាននឹងសួរសំណួរអ្នក ហើយអ្នកនឹងមានឱកាសក្នុងការឆ្លើយ។

សូមត្រៀមការសម្តែងតួសម្រាប់ការសម្ភាសន៍តាមវិទ្យុ ដោយមានសំណួរដែលពិធីករវិទ្យុសួរ និងមានចម្លើយដែលអ្នកត្រូវឆ្លើយ។

## សេចក្តីណែនាំសម្រាប់ក្រុមទី៣៖

រដ្ឋាភិបាលកំពុងពិភាក្សាវែកញែកអំពីបញ្ហានៃការបង់ថ្លៃរៀននៅសាកលវិទ្យាល័យ ។ ដោយសិស្សានុសិស្សដែលទើបបានប្រឡងបញ្ចប់ថ្នាក់មធ្យមសិក្សាទុតិយភូមិ គ្មានលទ្ធភាពចូលរៀននៅសកលវិទ្យាល័យ ដូច្នេះ រដ្ឋាភិបាលកំពុងពិភាក្សាដើម្បីរកវិធីបញ្ចុះថ្លៃរៀននៅសាកលវិទ្យាល័យ ដែលធ្វើដូច្នេះដើម្បីក្មេងជំនាន់ក្រោយអាចទទួលបានការអប់រំប្រសើរជាងមុន នេះជាវិធីដែលយូរៗទៅនាំឲ្យប្រទេសមានការចម្រើនរុងរឿង។

មានគណបក្សនយោបាយមួយបានឲ្យយោបល់អំពីផែនការមួយ ដែលអាចអនុវត្តបាននៅក្នុងប្រទេសដទៃ។ និស្សិតទាំងឡាយដែលគ្មានលទ្ធភាពក្នុងការបង់ថ្លៃរៀននៅសកលវិទ្យាល័យអាចខ្ចីប្រាក់ពីរដ្ឋាភិបាល ហើយសងរដ្ឋាភិបាលវិញជាដំណាក់កាលៗ នៅពេលដែលពួកគេចាប់ផ្តើមមានការងារធ្វើ និងមានប្រាក់ចំណូល។ គណបក្សនយោបាយដែលកំពុងកាន់អំណាចមានការបារម្ភ និងមិនគាំទ្រគំនិតមួយនេះទេ ព្រោះថា ផែនការនេះនឹងធ្វើឲ្យរដ្ឋាភិបាលត្រូវចំណាយច្រើន។

ក្រុមនិស្សិតបានសម្រេចចិត្តជួបជុំដើម្បីពិភាក្សាថា គួរគាំទ្រ ឬមិនគាំទ្រផែនការនេះ។ អ្នកគួរពិភាក្សា និងសរសេរមូលហេតុ ដែលអ្នកគាំទ្រ ឬមិនគាំទ្រផែនការនៃការកាត់បន្ថយថ្លៃបង់សាកលវិទ្យាល័យនេះ។

ក្រុមរបស់អ្នកបានសម្រេចចិត្តសរសេរលិខិតមួយ ទៅតំណាងរបស់អ្នកនៅក្នុងរដ្ឋាភិបាល ដើម្បីបង្ហាញ អំពីទស្សនៈរបស់អ្នកក្នុងនាមជានិស្សិត ដើម្បីគាំទ្រ ឬប្រឆាំងនឹងផែនការនោះ។ ក្រុមអ្នកសរសេរលិខិតនេះ និងធ្វើជូនទៅតំណាងរបស់អ្នក និងបង្ហាញហេតុផលនៃការគាំទ្រ ឬប្រឆាំងនឹងផែនការនោះ។

សូមត្រៀមការសម្តែងតួអំពីការជួបជាមួយតំណាងរបស់អ្នក និងការជូនលិខិតនោះទៅគាត់ព្រមទាំងការបង្ហាញអំពីហេតុផលរបស់អ្នក។

## *ក្រុមនគរបាលបានប៉ះទង្គិចជាមួយអ្នកភូមិដែលរស់នៅតំបន់បឹងកក់*

*កាលពីម្សិលមិញ ក្រុមនគរបាលបានរារាំងក្រុមអ្នកភូមិប្រហែល៥០០នាក់ដែលរស់នៅតំបន់បឹងកក់ មិនឲ្យជួបជុំគ្នាតាមការស្នើសុំទេ ហើយក្រោយមកក្រុមនគរបាលបានប្រើខែល និងដំបងធក់ដើម្បីបំបែកក្រុមបាតុកប្រហែល២០០ក្នុងក្រុម ដែលបានបន្តដំណើរទៅធ្វើការតវ៉ានៅខាងក្រៅផ្ទះនាយករដ្ឋមន្ត្រីហ៊ុនសែន។*

*អ្នកភូមិបឹងកក់ម្នាក់បាននិយាយថា អ្នកភូមិត្រូវបង្ខំចិត្តធ្វើបាតុកម្មដោយឥតគ្រោងទុកនេះ បន្ទាប់ពីអាជ្ញាធរឃុំស្រះចកបានរារាំងពួកគាត់មិនឲ្យជួបជុំគ្នាតាមការគ្រោងទុក នៅវិទ្យាស្ថានជាតិអប់រំដែលស្ថិតនៅក្បែរនោះ។ ក្រុមនគរបាល និងអ្នកភូមិបានប៉ះទង្គិចបន្តិចបន្តួចនៅពេលដែលបាតុករធ្វើដំណើរសំដៅទៅផ្ទះនាយករដ្ឋមន្ត្រីនៅក្បែរវិមានឯករាជ្យ។*

*"ពួកយើងមានគម្រោងជួបជុំគ្នាដើម្បីពិគ្រោះយោបល់គ្នាដោយសន្តិភាព នៅវិទ្យាស្ថានជាតិអប់រំ ប៉ុន្តែចៅសង្កាត់ឃុំស្រះចកបានហាមឃាត់យើងមិនឲ្យជួបជុំគ្នា ..."*

*គាត់បាននិយាយថា ក្រុមអ្នកភូមិមិនបានធ្វើការប្រឆាំងនឹងអ្នកណាម្នាក់ជាក់លាក់ ក្រៅពីបញ្ជាក់ការពិតថា ពួកគាត់ "ត្រូវការដំណោះស្រាយមួយពីរដ្ឋាភិបាល ព្រោះថា លំនៅដ្ឋានរបស់ប្រជាពលរដ្ឋកំពុងតែលិចជ្រៅទៅៗ"។*

*អ្នកភូមិបានភ្ជាប់រឿងលិចទឹកនេះទៅនឹងការបូមដីបំពេញបឹង ដើម្បីអភិវឌ្ឍន៍លើដីទំហំ១៣៣ហិកតារដែលកំពុងមានវិវាទនោះ។ ក្រុមសិទ្ធិមនុស្សបានវាយតម្លៃថា នៅទីបំផុត ប្រជាពលរដ្ឋប្រហែលជាង៤០០០គ្រួសារនឹងត្រូវគេបណ្ដេញចេញដើម្បីយកដីសម្រាប់គម្រោងអភិវឌ្ឍន៍នេះ។*

*នៅក្នុងសេចក្ដីថ្លែងការណ៍មួយកាលពីម្សិលមិញ ក្រុមការងារពិសេសសិទ្ធិលំនៅដ្ឋាន បានរិះគន់យ៉ាងធ្ងន់ៗអំពីការរារាំងការជួបជុំ ដែលតាមសេចក្ដីថ្លែងការណ៍នេះថា មានគម្រោងគ្រាន់តែជាវេទិកាមួយដើម្បីពិភាក្សាពីតម្រូវការរបស់អ្នករស់នៅបឹងកក់ ដើម្បីកុំឲ្យមានការបណ្ដេញពួកគេចេញពីលំនៅដ្ឋានរបស់ពួកគាត់ដោយបង្ខំ និងដើម្បីទទួលបានសំណងជាលំនៅដ្ឋានសមរម្យជាការប្ដូរនឹងការរុះរើទៅកន្លែងថ្មីតែប៉ុណ្ណោះ។*

*សេចក្ដីថ្លែងការណ៍នោះ បានបញ្ជាក់ថា "ក្រុមការងារពិសេសសិទ្ធិលំនៅដ្ឋាន សូមអំពាវនាវទៅអាជ្ញាធរ មេត្តាចុះស៊ើបអង្កេតព្រឹត្តិការណ៍នេះ ព្រោះថា ការរារាំងបែបនេះជាការរំលោភបំពានសិទ្ធិប្រជាពលរដ្ឋក្នុងការជួបជុំគ្នា ព្រមទាំងសូមឲ្យអាជ្ញាធរ មេត្តាគោរពសិទ្ធិមនុស្ស ដូចមានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាផង"។*

***អត្ថបទនេះដកស្រង់ចេញពីកាសែតភ្នំពេញប៉ុស្តិ៍ ដែលចុះផ្សាយ នៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១០***

## ៧. សិទ្ធិក្រុមភាគតិច

នៅក្នុងលទ្ធិប្រជាធិបតេយ្យ គណបក្សនយោបាយណាដែលទទួលបានសន្លឹកឆ្នោតភាគច្រើន គឺជាអ្នកដែលបង្កើតរដ្ឋាភិបាល។ ប្រព័ន្ធបែបនេះជួយធ្វើឲ្យប្រាកដថា គុណតម្លៃ និងផលប្រយោជន៍របស់ប្រជាពលរដ្ឋភាគច្រើន ត្រូវបានតំណាងដោយរដ្ឋាភិបាល។ ចុះចំណែកប្រជាពលរដ្ឋក្រុមភាគតិចវិញ? ចុះប្រសិនបើប្រជាពលរដ្ឋភាគច្រើនមានបំណងចង់បំពានសិទ្ធិរបស់ប្រជាពលរដ្ឋក្រុមភាគតិច ដែលរដ្ឋាភិបាលមិនបានការពារត្រឹមត្រូវវិញ វាយ៉ាងម៉េចដែរ?



នៅក្នុងលទ្ធិប្រជាធិបតេយ្យ រដ្ឋាភិបាលត្រូវតែការពារសិទ្ធិរបស់មនុស្សក្រុមភាគតិចនេះ។ ជាទូទៅប្រព័ន្ធបែបនេះគេច្រើនតែនិយាយថា "គោលការណ៍មតិភាគច្រើន សិទ្ធិក្រុមភាគតិច" ដែលទាំងពីជាធាតុយ៉ាងសំខាន់នៅក្នុងលទ្ធិប្រជាធិបតេយ្យ។

បុគ្គលទាំងអស់ដែលស្ថិតនៅក្នុងក្រុមប្រជាពលរដ្ឋភាគតិច មិនថា ដោយសារជា ជនជាតិភាគតិច សាសនា ឬជំនឿនយោបាយ ឬកម្រិតទ្រព្យសម្បត្តិ ឬមិនថា ឋានៈក្នុងសង្គមទេ សុទ្ធតែមានសិទ្ធិដូចជាអ្នកដទៃដែរ។ ឧទាហរណ៍ៈ ប្រជាពលរដ្ឋទាំងអស់នៃក្រុមមនុស្សភាគតិចនៅក្នុងសង្គម មានសិទ្ធិក្នុងការប្រតិបត្តិសាសនារបស់ខ្លួន សិទ្ធិក្នុងការនិយាយភាសារបស់ខ្លួន សិទ្ធិក្នុងការបញ្ចេញមតិរបស់ខ្លួន និងសិទ្ធិក្នុងការបោះឆ្នោតជ្រើសរើសតំណាងរបស់ខ្លួន។ គ្មានអ្នកណាអាចបង្ខំ ប្រជាពលរដ្ឋនៅក្នុងក្រុមភាគតិចឲ្យផ្លាស់ប្តូរទស្សនៈនយោបាយ សាសនា ឬគុណតម្លៃរបស់ពួកគាត់ ឲ្យដូចគ្នានឹងក្រុមមនុស្សភាគច្រើនបានឡើយ។

ទោះបីជាមានការគាំទ្រដោយមតិភាគច្រើនក៏ដោយ ក៏គ្មានរដ្ឋាភិបាលណាអាចដកហូតសិទ្ធិរបស់ប្រជាពលរដ្ឋនៅក្នុងក្រុមមនុស្សភាគតិចនោះទេ។ រដ្ឋាភិបាលប្រជាធិបតេយ្យដឹងថា កាតព្វកិច្ចរបស់ខ្លួនគឺការពារសិទ្ធិរបស់ក្រុមភាគតិច។

## សិទ្ធិក្រុមភាគតិចនៅប្រទេសកម្ពុជា

ជនជាតិចាម ដែលជាក្រុមជនជាតិភាគតិច មានប្រហែល៧%នៃប្រជាពលរដ្ឋទាំងអស់នៅក្នុងប្រទេស កម្ពុជា។ ប្រជាពលរដ្ឋភាគច្រើននៅក្នុងប្រទេសកម្ពុជា កាន់សាសនាព្រះពុទ្ធ តែជនជាតិចាមកាន់សាសនាឥស្លាម។ នៅក្រោមច្បាប់ប្រទេសកម្ពុជា និងច្បាប់អន្តរជាតិ ជនជាតិចាមមានសិទ្ធិក្នុងការកាន់សាសនារបស់ពួកគេដោយសុខសាន្ត មានសិទ្ធិក្នុងការបញ្ចេញមតិ និងសិទ្ធិក្នុងការបោះឆ្នោតដោយសេរី។ គេមិនត្រូវរើសអើង ប្រឆាំងនឹងពួកគាត់ ក្នុងការការពារសិទ្ធិទាំងនេះ ឬសិទ្ធិផ្សេងឡើយ។

មានជនជាតិភាគតិចជាច្រើនក្រុមនៅប្រទេសកម្ពុជា ដូចជា ភ្នង និងចារ៉ាយ ដែលជាជនជាតិភាគតិចនៅក្នុងចំណោមប្រជាពលរដ្ឋទាំងអស់។ ក្រុមទាំងអស់នេះមានវប្បធម៌ និយាយភាសាខុសពីប្រជាពលរដ្ឋផ្សេងៗទៀត។ វប្បធម៌របស់ពួកគាត់ត្រូវបានប្រតិបត្តិ និងជឿតៗគ្នាពីជំនាន់មួយទៅជំនាន់មួយ។ ជនជាតិដើមភាគតិចទាំងអស់នេះមានសិទ្ធិក្នុងការបន្ត របៀបរបបរស់នៅរបស់ពួកគាត់ និងការប្រតិបត្តិវប្បធម៌ និងជំនឿរបស់ពួកគាត់ដោយសុខសាន្ត ហើយក្រុមមនុស្សភាគច្រើន ឬរដ្ឋាភិបាលមិនត្រូវរំលោភសិទ្ធិទាំងនេះទេ។





## ៨. នីតិរដ្ឋ

នៅក្នុងលទ្ធិប្រជាធិបតេយ្យ ការប្រើអំណាចដោយរដ្ឋាភិបាល ត្រូវតែស្ថិតនៅក្នុងដែនកំណត់មួយ ដែលកំណត់ដោយច្បាប់ និងរដ្ឋធម្មនុញ្ញ ដែលជាច្បាប់កំពូលរបស់ប្រទេស។

នៅក្នុងលទ្ធិប្រជាធិបតេយ្យ៖

- គ្មានអ្នកណាធំជាងច្បាប់ទេ
- គ្រប់គ្នាត្រូវតែមានកាតព្វកិច្ចគោរពច្បាប់ និង
- គ្រប់គ្នាមានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់

គោលការណ៍នេះត្រូវបានគេស្គាល់ថាជា **នីតិរដ្ឋ**។ **នីតិរដ្ឋ**ជួយរក្សាសណ្តាប់ធ្នាប់នៅក្នុងសង្គម និងការពារសិទ្ធិរបស់ប្រជាពលរដ្ឋកុំឲ្យមានការរំលោភអំណាច។ នៅក្នុងលទ្ធិប្រជាធិបតេយ្យ ច្បាប់ត្រូវតែឆ្លុះបញ្ចាំងពីគុណតម្លៃ និងផលប្រយោជន៍របស់ប្រជាពលរដ្ឋដែលបានផ្តល់សិទ្ធិអំណាចដល់រដ្ឋាភិបាលក្នុងការបង្កើតច្បាប់ ដោយការបោះឆ្នោត មិនមែនឆ្លុះបញ្ចាំងត្រឹមតែបុគ្គលមានអំណាចតែពីរ-បីនាក់នោះទេ។ ច្បាប់ទាំងអស់ត្រូវតែមានន័យច្បាស់លាស់ អាចឲ្យប្រជាពលរដ្ឋទូទៅយល់បានដោយងាយស្រួល។

គោលការណ៍នីតិរដ្ឋមានន័យថា គ្មានអ្នកណាធំជាងច្បាប់ទេ ដែលរួមមានអ្នកដឹកនាំរដ្ឋ (សមាជិកនៃរដ្ឋាភិបាល) រដ្ឋមន្ត្រីគ្រប់ក្រសួង មន្ត្រីរដ្ឋាភិបាល និងស្ថាប័ននានាមិនអាចធំជាងច្បាប់ឡើយ។ រដ្ឋាភិបាលមិនអាចធ្វើអ្វីៗតាមចិត្ត និងប្រើអំណាចរបស់ខ្លួនមិនត្រឹមត្រូវ ឬរំលោភអំណាចរបស់ខ្លួនឡើយ។ នៅក្នុងប្រទេសដែលមិនកាន់លទ្ធិប្រជាធិបតេយ្យ រដ្ឋាភិបាលធ្វើសកម្មភាពក្រៅច្បាប់ដោយគ្មានអ្នកណាដាក់ទណ្ឌកម្ម ព្រមទាំងប្រើច្បាប់ជាឧបករណ៍ក្នុងការការពារផលប្រយោជន៍ផ្ទាល់ខ្លួន។ ឧទាហរណ៍៖ នៅក្នុងរបបផ្តាច់ការប្រទេសមួយត្រូវបានគ្រប់គ្រងដោយបុគ្គលតែម្នាក់ ឬមនុស្សមួយក្រុមតូច និងមិនមែនគ្រប់គ្រងតាមច្បាប់ទេ។



គោលការណ៍នីតិរដ្ឋមានន័យថា ច្បាប់អនុវត្តស្មើភាពគ្នាចំពោះមនុស្សគ្រប់រូប។ នេះមិនមែនគិតតែប្រជាពលរដ្ឋសាមញ្ញនៅក្នុងសង្គមនោះទេ ប៉ុន្តែរាប់ទាំងនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីដទៃទៀត ក្រុមនគរបាល និងតុលាការថែមទៀតផង។ មានន័យថា ប្រសិនអ្នកណាម្នាក់ធ្វើអ្វីខុសច្បាប់ អ្នកនោះនឹងត្រូវដាក់ទោសទៅតាមច្បាប់ ដោយមិនចាំបាច់គិតថា អ្នកធ្វើខុសច្បាប់នោះជាអ្នកដែលមានអំណាច ឬអ្នកមានទ្រព្យសម្បត្តិទេ គឺទាំងអស់គ្នាត្រូវតែគោរពច្បាប់។

គោលការណ៍នីតិរដ្ឋក៏មានន័យដែរថា មនុស្សគ្រប់រូបមានសិទ្ធិស្មើគ្នាទៅតាមផ្លូវច្បាប់។ សិទ្ធិស្មើគ្នាមាន២យ៉ាងគឺ៖ ទីមួយ មនុស្សគ្រប់រូបត្រូវស្ថិតនៅក្រោមច្បាប់ដូចគ្នា និងត្រូវទទួលទោសដូចគ្នា ប្រសិនបើអ្នកធ្វើខុសច្បាប់ មិនថា អ្នកធ្វើខុសច្បាប់នោះជាអ្នកក្រ ឬអ្នកមានទ្រព្យសម្បត្តិនោះទេ គឺមនុស្សគ្រប់រូបត្រូវទទួលទោសដូចគ្នា។ ឧទាហរណ៍៖ ប្រសិនបើ ចោរលួចម៉ូតូត្រូវដាក់ទោសឲ្យជាប់ពន្ធនាគាររយៈពេល៥ឆ្នាំ ដូច្នេះ ការដាក់ទោសបែបនេះគឺត្រូវអនុវត្តដូចគ្នាចំពោះមនុស្សគ្រប់រូបពីបទលួចម៉ូតូ។ អ្នកដែលមានទ្រព្យសម្បត្តិមិនត្រូវឲ្យរួចផុតពីការពន្ធនាគារ ឬត្រូវបន្ថយទោសដោយសារតែគេមានប្រាក់នោះឡើយ។ ដូចគ្នានេះដែរ ក៏មិនត្រូវមានច្បាប់សម្រាប់អនុវត្តចំពោះតែបុគ្គលពីរ-នាក់ ឬមនុស្សមួយក្រុមតូចនោះទេ។ មិនត្រូវដាក់ទោសប្រជាពលរដ្ឋខុសគ្នាតាមច្បាប់ ដោយសារតែពួកគាត់ជាអ្នកណា ឬស្ថិតនៅក្នុងក្រុមមួយណានោះទេ គឺត្រូវតែអនុវត្តច្បាប់ចំពោះមនុស្សគ្រប់រូបដូចៗគ្នា មិនថាអ្នកនោះជាកសិករក្រីក្រ ឬជានាយករដ្ឋមន្ត្រីក៏ដោយ។



ទីពីរ ដូចគ្នានឹងការដែលត្រូវស្ថិតនៅក្រោមច្បាប់ដែរ ប្រជាពលរដ្ឋទាំងអស់មានសិទ្ធិទទួលបានការការពារស្មើគ្នាតាមផ្លូវច្បាប់។ គោលការណ៍នេះមានសារៈសំខាន់ ជាពិសេស សម្រាប់ការពារសិទ្ធិរបស់សមាជិកនៅក្នុងក្រុមភាគតិច ឬក្រុមដែលទន់ខ្សោយ។ ឧទាហរណ៍៖ មនុស្សគ្រប់រូបត្រូវតែមានសិទ្ធិទទួលបានការការពារតាមរដ្ឋធម្មនុញ្ញ ដោយគ្មានការរើសអើងឡើយ។ គោលការណ៍នេះមានន័យថានគរបាល និងមន្ត្រីតុលាការត្រូវប្រព្រឹត្តចំពោះប្រជាពលរដ្ឋគ្រប់រូបដោយស្មើភាពគ្នា។ ប្រសិនបើអ្នកណាម្នាក់ជាជនរងគ្រោះដោយសារបទព្រហ្មទណ្ឌណាមួយ ដូចជា បទចោរកម្មជាដើម ដូច្នេះនគរបាលត្រូវតែធ្វើអ្វីៗគ្រប់យ៉ាងដើម្បី

រកចោរនោះយកមកកាត់ទោស។ នគរបាលត្រូវតែផ្តល់ពេលវេលា និងធនធានដូចគ្នាដើម្បីជួយដល់រងគ្រោះគ្រប់រូប។ ក្រុមនគរបាលមិនត្រូវផ្តល់អាទិភាពទៅជនរងគ្រោះណាម្នាក់ ដែលមានទ្រព្យសម្បត្តិ ឬមានអំណាចនោះទេ។ គោលការណ៍នេះក៏មានន័យដែរថា ប្រសិនបើអ្នកណាម្នាក់ត្រូវបានចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយ នោះគាត់ក៏មានសិទ្ធិទទួលបានការកាត់ក្តីដោយយុត្តិធម៌ ដោយមិនគិតថា គាត់មានឋានៈអ្វីនៅក្នុងសង្គមទេ។



| រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា |
|---|
| រដ្ឋធម្មនុញ្ញគឺជាច្បាប់កំពូលនៅក្នុងប្រទេសកម្ពុជា។ រដ្ឋធម្មនុញ្ញចែងអំពីប្រព័ន្ធរបស់រដ្ឋាភិបាលនៃប្រទេសកម្ពុជា និងអំពីអំណាច និងមុខងារផ្សេងៗនៅក្នុងជួររដ្ឋាភិបាល។ រដ្ឋធម្មនុញ្ញនេះចែងអំពីសិទ្ធិរបស់ប្រជាពលរដ្ឋកម្ពុជា និងដាក់ចេញនូវភារកិច្ចដែលរដ្ឋាភិបាលត្រូវបំពេញ។ រដ្ឋធម្មនុញ្ញត្រូវបានអនុម័ត និងប្រកាសឲ្យប្រើប្រាស់ នៅឆ្នាំ១៩៩៣។ រដ្ឋធម្មនុញ្ញត្រូវបានធ្វើវិសោធនកម្ម ឬមានការកែប្រែខ្លះនៅឆ្នាំ១៩៩៩។<br><br>ច្បាប់ និងសកម្មភាពទាំងអស់របស់រដ្ឋាភិបាលត្រូវតែគោរពទៅតាមរដ្ឋធម្មនុញ្ញ។ ស្ថាប័ន ឬមន្ត្រីរដ្ឋាភិបាល មិនត្រូវអនុម័តច្បាប់និងធ្វើសេចក្តីសម្រេចចិត្តណាមួយដែលផ្ទុយនឹងរដ្ឋធម្មនុញ្ញឡើយ។ មានស្ថាប័នការពិសេសមួយដែលហៅថា **ក្រុមប្រឹក្សាធម្មនុញ្ញ** ដែលមានតួនាទីក្នុងការពិនិត្យច្បាប់ឡើងវិញ ដើម្បីឲ្យប្រាកដថា ច្បាប់ទាំងនោះមិនផ្ទុយនឹងរដ្ឋធម្មនុញ្ញទេ[១៧]។<br><br>រដ្ឋធម្មនុញ្ញ ក៏អាចត្រូវកែប្រែដែរ ប្រសិនបើមានសំលេង២/៣ (៦៦%) នៃសមាជិករដ្ឋសភា បោះឆ្នោតធ្វើវិសោធនកម្ម[១៨]។ ទោះបីជាយ៉ាងនេះក៏ដោយ ក៏ត្រូវតែមានការកំណត់អំពីអ្វីដែលត្រូវនឹងកែប្រែដែរ។ ជាធម្មតាច្បាប់គ្រាន់តែតម្រូវឲ្យមានសំឡេងភាគច្រើន (៥១%) ដើម្បីអនុម័ត ឬកែប្រែ។ |

[១៧] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ មាត្រា១៤០ ១៤១ និង១៤២។

[១៨] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ មាត្រា១៥១។

# មេរៀនទី៩៖ សិទ្ធិក្រុមភាគតិច និងនីតិរដ្ឋ

**គោលបំណង៖ អ្នកចូលរួមនឹងយល់ដឹងថា នៅក្នុងលទ្ធិប្រជាធិបតេយ្យ សិទ្ធិក្រុមភាគតិចត្រូវតែទទួលបានការការពារ។ ពួកគាត់ក៏នឹងយល់ដឹងអំពីគោលការណ៍នៃនីតិរដ្ឋដែរ។**

**សម្ភារ:៖** ក្រដាសផ្ទាំងធំ ឬក្តារខៀន ហ្វឺតពណ៌។

**វិធីសាស្ត្រ៖** ល្បែង ការបំផុសគំនិត ការពិភាក្សាជជែកវែកញែក។

| ដំណើរការ | រយៈពេល (គិតជានាទី) |
|---|---|
| ១. ល្បែងស្មើភាពគ្នា | ១៥ |
| ២. ណែនាំព័ត៌មាននៅក្នុងផ្នែកទី៧ | ១៥ |
| ៣. ការបំផុសគំនិតអំពីក្រុមភាគតិចនៅប្រទេសកម្ពុជា | ១០ |
| ៤. ណែនាំព័ត៌មាននៅក្នុងផ្នែកទី៨ | ២០ |
| ៥. សង្ខេបសកម្មភាពពិភាក្សាជជែកវែកញែក | ២០ |
| **សរុប៖** | ៨០ |

## ការណែនាំសម្រាប់អ្នកសម្របសម្រួល

### ១. ល្បែងស្មើភាពគ្នា

- ចែកអ្នកចូលរួមជា២ក្រុម។ ក្រុមមួយមានអ្នកចូលរួមភាគច្រើន និងក្រុមមួយទៀតមានអ្នកចូលរួមតែពីរ-បីនាក់ប៉ុណ្ណោះ។ សូមពន្យល់ថា ក្រុមធំគឺជាដំរី ហើយក្រុមតូចគឺជាពពែ។
- សូមប្រាប់អ្នកចូលរួមថា ពួកគាត់នឹងលេងល្បែងមួយ ដែលពួកគាត់ត្រូវតែឈរជើងម្ខាងរហូតដល់ចប់ ល្បែងនេះ។ ប្រសិនបើអ្នកណាម្នាក់បាត់បង់លំនឹងឈរ ហើយដាក់ជើងម្ខាងទៀតចុះប៉ះដី នោះគាត់ត្រូវ "ចេញ" ពីក្រុម។ ក្រុមណាដែលនៅសល់អ្នកឈរច្រើនជាងគេនៅចុងបញ្ចប់នៃល្បែងនេះនឹងទទួលជ័យជំនះ។
- សូមឲ្យអ្នកចូលរួមម្នាក់ៗឈរជើងម្ខាង ហើយពីរ-បីវិនាទីក្រោយមក សូមឲ្យក្រុមទាំងពីរលោតជើងមួយ។
- ពីរ-បីវិនាទីក្រោយមកទៀត សូមប្រាប់ឲ្យក្រុមដំរីឈប់លោត ប៉ុន្តែក្រុមពពែនៅតែបន្តលោត។ បន្ទាប់មកនិយាយថា ក្រុមដំរីអាចសម្រាក៥វិនាទី ហើយអាចដាក់ជើងទាំងពីរលើដីបាន។ បន្ទាប់មកសូមប្រាប់ឲ្យក្រុមពពែយកដៃម្ខាងទះក្បាលស្រាលៗ និងដៃម្ខាងទៀតអង្អែលក្បាលពោះរបស់គាត់។ បន្ទាប់មកទៀត សូមប្រាប់ក្រុមដំរី និងក្រុមពពែឲ្យលោតពីម្ខាងទៅម្ខាង ប៉ុន្តែក្រុមពពែត្រូវតែបិទភ្នែកនៅពេលដែលលោត។
- សូមប្រាប់សមាជិកក្រុមដំរីណាដែលត្រូវដកចេញថា ពួកគាត់មានឱកាសលើកទីពីរ។
- ចុងបញ្ចប់សូមប្រាប់ក្រុមពពែថា ពួកគាត់ទាំងអស់ត្រូវដកចេញ ដោយសារតែអ្នកសម្របសម្រួលមិនចូលចិត្តក្រុមពពែ។
- បន្ទាប់ពីបញ្ចប់ល្បែងនេះ អ្នកសម្របសម្រួលត្រូវជួយសម្របសម្រួលការពិភាក្សាអំពីល្បែងនេះដោយសួរសំណួរដូចខាងក្រោមនេះ៖
    - តើអ្នកទាំងអស់គ្នាយល់យ៉ាងណាចំពោះល្បែងនេះ? តើអ្នកទាំងអស់គ្នាគិតថា វាយុត្តិធម៌ទេ? ហេតុអ្វីមិនយុត្តិធម៌?
    - តើក្រុមពពែដែលជាក្រុមភាគតិច មានអារម្មណ៍ដូចម្តេចនៅពេលលេងល្បែងនេះ?
    - តើក្រុមដំរីដែលជាក្រុមភាគច្រើនមានអារម្មណ៍ដូចម្តេចនៅពេលលេងល្បែងនេះ?
    - តើអ្នកទាំងអស់គ្នាគិតយ៉ាងណាចំពោះបទបញ្ញាទាំងនេះ? តើបទបញ្ញាទាំងនោះត្រូវបានអនុវត្តដោយស្មើភាពគ្នាទេ?

## ២. ណែនាំព័ត៌មាននៅក្នុងផ្នែកទី៧ (សូមមើលទំព័រទី៩៧ ដល់ទី៩៨)

**ផ្នែកទី៧៖** វាមានសារៈសំខាន់ណាស់ដែលអ្នកចូលរួមយល់ដឹងថា៖

- នៅក្នុងលទ្ធិប្រជាធិបតេយ្យ រដ្ឋាភិបាលត្រូវការពារសិទ្ធិរបស់ក្រុមភាគតិច
- ប្រជាពលរដ្ឋគ្រប់រូបដែលស្ថិតនៅក្នុងក្រុមភាគតិច ក្នុងចំណោមប្រជាពលរដ្ឋទាំងអស់ គឺមានសិទ្ធិមនុស្សស្មើៗគ្នា ដូចអ្នកដទៃទៀតដែរ។
- មានក្រុមភាគតិចច្រើនប្រភេទនៅក្នុងចំណោមប្រជាពលរដ្ឋទាំងអស់
- ទោះបីជាមានការគាំទ្រភាគច្រើនក៏ដោយ ក៏រដ្ឋាភិបាលមិនអាចដកហូតសិទ្ធិរបស់ប្រជាពលរដ្ឋនៅក្នុងក្រុមភាគតិចណាមួយបានឡើយ។

## ៣. ការបំផុសគំនិតអំពីក្រុមភាគតិចនៅប្រទេសកម្ពុជា៖

- សូមសួរអ្នកចូលរួមថា តើពួកគាត់អាចនឹកកេក្រុមភាគតិចណាមួយនៅក្នុងប្រទេសកម្ពុជាបានដែរឬទេ។ សូមសួរថា តើគាត់ដឹងអ្វីខ្លះអំពីក្រុមភាគតិចទាំងនេះ។ អ្នកសម្របសម្រួលអាចសួរអ្នកចូលរួមថា តើមានអ្នកណាដែលស្ថិតនៅក្នុងក្រុមភាគតិចណាមួយដែរឬទេ និងមានបទពិសោធន៍យ៉ាងណាដែរ។ តើពួកគាត់គិតថា សិទ្ធិរបស់ពួកគាត់មានគេគោរពទេ។
- អានឲ្យលឺៗ ឬពន្យល់ខ្លឹមសារនៅក្នុងប្រអប់អំពីសិទ្ធិរបស់ក្រុមភាគតិចនៅប្រទេសកម្ពុជា។
- សូមសួរអ្នកចូលរួមថា តើពួកគាត់គិតថា រដ្ឋាភិបាល និងក្រុមភាគច្រើនគួរតែគោរពសិទ្ធិរបស់ក្រុមភាគតិចទាំងអស់នេះទេ? ហេតុអ្វីត្រូវ ឬមិនត្រូវគោរព?

## ៤. ណែនាំព័ត៌មាននៅក្នុងផ្នែកទី៨ (សូមមើលទំព័រទី៩៩ ដល់ទី១០១)

**ផ្នែកទី៨៖** វាមានសារៈសំខាន់ណាស់ដែលអ្នកចូលរួមយល់ដឹងថា៖

- នៅក្នុងលទ្ធិប្រជាធិបតេយ្យ ការប្រើប្រាស់អំណាចដោយរដ្ឋាភិបាលត្រូវតែមានដែនកំណត់មួយដែលបញ្ញត្តិដោយច្បាប់ និងរដ្ឋធម្មនុញ្ញ។
- នីតិរដ្ឋជួយរក្សាឲ្យមានសណ្តាប់ធ្នាប់នៅក្នុងសង្គម និងការពារសិទ្ធិរបស់ប្រជាពលរដ្ឋមិនឲ្យមានការប្រើអំណាចមិនត្រឹមត្រូវ។
- គោលការណ៍នៃនីតិរដ្ឋមានន័យថា គ្មានអ្នកណាធំជាងច្បាប់ទេ រួមទាំងរដ្ឋាភិបាលផង។
- គោលការណ៍នៃនីតិរដ្ឋក៏មានន័យដែរថា ច្បាប់អនុវត្តស្មើភាពគ្នាចំពោះមនុស្សគ្រប់រូប រួមទាំងនាយក

រដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងនានា មន្ត្រីនគរបាល ចៅក្រម និងអ្នកមានស្តុកស្តម្ភ។

- គោលការណ៍នៃនីតិរដ្ឋក៏មានន័យដែរថា មនុស្សគ្រប់រូបមានស្មើៗគ្នាតាមផ្លូវច្បាប់។
- មនុស្សគ្រប់រូបត្រូវស្ថិតនៅក្រោមច្បាប់ដូចគ្នា និងត្រូវទទួលទោសដូចគ្នា ប្រសិនបើគេប្រព្រឹត្តខុសច្បាប់។
- ប្រជាពលរដ្ឋគ្រប់រូបមានសិទ្ធិពេញលេញក្នុងការទទួលបានការការពារស្មើគ្នាតាមផ្លូវច្បាប់។

## ៥. សង្ខេបសកម្មភាពពិភាក្សាជជែកវែកញែក

- សុំឲ្យអ្នកចូលរួមឈរនៅកណ្តាលបន្ទប់ និងពន្យល់ថា អ្នកសម្របសម្រួលនឹងអានសេចក្តីថ្លែងការណ៍មួយឮខ្លាំងៗ រួចសួរពួកគាត់ថា តើពួកគាត់យល់ស្រប ឬមិនយល់ស្រប។
- ប្រសិនបើពួកគាត់យល់ស្រប ពួកគាត់គួរខិតទៅផ្នែកខាងស្តាំនៃបន្ទប់។ ប្រសិនបើពួកគាត់មិនយល់ស្របទេ ពួកគាត់ត្រូវខិតទៅផ្នែកខាងឆ្វេងនៃបន្ទប់។
- សូមអានសេចក្តីថ្លែងការណ៍ដូចខាងក្រោម៖

*"នាយករដ្ឋមន្ត្រីមិនត្រូវមានកាតព្វកិច្ចត្រូវគោរពច្បាប់ ឬត្រូវហាមប្រាមដោយច្បាប់ ក្នុងការសម្រេចចិត្ត ឬធ្វើសកម្មភាពរបស់គាត់ទេ ព្រោះគាត់ជាអ្នកដឹកនាំ និងដឹងនូវអ្វីដែលល្អបំផុតសម្រាប់ប្រទេស ច្បាប់គឺរាំខានគាត់មិនឲ្យសម្រេចកិច្ចការអ្វីបានតែប៉ុណ្ណោះ។"*

- សូមទុកពេលឲ្យអ្នកចូលរួមដើម្បីជ្រើសរើសថា តើពួកគេយល់ស្រប ឬមិនយល់ស្រប។ បន្ទាប់ពីអ្នកចូលរួមបានខិតទៅខាងឆ្វេង ឬខាងស្តាំបន្ទប់ហើយ សូមសួរអ្នកចូលរួមពីរ-បីនាក់ថា តើហេតុអ្វីបានជាគាត់យល់ស្រប ឬមិនយល់ស្របនឹងសេចក្តីថ្លែងការណ៍នោះ។ សូមជួយសម្របសម្រួលឲ្យមានការពិភាក្សាយ៉ាងសកម្មមួយ ប្រសិនបើ ពួកគាត់មិនយល់ស្របគ្នាទេ។ ប្រសិនបើគ្រប់គ្នាមិនយល់ស្របនឹងសេចក្តីថ្លែងការណ៍នេះ សូមឲ្យអ្នកចូលរួមពីរ-បីនាក់ពន្យល់ថា ហេតុអ្វីបានជាមិនយល់ស្រប។
- សូមរំលឹកអ្នកចូលរួមថា នីតិរដ្ឋមានន័យថា គ្មានអ្នកណាម្នាក់ធំជាងច្បាប់ទេ និងមនុស្សគ្រប់គ្នារួមទាំង នាយករដ្ឋមន្ត្រីផងក៏ត្រូវមានកាតព្វកិច្ចត្រូវគោរពច្បាប់ដែរ និងថា គោលការណ៍នេះ គឺជាផ្នែកមួយយ៉ាងសំខាន់នៅក្នុងលទ្ធិប្រជាធិបតេយ្យ ដើម្បីទប់ស្កាត់ចំពោះការប្រើអំណាចមិនត្រឹមត្រូវ។
- សូមឲ្យអ្នកចូលរួមទាំងអស់ត្រលប់មកឈរនៅកណ្តាលបន្ទប់វិញ ហើយធ្វើដូចគ្នាចំពោះសេចក្តីថ្លែងការណ៍ខាងក្រោមនេះ៖

*"នៅក្នុងលទ្ធិប្រជាធិបតេយ្យ រដ្ឋាភិបាលត្រូវតែធ្វើសកម្មភាពណាដែលមានប្រយោជន៍សម្រាប់ក្រុមភាគច្រើនជានិច្ច ទោះបីជាសកម្មភាពនោះធ្វើឲ្យមានគ្រោះថ្នាក់ដល់ក្រុមភាគតិចក៏ដោយ។ ឧទាហរណ៍៖ រដ្ឋាភិបាលអាចបង្កើតច្បាប់ដែលតម្រូវឲ្យគ្រប់គ្នាគោរព សាសនាព្រះពុទ្ធ ព្រោះវានឹងបង្កើត ឲ្យមានសាសនាដែលមានសុខដុមរមនា និងឯកភាពគ្នានៅក្នុងសង្គម។*

- បន្ទាប់ពីអ្នកសម្របសម្រួលបានសួរអ្នកចូលរួមពីរ-បីនាក់ថា ហេតុអ្វីបានជាពួកគាត់យល់ស្រប ឬមិនយល់ស្របហើយ សូមរំលឹកពួកគាត់ថា នៅក្នុងលទ្ធិប្រជាធិបតេយ្យ រដ្ឋាភិបាលត្រូវតែការពារសិទ្ធិរបស់ក្រុមភាគតិច រួមទាំង សាសនារបស់ក្រុមភាគតិចផង។ រដ្ឋាភិបាលមិនអាចបង្ខំឲ្យអ្នកដែលមិនកាន់សាសនាព្រះពុទ្ធ ឲ្យប្រតិបត្តិសាសនាព្រះពុទ្ធទេ។
- សូមឲ្យអ្នកចូលរួមទាំងអស់ត្រលប់មកឈរនៅកណ្តាលបន្ទប់វិញ ហើយធ្វើដូចគ្នាចំពោះសេចក្តីថ្លែងការណ៍ដូចខាងក្រោម៖

*ប្រសិនបើអ្នកធ្វើខុសច្បាប់ ទោះបីជាច្បាប់នោះតូចតាចប៉ុន្មានក៏ដោយ ក៏ក្រុមគ្រួសាររបស់អ្នកមិនត្រូវបង់ប្រាក់ឲ្យនគរបាលដើម្បីដោះស្រាយបញ្ហាឬបន្ថយទោសឡើយ។"*

- បន្ទាប់ពីអ្នកសម្របសម្រួលបានសួរអ្នកចូលរួមពីរ-បីនាក់ថា ហេតុអ្វីបានជាពួកគាត់យល់ស្រប ឬមិនយល់ស្របហើយ សូមរំលឹកពួកគាត់ថា នៅក្នុងលទ្ធិប្រជាធិបតេយ្យ មនុស្សទាំងអស់គឺស្ថិតនៅក្រោមច្បាប់ស្មើគ្នា។ អ្នកដែលមានទ្រព្យសម្បត្តិមិនគេចផុតពីការដាក់ទោសទេ នៅពេលដែលគេប្រព្រឹត្តខុសច្បាប់ ព្រមទាំងត្រូវទទួលទោសស្មើគ្នាដូចអ្នកដទៃទៀតដែរ។

# ៩. ការបែងចែកអំណាច

## ៩.១ ស្ថាប័ននានារបស់រដ្ឋាភិបាល

នៅក្នុងលទ្ធិប្រជាធិបតេយ្យ រដ្ឋាភិបាលមានបីស្ថាប័ន ដែលមានមុខងារដោយឡែកពីគ្នា ប៉ុន្តែមានទំនាក់ទំនងគ្នា៖

**ស្ថាប័ននីតិប្បញ្ញត្តិ** ជាស្ថាប័នតំណាងរាស្ត្រដែលជាប់ឆ្នោត។

**ស្ថាប័ននីតិប្រតិបត្តិ** ជាទូទៅមាន នាយករដ្ឋមន្ត្រី និងក្រសួង មន្ទីរនានារបស់រដ្ឋាភិបាល។

**ស្ថាប័នតុលាការ** ជាស្ថាប័នដែលមានតុលាការ និងចៅក្រម។

តួនាទីរបស់ស្ថាប័ននីតិប្បញ្ញត្តិគឺបង្កើតច្បាប់។ នៅពេលការបោះឆ្នោត ប្រជាពលរដ្ឋបោះឆ្នោតជ្រើសរើសតំណាងរបស់ខ្លួន ដែលមានសិទ្ធិអំណាចក្នុងការអនុម័តច្បាប់។ ស្ថាប័ននីតិប្បញ្ញត្តិពិភាក្សាលើសំណើច្បាប់ អំពីបញ្ហាមួយចំនួន និងធ្វើសេចក្តីសម្រេចចិត្តដោយការបោះឆ្នោតថា តើច្បាប់មួយណាត្រូវ និងមិនត្រូវអនុម័តជាផ្លូវការ។ ជួនកាលច្បាប់ដែលបានស្នើឡើងនេះត្រូវឆ្លងកាត់ការកែសម្រួលជាច្រើនលើក មុនពេលឆ្លង ឬអនុម័តដោយតំណាងរាស្ត្រ។ ដោយសារតំណាងរាស្ត្រនៅក្នុងស្ថាប័ននីតិប្បញ្ញត្តិមានសិទ្ធិអំណាចដោយសារប្រជាពលរដ្ឋប្រគល់ឲ្យតាមរយៈនៃការបោះឆ្នោត ដូច្នេះពួកគាត់ជានិច្ចជាកាលត្រូវតែអនុម័តច្បាប់ទាំងឡាយណាដែលផ្តល់ផលប្រយោជន៍ខ្លាំងបំផុតដល់ប្រជាពលរដ្ឋ។

មុខងាររបស់ស្ថាប័ននីតិប្រតិបត្តិគឺ អនុវត្តច្បាប់ និងកិច្ចការរបស់រដ្ឋាភិបាល។ ស្ថាប័ននីតិប្រតិបត្តិធ្វើកិច្ចការទាំងនេះ ដោយបង្កើតគោលនយោបាយ និងបទបញ្ញា ធ្វើសេចក្តីសម្រេចចិត្ត និងដោះស្រាយបញ្ហាមួយចំនួនដែលប៉ះពាល់ដល់សង្គម។ ជាទូទៅ គឺបណ្តា**ក្រសួង** ជាផ្នែកមួយនៃស្ថាប័ននីតិប្រតិបត្តិ ដែលត្រូវតាក់តែងសេចក្តីព្រាងច្បាប់ និងបញ្ជូនច្បាប់បានព្រាងរួចហើយ (សេចក្តីព្រាងច្បាប់) នោះទៅឲ្យស្ថាប័ននីតិប្បញ្ញត្តិដើម្បីពិភាក្សាវែកញែក។ ប្រសិនបើ ស្ថាប័ននីតិប្បញ្ញត្តិអនុម័តច្បាប់នេះ ដូច្នេះសមីក្រសួងត្រូវតែទទួលខុសត្រូវក្នុងការអនុវត្តច្បាប់ថ្មីនេះ។

មុខងាររបស់ស្ថាប័នតុលាការគឺ៖

- បកស្រាយ និងអនុវត្តច្បាប់ទៅតាមអង្គហេតុនៃរឿងក្តី ដែលប្តឹងទៅតុលាការ។
- ដោះស្រាយវិវាទតាមច្បាប់
- រកដំណោះស្រាយតាមផ្លូវច្បាប់ជូនប្រជាពលរដ្ឋដែលទទួលរងការខូចខាតដោយសារអំពើរបស់អ្នកដទៃ។

ស្ថាប័នតុលាការ ក៏ត្រូវការពារសិទ្ធិ និងសេរីភាពរបស់ប្រជាពលរដ្ឋដែលរស់នៅក្នុងរបបលទ្ធិប្រជាធិបតេយ្យ និងត្រូវទទួលខុសត្រូវក្នុងការធានាថា ប្រជាពលរដ្ឋទទួលបានការជម្រះក្តីដោយស្មើភាពគ្នា និងដោយយុត្តិធម៌ទៅតាមច្បាប់។

| ស្ថាប័នទាំង៣របស់រដ្ឋាភិបាលនៅក្នុងប្រទេសកម្ពុជា |
| --- |
| នៅក្នុងប្រទេសកម្ពុជា ស្ថាប័ននីតិប្បញ្ញត្តិ ត្រូវបានបង្កើតឡើងដោយ **រដ្ឋសភា** និង **ព្រឹទ្ធសភា**។ សំណើច្បាប់ ត្រូវតែអនុម័តដោយរដ្ឋសភា និងព្រឹទ្ធសភា និងត្រូវឡាយព្រះហស្តលេខា (ចុះហត្ថលេខា) ដោយព្រះមហាក្សត្រ ដើម្បីឲ្យក្លាយទៅជាច្បាប់ជាផ្លូវការ។<br><br>នាយករដ្ឋមន្ត្រីត្រូវបានបោះឆ្នោតជ្រើសរើសដោយសមាជិករដ្ឋជាតិ។ នេះមានន័យថា គណបក្សដែលឈ្នះឆ្នោត និងទទួលបានអសនៈ (កៅអី) ច្រើនជាងគេ ជាអ្នកបោះឆ្នោតជ្រើសរើសនាយករដ្ឋមន្ត្រី។ បន្ទាប់មកនាយករដ្ឋមន្ត្រីតែងតាំង រដ្ឋមន្ត្រីនានា និងរដ្ឋលេខាធិការ។ ព្រះមហាក្សត្រ នាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីនិងក្រសួងសាមី ព្រមទាំងរដ្ឋលេខាធិការនិងនាយកដ្ឋានក្រោមឱវាទរដ្ឋលេខាធិការ បង្កើតបានជាស្ថាប័ននីតិប្រតិបត្តិរបស់រដ្ឋាភិបាល ដែលមានឈ្មោះថា **រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា**។ **ទីស្តីការគណៈរដ្ឋមន្ត្រី** មានអំណាចធំជាងគេនៅក្នុងស្ថាប័ននីតិប្រតិបត្តិ។ ទីស្តីការគណៈរដ្ឋមន្ត្រីត្រូវបង្កើតឡើងដោយនាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី និងរដ្ឋលេខាធិការ។ ការសម្រេចចិត្ត និងគោលនយោបាយសំខាន់ៗជាច្រើន ត្រូវបានបង្កើតឡើងដោយគណៈរដ្ឋមន្ត្រី។ អាជ្ញាធរថ្នាក់ក្រោមជាតិ (អាជ្ញាធរមូលដ្ឋាន) ដូចជា អភិបាលខេត្ត-ក្រុង និងអភិបាលស្រុក-ខណ្ឌ ក៏ជាផ្នែកនៃស្ថាប័ន នីតិប្រតិបត្តិដែរ។<br><br>នៅក្នុងប្រទេសកម្ពុជា តុលាការចែកចេញជា២ផ្នែកគឺៈ តុលាការ និង**ក្រុមប្រឹក្សាធម្មនុញ្ញ**។ តុលាការមាន៣ថ្នាក់គឺៈ តុលាការខេត្ត-ក្រុង (សាលាដំបូង) សាលាឧទ្ធរណ៍ និងតុលាការកំពូល។ ប្រសិនបើ ប្រជាពលរដ្ឋមិនពេញចិត្ត ឬមិនការសប្បាយចិត្តនឹងសេចក្តីសម្រេចរបស់តុលាការថ្នាក់ទាប (សាលាដំបូង) ទេ ដូច្នេះពួកគាត់អាចបន្តប្តឹងទៅតុលាការថ្នាក់ខ្ពស់ជាងនេះ (សាលាឧទ្ធរណ៍) បាន។ ក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យឡើងវិញលើច្បាប់នានា ដើម្បីធានាថា ច្បាប់ទាំងនោះមិនផ្ទុយនឹងរដ្ឋធម្មនុញ្ញទេ។ ចៅក្រមត្រូវបានស្នើបង្កើតឡើងដោយ **ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម** ហើយត្រូវបានតែងតាំងដោយព្រះមហាក្សត្រ។ តាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ព្រះមហាក្សត្រ និងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវតែប្រកាន់ជំហរ ឯករាជ្យពីតុលាការ។ |

## ៩.២ តុល្យភាពនៃអំណាច

នៅក្នុងលទ្ធិប្រជាធិបតេយ្យ ស្ថាប័នទាំង៣នៃរដ្ឋាភិបាលត្រូវបែងចែកអំណាចឲ្យដាច់ពីគ្នា ព្រមទាំងដាក់កម្រិតនៃដែនអនុវត្តអំណាចលើគ្នាទៅវិញទៅមក។

| រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា |
|---|
| មាត្រា៥១៖ អំណាចបែងចែកដាច់ពីគ្នា រវាងអំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ។ |

នេះមានន័យថា ស្ថាប័ននីមួយៗត្រូវតែបំពេញតួនាទី និងមុខងាររបស់ខ្លួនដោយឯករាជ្យពីស្ថាប័នផ្សេងៗ។ អំណាចរបស់ស្ថាប័ននីមួយៗមានដែនកំណត់ទៅតាមតួនាទី និងការទទួលខុសត្រូវច្បាស់លាស់ដែលកំណត់ដោយរដ្ឋធម្មនុញ្ញ។ គ្មានស្ថាប័នណាមួយ អនុវត្តតួនាទី និងការទទួលខុសត្រូវដែលមិនមែនជាតួនាទី និងការទទួលខុសរបស់ខ្លួននោះឡើយ។

លក្ខណៈយ៉ាងសំខាន់នៅក្នុងលទ្ធិប្រជាធិបតេយ្យគឺ ស្ថាប័ននានានៃរដ្ឋាភិបាលត្រូវធ្វើសកម្មភាពឲ្យមាន **តុល្យភាពនៃអំណាច** រវាងស្ថាប័ននីមួយៗ។ នេះមានន័យថា គ្មានស្ថាប័នណាមួយ មានអំណាចផ្តាច់មុខតែឯង រីឯស្ថាប័នដទៃទៀតដាក់ការត្រួតពិនិត្យលើអំណាចនោះ។ អំណាចរបស់រដ្ឋាភិបាលត្រូវមានតុល្យភាព រវាងស្ថាប័នទាំង៣នោះ។



# មេរៀនទី៥៖ ការបែងចែកអំណាចដាច់ពីគ្នា

**គោលបំណង៖** អ្នកចូលរួមនឹងដឹងអំពីស្ថាប័នទាំង៣របស់រដ្ឋាភិបាល និងមុខងាររបស់ស្ថាប័នទាំងនោះ។ ពួកគាត់នឹងយល់ដឹងអំពីគោលការណ៍នៃការបែងចែកអំណាចដាច់ពីគ្នា និងដឹងថា តើស្ថាប័ននីមួយៗដាក់ការត្រួតពិនិត្យ តុល្យភាពនៃអំណាចរបស់ស្ថាប័ននីមួយៗ ដោយរបៀបណា។

**សម្ភារៈ៖** ខ្សែពួរ ឬក្រមាចំនួន៣ ក្រដាសផ្ទាំងធំ ឬក្ដារខៀន ហ្វឺតពណ៌។

**វិធីសាស្ត្រ៖** ល្បែង សំណួរល្បងការយល់ដឹង ការពិភាក្សា។

| ដំណើរការ | រយៈពេល (គិតជានាទី) |
|---|---|
| ១. ល្បែងតុល្យភាព | ១០ |
| ២. ណែនាំព័ត៌មាននៅក្នុងផ្នែកទី៩.១ និងទី៩.២ | ៣០ |
| ៣. សង្ខេបដោយប្រើសំណួរល្បងការយល់ដឹង | ១៥ |
| **សរុប៖** | **៥៥** |

## ការណែនាំសម្រាប់អ្នកសម្របសម្រួល

### ១. ល្បែងតុល្យភាព

- សុំឲ្យអ្នកចូលរួម៣នាក់ស្ម័គ្រចិត្តជួយអ្នកក្នុងការលេងល្បែងនេះ។ អ្នកទាំង៣នេះត្រូវតែមានកម្លាំងប្រហាក់ប្រហែលគ្នា។ សុំឲ្យអ្នកទាំងបីចងចុងខ្សែពួរ ឬចុងក្រមាទាំង៣នោះជាប់គ្នាដើម្បីបង្កើតជាត្រីកោណមួយ។
- នៅពេលដែលអ្នកសម្របសម្រួលប្រាកដថា ចំណងទាំងនោះជាប់មាំហើយ សូមឲ្យអ្នកស្ម័គ្រចិត្តម្នាក់ៗកាន់ក្រមាមួយម្នាក់ (ជ្រុងមួយនៃត្រីកោណ)។ សូមឲ្យអ្នកស្ម័គ្រចិត្តទាញថ្នមៗ និងទ្រេតទៅក្រោយក្នុងពេលព្រមគ្នា។ វាគួរតែមានលក្ខណៈដូចនេះ៖

រូបភាពអំពីល្បែងខាងលើ



- សូមពន្យល់អ្នកចូលរួមថា ដោយសារតែអ្នកស្ម័គ្រចិត្តម្នាក់ៗទាញជ្រុងត្រីកោណម្នាក់មួយៗ ដូច្នេះកម្លាំងមានតុល្យភាព។ គ្មានអ្នកណាអាចទាញយកត្រីកោណទាំងមូលបានទេ ហើយគ្មានអ្នកណាម្នាក់ដួលឡើយ។
- សូមសួរថា តើនឹងមានអ្វីកើតឡើងប្រសិនបើ មានអ្នកស្ម័គ្រចិត្តណាម្នាក់មានកម្លាំងខ្លាំងជាង ឬអ្នកស្ម័គ្រចិត្ត២នាក់ទៀតលែងក្រមានោះ។ អ្នកសម្របសម្រួលអាចឲ្យអ្នកស្ម័គ្រចិត្តធ្វើបង្ហាញ ប៉ុន្តែត្រូវប្រយ័ត្ន កុំឲ្យអ្នកណាដួល។

២.	ណែនាំព័ត៌មាននៅក្នុងផ្នែកទី៩.១ និងទី៩.២ (សូមមើលទំព័រទី១០៧ ដល់ទី១០៩)

**ផ្នែកទី៩.១ និងទី៩.២៖** វាមានសារៈសំខាន់ណាស់ដែលអ្នកចូលរួមយល់ដឹងថា៖

- នៅក្នុងលទ្ធិប្រជាធិបតេយ្យ រដ្ឋាភិបាលមានស្ថាប័ន៣ដែលមានមុខងារចែកដាច់ពីគ្នា ប៉ុន្តែមានទំនាក់ទំនងគ្នា។
- តួនាទីរបស់ស្ថាប័ននីតិបញ្ញត្តិគឺពិភាក្សា ជជែកវែកញែក អំពីសំណើច្បាប់ និងបោះឆ្នោតអនុម័តថាសំណើច្បាប់មួយណាត្រូវអនុម័តជាផ្លូវការ។
- តួនាទីរបស់ស្ថាប័ននីតិប្រតិបត្តិគឺ អនុវត្តច្បាប់ និងបំពេញកិច្ចការរបស់រដ្ឋាភិបាល ហើយស្ថាប័ននេះត្រូវបានបង្កើតដោយរដ្ឋមន្ត្រី និងក្រសួងនានា។
- តួនាទីរបស់ស្ថាប័នតុលាការគឺបកស្រាយ និងអនុវត្តច្បាប់នោះ ដោះស្រាយវិវាទ និងរកដំណោះស្រាយតាមផ្លូវច្បាប់ជូនប្រជាពលរដ្ឋដែលទទួលរងការខូចខាត។
- នៅក្នុងលទ្ធិប្រជាធិបតេយ្យ ស្ថាប័នទាំង៣នៃរដ្ឋាភិបាលត្រូវមានអំណាចដាច់ពីគ្នា និងមានតុល្យភាពរវាងស្ថាប័ននីមួយៗ។
- គ្មានស្ថាប័នណាមួយអនុវត្តមុខងារ ក្រៅវង្វង់នៃតួនាទី និងការទទួលខុសត្រូវដែលកំណត់ដោយ រដ្ឋធម្មនុញ្ញឡើយ។

៣.	សង្ខេបដោយប្រើសំណួរល្បងការយល់ដឹង៖

- សូមបែកចែកអ្នកចូលរួមជា៤ក្រុម ហើយពន្យល់ថា ពួកគាត់នឹងទទួលបានសំណួរល្បងការយល់ដឹងមួយ។ ក្រុមនីមួយៗត្រូវតែជ្រើសរើសយកសំឡេងសត្វណាមួយ ដែលក្រុមត្រូវស្រែកឡើងនៅពេលដែលក្រុមដឹងចម្លើយ។ អ្នកណាដែលស្រែកបានមុន នឹងអាចឆ្លើយសំណួរនោះ ហើយទទួលបានមួយពិន្ទុ។ ប្រសិនបើ ក្រុមឆ្លើយខុស នោះក្រុមបន្ទាប់នឹងមានឱកាសឆ្លើយម្តង។
- សំណួរសួរថា តើតួនាទី និងមុខងារខាងក្រោមនេះស្ថិតនៅក្នុងស្ថាប័នណាមួយ?
  - ក្រសួងរៀបចំដែនដី (ចម្លើយ៖ ស្ថាប័ននីតិប្រតិបត្តិ)
  - ចៅក្រមនៅតុលាការក្រុង (ចម្លើយ៖ ស្ថាប័នតុលាការ)
  - នគរបាល (ចម្លើយ៖ ស្ថាប័ននីតិប្រតិបត្តិ។ នគរបាលអនុវត្ត និងពង្រឹងការអនុវត្តច្បាប់)
  - នាយករដ្ឋមន្ត្រី (ចម្លើយ៖ ស្ថាប័ននីតិប្រតិបត្តិ និងអំណាចនីតិបញ្ញត្តិ៖ គាត់ក៏ជាសមាជិកម្នាក់នៅក្នុងរដ្ឋសភាដែរ)
  - ព្រឹទ្ធសភា (ចម្លើយ៖ ស្ថាប័ននីតិបញ្ញត្តិ)
  - ក្រសួងយុត្តិធម៌ (ចម្លើយ៖ ស្ថាប័ននីតិប្រតិបត្តិ)
- សូមបូកសរុបពិន្ទុ ហើយប្រកាសក្រុមដែលឈ្នះ។

## ៩.៣ តុលាការឯករាជ្យ

សង្គមមួយមិនអាចជាសង្គមដែលមានលទ្ធិប្រជាធិបតេយ្យពិតប្រាកដទេ ប្រសិនបើ អំណាចតុលាការបែកមិនដាច់ និងមិនឯករាជ្យពីស្ថាប័ន២ទៀតទេ។ វាជាការចាំបាច់ណាស់ដែលតុលាការបំពេញតួនាទីរបស់ខ្លួនដោយមិនមានការជ្រៀតជ្រែកពីស្ថាប័នដទៃទៀត។ តុលាការមានតួនាទីយ៉ាងសំខាន់ក្នុងការរក្សាតុល្យភាពនៃអំណាចរវាងស្ថាប័ននីមួយៗដើម្បីកុំឲ្យការបំពានអំណាចពីស្ថាប័ននីតិប្រតិបត្តិ និងស្ថាប័ននីតិបញ្ញត្តិ។ វានឹងមិនអាចមាននីតិរដ្ឋបានទេ ប្រសិនបើ តុលាការមិនឯករាជ្យ ក្នុងការដោះស្រាយវិវាទ ក្នុងការការពារសិទ្ធិរបស់ប្រជាពលរដ្ឋ និងក្នុងការអនុវត្តច្បាប់ដោយគ្មានឥទ្ធិពលពីខាងក្រៅ។

វាដូចគ្នានឹងអាជ្ញាកណ្តាលបាល់ទាត់ ដែលតែងតែសម្រេចចិត្តឲ្យក្រុមណាឈ្នះ ដោយផ្អែកលើបទបញ្ញា (ច្បាប់បាល់ទាត់) និងរបៀបអនុវត្តបទបញ្ញានេះនៅពេលប្រកួតដែរ ចៅក្រមតែងតែសម្រេចនៅតុលាការ ដោយផ្អែកលើច្បាប់ពាក់ព័ន្ធ និងរបៀបអនុវត្តច្បាប់នោះទៅតាមអង្គហេតុនៃរឿងក្តី។ អាជ្ញាកណ្តាលមិនត្រូវឲ្យក្រុមណាឈ្នះដោយមូលហេតុផ្សេងពីនេះឡើយ ដូចជា ការស៊ីសំណូក ឬដោយសារតែគាត់ជាមិត្តរបស់អ្នកទាត់បាល់ម្នាក់នៅក្នុងក្រុមណាមួយ។ អ្នកលេងបាល់ (កីឡាករ)នោះមិនត្រូវព្យាយាមដាក់សម្ពាធឲ្យអាជ្ញាកណ្តាលលំអៀងទៅរកក្រុមខ្លួនឡើយ។



ដូចគ្នានេះដែរ នាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងនានា និងអ្នកដែលមានអំណាចនៅក្នុងរដ្ឋាភិបាល ដាច់ខាតមិនត្រូវព្យាយាមប្រើឥទ្ធិពលលើការសម្រេចចិត្តរបស់តុលាការឡើយ។ សមាជិកនៅក្នុងស្ថាប័នផ្សេងទៀតត្រូវតែគោរព និងធ្វើតាមការវិនិច្ឆ័យរបស់តុលាការ ទោះបីជាខ្លួនមិនឯកភាពនឹងការសម្រេចចិត្ត ឬទោះបីជាវាផ្ទុយនឹងផលប្រយោជន៍របស់ខ្លួនក៏ដោយ។

នៅពេលដែលរឿងក្ដីណាមួយទៅដល់តុលាការ ដាច់ខាតមិនត្រូវមានឥទ្ធិពលពីខាងក្រៅទៅលើចៅក្រមដែលកំពុងតែធ្វើសវនាការរឿងក្ដីនោះឡើយ។ ឧទាហរណ៍៖ ប្រសិនបើ ភាគីម្ខាងនៅក្នុងរឿងក្ដីនោះជាអ្នកដែលមានទ្រព្យសម្បត្តិ ឬជាអ្នកដែលមានអំណាចក៏ដោយ ក៏វាមិនគួរមានឥទ្ធិពលទៅលើចៅក្រមឡើយ។ ចៅក្រមដាច់ខាតមិនត្រូវទទួលប្រាក់ ឬអំណោយ ដើម្បីឲ្យមានការសម្រេចចិត្តរឿងក្ដីដោយឡែកណាមួយឡើយ។ ចៅក្រមត្រូវតែពិចារណាតែលើអង្គហេតុនៃរឿងក្ដី និងវិធីក្នុងការអនុវត្តច្បាប់នៅពេលធ្វើសេចក្ដីសម្រេចចិត្តណាមួយតែប៉ុណ្ណោះ។ នេះគឺជាអ្វីដែលចៅក្រមត្រូវធ្វើចំពោះរឿងក្ដីទាំងអស់ ដោយមិនខ្វល់ថាអ្នកណាពាក់ព័ន្ធនឹងរឿងក្ដីនោះឡើយ។ ទោះបីជា ភាគីម្ខាងនៅក្នុងរឿងក្ដីនោះជាមន្ត្រីនៃរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឬជានាយករដ្ឋមន្ត្រីក៏ដោយ ក៏ចៅក្រមត្រូវតែសម្រេចចិត្តទៅលើក្ដីនោះ ទៅតាមច្បាប់កំណត់។ ការសម្រេចចិត្តរបស់ចៅក្រម ត្រូវតែគ្មានការគំរាមកំហែង ការសូកប៉ាន់ និងសម្ពាធពីខាងក្រៅឡើយ។ ចៅក្រមមិនត្រូវភ័យខ្លាចថា គាត់នឹងត្រូវដាក់ទោសដោយវិធីណាមួយនោះទេ ប្រសិនបើ ការសម្រេចសេចក្ដីនោះ ប្រឆាំងនឹងរាជរដ្ឋាភិបាល ឬអ្នកដែលមានអំណាច។



**រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា**

មាត្រា១០៩៖ អំណាចតុលាការជាអំណាចឯករាជ្យ។ អំណាចតុលាការជានារក្សាអនាគត និងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ។

ឯករាជ្យភាពរបស់តុលាការនាំឲ្យតុលាការមានអំណាច និងធម្មានុរូបភាព (សុពលភាពតាមច្បាប់)។ ប្រសិនបើតុលាការមានឯករាជ្យភាពពិតប្រាកដ ពេលនោះសាធារណជននឹងមានទំនុកចិត្តក្នុងការប្រើតុលាការក្នុងការដោះស្រាយវិវាទ និងក្នុងការស្វែងរកយុត្តិធម៌ ព្រោះជាតុលាការដែលមិនពាក់ព័ន្ធនយោបាយ និង **មិនលំអៀង**។ មិនលំអៀងមានន័យថា ការសម្រេចចិត្តត្រូវធ្វើឡើងដោយផ្អែកលើមូលដ្ឋាននៃច្បាប់ និងទៅតាមអង្គហេតុនៃរឿងក្តី ដោយមិនលំអៀង ឬដោយគ្មានឥទ្ធិពលពីខាងក្រៅ។

| ករណីសិក្សា៖ រឿងរ៉ាវរបស់វណ្ណា<br>គ្មានយុត្តិធម៌ |
|---|
| វណ្ណាកំពុងរៀនច្បាប់នៅសាកលវិទ្យាល័យមួយ។ គាត់រស់នៅក្នុងសហគមន៍មួយនៅក្នុងទីក្រុងភ្នំពេញ ដែលកំពុងប្រឈមមុខនឹងការបណ្តេញចេញ ដោយសារក្រុមហ៊ុនមួយចង់បានដីដើម្បីសង់សណ្ឋាគារប្រណិតមួយ។ ម្ចាស់ក្រុមហ៊ុននោះជាអ្នកដែលមានអំណាច និងមានទ្រព្យសម្បត្តិម្នាក់ ហើយក៏ជាសមាជិកព្រឹទ្ធសភាដែរ។<br><br>វណ្ណាដឹងថា តាមច្បាប់ភូមិបាលឆ្នាំ២០០១ សហគមន៍របស់គាត់មានសិទ្ធិស្របច្បាប់ចំពោះដីនោះ។ គាត់ដឹងថា ការបណ្តេញចេញនោះជាអំពើល្មើសច្បាប់ ប៉ុន្តែគាត់មិនមានជំនឿថា តុលាការនឹងអនុវត្តច្បាប់ដោយស្មើភាព និងដោយមិនមានឥទ្ធិពលពីខាងក្រៅឡើយ។<br><br>ថ្ងៃមួយ វណ្ណាបានរៀបចំបាតុកម្មដោយសន្តិវិធីមួយនៅខាងមុខការិយាល័យរបស់ក្រុមហ៊ុននោះ។ វណ្ណាត្រូវគេចាប់ខ្លួន និងត្រូវចោទប្រកាន់ពីបទល្មើសដែលគាត់មិនបានធ្វើ។<br><br>នៅយប់មុនពេលកាត់ក្តីវណ្ណា មានគេទូរស័ព្ទទៅលោកស្រីចៅក្រមដែលជាប្រធានក្នុងការកាត់រឿងក្តីនោះ។ គេបានប្រាប់លោកស្រីចៅក្រមថា បើគាត់រកមិនឃើញកំហុសរបស់វណ្ណាទេ នោះលោកស្រីចៅក្រមនឹងត្រូវបាត់បង់ការងារ។ គាត់ក៏នឹងទទួលបានរង្វាន់ដែរ ប្រសិនបើគាត់រកឃើញកំហុសរបស់វណ្ណា។ ថ្ងៃបន្ទាប់មក វណ្ណាត្រូវចៅរកឃើញកំហុស ទោះបីជាគ្មានភស្តុតាងក៏ដោយ។ វណ្ណាត្រូវតុលាការកាត់ទោសឲ្យជាប់ពន្ធនាគារ៥ឆ្នាំ។ |

# មេរៀនទី៦៖ តុលាការឯករាជ្យ



**គោលបំណង៖ អ្នកចូលរួមនឹងយល់ដឹងអំពីសារៈសំខាន់នៃ តុលាការឯករាជ្យ នៅក្នុងលទ្ធិប្រជាធិបតេយ្យ។**

**សម្ភារៈ៖** ក្រដាសផ្ទាំងធំ ឬក្ដារខៀន ហ្វឺតពណ៌ ឯកសារសម្រាប់ចែកទី១ និងទី២។

**វិធីសាស្ត្រ៖** រឿងរ៉ាវ ការពិភាក្សា។

| ដំណើរការ | រយៈពេល (គិតជានាទី) |
|---|---|
| ១. ការពិភាក្សាអំពីរូបភាព | ១០ |
| ២. ណែនាំព័ត៌មាននៅក្នុងផ្នែកទី៩.៣ | ១៥ |
| ៣. ការពិភាក្សាអំពីរឿងរ៉ាវរបស់វណ្ណា | ២០ |
| ៤. សង្ខេប | ២០ |
| **សរុប៖** | **៦៥** |

## ការណែនាំសម្រាប់អ្នកសម្របសម្រួល

### ១. ការពិភាក្សាអំពីរូបភាព

- សូមចែកឯកសារសម្រាប់ចែកទី១ទៅឲ្យអ្នកចូលរួមគ្រប់គ្នា។ សូមឲ្យអ្នកចូលរួមណាម្នាក់រៀបរាប់អំពីអ្វីដែលកំពុងកើតឡើងតាមរូបភាពនោះ។

- សូមសួរអ្នកចូលរួមថា តើអាជ្ញាកណ្ដាលនៅក្នុងកីឡាបាល់ទាត់មានតួនាទីអ្វី។ អ្នកសម្របសម្រួលអាចសួរថា៖

    - តើអាជ្ញាកណ្ដាលគួរតែធ្វើសេចក្ដីសម្រេចចិត្តដោយយោងទៅលើអ្វី?

    - តើពេលណាដែលអាជ្ញាកណ្ដាលគួរតែសម្រេចចិត្តថា ក្រុមណាមួយជាអ្នកឈ្នះ?

    - តើក្រុមបាល់ទាត់ទាំងនោះគិតយ៉ាងណា នៅពេលដែលអាជ្ញាកណ្ដាលធ្វើការសម្រេចចិត្តដោយយោងទៅតាមមូលហេតុផ្សេងដោយមិនគោរពតាមច្បាប់បាល់ទាត់? ចុះប្រសិនបើអាជ្ញាកណ្ដាលមានមិត្តល្អម្នាក់នៅក្នុងក្រុមណាមួយ ហើយគាត់សម្រេចចិត្តឲ្យក្រុមនោះឈ្នះយ៉ាងម៉េចដែរ?ចុះបើមានសមាជិកនៅក្នុងក្រុមណាមួយដាក់សម្ពាធឲ្យអាជ្ញាកណ្ដាលឲ្យក្រុមគេឈ្នះវិញ យ៉ាងម៉េចដែរ?

- សូមឲ្យប្រាកដថា គ្រប់គ្នាយល់ថា វាមានសារៈសំខាន់ណាស់ដែលអាជ្ញាកណ្ដាលត្រូវតែឯករាជ្យ និងធ្វើការសម្រេចចិត្ត ដោយយោងតាមច្បាប់ និងទៅតាមរបៀបអនុវត្តច្បាប់នៅពេលប្រកួតតែប៉ុណ្ណោះ។ អាជ្ញាកណ្ដាលមិនត្រូវឲ្យក្រុមណាមួយឈ្នះដោយសារមូលហេតុផ្សេងពីនេះឡើយ ដូចជា ការសូកប៉ាន់ ឬដោយសារតែគាត់ជាមិត្តរបស់កីឡាករ ឬជាមិត្តរបស់គ្រូបង្វឹកនៅក្រុមណាមួយ។ មិនត្រូវឲ្យមានអ្នកណាម្នាក់ព្យាយាមដាក់សម្ពាធឲ្យអាជ្ញាកណ្ដាលដើម្បីលំអៀងទៅរកក្រុមណាមួយទេ។

- សូមពន្យល់ថា វាដូចគ្នានឹងតុលាការដែរគឺ តុលាការត្រូវតែឯករាជ្យ។

### ២. ណែនាំព័ត៌មាននៅក្នុងផ្នែកទី៩.៣ (សូមមើលទំព័រទី១១៣ ដល់ទី១១៥)

**ផ្នែកទី៩.៣៖** វាមានសារៈសំខាន់ណាស់ដែលអ្នកចូលរួមយល់ដឹងថា៖

- សង្គមមួយមិនអាចជាសង្គមដែលមានលទ្ធិប្រជាធិបតេយ្យពិតប្រាកដទេ ប្រសិនបើតុលាការមានអំណាចមិនដាច់ និងមិនឯករាជ្យពីស្ថាប័ន២ទៀត។
- តុលាការមានតួនាទីយ៉ាងសំខាន់ ក្នុងការរក្សាតុល្យភាពរវាងការប្រើប្រាស់អំណាចមិនត្រឹមត្រូវដោយស្ថាប័នដទៃទៀត។
- វាមិនអាចជានីតិរដ្ឋទេ ប្រសិនបើតុលាការមិនអាចដោះស្រាយវិវាទដោយសេរី ឬដោយគ្មានសម្ពាធ

និងអនុវត្តច្បាប់ដោយគ្មានការប្រើឥទ្ធិពលពីខាងក្រៅ។

- ចៅក្រមមិនត្រូវទទួលប្រាក់ ឬអំណោយ ដើម្បីសម្រេចចិត្តរឿងក្តីទៅតាមរបៀបដោយឡែកណាមួយឡើយ។
- ចៅក្រមត្រូវពិចារណាតែលើអង្គហេតុនៃរឿងក្តី និងវិធីក្នុងការអនុវត្តច្បាប់នៅពេលធ្វើការសម្រេចចិត្តណាមួយតែប៉ុណ្ណោះ ដោយមិនខ្វល់ថា មានភាគីណាពាក់ព័ន្ធក្នុងរឿងក្តីនោះ។
- ប្រសិនបើ តុលាការពិតជាឯករាជ្យ មិនពាក់ព័ន្ធនយោបាយ និងមិនលំអៀងមែន នោះសាធារណជននឹងមានជំនឿថា ពួកគាត់អាចប្រើតុលាការក្នុងការដោះស្រាយវិវាទ និងក្នុងការស្វែងរកយុត្តិធម៌។

## ៣. ការពិភាក្សាអំពីរឿងរ៉ាវរបស់វណ្ណា

- សូមចែកឯកសារសម្រាប់ចែកទី២អំពីរឿងរ៉ាវរបស់វណ្ណា។ សូមឲ្យអ្នកចូលរួមណាម្នាក់អានវាឲ្យលឺៗ។
- សូមសួរអ្នកចូលរួមថា តើពួកគាត់យល់យ៉ាងណាចំពោះរឿងរ៉ាវនេះ។ ដើម្បីសម្របសម្រួលដល់ការពិភាក្សា អ្នកសម្របសម្រួលអាចសួរថា៖
  - ហេតុអ្វីបានជាវណ្ណាមិនទៅរកតុលាការដើម្បីការពារសិទ្ធិដីធ្លីរបស់សហគមន៍គាត់?
  - ហេតុអ្វីបានជា អ្នកគិតថា វណ្ណាត្រូវគេចាប់ខ្លួន?
  - តើមានរឿងអ្វីកើតឡើង នៅយប់មុនកាត់ក្តីរបស់វណ្ណា ?
  - តើអ្នកគិតថា អ្នកណាទូរស័ព្ទទៅចៅក្រម?
  - នៅក្នុងរឿងក្តីរបស់វណ្ណានេះ តើចៅក្រមធ្វើការដោយឯករាជ្យ និងគ្មានឥទ្ធិពលពីខាងក្រៅដែរឬទេ?
  - តើអ្នកគិតយ៉ាងណា ចំពោះអ្វីដែលបានកើតឡើងចំពោះវណ្ណា?
- ចុងបញ្ចប់សូមសួរអ្នកចូលរួមថា តើរឿងរ៉ាវនឹងទៅជាយ៉ាងណាវិញ ប្រសិនបើមានតុលាការឯករាជ្យ។ តើនឹងមានអ្វីកើតឡើងចំពោះវណ្ណា និងសហគមន៍របស់គាត់?

## ៤. សង្ខេប

- សូមពន្យល់ថា រឿងរ៉ាវរបស់វណ្ណាគឺជារឿងប្រឌិតទេ ប៉ុន្តែវាមានរឿងពិតដូចគ្នានឹងរឿងនេះដែរ។ សូមសួរអ្នកចូលរួមថា តើពួកគាត់មានដែលធ្លាប់ឮ ឬដឹងអំពីរឿងរ៉ាវពិតដូចគ្នានេះ នៅក្នុងប្រទេសកម្ពុជា ឬកន្លែងណាផ្សេងទេ។ សូមអញ្ជើញអ្នកចូលរួមឲ្យចែករំលែករឿងរ៉ាវដែលពួកគាត់ដឹង។

- នៅក្នុងរឿងរ៉ាវទាំងនេះ តើវានឹងទៅជាយ៉ាងណាវិញ ប្រសិនបើ តុលាការបំពេញការងាររបស់ខ្លួនដោយឯករាជ្យ?

- សូមឲ្យអ្នកចូលរួមពីរ-បីនាក់រំលឹកឡើងវិញថា ហេតុអ្វីបានជាវាមានសារៈសំខាន់ក្នុងការបែងចែកអំណាចដាច់ពីគ្នាបែបនេះ ជាពិសេស តុលាការឯករាជ្យ នៅក្នុងលទ្ធិប្រជាធិបតេយ្យ។


7
10

## ឯកសារសម្រាប់ចែកទី២ : មេរៀនទី៥

| ករណីសិក្សា៖ រឿងរ៉ាវរបស់វណ្ណា<br>គ្មានយុត្តិធម៌ |
|---|
| វណ្ណាកំពុងរៀនច្បាប់នៅសាកលវិទ្យាល័យមួយ។ គាត់រស់នៅក្នុងសហគមន៍មួយនៅក្នុងទីក្រុងភ្នំពេញដែលកំពុងប្រឈមមុខនឹងការបណ្តេញចេញ ដោយសារក្រុមហ៊ុនមួយចង់បានដីដើម្បីសង់សណ្ឋាគារប្រណិតមួយ។ ម្ចាស់ក្រុមហ៊ុននោះជាអ្នកដែលមានអំណាច និងមានទ្រព្យសម្បត្តិម្នាក់ ហើយក៏ជាសមាជិកព្រឹទ្ធសភាដែរ។<br><br>វណ្ណាដឹងថា តាមច្បាប់ភូមិបាលឆ្នាំ២០០១ សហគមន៍របស់គាត់មានសិទ្ធិស្របច្បាប់ចំពោះដីនោះ។ គាត់ដឹងថា ការបណ្តេញចេញនោះជាអំពើល្មើសច្បាប់ ប៉ុន្តែគាត់មិនមានជំនឿថា តុលាការនឹងអនុវត្តច្បាប់ដោយស្មើភាព និងដោយមិនមានឥទ្ធិពលពីខាងក្រៅឡើយ។<br><br>ថ្ងៃមួយ វណ្ណាបានរៀបចំបាតុកម្មដោយសន្តិវិធីមួយនៅខាងមុខការិយាល័យរបស់ក្រុមហ៊ុននោះ។ វណ្ណា ត្រូវគេចាប់ខ្លួន និងត្រូវចោទប្រកាន់ពីបទល្មើសដែលគាត់មិនបានធ្វើ។<br><br>នៅយប់មុនពេលកាត់ក្តីវណ្ណា មានគេទូរស័ព្ទទៅលោកស្រីចៅក្រមដែលជាប្រធានក្នុងការកាត់រឿងក្តីនោះ។ គេបានលោកស្រីចៅក្រមថា បើគាត់រកមិនឃើញកំហុសរបស់វណ្ណាទេ នោះលោកស្រីចៅក្រមនឹងត្រូវបាត់បង់ការងារ។ គាត់ក៏នឹងទទួលបានរង្វាន់ដែរ ប្រសិនបើគាត់រកឃើញកំហុសរបស់វណ្ណា។ ថ្ងៃបន្ទាប់មក វណ្ណាត្រូវចៅរកឃើញកំហុស ទោះបីជាគ្មានភស្តុតាងក៏ដោយ។ វណ្ណាត្រូវតុលាការកាត់ទោសឲ្យជាប់ពន្ធនាគារ៥ឆ្នាំ។ |

# ១០. លក្ខណៈជាប្រជាពលរដ្ឋសកម្ម

## ១០.១ តើលក្ខណៈជាប្រជាពលរដ្ឋមានន័យដូចម្តេច?

**ប្រជាពលរដ្ឋ** គឺជាសមាជិកទាំងអស់នៅក្នុងប្រទេស ឬជាតិណាមួយដែលមានរដ្ឋាភិបាលជាប់ឆ្នោតតាមបែបប្រជាធិបតេយ្យ ជាតំណាង និងបម្រើប្រជាពលរដ្ឋ។ ប្រជាពលរដ្ឋមានសិទ្ធិស្របច្បាប់ និងទទួលបានការការពារពេញលេញ នៅក្នុងប្រទេសដែលមាន**សញ្ជាតិ**នោះ។ នៅក្នុងលទ្ធិប្រជាធិបតេយ្យ សិទ្ធិទាំងនេះរួមមាន សិទ្ធិក្នុងការចូលរួមបោះឆ្នោត និងក្លាយទៅជាបេក្ខជនឈរឈ្មោះបោះឆ្នោតដើម្បីធ្វើជាតំណាងប្រជាពលរដ្ឋនៅក្នុងជួររដ្ឋាភិបាល។ សិទ្ធិជាប្រជាពលរដ្ឋក៏រាប់ទាំង សិទ្ធិក្នុងការរស់នៅនិងធ្វើការជាអចិន្ត្រៃយ៍នៅក្នុងប្រទេសនោះ និងសិទ្ធិមានលិខិតឆ្លងដែនរបស់ប្រទេសនោះដែរ។ ប្រជាពលរដ្ឋមិនអាចត្រូវបានគេនិរទេស ឬបដិសេធមិនឲ្យចូលក្នុងប្រទេសវិញនៅពេលដែលគេធ្វើដំណើរទៅក្រៅប្រទេសនោះឡើយ។



មិនមែនមនុស្សទាំងអស់ដែលរស់នៅក្នុងប្រទេសណាមួយសុទ្ធតែជាប្រជាពលរដ្ឋនៃប្រទេសនោះទេ។ ជនបរទេសទាំងឡាយដែលមានទីលំនៅក្នុងប្រទេសណាមួយ ជាទូទៅជាមនុស្សដែលមានទីលំនៅស្របច្បាប់ ប៉ុន្តែមិនមែនជាប្រជាពលរដ្ឋនៃប្រទេសនោះទេ។ អ្នកមានទីលំនៅស្របច្បាប់មានសិទ្ធិច្រើន ប៉ុន្តែមិនមានសិទ្ធិទាំងអស់ជាប្រជាពលរដ្ឋទេ។ ឧទាហរណ៍៖ ជាទូទៅពួកគេមិនមានសិទ្ធិក្នុងការបោះឆ្នោតទេ។ ជនបរទេសអាចក្លាយទៅជាប្រជាពលរដ្ឋបានប្រសិនបើ គេរស់នៅក្នុងប្រទេសនោះក្នុងរយៈពេលកំណត់ជាក់លាក់ណាមួយ ព្រមទាំងយល់ព្រមបំពេញការទទួលខុសត្រូវកំណត់ជាក់លាក់មួយចំនួន។ ប្រជាពលរដ្ឋនៃប្រទេសមួយក៏អាចទៅរស់នៅបរទេសបានដែរ។ ឧទាហរណ៍៖ ប្រជាពលរដ្ឋខ្មែរដែលកំពុងរៀននៅសាកលវិទ្យាល័យនៅប្រទេសសិង្ហបុរី នៅតែជាប្រជាពលរដ្ឋខ្មែរដដែលគឺនៅតែទទួលបានសិទ្ធិទាំងអស់ និងការ

ការពារជាប្រជាពលរដ្ឋនៃប្រទេសកម្ពុជា។ នៅក្នុងស្ថានភាពខ្លះមនុស្សអាចជាប្រជាពលរដ្ឋរបស់ប្រទេសលើសពីមួយ ហើយមានសិទ្ធិស្របច្បាប់ ជាប្រជាពលរដ្ឋនៃប្រទេសទាំងពីរ ឬទាំងអស់។

| សិទ្ធិរបស់ប្រជាពលរដ្ឋកម្ពុជា |
| --- |
| រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានផ្តល់សិទ្ធិជាច្រើនដល់ប្រជាពលរដ្ឋនៃប្រទេសកម្ពុជា។ ឧទាហរណ៍៖ ក្រៅពីសិទ្ធិទាំងអស់ដែលមាន ប្រជាពលរដ្ឋនៃប្រទេសកម្ពុជាមានសិទ្ធិ៖<br>• បោះឆ្នោត និងឈរឈ្មោះឲ្យគេបោះឆ្នោត (មាត្រា៣៤)<br>• ចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ របស់ប្រទេសជាតិ (មាត្រា៣៥)<br>• ធ្វើពាក្យបណ្តឹង ឬប្តឹងទាមទារទៅកាន់តុលាការទាក់ទងទៅនឹងបទល្មើសច្បាប់ដែលប្រព្រឹត្តដោយស្ថាប័នរដ្ឋ ឬមន្ត្រីរដ្ឋាភិបាល និង<br>• ជាម្ចាស់ដីធ្លី (មាត្រា៤៤) |

## ១០.២ ប្រជាពលរដ្ឋដែលមានព័ត៌មានគ្រប់គ្រាន់ សកម្ម និង ទទួលខុសត្រូវ

នៅក្នុងលទ្ធិប្រជាធិបតេយ្យ មានប្រទេសជាតិ និងរដ្ឋាភិបាល បម្រើ និងការពារប្រជាពលរដ្ឋ។ ប៉ុន្តែប្រជាពលរដ្ឋមិនអាចគ្រាន់តែបោះឆ្នោត រួចនៅស្ងៀមដោយពឹងផ្អែកតែលើរដ្ឋាភិបាលដែលត្រូវបំពេញកាតព្វកិច្ចទាំងអស់របស់ខ្លួននៅពេលដែលរដ្ឋាភិបាលបានជាប់ឆ្នោតឡើងកាន់ការិយាល័យនោះទេ។ លទ្ធិប្រជាធិបតេយ្យដែលខ្លាំង និងរស់រវើកតម្រូវឲ្យប្រជាពលរដ្ឋមានព័ត៌មានគ្រប់គ្រាន់ សកម្ម និងទទួលខុសត្រូវ ដើម្បីពួកគាត់អាចចូលរួមចំណែកជួយដល់ដំណើរការនៃលទ្ធិប្រជាធិបតេយ្យ និងកិច្ចការនយោបាយ។



ដូចបានពិភាក្សាខាងលើរួចហើយថា លទ្ធិប្រជាធិបតេយ្យមួយតម្រូវឲ្យមានការគោរពសិទ្ធិប្រជាពលរដ្ឋ។ ឧទាហរណ៍៖ សិទ្ធិក្នុងការចូលរួមបោះឆ្នោត សិទ្ធិក្រុមភាគតិច សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងការប្រមូលផ្តុំ សុទ្ធតែជាសិទ្ធិយ៉ាងសំខាន់នៅក្នុងដំណើរការនៃលទ្ធិប្រជាធិបតេយ្យ។ ប៉ុន្តែលទ្ធិប្រជាធិបតេយ្យក៏តម្រូវឲ្យប្រជាពលរដ្ឋបំពេញតួនាទីរបស់ពួកគាត់ដែរ។ ប្រជាពលរដ្ឋនៅក្នុងប្រទេសកាន់លទ្ធិប្រជាធិបតេយ្យទទួលខុសត្រូវក្នុងការស្វែងរកព័ត៌មាននិងចំណេះដឹង និងធ្វើឲ្យមតិ ឬយោបល់របស់ពួកគាត់ឮជាសាធារណៈដើម្បីធ្វើឲ្យរដ្ឋាភិបាលទទួលខុសត្រូវចំពោះអ្វីដែលខ្លួនធ្វើ។

លទ្ធិប្រជាធិបតេយ្យគឺជាដៃគូរវាងរដ្ឋាភិបាលដែលជាប់ឆ្នោត និងប្រជាពលរដ្ឋ។ រដ្ឋាភិបាលដែលជាប់ឆ្នោត និងប្រជាពលរដ្ឋត្រូវតែសកម្ម ដើម្បីឲ្យលទ្ធិប្រជាធិបតេយ្យដំណើរការទៅបានល្អ។ លទ្ធិប្រជាធិបតេយ្យពឹងផ្អែកទៅលើប្រជាពលរដ្ឋដែល៖

- យល់ដឹងអំពីសិទ្ធិរបស់ខ្លួន និងមានការទទួលខុសត្រូវជាប្រជាពលរដ្ឋ
- មានចំណេះដឹង ឬព័ត៌មានអំពីបញ្ហាសង្គម និងនយោបាយ
- មានសមត្ថភាពគិតនិងវិភាគយ៉ាងល្អិតល្អន់អំពីបញ្ហាទាំងនេះ
- មានការបារម្ភអំពីសិទ្ធិមនុស្ស ភាពត្រឹមត្រូវ និងយុត្តិធម៌នៅក្នុងសង្គម
- មានសមត្ថភាពក្នុងការបញ្ចេញមតិ ឬយោបល់
- សកម្មនៅក្នុងសហគមន៍របស់ពួកគាត់ និងនៅក្នុងវេទិកាសាធារណៈ
- គោរពគំនិត ឬយោបល់ និងផលប្រយោជន៍របស់អ្នកជិតខាង សហគមន៍ និងអ្នកដទៃទៀត។

**តើអ្នកអាចធ្វើយ៉ាងណាដើម្បីឲ្យក្លាយជាប្រជាពលរដ្ឋដែល សកម្ម និងមានការទទួលខុសត្រូវ ?**

មានកិច្ចការច្រើនណាស់ដែលអ្នកអាចធ្វើនៅក្នុងជីវិតប្រចាំថ្ងៃដើម្បីឲ្យក្លាយជាប្រជាពលរដ្ឋសកម្ម និងមានការទទួលខុសត្រូវ។ មានកិច្ចការដែលអ្នកអាចធ្វើនៅថ្នាក់សហគមន៍មូលដ្ឋាន និងនៅថ្នាក់ជាតិ ដោយខ្លួនអ្នកផ្ទាល់ និងដោយធ្វើការជាមួយប្រជាពលរដ្ឋដទៃទៀត។

ឧទាហរណ៍៖ អ្នកអាចបន្តតាមដានព័ត៌មានអំពីបញ្ហានៅក្នុងសហគមន៍មូលដ្ឋានរបស់អ្នក និងចូលរួម ឬរៀបចំការប្រជុំសហគមន៍។ ប្រសិនបើមានបញ្ហានៅក្នុងសហគមន៍របស់អ្នក អ្នកអាចជួយរកដំណោះស្រាយ ឬជួយផ្តល់គំនិត និងការបារម្ភរបស់សហគមន៍ទៅតំណាងរដ្ឋាភិបាល។ អ្នកអាចរៀបចំនិងណាត់ជួបប្រជុំជាមួយអាជ្ញាធរមូលដ្ឋាន ដូចជាក្រុមប្រឹក្សាឃុំ ដែលមានការទទួលខុសត្រូវចំពោះសុខុមាលភាពរបស់ប្រជាប្រជាពលរដ្ឋនៅក្នុងឃុំជាដើម។ ក្រុមប្រឹក្សាឃុំក៏ត្រូវតែបើកការប្រជុំយ៉ាងទៀងទាត់ ដែលអ្នកអាចចូលរួមក្នុងការប្រជុំនេះបានដែរ។

អ្នកក៏អាចចូលរួមជាមួយបញ្ហាថ្នាក់ជាតិសំខាន់ៗដែរ។ ឧទាហរណ៍៖ អ្នកអាចបន្តតាមដានព័ត៌មាន ឬសិក្សាស្វែងយល់អំពីវិធីដែលប្រទេសនោះកំពុងអភិវឌ្ឍ អំពីច្បាប់ថ្មី ឬអំពីបញ្ហាដែលប្រទេសជាតិទាំងមូលកំពុងបារម្ភ។ អ្នកអាចចូលរួម ឬរៀបចំក្រុមប្រជាពលរដ្ឋមកពីទូទាំងប្រទេសដែលមានក្តីបារម្ភ និងមានចំណាប់អារម្មណ៍ដូចគ្នា។ អ្នកអាចជាមនុស្សសកម្មក្នុងការចូលរួម ប្រជុំសាធារណៈ ពិគ្រោះយោបល់ និងអាចជាមនុស្សសកម្មតាមរយៈវេទិកាសាធារណៈផ្សេងៗ ដើម្បីពិភាក្សាអំពីបញ្ហានានា និងបញ្ចេញមតិ ឬយោបល់របស់អ្នកចំពោះបញ្ហានោះ។ អ្នកអាចរៀបចំការប្រជុំជាមួយតំណាងរដ្ឋាភិបាល ឬធ្វើការជាមួយ **ក្រុមសង្គមស៊ីវិល** ដើម្បីធ្វើសកម្មភាពគាំទ្រចំពោះអ្វីមួយដែលអ្នកជឿ ឬប្រឆាំងនឹងអ្វីមួយដែលអ្នកមិនយល់ស្រប។

តាមរយៈភាពសកម្ម និងធ្វើការយ៉ាងជិតស្និទ្ធបែបនេះ ប្រជាពលរដ្ឋក្តាប់បានអំណាចនយោបាយសំខាន់ៗ និងអាចធ្វើឲ្យមានភាពខុសគ្នាយ៉ាងពិតប្រាកដចំពោះវិធីគ្រប់គ្រង និងដំណើរការកិច្ចការអភិវឌ្ឍន៍ប្រទេស។ ប្រជាពលរដ្ឋដែលខ្លាំង និងសកម្ម មានអំណាចក្នុងការបង្កើតសង្គមមួយដែលគោរពសិទ្ធិមនុស្ស និងធ្វើឲ្យរដ្ឋាភិបាលទទួលខុសត្រូវចំពោះកិច្ចការដែលរដ្ឋត្រូវបម្រើប្រជាពលរដ្ឋ។



# មេរៀនទី៧ ៖ ប្រជាពលរដ្ឋដែលសកម្ម និងមានការទទួលខុសត្រូវ



**គោលបំណង៖** អ្នកចូលរួមនឹងយល់ដឹងថា ប្រជាពលរដ្ឋមានន័យដូចម្ដេច និងយល់ដឹងថា ប្រជាពលរដ្ឋមានតួនាទីយ៉ាងសំខាន់នៅក្នុងសង្គមប្រជាធិបតេយ្យ។ ពួកគាត់នឹងយល់ដឹងថា ប្រជាពលរដ្ឋមានករណីយកិច្ច ក៏ដូចជាមានសិទ្ធិនានា និងដឹងថា ពួកគាត់អាចធ្វើអ្វីខ្លះ ដើម្បីក្លាយជាប្រជាពលរដ្ឋដែលមានចំណេះដឹង ឬព័ត៌មានគ្រប់គ្រាន់ ជាប្រជាពលរដ្ឋសកម្ម និងមានការទទួលខុសត្រូវ។

**សម្ភារៈ៖** ក្រដាសផ្ទាំងធំ ឬក្ដារខៀន និងហ្វឺតពណ៌។

**វិធីសាស្ត្រ៖** ការបំផុសគំនិត ការពិភាក្សា ការងារជាក្រុម និងបទបង្ហាញ។

| ដំណើរការ | រយៈពេល (គិតជានាទី) |
|---|---|
| ១. ណែនាំព័ត៌មាននៅក្នុងផ្នែកទី១០.១ | ១០ |
| ២. ការបំផុសគំនិតអំពីតួនាទីរបស់ប្រជាពលរដ្ឋ | ១០ |
| ៣. ណែនាំព័ត៌មាននៅក្នុងផ្នែកទី១០.២ | ២០ |
| ៤. ការងារជាក្រុម | ២០ |
| ៥. បទបង្ហាញ | ២០ |
| ៦. សង្ខេប | ១០ |
| **សរុប៖** | ៩០ |

## ការណែនាំសម្រាប់អ្នកសម្របសម្រួល

### ១. ណែនាំព័ត៌មាននៅក្នុងផ្នែកទី១០.១ : (សូមមើលទំព័រទី១២២ ដល់ទី១២៣)

**ផ្នែកទី១០.១៖** វាមានសារៈសំខាន់ណាស់ដែលអ្នកចូលរួមយល់ដឹងថា៖

- ប្រជាពលរដ្ឋជាសមាជិកយ៉ាងសំខាន់របស់ប្រទេសមួយដែលគ្រប់គ្រងដោយរដ្ឋាភិបាលជាប់ឆ្នោតតាមបែបលទ្ធិប្រជាធិបតេយ្យ ដើម្បីធ្វើជាតំណាង និងបម្រើប្រជាពលរដ្ឋ។
- ប្រជាពលរដ្ឋមានសិទ្ធិស្របច្បាប់ និងទទួលបានការការពារយ៉ាងពេញលេញនៅក្នុងប្រទេសដែលខ្លួនជាប្រជាពលរដ្ឋ ឬមានសញ្ជាតិនោះ។
- សិទ្ធិខ្លះរបស់ប្រជាពលរដ្ឋកម្ពុជា។

### ២. ការបំផុសគំនិតអំពីតួនាទីរបស់ប្រជាពលរដ្ឋ

- សូមសរសេរពាក្យ "តួនាទីរបស់ប្រជាពលរដ្ឋនៅក្នុងលទ្ធិប្រជាធិបតេយ្យ" នៅលើក្តារខៀន ឬក្រដាសផ្ទាំងធំ រួចសូមសួរអ្នកចូលរួមអំពីគំនិតរបស់គាត់។ សូមសួរថា៖
  - តើប្រជាពលរដ្ឋត្រូវធ្វើអ្វីខ្លះដើម្បីជួយបង្កើតលទ្ធិប្រជាធិបតេយ្យរឹងមាំ និងរស់រវើក។
- សូមសរសេរគំនិតរបស់អ្នកចូលរួមនៅលើក្រដាសផ្ទាំងធំ។

### ៣. ណែនាំព័ត៌មាននៅក្នុងផ្នែកទី១០.២ (សូមមើលទំព័រទី១២៣ ដល់ទី១២៥)

**ផ្នែកទី១០.២៖** វាមានសារៈសំខាន់ណាស់ដែលអ្នកចូលរួមយល់ដឹងថា៖

- លទ្ធិប្រជាធិបតេយ្យមួយដែលខ្លាំង និងរស់រវើក តម្រូវឲ្យប្រជាពលរដ្ឋមានចំណេះដឹងឬមានព័ត៌មានគ្រប់គ្រាន់ សកម្ម និងមានការទទួលខុសត្រូវ។
- នៅក្នុងលទ្ធិប្រជាធិបតេយ្យ ប្រជាពលរដ្ឋមានសិទ្ធិ ប៉ុន្តែពួកគាត់ក៏ត្រូវមានករណីយកិច្ចដែរ។
- ប្រជាពលរដ្ឋមានការទទួលខុសត្រូវក្នុងការស្វែងរកចំណេះដឹង និងព័ត៌មាន និងធ្វើឲ្យមតិឬយោបល់របស់ពួកគាត់ ឮជាសាធារណៈ ដើម្បីធ្វើឲ្យរដ្ឋាភិបាលមានការទទួលខុសត្រូវ។
- ប្រជាពលរដ្ឋដែលមានចំណេះដឹងឬព័ត៌មានគ្រប់គ្រាន់ សកម្ម និងមានការទទួលខុសត្រូវ គឺមានន័យថា លទ្ធិប្រជាធិបតេយ្យគឺពឹងផ្អែកលើប្រជាពលរដ្ឋបែបនេះ។
- ពួកគាត់ត្រូវធ្វើអ្វីខ្លះដើម្បីឲ្យក្លាយទៅជាប្រជាពលរដ្ឋដែលសកម្ម និងមានការទទួលខុសត្រូវ ទាំងនៅថ្នាក់មូលដ្ឋាន និងនៅថ្នាក់ជាតិ។
- តាមរយៈភាពសកម្ម និងធ្វើការយ៉ាងជិតស្និទ្ធនេះ ធ្វើឲ្យប្រជាពលរដ្ឋអាចក្តាប់អំណាចនយោបាយសំខាន់ៗ និងអាចធ្វើឲ្យមានភាពខុសគ្នាយ៉ាងពិតប្រាកដចំពោះវិធីគ្រប់គ្រង និងដំណើរការកិច្ចការអភិវឌ្ឍន៍ប្រទេស។

## ៤. ការងារជាក្រុម

- សូមពន្យល់ថា អ្នកសម្របសម្រួលនឹងចែកអ្នកចូលរួមជាក្រុម ហើយក្រុមនីមួយៗនឹងគិតអំពីបញ្ហាសង្គម ឬនយោបាយ ឬស្ថានភាពដែលពួកគាត់ចង់ចូលរួមជាប្រជាពលរដ្ឋសកម្ម។ ពួកគាត់អាចរើសយកបញ្ហាដែលធ្វើឲ្យមានឥទ្ធិពលដល់ពួកគាត់ដោយផ្ទាល់ ឬយកបញ្ហាណាដែលមានឥទ្ធិពលដល់មនុស្សនៅជុំវិញពួកគាត់ ដូចជា ការបំពានសិទ្ធិមនុស្សជាដើម។ វាគប្បីជាបញ្ហា ឬស្ថានភាពដែលពួកគាត់មានអារម្មណ៍ចង់ដឹងចង់ឮ និងចង់ធ្វើអ្វីមួយដើម្បីផ្លាស់ប្តូរ។

- ក្រុមនីមួយៗត្រូវសម្រេចចិត្តយកបញ្ហាមួយ ហើយសរសេរគំនិតខ្លះអំពីអ្វីដែលពួកគាត់អាចធ្វើដើម្បីឲ្យក្លាយទៅជាប្រជាពលរដ្ឋដែលមានចំណេះដឹង ឬមានព័ត៌មានគ្រប់គ្រាន់ និងសកម្ម ដើម្បីធ្វើឲ្យស្ថានភាពនោះប្រសើរ។ ប្រសិនបើក្រុមណាមួយមានពេល ពួកគាត់អាចធ្វើផែនការសម្រាប់ជំហានដែលត្រូវធ្វើ។ សូមលើកទឹកចិត្តអ្នកចូលរួមឲ្យមានគំនិតច្នៃប្រឌិត។

- ក្រុមទាំងអស់មានពេល២០នាទី ដើម្បីធ្វើលំហាត់នេះ រួចបន្ទាប់មក ក្រុមទាំងអស់នឹងមានឱកាសឡើងបង្ហាញអ្នកចូលរួមទាំងមូល។

- សូមឲ្យប្រាកដថា អ្នកចូលរួមទាំងអស់យល់អំពីកិច្ចការដែលពួកគាត់ត្រូវធ្វើ និងបែងចែកអ្នកចូលរួមជា៣ ឬ៤ក្រុម (ក្រុមនីមួយៗមិនត្រូមមានសមាជិកលើសពី៦នាក់ទេ)។ សូមឲ្យក្រុមនីមួយៗយកក្រដាសផ្ទាំងធំ និងហ្វឺត។

- សូមអ្នកសម្របសម្រួលដើរមើលតាមក្រុមនីមួយៗ ក្រែងពួកគាត់ត្រូវការជំនួយ។

## ៥. បទបង្ហាញ

- នៅពេលដែលក្រុមទាំងអស់ធ្វើកិច្ចការរបស់ក្រុមរួចហើយ សូមអញ្ជើញក្រុមនីមួយៗឲ្យឡើងបង្ហាញអំពីគំនិតរបស់ក្រុម។

- បន្ទាប់ពីក្រុមនីមួយៗបង្ហាញចប់ សូមសួរអ្នកចូលរួមដទៃទៀតថា តើពួកគាត់មានសំណួរ យោបល់ ឬសំណើអ្វីទេ។

## ៦. សង្ខេប

- សូមរំលឹកអ្នកចូលរួមថា ការធ្វើជាប្រជាពលរដ្ឋសកម្ម ពួកគាត់អាចធ្វើឲ្យមានភាពខុសគ្នាយ៉ាងពិតប្រាកដចំពោះវិធីគ្រប់គ្រង និងដំណើរការនៃកិច្ចការអភិវឌ្ឍន៍ប្រទេស។
- សូមសួរអ្នកចូលរួមថា តើគាត់យល់យ៉ាងណាអំពីការក្លាយទៅជាប្រជាពលរដ្ឋសកម្ម។ តើពួកគាត់គិតថា ពួកគាត់នឹងកាន់តែសកម្មជាងមុននៅក្នុងសង្គមទេ? ប្រសិនបើដូច្នោះ តើពួកគាត់នឹងចាប់ផ្តើមធ្វើអ្វីខ្លះចាប់ពីពេលនេះតទៅ? ប្រសិនបើមិនដូច្នោះទេ តើហេតុអ្វី?
- សូមរំលឹកអ្នកចូលរួមថា លទ្ធិប្រជាធិបតេយ្យគឺជាដៃគូរវាងរដ្ឋាភិបាលជាប់ឆ្នោត និងប្រជាពលរដ្ឋ។ទាំង រដ្ឋាភិបាល និងប្រជាពលរដ្ឋត្រូវតែសកម្ម ដើម្បីធ្វើឲ្យលទ្ធិប្រជាធិបតេយ្យនោះមានដំណើរការល្អ។ សូមពន្យល់ថា លទ្ធិប្រជាធិបតេយ្យត្រូវការប្រជាពលរដ្ឋដែលខ្លាំង និងសកម្ម ដើម្បីបង្កើតសង្គមមួយដែលរដ្ឋាភិបាលត្រូវទទួលខុសត្រូវចំពោះការបម្រើប្រជាពលរដ្ឋ។

# សទ្ទានុក្រម

**ដែលទទួលខុសត្រូវ៖** ការទទួលខុសត្រូវចំពោះឥទ្ធិពលដែលកើតឡើងពីការសម្រេចចិត្ត ឬសកម្មភាពរបស់អ្នកណាម្នាក់។ ទម្រង់ដែលសំខាន់ជាងគេនៃភាពទទួលខុសត្រូវនៅក្នុងលទ្ធិប្រជាធិបតេយ្យ គឺថា ប្រសិនបើប្រជាពលរដ្ឋភាគច្រើនមិនសប្បាយចិត្តនឹងការសម្រេចចិត្តរបស់តំណាងរបស់ពួកគាត់ នោះពួកគាត់អាចបោះឆ្នោតទម្លាក់តំណាងនោះចេញពីអំណាចនៅពេលបោះឆ្នោតលើកក្រោយ។

**បេក្ខជន (នៅក្នុងការបោះឆ្នោត)៖** អ្នកណាដែលចង់ធ្វើជាតំណាងសង្គមនៅក្នុងរដ្ឋាភិបាល។ ប្រសិនបើបេក្ខជនណាម្នាក់ឈ្នះសំលេងឆ្នោតគ្រប់គ្រាន់ នោះគេនឹងក្លាយទៅជាផ្នែកមួយនៅក្នុងរដ្ឋាភិបាល។

**តុល្យភាពនៃអំណាច៖** ជាប្រព័ន្ធដែលគ្មានស្ថាប័នណាមួយនៅក្នុងរដ្ឋាភិបាលមានអំណាចផ្តាច់ការ ដោយសារស្ថាប័នដទៃទៀតដាក់ដែនកំណត់ទៅលើអំណាចនោះ។ អំណាចរបស់រដ្ឋាភិបាលត្រូវតែមានតុល្យភាព រវាងស្ថាប័នទាំង៣។

**ប្រជាពលរដ្ឋ៖** ជាសមាជិកយ៉ាងសំខាន់នៅក្នុងប្រទេស ឬប្រជាជាតិណាមួយ ដែលនៅក្នុងប្រទេសនោះ រដ្ឋាភិបាលជាប់ឆ្នោតដោយការបោះឆ្នោតតាមបែបប្រជាធិបតេយ្យមួយ ត្រូវបានបង្កើតឡើង ដើម្បីជាតំណាង និងបម្រើប្រជាពលរដ្ឋរបស់ខ្លួន។ ប្រជាពលរដ្ឋមានសិទ្ធិស្របច្បាប់ និងការការពារនៅក្នុងប្រទេសនៃសញ្ជាតិរបស់ខ្លួន។

**ភាពជាពលរដ្ឋ៖** ឋានៈស្របច្បាប់ជាប្រជាពលរដ្ឋម្នាក់នៃប្រទេសណាមួយ។

**ក្រុមសង្គមស៊ីវិល៖** ក្រុមមនុស្សនៅក្នុងសង្គម ដែលរួបរួមគ្នាធ្វើការដើម្បីបុព្វហេតុ ឬបញ្ហារួមគ្នា។ ក្រុមសង្គមស៊ីវិលមិនមែនជាផ្នែកនៃរដ្ឋាភិបាល និងជាក្រុមដែលធ្វើការដោយមិនរកប្រាក់ចំណេញ។

**រដ្ឋធម្មនុញ្ញ៖** រដ្ឋធម្មនុញ្ញ គឺជាច្បាប់កំពូលនៅក្នុងប្រទេស និងមានចែងអំពីអំណាច និងមុខងាររបស់រដ្ឋាភិបាល។ ច្បាប់នេះ ក៏មានចែងអំពីការគោរព និងការការពារ សិទ្ធិ និងសេរីភាពរបស់ប្រជាពលរដ្ឋដែរ។

**ក្រុមប្រឹក្សារដ្ឋធម្មនុញ្ញ៖** ជាផ្នែកមួយនៃអង្គចៅក្រម ដែលមានតួនាទីពិនិត្យឡើងវិញនូវច្បាប់ ដើម្បីឲ្យប្រាកដថា ច្បាប់ទាំងនោះមិនផ្ទុយគ្នានឹងរដ្ឋធម្មនុញ្ញ។

**គណៈរដ្ឋមន្ត្រី៖** ជាក្រុមដែលមានអំណាចខ្ពស់បំផុតនៅក្នុងស្ថាប័ននីតិប្រតិបត្តិ។ គណៈរដ្ឋមន្ត្រី ចំណុះទៅដោយ នាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រីផ្សេងៗ និងទេសរដ្ឋមន្ត្រី និងរដ្ឋលេខាធិការ។ ការសម្រេចចិត្ត និងគោលនយោបាយសំខាន់ៗជាច្រើន ត្រូវបានធ្វើឡើងដោយគណៈរដ្ឋមន្ត្រី។ គណៈរដ្ឋមន្ត្រីមានឈ្មោះម្យ៉ាងទៀតថា រាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា។

**សាលាឧទ្ធរណ៍៖** ប្រសិនបើប្រជាពលរដ្ឋមិនសប្បាយចិត្តជាមួយនឹងការសម្រេចចិត្តដែលធ្វើឡើងដោយតុលាការជាន់ទាប នោះពួកគេអាចជំទាស់នឹងការសម្រេចចិត្តនោះនៅឯសាលាឧទ្ធរណ៍។

**លទ្ធិប្រជាធិបតេយ្យ៖** ជាប្រព័ន្ធមួយរបស់រដ្ឋាភិបាល ដែលអំណាចនយោបាយបានមកពីបំណងប្រាថ្នារបស់ប្រជាពលរដ្ឋ។

**ការបោះឆ្នោត** : ជាប្រព័ន្ធមួយ ដែលប្រជាពលរដ្ឋនៅក្នុងសង្គមជ្រើសរើសតំណាងរបស់ខ្លួននៅក្នុងរដ្ឋាភិបាលដោយការបោះឆ្នោត។

**ដោយសមធម៌៖** យុត្តិធម៌ និងមិនលំអៀង។

**រដ្ឋាភិបាល៖** ជាក្រុមមនុស្ស ឬស្ថាប័ន ដែលមានសិទ្ធិអំណាចក្នុងការធ្វើសេចក្តីសម្រេចចិត្តអំពីច្បាប់ គោលនយោបាយ និងវិធីដែលសង្គមដំណើរការ។ មានស្ថាប័នរបស់រដ្ឋាភិបាលចំនួនបី៖ អង្គនីតិប្បញ្ញត្តិ អង្គនីតិប្រតិបត្តិ និងអង្គតុលាការ។

**សិទ្ធិមនុស្ស៖** សិទ្ធិមនុស្សអាចឲ្យមនុស្សរស់នៅដោយសប្បាយរីករាយ មានសុខភាពល្អ និងជីវិតមានសេរីភាព។ ការទទួលបាននូវតម្រូវការជាមូលដ្ឋានរបស់យើង ដូចជាអាហារ ទឹក និងលំនៅឋានសមរម្យ និងភាពសប្បាយរីករាយជាមួយសេរីភាពមូលដ្ឋាន ដូចជាសេរីភាពក្នុងការបញ្ចេញមតិយោបល់របស់យើង ការគោរពសាសនារបស់យើង គឺសុទ្ធតែជាសិទ្ធិរបស់យើងក្នុងនាមជាមនុស្ស។ គ្រប់គ្នា គ្រប់ទីកន្លែងមានសិទ្ធិទាំងនេះដោយមិនប្រកាន់ពី អាយុ ភេទ សាសនា ឬទ្រព្យសម្បត្តិឡើយ។

**មិនលំអៀង (ការកាត់ក្តី)៖** ជាការសម្រេចចិត្តដែលធ្វើឡើងដោយយោងលើអង្គច្បាប់ និងអង្គហេតុនៃរឿងក្តីតែប៉ុណ្ណោះ និងដោយគ្មានភាពលំអៀង ឬឥទ្ធិពលពីអ្នកខាងក្រៅ។

**កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ៖** គឺជាច្បាប់មួយយ៉ាងសំខាន់ក្នុងចំណោមច្បាប់អន្តរជាតិស្តីពីសិទ្ធិមនុស្សទាំងអស់។ វាការពារសិទ្ធិមនុស្សដែលទាក់ទងជាមួយនឹងសេរីភាព ការចូលរួមក្នុងជីវិតសាធារណៈ និងការចាត់ទុកឲ្យស្មើភាពនិងយុត្តិធម៌នៅក្នុងសង្គមរបស់បុគ្គល ដូចជា សិទ្ធិរស់រានមានជីវិត សិទ្ធិរួចផុតពីការរើសអើង សិទ្ធិបោះឆ្នោត និងសិទ្ធិក្នុងការបញ្ចេញមតិ។

**កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌៖** គឺជាច្បាប់មួយយ៉ាងសំខាន់ក្នុងចំណោមច្បាប់អន្តរជាតិស្តីពីសិទ្ធិមនុស្សទាំងអស់។ វាការពារសិទ្ធិមនុស្សដែលទាក់ទងជាមួយនឹងតម្រូវការមូលដ្ឋានរបស់បុគ្គលដើម្បីឲ្យរស់នៅដោយមានភាពថ្លៃថ្នូរ ដូចជា សិទ្ធិក្នុងការទទួលបានការអប់រំ សិទ្ធិក្នុងការទទួលបានការថែទាំសុខភាព និងសិទ្ធិក្នុងការមានលំនៅឋានសមរម្យ។

**សន្ធិសញ្ញាអន្តរជាតិស្តីពីសិទ្ធិមនុស្ស៖** ជាច្បាប់ដែលទទួលស្គាល់ចំពោះសិទ្ធិរបស់មនុស្សម្នាក់ៗនៅជុំវិញពិភពលោក ហើយដែលកំណត់តួនាទីស្របច្បាប់ ឲ្យរដ្ឋាភិបាលគោរពនូវសិទ្ធិទាំងនោះ។ រដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជាទទួលស្គាល់ថា សន្ធិសញ្ញាអន្តរជាតិស្តីពីសិទ្ធិមនុស្ស ជាផ្នែកមួយនៃច្បាប់របស់ប្រទេសកម្ពុជា។

**ការកាត់ក្តី៖** ជាការសម្រេចចិត្តរបស់ចៅក្រមលើរឿងក្តីនៅតុលាការ។ ចៅក្រមគួរតែពិចារណាអំពីអង្គហេតុនៃរឿងក្តីនោះ និងវិធីក្នុងការប្រើច្បាប់ទៅលើអង្គហេតុទាំងនោះដើម្បីធ្វើការសម្រេចចិត្ត។

**ច្បាប់៖** ជាបទបញ្ញាដែលត្រូវបានយល់ព្រម និងធ្វើឲ្យទៅជាផ្លូវការដោយមនុស្សដែលមានសិទ្ធិអំណាចក្នុងការធ្វើសេចក្តីសម្រេចចិត្តអំពីវិធីរៀបចំ និងដំណើរការសង្គម។

**ប្រជាធិបតេយ្យសេរី៖** ជាប្រព័ន្ធមួយរបស់រដ្ឋាភិបាលដែលផ្អែកលើប្រជាធិបតេយ្យបែបតំណាងរាស្ត្រ លើការការពារសិទ្ធិបុគ្គល និងការគោរពចំពោះគំនិត និងជំនឿផ្សេងៗគ្នា។ នៅឆ្នាំ១៩៩៣ រដ្ឋធម្មនុញ្ញបានបង្កើតនូវប្រព័ន្ធរដ្ឋាភិបាលបែបនេះនៅក្នុងប្រទេសកម្ពុជា។

**ក្រសួង៖** ជាស្ថាប័ននៅក្នុងក្របខ័ណ្ឌនៃអង្គនីតិប្រតិបត្តិរបស់រដ្ឋាភិបាល ដែលទទួលខុសត្រូវចំពោះទស្សនវិស័យជាក់លាក់ណាមួយ។ ឧទាហរណ៍ ក្រសួងហិរញ្ញវត្ថុ ក្រសួងសាធារណៈការនិងដឹកជញ្ជូន និងក្រសួងកិច្ចការនារី ជាដើម។

**រដ្ឋសភា៖** ជាស្ថាប័នជាប់ឆ្នោត ដែលជាផ្នែកមួយនៃអង្គនីតិប្បញ្ញត្តិនៅក្នុងប្រទេសកម្ពុជា ដែលត្រូវសម្រេចចិត្តថា ត្រូវបង្កើតច្បាប់ណា។ គណបក្សនយោបាយណាដែលឈ្នះអាសនៈភាគច្រើននៅក្នុងរដ្ឋសភានឹងក្លាយជាគណបក្សកាន់អំណាច និងមានសិទ្ធិជ្រើសរើសនាយករដ្ឋមន្ត្រី។ អាណត្តិរបស់សមាជិករដ្ឋសភាគឺ រយៈពេលប្រាំឆ្នាំ។

**ភាគី (ក្នុងរឿងក្តីនៅតុលាការ)៖** ជាអ្នកដែលជាប់ពាក់ព័ន្ធជាមួយនឹងរឿងក្តីនៅតុលាការ ដូចជា អ្នកដែលដាក់ពាក្យប្តឹងគេ ឬអ្នកដែលត្រូវគេប្តឹង។

**គណបក្សនយោបាយ៖** ជាស្ថាប័នមួយដែលបង្កើតឡើងដោយក្រុមមនុស្ស ដែលចែករំលែកនូវតម្លៃ និងទស្សនៈរួមគ្នា ក្នុងគោលបំណងឲ្យមានអំណាចនយោបាយនៅក្នុងរដ្ឋាភិបាល។

**ផ្តល់សច្ចានុម័ត (សន្ធិសញ្ញាអន្តរជាតិ)៖** ធ្វើឡើងនៅពេលដែលរដ្ឋាភិបាលបានយល់ព្រមជាផ្លូវការ ដើម្បីអនុវត្តទៅតាមសន្ធិសញ្ញាអន្តរជាតិ។

**ប្រជាធិបតេយ្យបែបតំណាងរាស្ត្រ៖** គឺជាប្រព័ន្ធមួយរបស់រដ្ឋាភិបាលដែលប្រជាពលរដ្ឋអាចជ្រើសរើសដោយសេរីនូវតំណាងរាស្ត្រដើម្បីធ្វើការសម្រេចចិត្តអំពីសង្គមជំនួសពួកគាត់។ ទោះបីប្រជាពលរដ្ឋត្រូវបានតំណាង

ដោយរដ្ឋាភិបាលក៏ដោយ ក៏សមាជិកទាំងអស់របស់សង្គមមានសិទ្ធិក្នុងការចូលរួម និងបញ្ចេញសំឡេងអំពីបញ្ហា និងក្នុងការសម្រេចចិត្តដែលមានឥទ្ធិពលដល់ពួកគាត់។

**រាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា៖** គឺជាស្ថាប័នដែលមានអំណាចខ្ពស់បំផុតនៅក្នុងអង្គនីតិប្រតិបត្តិ។ ស្ថាប័ននេះចំណុះដោយ នាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រីនានា និងទេសរដ្ឋមន្ត្រីនិងរដ្ឋលេខាធិការ។ ការសម្រេចចិត្ត និងគោលនយោបាយសំខាន់ៗជាច្រើនត្រូវបានធ្វើឡើងដោយគណៈរដ្ឋមន្ត្រី។ គេហៅ រាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា ម្យ៉ាងទៀតថា គណៈរដ្ឋមន្ត្រី។

**ធម្មាធិបតេយ្យ (នីតិរដ្ឋ)៖** គឺជាគោលការណ៍មួយ ដែលគ្មានអ្នកណានៅខ្ពស់ជាងច្បាប់ (ភាសាសាមញ្ញថាគ្មានអ្នកយកច្បាប់ទៅទ្រាប់អង្គុយ) ហើយគ្រប់គ្នានៅក្រោមច្បាប់ និងគ្រប់គ្នាមានភាពស្មើគ្នានៅចំពោះមុខច្បាប់។ ធម្មាធិបតេយ្យ (នីតិរដ្ឋ) ជួយរក្សាសណ្តាប់ធ្នាប់នៅក្នុងសង្គម និងជួយការពារសិទ្ធិប្រជាពលរដ្ឋប្រឆាំងនឹងការរំលោភអំណាច។

**សង្គម៖** គឺជាមនុស្សមួយក្រុមធំ ដែលរស់នៅក្នុងប្រទេស ឬតំបន់ណាមួយ ដែលជាទូទៅមាន ប្រពៃណីវប្បធម៌ និងសីលធម៌រួមគ្នា។ ក្រុម ឬបុគ្គលនៅក្នុងសង្គមមួយមានគុណតម្លៃ គំនិត និងជំនឿផ្សេងគ្នា ប៉ុន្តែពួកគេជាទូទៅចែករំលែក ការតាំងចិត្តរស់ទៅតាមវិធីមួយ និងដោយយោងទៅតាមបទបញ្ញាជាក់លាក់ណាមួយដែលគោរពនូវប្រពៃណីនៃសង្គមនោះ។

**ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម៖** ជាស្ថាប័នមួយដែលស្នើថា អ្នកណាគួរក្លាយទៅជាចៅក្រមនៅក្នុងប្រទេសកម្ពុជា។ បន្ទាប់មកចៅក្រមនោះត្រូវបានតែងតាំងដោយ ព្រះមហាក្សត្រ។ នៅក្នុងរដ្ឋធម្មនុញ្ញ ព្រះមហាក្សត្រ និងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវតែប្រកាន់ខ្ជាប់នូវឯករាជភាពរបស់អង្គចៅក្រម។

**តុលាការកំពូលនៃប្រទេសកម្ពុជា៖** គឺជាតុលាការជំនុំជម្រះរឿងក្តីថ្នាក់ខ្ពស់បំផុត នៅក្នុងប្រទេសកម្ពុជា។

**អង្គនីតិប្រតិបត្តិ៖** ជាស្ថាប័ននៃរដ្ឋាភិបាលដែលចំណុះដោយ នាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីនិងនាយកដ្ឋានរដ្ឋាភិបាលផ្សេងៗទៀត។ តួនាទីរបស់ស្ថាប័នអង្គនីតិប្រតិបត្តិ គឺអនុវត្តច្បាប់ និងធ្វើការងាររបស់រដ្ឋាភិបាល ដោយបង្កើតគោលនយោបាយ និងបទបញ្ញា ធ្វើសេចក្តីសម្រេចចិត្តនិងធ្វើសកម្មភាពទៅលើបញ្ហាដែលមានឥទ្ធិពលដល់សង្គម។

**អង្គតុលាការ៖** ជាស្ថាប័នរបស់រដ្ឋាភិបាលដែលចំណុះដោយតុលាការ និងចៅក្រម។ តួនាទីរបស់អង្គតុលាការគឺបកស្រាយ និងអនុវត្តច្បាប់ទៅលើអង្គហេតុនៃរឿងក្តីដែលប្តឹងមកតុលាការ ដោះស្រាយវិវាទផ្លូវច្បាប់ យោងទៅតាមច្បាប់ និងផ្តល់ដំណោះស្រាយផ្លូវច្បាប់ជូនប្រជាពលរដ្ឋចំពោះការខូចខាតដែលពួកគាត់ទទួលរងដោយសារតែអំពើរបស់អ្នកដទៃ។ អង្គតុលាការក៏ការពារសិទ្ធិ និងសេរីភាពរបស់ប្រជាពលរដ្ឋដែលរស់នៅក្នុងលទ្ធិប្រជាធិបតេយ្យ ហើយក៏ទទួលខុសត្រូវក្នុងការធ្វើឲ្យមានការប្រព្រឹត្ត និងយុត្តិធម៌ស្មើភាពគ្នានៅចំពោះមុខច្បាប់។

**អង្គនីតិប្បញ្ញត្តិ៖** គឺជាសាខារបស់រដ្ឋាភិបាលដែលចំណុះដោយក្រុមតំណាងរាស្ត្រជាប់ឆ្នោត ដែលមានតួនាទីពិភាក្សា ជជែកវែកញែក និងសម្រេចចិត្តថា តើគួរបង្កើតច្បាប់ដែលបានដាក់ស្នើនោះទេ។ នៅក្នុងប្រទេសកម្ពុជា អង្គនីតិប្បញ្ញត្តិចំណុះដោយរដ្ឋសភា និងព្រឹទ្ធសភា។ ច្បាប់ដែលបានដាក់ស្នើត្រូវតែបានយល់ព្រមដោយរដ្ឋសភា និងពិនិត្យដោយព្រឹទ្ធសភា និងបានឡាយព្រះហស្តលេខាដោយព្រះមហាក្សត្រ។

**សិទ្ធិក្នុងការប្រមូលផ្តុំ៖** គឺជាសិទ្ធិសម្រាប់ឲ្យប្រជាពលរដ្ឋជួបជុំគ្នាដោយអហិង្សា ដោយមិនមានអ្នកដទៃហាមឃាត់ពួកគាត់។ នេះមានន័យថា រដ្ឋាភិបាលមិនគួរបញ្ឈប់ប្រជាពលរដ្ឋពីការប្រមូលផ្តុំគ្នាដោយអហិង្សា ដើម្បីពិភាក្សាអំពីទស្សនៈ និងគំនិតរបស់ពួកគាត់ទេ។

**សិទ្ធិក្នុងការចូលរួមសមាគម៖** គឺជាសិទ្ធិសម្រាប់ឲ្យប្រជាពលរដ្ឋជ្រើសរើស (ឬមិនជ្រើសរើស) បង្កើត ឬចូលរួមជាមួយស្ថាប័ន ឬក្រុមផ្សេងៗ។ នេះរួមបញ្ចូលទាំងសិទ្ធិក្នុងការបង្កើត ឬចូលរួមក្នុងគណបក្សនយោបាយផង។

**សិទ្ធិក្នុងការបញ្ចេញមតិដោយសេរី៖** គឺជាសិទ្ធិក្នុងការទទួល និងទំនាក់ទំនងជាសាធារណៈ នូវព័ត៌មាន គំនិត និងយោបល់នានា។ ការបញ្ចេញមតិមានទ្រង់ទ្រាយផ្សេងៗគ្នា មានដូចជា៖ ការសរសេរ ការថ្លែងសុន្ទរកថា ប្រព័ន្ធផ្សព្វផ្សាយ ឬការប្រើរូបតំណាង។ នៅក្នុងលទ្ធិប្រជាធិបតេយ្យ ប្រជាពលរដ្ឋត្រូវតែអាចនិយាយអំពីអ្វីដែលពួកគាត់គិត និងជឿជាក់ ដោយមិនមានភាពភ័យខ្លាចថា ពួកគាត់នឹងត្រូវគេដាក់ទោសទេ បើទោះបីជាអ្នកដទៃ ឬរដ្ឋាភិបាលមិនមានគំនិតយោបល់ដូចពួកគាត់ក៏ដោយ។

**ព្រឹទ្ធសភា៖** ជាផ្នែកមួយរបស់អង្គនីតិបញ្ញត្តិ នៅក្នុងប្រទេសកម្ពុជា ដែលពិនិត្យឡើងវិញនូវច្បាប់ដែលបានដាក់ស្នើ។ ព្រឹទ្ធសភាអាចដាក់ស្នើច្បាប់ឲ្យអនុម័ត និងព្រឹទ្ធសភាមានអំណាចក្នុងការពិនិត្យឡើងវិញនូវច្បាប់ដែលបានដាក់ស្នើ ហើយផ្តល់អនុសាសន៍ឲ្យផ្លាស់ប្តូរ។ ប៉ុន្តែរដ្ឋសភាមានអំណាចចុងក្រោយក្នុងការអនុម័តច្បាប់។ អាណត្តិរបស់សមាជិកព្រឹទ្ធសភាគឺ ៦ឆ្នាំ។

**សន្ធិសញ្ញា៖** គឺជាការព្រមព្រៀងស្របច្បាប់ដែលធ្វើឡើងដោយរដ្ឋាភិបាលនៅជុំវិញពិភពលោក។

**អង្គការសហប្រជាជាតិ៖** គឺជាអង្គការអន្តរជាតិ ដែលចំណុះដោយប្រជាជាតិភាគច្រើននៅលើពិភពលោក។ គោលបំណងរបស់អង្គការសហប្រជាជាតិគឺធ្វើឲ្យមានសន្តិភាពលើពិភពលោក ដោយការពារមិនឲ្យមានជម្លោះ លើកតម្កើងសិទ្ធិមនុស្ស និងជួយអភិវឌ្ឍសេដ្ឋកិច្ច។

**សេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស៖** គឺជា ឯកសារច្បាប់អន្តរជាតិមួយសំខាន់ជាងគេ ស្តីពីសិទ្ធិមនុស្ស។ សេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស ត្រូវបានអនុម័តដោយអង្គការសហប្រជាជាតិនៅឆ្នាំ១៩៤៨។ វាគឺជាបញ្ជីសិទ្ធិមនុស្ស ដែលរដ្ឋាភិបាលបានសន្យាថានឹងគោរព និងការពារ។

# សំនួរស្ទាបស្ទង់ចំណេះដឹងអ្នកចូលរួម មុន និងក្រោយវគ្គបណ្តុះបណ្តាល

១. **ច្បាប់មួយដែលល្អគឺ៖**

- ☐ ជាច្បាប់ដែលការពារសិទ្ធិសេរីភាពរបស់ប្រជាជន
- ☐ ជាច្បាប់ដែលអនុញ្ញាតអោយរដ្ឋាភិបាលធ្វើអ្វីៗតាមចិត្តចង់
- ☐ ជាច្បាប់ដែលបញ្ឈប់ប្រជាជនពីការធ្វើសកម្មភាពដោយសេរី
- ☐ អត់ដឹង

២. **សិទ្ធិមនុស្សគឺ៖**

- ☐ សិទ្ធិដែលរដ្ឋាភិបាលធ្វើអ្វីៗតាមចិត្ត
- ☐ សិទ្ធិដែលមានតែប្រជាជនរស់នៅក្នុងប្រទេសអ្នកមាន
- ☐ សិទ្ធិដែលមនុស្សគ្រប់រូប គ្រប់ទីកន្លែងមាន ដើម្បីរស់នៅដោយសប្បាយរីករាយមានសុខភាពល្អ និងសេរីភាពក្នុងការរស់នៅ
- ☐ អត់ដឹង

៣. **សិទ្ធិមនុស្សមកពី៖**

- ☐ តំលៃជាសាកលនៃវប្បធម៌ និងសហគមន៍ទាំងឡាយនៅលើពិភពលោក
- ☐ នាយករដ្ឋមន្ត្រីរបស់យើងគឺជាអ្នកសម្រេច ថាតើសិទ្ធិមនុស្សអ្វីខ្លះដែលយើងមាននិងអាចដកសិទ្ធិទាំងនោះវិញបាន
- ☐ ឪពុកម្តាយរបស់យើង
- ☐ អត់ដឹង

៤. **សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សគឺជា៖**

- ☐ សេចក្តីថ្លែងការណ៍មួយដែលផ្តល់សិទ្ធិ និងអំណាចទៅឲ្យរដ្ឋាភិបាលនៅលើពិភពលោក
- ☐ ឯកសារច្បាប់អន្តរជាតិមួយ ដែលដាក់បញ្ចូលសិទ្ធិមនុស្សទាំងឡាយដែលទទួលស្គាល់ដោយសហគមន៍អន្តជាតិ
- ☐ សេចក្តីថ្លែងការណ៍មួយ ដែលមានតែរដ្ឋាភិបាលនៃប្រទេសអភិវឌ្ឍន៍យល់ព្រមជាមួយ
- ☐ អត់ដឹង

៥. **យោងតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា រដ្ឋាភិបាលកម្ពុជា៖**

- ☐ គ្មានកាតព្វកិច្ចស្ថិតនៅក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិទេ
- ☐ មានកាតព្វកិច្ចគោរពតែសិទ្ធិរបស់ក្រុមមនុស្ស ដែលធ្វើការជាមួយរដ្ឋាភិបាលប៉ុណ្ណោះ
- ☐ មានកាតព្វកិច្ចក្នុងការគោរព ការពារ និងបំពេញបន្ថែមសិទ្ធិមនុស្ស
- ☐ អត់ដឹង

៦. ក្នុងលទ្ធិប្រជាធិបតេយ្យ រដ្ឋាភិបាលទទួលបានអំណាចតាមរយៈ៖

- ☐ ប្រជាពលរដ្ឋបោះឆ្នោតឲ្យ
- ☐ ចំណាយប្រាក់ច្រើន
- ☐ ប្រើកម្លាំងទាហាន និងនគបាល ដើម្បីទទួលបានអំណាច និងរក្សាអំណាច
- ☐ អត់ដឹង

៧. នៅក្នុងលិទ្ធិប្រជាធិបតេយ្យ រដ្ឋាភិបាលគឺទទួលខុសត្រូវខ្ពស់នៅចំពោះមុខ៖

- ☐ នាយករដ្ឋមន្ត្រី
- ☐ ព្រះមហាក្សត្រ
- ☐ ប្រជាជន
- ☐ អត់ដឹង

៨. ការបោះឆ្នោតនៅប្រទេសកម្ពុជា៖

- ☐ មានតែបុរសទេដែលអាចបោះឆ្នោតបាន
- ☐ ប្រជាពលរដ្ឋដែលមានអាយុ លើសពី១៨ឆ្នាំ អាចបោះឆ្នោតបាន
- ☐ មនុស្សគ្រប់រូបអាចបោះឆ្នោតបាន
- ☐ អត់ដឹង

៩. ក្នុងលទ្ធិប្រជាធិបតេយ្យ ប្រសិនបើរដ្ឋាភិបាលមិនគាំទ្រក្រុមមនុស្សសម្លេងភាគច្រើនលើសលុបទេ៖

- ☐ រដ្ឋាភិបាលនឹងត្រូវប្រជាពលរដ្ឋបោះឆ្នោតទម្លាក់ នៅពេលបោះឆ្នោតអាណត្តិក្រោយ
- ☐ រដ្ឋាភិបាលអាចប្រើកម្លាំងដើម្បីបន្តការកាន់អំណាច
- ☐ រដ្ឋាភិបាលអាចអោយលុយប្រជាពលរដ្ឋ ដើម្បីគាំទ្រអោយពួកគេឈ្នះឆ្នោត
- ☐ អត់ដឹង

១០. ក្នុងលទ្ធិប្រជាធិបតេយ្យប្រព័ន្ធផ្សព្វផ្សាយគួរតែ៖

- ☐ គ្រប់គ្រងដោយរដ្ឋាភិបាល
- ☐ គ្រប់គ្រងដោយក្រុមហ៊ុនទាំងឡាយដែលមានលុយច្រើន
- ☐ សេរី និង ឯករាជ្យ
- ☐ អត់ដឹង

១១. ក្នុងលទ្ធិប្រជាធិបតេយ្យ សិទ្ធិរបស់ក្រុមមនុស្សដែលមានសម្លេងភាគតិច៖

- ☐ មិនសំខាន់ទេ ពីព្រោះមានសម្លេងភាគច្រើនលើសលុបបោះឆ្នោតក្នុងរដ្ឋាភិបាល
- ☐ គឺខ្សោយជាងសិទ្ធិរបស់ក្រុមមនុស្សដែលមានសម្លេងភាគច្រើន
- ☐ ត្រូវតែទទួលការការពារពីរដ្ឋាភិបាល
- ☐ អត់ដឹង

**១២. នីតិរដ្ឋមានន័យថា៖**

- ☐ រដ្ឋាភិបាលកាន់អំណាចដោយគ្មានរយៈពេលកំណត់
- ☐ គ្មាននរណាម្នាក់នៅលើច្បាប់ទេ រួមទាំងរដ្ឋាភិបាលផងដែរ
- ☐ តុលាការត្រូវតែគោរពនាយករដ្ឋមន្ត្រី
- ☐ អត់ដឹង

**១៣. តួនាទីរបស់អង្គនីតិបញ្ញត្តិគឺ៖**

- ☐ បង្កើតច្បាប់
- ☐ អនុវត្តច្បាប់
- ☐ ដោះស្រាយទំនាស់
- ☐ អត់ដឹង

**១៤. ក្នុងលទ្ធិប្រជាធិបតេយ្យ បើសិន បើចៅក្រមធ្វើសេចក្តីសម្រេចមួយដែលប្រឆាំងនឹងនាយករដ្ឋមន្ត្រី៖**

- ☐ ចៅក្រមរូបនោះគួរតែត្រូវទទួលទណ្ឌកម្ម ពីព្រោះនាយករដ្ឋមន្ត្រីត្រូវតែមានសេរីភាពក្នុងការធ្វើអ្វីដែលគាត់ត្រូវការ និងចង់បាន
- ☐ នាយករដ្ឋមន្ត្រីត្រូវតែគោរពសេចក្តីសម្រេចនោះ
- ☐ នាយករដ្ឋមន្ត្រីអាចព្រងើយកន្តើយនឹងសេចក្តីសម្រេចនោះបាន
- ☐ អត់ដឹង

**១៥. ក្នុងលទ្ធិប្រជាធិបតេយ្យ តួនាទីរបស់ប្រជាជនគឺ៖**

- ☐ បោះឆ្នោត
- ☐ គោរពនាយករដ្ឋមន្ត្រី រួមបញ្ចូលទាំងការបោះឆ្នោតឲ្យគណៈបក្សរបស់គាត់ផងដែរ
- ☐ ត្រូវបានគេផ្តល់ព័ត៌មានអោយ សកម្ម និងទទួលខុសត្រូវ រួមបញ្ចូលទាំងការបោះឆ្នោត
- ☐ អត់ដឹង

***ពលរដ្ឋវិជ្ជា: សេចក្តីផ្តើម នៃច្បាប់ សិទ្ធិមនុស្ស និងលិទ្ធិប្រជាធិបតេយ្យ សម្រាប់ប្រជាពលរដ្ឋកម្ពុជា*** *ជាធនធានមួយសម្រាប់ជាទីចំណាប់អារម្មណ៍នៃប្រជាពលរដ្ឋកម្ពុជា ក្នុងការស្វែងយល់បន្ថែមអំពីសិទ្ធិ និងករណីយកិច្ចរបស់ប្រជាពលរដ្ឋកម្ពុជា និងរបៀបដែលពួកគេអាចចូលរួមក្នុងការងារសង្គម។*

*សៀវភៅនេះ ត្រូវបានរៀបចំតាក់តែង និងសរសេរសម្រាប់សិស្សានុសិស្សថ្នាក់វិទ្យាល័យ ប៉ុន្តែក៏អាចសម្រាប់ការអប់រំដល់មិត្តអ្នកអានទូទៅផងដែរ។*

*សៀវភៅនេះ ត្រូវបានសរសេរឡើង ក្នុងស្មារតីសុទិដ្ឋិនិយមសម្រាប់មនុស្សជំនាន់ក្រោយ និងក្នុងសេចក្តីជឿជាក់ថា វាជួយឲ្យប្រជាពលរដ្ឋ បង្កើតបាននូវលទ្ធិប្រជាធិបតេយ្យដ៏រឹងមាំនិងដ៏អស្ចារ្យមួយ។*

Bridges Across Borders Cambodia